# ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១

## ប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ តាមច្រកអន្តរជាតិសម្រាប់ខេត្តសៀមរាប សរុបចំនួន ៤១នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃសៅរ៍ ទី០១ ខែឧសភា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៤១នាក់ ស្រី ១៥នាក់ ក្នុងនោះកុមារា ១នាក់ កុមារី ០០នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ១នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៣១នាក់ ស្រី ១២នាក់ កុមារា ១នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៨នាក់ ស្រី ២នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ១នាក់ ស្រីចំនួន ១នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ប្រុសចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ១៨នាក់ ស្រី ៦នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអស់ហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## សមត្ថកិច្ចនៅកំពុងបន្តសាកសួរជនជាតិវៀតណាម និងជនជាតិចិនប្រមាណ ១៣០ នាក់ ដែលលួចឆ្លងដែនខុសច្បាប់

https://www.postkhmer.com/ គឹម សារុំ | Publication date 02 May 2021 | 11:43 ICT

**ស្វាយរៀង៖** សមត្ថកិច្ចចម្រុះខេត្តស្វាយរៀង រហូតមកដល់ថ្ងៃទី ២ ឧសភានេះ នៅកំពុងបន្តសាកសួរជនជាតិវៀតណាម និងជនជាតិចិនប្រុសស្រីប្រមាណ ១៣០ នាក់ ករណីឆ្លងដែនខុសច្បាប់ ដែលត្រូវបានឃាត់ខ្លួនកាលពីថ្ងៃទី ២៧ ខែមេសា។

លោក ស្រី វុត្ថា មេបញ្ជាការរងកងរាជអាវុធហត្ថខេត្តស្វាយរៀង ប្រាប់ ភ្នំពេញ ប៉ុស្តិ៍ នៅព្រឹកថ្ងៃទី ២ ខែឧសភានេះថា ករណីជនជាតិវៀតណាម និងជនជាតិចិនប្រុសស្រីប្រមាណ ១៣០ នាក់នោះ សមត្ថកិច្ចចម្រុះនៅមិនទាន់សាកសួរពួកគេចប់នៅឡើយទេ។ លោកថ្លែងថា៖ «ពេលនេះ សមត្ថកិច្ចពាក់ព័ន្ធកំពុងញែករកអ្នកមានច្បាប់ និងអ្នកគ្មានច្បាប់។ បើអ្នកមានច្បាប់នឹងត្រូវបញ្ជូនទៅមណ្ឌលចត្តាឡីស័ក បើអ្នកឆ្លងដែនខុសច្បាប់ គឺគិតតាមនោះទៀត»។ កាលពីវេលាទៀបភ្លឺថ្ងៃទី ២៧ ខែមេសា កម្លាំងកងរាជអាវុធហត្ថខេត្តស្វាយរៀងបានល្បាតក្នុងក្រុងបាវិត ហើយបានប្រទះឃើញជនជាតិវៀតណាម និងជនជាតិចិនប្រុសស្រីប្រមាណ ១៣០ នាក់ កំពុងនាំគ្នាចុះពីលើម៉ូតូចូលក្នុងបរិវេណផ្ទះសំណាក់ឈ្មោះឋានសួគ៌បួនរដូវ ហើយសមត្ថកិច្ចក៏ឃាត់ខ្លួនតែម្តង។

ពាក់ព័ន្ធជនបរទេសលួចឆ្លងដែនខុសច្បាប់នេះដែរ ភ្នំពេញ ប៉ុស្តិ៍ មិនអាចទាក់ទងលោក តូច ប៉ូលីវ៉ា អភិបាលរងខេត្តស្វាយរៀង ដើម្បីសុំអត្ថាធិប្បាយបានទេ នៅព្រឹកថ្ងៃទី ២ ឧសភានេះ។ ប៉ុន្តែ លោកធ្លាប់ប្រាប់កាលពីថ្ងៃទី ២៨ មេសាថា មនុស្សប្រុសស្រីប្រមាណ ១៣០ នាក់ ជាជនជាតិចិន និងវៀតណាម ដែលអ្នកខ្លះពាក់ព័ន្ធរឿងឆ្លងដែនខុសច្បាប់តាមច្រកព្រំដែនកម្ពុជា-វៀតណាម។ លោក ប៉ូលីវ៉ា ថ្លែងថា៖ «បន្ទាប់ពីស្រង់សាវតាជាតិពួកគេអស់គ្នាហើយនោះ គឺអាជ្ញាធរខេត្តនឹងធ្វើការទំនាក់ទំនងជាមួយភាគីដៃគូថា តើនឹងត្រូវធ្វើយ៉ាងម៉េចទៀត។ ការងារយ៉ាងណាទៀតនោះ គឺអាជ្ញាធរខេត្តនឹងប្រជុំពិភាក្សាជាមួយជំនាញពាក់ព័ន្ធបន្តទៀត»៕

## សង់ត្រាល់៖ពលករខ្មែរប្រមាណ៦០ភាគរយមិនមានការងារធ្វើគ្រប់គ្រាន់អំឡុងពេលថៃផ្ទុះកូវីដ១៩

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 02/05/2021 - 08:58

តាមការអង្កេតរបស់មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅកាត់ថា សង់ត្រាល់ គឺមានពលករខ្មែរប្រមាណ៦០ភាគរយក្នុងចំណោមពលករខ្មែរទាំងស្របច្បាប់ និងមិនស្របច្បាប់ជិត២លាននាក់មិនមានការងារធ្វើគ្រប់គ្រាន់នៅថៃ អំឡុងពេលដែលប្រទេសនេះ កំពុងប្រឈមនឹងការរាតត្បាតខ្លាំងនៃជំងឺកូវីដ១៩។

ថ្លែងប្រាប់វិទ្យុបារាំងអន្តរជាតិនៅថ្ងៃទី២ ឧសភានេះ លោក ឌី ថេហូយ៉ា ប្រធានកម្មវិធីនៃអង្គការសង់ត្រាល់ បានប៉ាន់ប្រមាណថា ៦០ភាគរយ នៃពលករខ្មែរដែលមិនមានការងារធ្វើគ្រប់គ្រាន់នៅប្រទេសថៃ ដោយសារការកាត់បន្ថយម៉ោងការងារពីថៅកែ ដែលមុនផ្ទុះកូវីដ១៩ខ្លាំងនៅថៃ ពលករអាចធ្វើការថែមម៉ោងបានពេញមួយសប្តាហ៍។ ហើយក្នុងចំណោម៦០ភាគរយនេះក៏មានករណីខ្លះរោងចក្របានបិទទ្វារតែម្តងទើបជាហេតុធ្វើឲ្យពលករមិនមានការធ្វើ។ បើតាមលោក ឌី ថេហូយ៉ា ភាគច្រើននៃពលករខ្មែរដែលគ្មានការងាធ្វើ ឬការងារមិនគ្រប់គ្រាន់ ជាពលករខុសច្បាប់ដែលជាកម្មករសំណង់ ការងារក្នុងចម្ការជើម។

ចំណែកពលករស្របច្បាប់ដែលមានចុះកិច្ចព្រមព្រៀងរវាងកម្ពុជានិងថៃ ប្រមាណ៣០ទៅ៤០ ពួកគេនៅមានលំនឹងការងារ ទោះជាគ្រានេះថៃកំពុងប្រឈមនឹងការរាតត្បាតខ្លាំងនៃជំងឺកូវីដ១៩ ក៏ដោយ ដែលភាគច្រើននៃពួកគេទាំងនេះបំរើការងារក្នុងរោងចក្រធំៗរបស់ថៃ។ ខណៈដែលគ្មានការងារធ្វើនិងមិនបានបំពេញការងារឲ្យពេញដៃពេញជើងដូចមុនផ្ទុះកូវីដ១៩ ពលករខ្មែរក៏កំពុងព្រួយបារម្ភពីការឆ្លងវីរុសកូវីដ១៩ នៅក្នុងប្រទេសដែរ ដែលក្នុងមួយថ្ងៃថៃរកឃើញចំនួនអ្នកឆ្លងថ្មីយ៉ាងណាស់១ពាន់ករណី។ មិនខុសពីកម្ពុជាដែរ នៅក្នុងប្រទេសថៃ តំបន់មួយចំនួនត្រូវបានកំណត់ពណ៌ ដោយក្នុងនោះ៤៥ខេត្តជាតំបន់ក្រហម ខេត្តក្រុង៦ជាតំបន់ក្រហមចាស់ និង២៦ខេត្តជាតំបន់លឿងទុំ។ កន្លងមកមានពលករខ្មែរចំនួន១០នាក់ ដែលកំពុងធ្វើការនៅក្នុងខេត្តសាមុតប្រាកាន ត្រូវបានរកឃើញថាវិជ្ជមានកូវីដ-១៩។

នៅចំពោះមុខបញ្ហានេះលោក ឌី ថេហូយ៉ា លើកឡើងថា រដ្ឋាភិបាលកម្ពុជានិងស្ថានទូតខ្មែរគួរយកចិត្តទុកដាក់ចំពោះសុខទុក្ខពលករខ្មែរនៅប្រទេសថៃតាមរយៈផ្តល់ការគាំពារផ្នែកស្បៀងអាហារក្នុងករណីដែលពលករគ្មានការធ្វើនិងបាត់បង់ប្រាក់ចំណូលនៅក្នុងប្រទេសថៃ។ មួយវិញទៀតនៅពេលដែលពលករត្រឡប់មកវិញក្រោយស្ងប់ស្ងាត់កូវីដ១៩ទាំងនៅថៃនិងកម្ពុជាគឺការផ្តល់ការងារកសិកម្មទៅកាន់ពួកគេជារឿងសំខាន់៕

## ប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិសម្រាប់ខេត្តសៀមរាប សរុបចំនួន ៣៧នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃអាទិត្យ ទី០២ ខែឧសភា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៣៧នាក់ ស្រី ១៧នាក់ ក្នុងនោះកុមារ ០០នាក់ កុមារី ២នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៧នាក់ ស្រី ២នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

3- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៧នាក់ ស្រី ៤នាក់ កុមារ ០០នាក់ កុមារី ១នាក់។

៤-សម្រាប់ច្រកពអរជាតិអូរស្មាច់÷ ចំនួន ២៣នាក់ ស្រី ១១នាក់ កុមារ ០០នាក់ កុមារី ១នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ប្រុសចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៣៧នាក់ ស្រី ១៧នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

# ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១

## នគរបាល៩១១ ប៉ុស្តិ៍សិលាខ្មែរឃាត់ខ្លួនមនុស្ស ០២នាក់ និងមេខ្យល់ ០១នាក់

https://m.facebook.com/FridayDailyNews/ 03/05/2021

ខេត្តបន្ទាយមានជ័យ៖ ថ្ងៃចន្ទ ៧រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី ០៣ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង ៦ និង ៤០នាទី (ដោយគោរព និងអនុវត្តយ៉ាងម៉ឺងម៉ាត់ របស់លោកមេបញ្ជាការ និងមានការ ឯកភាពពីលោកមេបញ្ជាការរងទទួលទិស)។ កម្លាំងប៉ុស្តិ៍ចំនួន ០៦នាក់ ដឹកនាំដោយលោកវរសេនីយ៍ត្រី ប៉ាក់ សារ៉ាត់ នាយប៉ុស្តិ៍ ចូលរួមសហការជាមួយកម្លាំងនគរបាលរដ្ឋបាល និងកម្លាំងយោធា បានធ្វើការឃាត់សួនាំប្រជាពល រដ្ឋចំនួន ០២នាក់ ស្រី ០នាក់ បម្រុងលួចឆ្លងដែនដោយខុសច្បាប់ អ្នកទាំង ០២នាក់ មានទីលំនៅភូមិដំរីលើ ឃុំ សឿ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ។ យកមកសួរនាំ រួចកម្លាំងយើងបន្តឈានទៅរកឃាត់ខ្លួនមេខ្យល់សួរនាំ មនុស្សឆ្លងដែនដោយខុសច្បាប់ បាន០១នាក់បន្ថែមទៀត មានទីលំនៅភូមិសិលាខ្មែរ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។ ក្រោយសួរនាំតាមនីតិវិធីរួចរាល់កម្លាំងនគរបាលការពារព្រំដែនគោក ប៉ុស្តិ៍សិលាខ្មែរ នៃវរសេនាតូចនគរបាលការពារព្រំដែកគោកលេខ៩១១ បានប្រគល់ជូននគរបាលប៉ុស្តិ៍រដ្ឋបាលអូរបីជាន់ ដើម្បីសួរនាំតាមនីតិវិធីបន្ត។ ប្រភព៖ ប៉ុស្តិ៍ការពារព្រំដែនសិលា

## ប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៥២នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃចន្ទ ទី០៣ ខែឧសភា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៥២នាក់ ស្រី ២៦នាក់ ក្នុងនោះកុមារា ៥នាក់ កុមារី ៣នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១២នាក់ ស្រី ៥នាក់ កុមារា ២នាក់ កុមារី ១នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ១៣នាក់ ស្រី ៥នាក់ កុមារា ៣នាក់ កុមារី ១នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ២៧នាក់ ស្រី ១៦នាក់ កុមារា ០០នាក់ កុមារី ១នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់.

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ប្រុសចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៥២នាក់ ស្រី ២៦នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអស់ហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១

### ឃាត់ខ្លួនមេខ្យល់នាំពលករឆ្លងដែនខុសច្បាប់ ២នាក់ នៅបាត់ដំបង

http://www.arey-news.com/ (ថ្ងៃទី 05 May 2021 ម៉ោង 10:18 am)

បាត់ដំបង: ឃាត់ខ្លួនកាលពីថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២១ មេខ្យល់ដែលជាប្ដីប្រពន្ធហើយសកម្មក្នុងការនាំពលករឆ្លងដែនខុសច្បាប់ ត្រូវបានកម្លាំងវរសេនាតូចលេខ៥៣៣ កងពលតូចថ្មើរជើងលេខ៥៣ ក្នុងពេលដែលពួកគេកំពុងនាំពលករឆ្លងដែនទៅប្រទេសថៃចំនួន១០នាក់នៅភូមិសាស្ត្រចំណុចស្ពានបី ភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ។ មេខ្យល់ដែលត្រូវបានចាប់ខ្លួន ១.ឈ្មោះ ភោគ ធឿន (ហៅនាង) អាយុ៣៥ឆ្នាំ រស់នៅ ភូមិ ភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង និង ប្ដីឈ្មោះ សៅ ធី អាយុ ៣០ឆ្នាំ ទីលំនៅ មិនពិតប្រាកដ ។ បច្ចុប្បន្នពួកគេត្រូវបានអធិការដ្ឋាននគរបាលស្រុកកំរៀង ចាត់ការតាមនីតិវិធី។ ចំណែក ពលករទាំង១០នាក់ ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័កចំនួន១៤ថ្ងៃ នៅមណ្ឌលចត្តាឡីស័ក ស្រុកកំរៀង៕

## សមត្ថកិច្ចបញ្ជូនបុរសម្នាក់ទៅស្នងការដ្ឋាន បន្ទាប់ពីឃាត់ខ្លួនករណីនាំមនុស្ស ១១ នាក់ បម្រុងឆ្លងដែន

https://m.postkhmer.com/ អោម ប៊ុនធឿន 04 May 2021 | 18:55 ICT

**បន្ទាយមានជ័យៈ** នគរបាលស្រុកស្វាយចេក បានបញ្ជូនជនសង្ស័យជាមេខ្យល់ម្នាក់ ទៅស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ នៅរសៀលថ្ងៃទី ៤ ខែឧសភានេះ បន្ទាប់ពីឃាត់ខ្លួនពាក់ព័ន្ធករណីលួចដឹកជញ្ជូនពលរដ្ឋ ១១ នាក់ បម្រុងឆ្លងដែនទៅប្រទេសថៃ ដោយខុសច្បាប់។

អធិការនគរបាលស្រុកស្វាយចេក លោក ជា ស្លួញ បានឲ្យដឹងនៅថ្ងៃនេះថា សមត្ថកិច្ចលោកបានចាប់ខ្លួនមេខ្យល់ម្នាក់ឈ្មោះ ស្រឿង សារ៉េត ភេទប្រុស អាយុ ៣៧ ឆ្នាំ និងរថយន្ត ១ គ្រឿង ខណៈកំពុងដឹកពលរដ្ឋប្រុសស្រី និងក្មេងសរុប ១១ នាក់ បម្រុងឆ្លងដែនទៅប្រទេសថៃ ដោយខុសច្បាប់កាលពីយប់ថ្ងៃទី ៣ ខែឧសភា នៅចំណុចភូមិដំណាក់កកោះ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។ បើតាមលោក ជា ស្លួញ មុនពេលឃាត់ខ្លួនជនសង្ស័យរូបនេះ កម្លាំងនគរបាលនៃអធិការដ្ឋាននគរបាលស្រុកស្វាយចេក ដែលឈរជើងនៅគោលដៅខ្លោងទ្វារចូលក្នុងភូមិតេជោភ្នំឆត្រ បានសហការជាមួយនគរបាលប៉ុស្តិ៍ការពារព្រំដែនគោកចម្ការគ នៃវរសេនាតូចការពារព្រំដែនគោកលេខ ៩១១ ដោយបានចុះល្បាតនៅចំណុចភូមិដំណាក់កកោះ។ ពេលនោះស្រាប់តែបានឃើញរថយន្ត ១ គ្រឿង មានដឹកពលករចំនួន ១១ នាក់ បម្រុងឆ្លងដែនចូលទៅប្រទេសថៃ ក៏បានឃាត់រថយន្ត និងមនុស្សយកមកសាកសួរនៅអធិការដ្ឋាននគរបាលស្រុកស្វាយចេកតែម្តង។

លោកថ្លែងថាៈ «ឥឡូវយើងបានដំណើរការបញ្ជូនជនសង្ស័យទៅស្នងការដ្ឋានហើយ ដើម្បីរៀបចំនីតិវិធីបញ្ជូនទៅតុលាការតែម្តង»។ បើតាមលោក ជា ស្លួញ ពលរដ្ឋទាំង ១១ នាក់នោះមានស្រី ៧ នាក់ ក្នុងនោះមានកុមារីម្នាក់ផង។ ក្រៅពីនោះមានកុមារ ២ នាក់ និងមនុស្សប្រុសពេញវ័យ។ ពួកគេទាំងនោះរស់នៅខេត្តបន្ទាយមានជ័យ និងខេត្តមានជ័យ។ ចំណែករថយន្តម៉ាកស្តារិចពណ៌ទឹកប្រាក់ពាក់ស្លាកលេខភ្នំពេញ2BB-9491 ជារបស់អ្នកបើកបរជាមេខ្យល់ឈ្មោះ ស្រឿង សារ៉េត រស់នៅភូមិបន្ទាយឆ្មារត្បូង ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ លោកអធិការស្រុកបានបញ្ជាក់ថាៈ «ចំពោះពលរដ្ឋសរុបទាំង ១១ នាក់ ដែលមានទាំងក្មេង ៣ នាក់ផងនោះ យើងបានបញ្ជូនទៅធ្វើចត្តាឡីស័កនៅវិទ្យាល័យស្វាយចេកអស់ហើយ»។

លោកស្រី ឌី សុជាតិ ស្នងការរងទទួលការងារយេនឌ័រ និងប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្តបន្ទាយមានជ័យឲ្យដឹងថា លោកស្រីមិនទាន់ទទួលបានសំណុំរឿង និងជនសង្ស័យនៅឡើយទេ នៅរសៀលថ្ងៃទី ៤ ខែឧសភានេះ។ លោកស្រីបានថ្លែងថា «ខ្ញុំមិនទាន់បានទទួលនៅឡើយទេ។ ដំបូងខាងអធិការប្រាប់ថា បញ្ជូនមកនៅពេលព្រឹក ប៉ុន្តែដោយសារធ្វើសំណុំរឿងមិនទាន់ លោកក៏បានបញ្ជាក់មកវិញថា នឹងបញ្ជូនមកនៅពេលរសៀល»៕

## លោកឧត្តមសេនីយ៍ត្រី ម៉ុន មាគ៌ា បានអញ្ជើញដឹកនាំកិច្ចប្រជុំ តាមរយៈប្រព័ន្ធ Zoom ស្តីពីការពង្រឹងការងារការឆ្លងដែនខុសច្បាប់ របស់ជនបរទេស ចូលមកកាន់មូលដ្ឋានខេត្តត្បូងឃ្មុំ និងការងារផ្សេងៗ ដើម្បីបង្ការទប់ស្កាត់ជំងឺកូវីដ១៩

http://cambodiapolice.com/policekh/ 8:30 pm 4 ឧសភា 2021

ខេត្តត្បូងឃ្មុំៈ នៅរសៀលថ្ងៃអង្គារ ទី០៤ ខែឧសភា ឆ្នាំ២០២១ លោកឧត្តមសេនីយ៍ត្រី ម៉ុន មាគ៌ា ស្នងការនគរបាលខេត្តត្បូងឃ្មុំ បានអញ្ជើញដឹកនាំកិច្ចប្រជុំ តាមរយៈប្រព័ន្ធ Zoom ស្តីពីការ ពង្រឹងការងារការឆ្លងដែនខុសច្បាប់ របស់ជនបរទេស ចូលមកកាន់មូលដ្ឋានខេត្តត្បូងឃ្មុំ និងការងារផ្សេងៗ ដើម្បីបង្ការទប់ស្កាត់ជំងឺកូវីដ១៩ ។

លោកឧត្តមសេនីយ៍ស្នងការ បានមានប្រសាសន៍ផ្តាំផ្ញើដល់បងប្អូនមន្ត្រីនគរបាលទាំងអស់ នៃស្នងការដ្ឋាននគរបាលខេត្តត្បូងឃ្មុំ ត្រូវប្រកាន់ខ្ជាប់នូវវិធានការ របស់ក្រសួងសុខាភិបាល និងអនុវត្ត ៣ការពារ ៣កុំ របស់ប្រមុខរាជរដ្ឋាភិបាល ៕

## ឧត្តមសេនីយ៍ទោ កឹង យន ណែនាំដល់កងកម្លាំងនគរបាលបង្ក្រាបសកម្មភាពលួចនាំមនុស្សចេញ-ចូលឆ្លងដែនខុសច្បាប់ ក្នុងភូមិសាស្ត្រស្នួលស្វាញ តាមបណ្តោយខ្សែបន្ទាត់ព្រំដែនកម្ពុជា -វៀតណាម

https://cen-news.com/ ByPen Srey NeatMay 5, 2021

ខេត្តស្វាយរៀង ៖ នៅរសៀលថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ លោកឧត្តមសេនីយ៍ទោ កឹង យន ស្នងការនគរបាលខេត្ត បានធ្វើការណែនាំដល់កងកម្លាំងនគរបាល ដែលត្រូវចាត់បញ្ជូនអោយចុះជួយតាមបណ្តាគោលដៅក្នុងភូមិសាស្ត្រស្នួលស្វាញ តាមបណ្តោយខ្សែបន្ទាត់ព្រំដែនកម្ពុជា -វៀតណាម ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការងារបង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាពលួចនាំមនុស្សចេញ-ចូលឆ្លងដែនខុសច្បាប់ ដើម្បីទប់ស្កាត់ការលួចឆ្លងដែនចេញ-ចូលដោយខុសច្បាប់ សំដៅទប់ស្កាត់ការរីករាលដាលឆ្លងជំងឺកូវីដ-១៩ និងបទល្មើសនានាឆ្លងកាត់ព្រំដែន ៕

## សមត្ថកិច្ចឃាត់ខ្លួនជនជាតិចិន៦នាក់ ក្នុងករណីជួញដូរមនុស្សនិងឆ្លងដែនខុសច្បាប់

http://nokorwatnews.com/ 04/05/2021

ខេត្តស្វាយរៀង ៖ បុរសជាជនជាតិចិនចំនួន៦នាក់ ត្រូវបាននគរបាលប៉ុស្តិ៍រដ្ឋបាល កម្លាំងអធិការដ្ឋាននគបាលស្រុក និងកម្លាំងនគរបាលអន្តោប្រវេសន៍ ស្នងការខេត្តឃាត់ខ្លួនមកសាកសួរបន្ទាប់ពីប្រជាពលរដ្ឋរាយការណ៍មកថា មានជនជាតិចិនដើរតាមផ្លូវជាតិលេខ១ រួចចុះកាត់វាលស្រែក្រោយផ្ទះអ្នកស្រុក ខណៈសង្ស័យអ្នកបើករថយន្តឃើញកំលាំងសមត្ថកិច្ចនគបាលស្រុកស្វាយទាប ដាក់ប៉ុស្តិ៍ត្រួតពិនិត្យតាមដងផ្លូវជាតិលេខ១ ទំលាក់ចុះរួចបើកគេចខ្លួន។

ការឃាត់ខ្លួននេះធ្វើឡើងនៅវេលាម៉ោង៨ និង៤០នាទី យប់ថ្ងៃទី៣ ឧសភា ២០២១ ស្ថិតក្នុងភូមិប្រសូតិ២ ឃុំកណ្តៀងរាយ ស្រុកស្វាយទាប ។ សមត្ថកិច្ចបានអោយដឹងថាជនជាតិចិនទាំងនោះមាន ៖

ទី១. ឈ្មោះ លួន យុន ភេទប្រុស អាយុ១៨ឆ្នាំ

ទី២. ឈ្មោះ តាំង ឡាំង ភេទប្រុស អាយុ២២ឆ្នាំ

ទី៣. ឈ្មោះ.ឆេង ជិនតាវ ភេទប្រុស អាយុ១៨ឆ្នាំ

ទី៤. ឈ្មោះ ទូ ជាអូ ភេទប្រុស អាយុ១៨ឆ្នាំ

ទី៥. ឈ្មោះ ហ្វាង ចូអ៊ី ភេទប្រុស អាយុ២១ឆ្នាំ

ទី៦. ឈ្មោះ ចាង អ៊ីធឹង ភេទប្រុស អាយុ១៨ឆ្នាំ អ្នកទាំងអស់មានទីលំនៅ នៅប្រទេសចិន និងបានដកហូតវត្ថុតាង ទូរស័ព្ទដៃចំនួន០៥គ្រឿងផងដែរ។ ប្រភពបន្តថា គោលបំណងជនជាតិចិនទាំងនោះ ឆ្លងដែនមកកម្ពុជា រកការងារធ្វើ (ដោយគ្មានប៉ាស្ព័រលិខិតស្នាមទាំង០៦នាក់)។ សមត្ថកិច្ចបានបញ្ជាក់ទៀតថា ជនជាតិចិនទាំង០៦នាក់ត្រូវបានអ្នកបើករថយន្ត មិនស្គាល់ម៉ាកមួយគ្រឿងដឹកតាមដងផ្លូវជាតិលេខ១ ប៉ុន្តែចៃដន្យឃើញសមត្ថកិច្ចដាក់កម្លាំងត្រួតពិនិត្យយានយន្ត ទើបឃើញសភាពការណ៍មិនស្រួលក៏ទំលាក់ជនជាតិចិនទាំងនោះឲ្យចុះដើរវាងចៃដន្យប្រជាពលរដ្ឋឃើញក៏បានរាយការណ៍មកសមត្ថកិច្ច ទើបសមត្ថកិច្ចក៏បានតាមប្រម៉ាញ់ស្ទាក់រហូតដល់ផ្លូវជាតិលេខ៣១៤D ស្ថិតក្នុងភូមិប្រសូតិ០១ ឃុំកណ្តៀងរាយ ស្រុកស្វាយទាបទើបសមត្ថកិច្ចបង្ក្រាបបានតែម្តង ។ ប្រភពបន្តថាបន្ទាប់ពីធ្វើតេស្តរហ័ស លទ្ធផលអវិជ្ជមានមកសមត្ថកិច្ចក៏បានបញ្ជូនជនជាតិចិនទាំងនោះទៅធ្វើចត្តាឡីស័ក

នៅផ្ទះសំណាក់គ្រូបង្រៀន ក្រុងស្វាយរៀង។ ចំណែកអ្នកបើករថយន្តដឹកជនជាតិចិនទាំងនោះសមត្ថកិច្ចបន្តធ្វើការស្រាវជ្រាវ ដើម្បីចាត់ការតាមច្បាប់៕

## ពលករខ្មែរមកពីថៃចំនួន៥នាក់ទៀត ទិជ្ជមានកូវីដ-១៩

https://thmeythmey.com/ 04, May 2021 ,  8:29 pm

ភ្នំពេញ៖ រដ្ឋបាលខេត្តបាត់ដំបង បានប្រកាសថា មានពលករខ្មែរចំនួន៥នាក់ទៀត មានតេស្តវិជ្ជមានកូវីដ-១៩។ រដ្ឋបាលខេត្តបាត់ដំបង ពលករខ្មែរទាំង៥នាក់ មានទីលំនៅក្នុងភូមិសម្តេច ឃុំតាប៉ុន ស្រុកសង្កែ ហើយពួកគាត់បានធ្វើដំណើរពីប្រទេសថៃ មកដល់កម្ពុជា តាមច្រកអូរបើជាន់ ខេត្តបន្ទាយជ័យ តាមរយៈរថយន្តឈ្នួល កាលពីថ្ងៃទី១ ឧសភា។ បន្ទាប់មកពួកគាត់ និងពលករខ្មែរផ្សេងទៀត ត្រូវបានដឹកតាមរថយន្តកងទ័ព ដើម្បីដាក់ធ្វើចត្តាឡីស័ក នៅតាមមូលដ្ឋានភូមិឃុំ រៀងខ្លួន។ យ៉ាងណាក៏ដោយ សេចក្តីប្រកាសព័ត៌មានរបស់ប្រចាំថ្ងៃ របស់ក្រសួងសុខាភិបាល នៅថ្ងៃទី៤ ឧសភានេះ នៅមិនទាន់បញ្ចូលតួលេខពលករខ្មែរ ទាំង៥នាក់នៅឡើយ បើទោះរដ្ឋបាលខេត្តបានទទួលលទ្ធផលតេស្តរបស់ពួកគាត់ នៅថ្ងៃទី៣ ខែឧសភា។ ចាប់តាំងពីមានផ្ទុកជំងឺកូវីដ-១៩ ខេត្តបាត់ដំបង រកឃើញអ្នកជំងឺកូវីដ-១៩ ចំនួន ៣៥នាក់ ក្នុងនោះ២៨នាក់បានជាសះស្បើយ និង៧នាក់ កំពុងសម្រាកព្យាបាល។ នេះបើយោងតាម សេចក្តីជូនដំណឹង របស់រដ្ឋបាលខេត្តបាត់ដំបង៕

## ក្រសួងការបរទេស៖ ករណីទី១ ពលករខ្មែរនៅប្រទេសថៃ ស្លាប់ដោយសារកូវីដ១៩

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 04/05/2021 - 09:04 ដោយ៖អោ ស្រីពេជ្រ

ពលករខ្មែរធ្វើការនៅប្រទេសថៃ បានស្លាប់ដោយសារជំងឺកូវីដ១៩ នៅក្នុងមន្ទីរពេទ្យទីក្រុងបាំងកក កាលពីថ្ងៃទី៣០ មេសាឆ្នាំ២០២១ កន្លងទៅ។ តាមរយៈវិទ្យុបារាំងអន្តរជាតិ rfi នៅថ្ងៃទី០៤ ឧសភានេះ អ្នកនាំពាក្យក្រសួងការបរទេស លោក កុយ គួង បានឲ្យដឹងថា សពពលករខ្មែរដែលបានស្លាប់នោះ ត្រូវបានបូជានៅប្រទេសថៃតែម្តង។ មានដើមកំណើតមកពីខេត្តត្បូងឃ្មុំ មកធ្វើការងារនៅទីក្រុងបាងកក ពលករខ្មែរម្នាក់ដែលជាករណីទីមួយ ត្រូវបានកូវីដ១៩ឆក់យកជីវិតនៅក្នុងទឹកដីនៃប្រទេសថៃ នាថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១។

បើតាមស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ សពខាងលើ គឺជាពលករស្របច្បាប់ ភេទប្រុស មានវ័យ៣៤ឆ្នាំ និងដែលបានឆ្លងជំងឺកូវីដ១៩ កាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២១ ក្រោយទទួលការព្យាបាលនៅមន្ទីរពេទ្យក្នុងទីក្រុងបាំងកក។ សពជាពលករនេះ ចាំបាច់ត្រូវបូជានៅប្រទេសថៃតែម្តង៕

នៅថ្ងៃទី០៤ឧសភានេះ អ្នកនាំពាក្យក្រសួងការបរទេស លោក កុយ គួង បានលើកឡើងថា ប្រពន្ធរបស់សពខាងលើដែលជាពលករខ្មែរដូចគ្នានោះ បានឆ្លងកូវីដ១៩ ទន្ទឹមនឹងស្វាមីខ្លួនដែរ។ បច្ចុប្បន្ននេះ នាងកំពុងតែបន្តព្យាបាលក្នុងមន្ទីរពេទ្យ ដោយមានការដាក់ឧបករណ៍ជំនួយដង្ហើម។ អ្នកនាំពាក្យក្រសួងការបរទេស បានគូសបញ្ជាក់ថា ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានទាក់ទងទៅមន្ទីរពេទ្យព្យាបាលប្រពន្ធសពជាប្រចាំ និងបានអះអាងដែរថា មន្ទីរពេទ្យក៏បានយកចិត្តទុកដាក់ព្យាបាលអ្នកជម្ងឺជាពលករខ្មែររូបនេះផងដែរ។

នាអំឡុងពេលផ្ទុះជំងឺកូវីដ១៩ខ្លាំងនៅប្រទេសថៃនេះ លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស បានឲ្យដឹងថា ស្ថានទូតកម្ពុជា កំពុងទាក់ទងសហការជាមួយក្រុមហ៊ុនបញ្ជូន និងទទួលពលករ ដើម្បីទាមទារអត្ថប្រយោជន៍នានា ជូនគ្រួសារជនរងគ្រោះដោយវិបត្តិកូវីដ១៩នេះ៕

# ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២១

## សមត្ថកិច្ចឃាត់ខ្លួនស្ត្រីជនជាតិវៀតណាមម្នាក់ជាមេខ្យល់និងអ្នករត់ម៉ូតូឌុប២នាក់ពាក់ព័ន្ធករណីនាំជនជាតិចិន៥នាក់លួចឆ្លងដែនខុសច្បាប់

http://nokorwatnews.com/ 05/05/2021

ខេត្តស្វាយរៀង៖ ស្ត្រីជាប់សង្ស័យជាមេខ្យល់ម្នាក់ និងជនជាតិវៀតណាម ជាអ្នករត់ម៉ូតូឌុប២នាក់ ត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួនបន្ទាប់ពីដឹកជនជាតិចិន៥នាក់ លួចឆ្លងដែនខុសច្បាប់ កាលពីវេលាម៉ោង៦ព្រឹក ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១ នៅចំណុចមុខវត្តតាពៅ ស្ថិតនៅភូមិតាពៅ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង។

បើតាមសមត្ថកិច្ចនគរបាលបានឱ្យដឹងថា ជនសង្ស័យដែលឃាត់ខ្លួនបានមានទី១-ឈ្មោះ ថាន់ ធីប៉ៃ ភេទស្រី អាយុ ២៩ឆ្នាំ ជនជាតិវៀតណាម មុខរបរលក់ផ្លែឈើ (មេខ្យល់), ទី២-ឈ្មោះ លី ធី ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិ វៀតណាម មុខរបររត់ម៉ូតូឌុប និងទី៣-ឈ្មោះ ឡេ វ៉ាំងមិន ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិវៀតណាម មុខរបររត់ម៉ូតូឌុប ។ អ្នកទាំង៣នាក់ស្នាក់នៅផ្ទះជួលផ្លូវសាលារៀន ក្នុងភូមិបាវិតកណ្ដាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង។ ចំណែកជនជាតិចិនទាំង៥នាក់មាន៖

ទី១-ឈ្មោះ វង់ ជីញ ភេទប្រុស ជនជាតិចិន អាយុ២៨ឆ្នាំ មាន ស្រុកកំណើតនៅខេត្តស៊ីឈន់ ក្រុងតាចូវ។

ទី២-ឈ្មោះ លាវ ឆាវយៀក ភេទប្រុស ជនជាតិចិន អាយុ៣១ឆ្នាំ មានស្រុកកំណើតនៅទីក្រុងឆុងឈីញ។

ទី៣-ឈ្មោះ វ៉ៃ សើវយៀក ភេទស្រី ជនជាតិចិន អាយុ៣០ឆ្នាំ មានស្រុកកំណើតនៅខេត្តគ័ងស៊ី ក្រុងប៉ីហាយ។

ទី៤-ឈ្មោះ លូ ចុងជៀន ភេទប្រុស ជនជាតិចិន អាយុ៤២ឆ្នាំ មានស្រុកកំណើតនៅខេត្តហ្វូជៀន ក្រុងស៊ែមិន។

ទី៥-ឈ្មោះ លី ហាយចូវ ភេទប្រុស ជនជាតិចិន អាយុ៤១ឆ្នាំ មានស្រុកកំណើតនៅខេត្តក្វាងទុង ក្រុងតុងគន់។

ជនជាតិចិនទាំង៥នាក់នេះគ្មានលិខិតឆ្លងដែនទាំងអស់គ្នា។ បច្ចុប្បន្នជនសង្ស័យទាំង៣នាក់ ត្រូវបានឃាត់ខ្លួនបណ្ដោះអាសន្ននៅអធិការដ្ឋាននគរបាលក្រុងបាវិត ដើម្បីចាត់ការតាមច្បាប់៕

## បញ្ជូនជនសង្ស័យ ០៣នាក់ ទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ០២នាក់ជាមេខ្យល់ និងម្នាក់ទៀតជាអ្នកដឹកជញ្ជូន

http://www.arey-news.com/ (ថ្ងៃទី 05 May 2021 ម៉ោង 4:19 pm)

**បន្ទាយមានជ័យ:** យោងតាមផែកអគ្គស្នងការដ្ឋាននគរបាលជាតិបានឲ្យដឹងថា ជនសង្ស័យចំនួន០៣នាក់ ក្នុងនោះ០២នាក់ ជាមេខ្យល់ត្រូវបានកម្លាំងនគរបាលស្រុកអូរជ្រៅ ចាប់ឃាត់ខ្លួនពីបទនាំមនុស្សឆ្លងដែនទៅថៃដោយខុសច្បាប់ និងម្នាក់ទៀត ត្រូវបានកម្លាំងនគរបាលស្រុកស្វាយចេកចាប់ខ្លួនបទដឹកជញ្ជូនមនុស្សឆ្លងដែនទៅថៃដោយខុសច្បាប់ ត្រូវបានកម្លាំងនគរបាលការិយាល័យ ប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បញ្ជូនខ្លួនទៅសាលាដំបូង ខេត្តបន្ទាយមានជ័យ នៅថ្ងៃទី០៥ខែឧសភា ឆ្នាំ២០២១ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

យោងតាមរបាយការណ៍របស់ លោកវរសេនីយ៍ឯក ឡាយ គឹមលួន នាយការិយាល័យនគរបាលប្រឆាំង ការជួញដូរមនុស្សនិងការពារអនីតិជន បានឲ្យដឹងថា ជនសង្ស័យទាំង០៣នាក់ ៖

១.ឈ្មោះ សេន រចនា ភេទប្រុស អាយុ៣១ឆ្នាំ នៅភូមិសិលាខ្មែរ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

២.ឈ្មោះយាម រិត ភេទប្រុសអាយុ៤៣ឆ្នាំ នៅភូមិទំនប់ដាច់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

ជនសង្ស័យទាំង០២នាក់នេះ ត្រូវបានកម្លាំងនគរបាលស្រុកអូរជ្រៅ ចាប់ឃាត់ខ្លួននៅវេលាម៉ោង១០និង៣០នាទី កាលពីព្រឹកថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១ នៅចំណុចច្រករបៀងឃុំអូរបីជាន់ ស្រុកអូរជ្រៅ ពីបទនាំមនុស្សឆ្លងដែនដោយខុខច្បាប់ទៅប្រទេសថៃ ។

ចំណែកម្នាក់ទៀត ឈ្មោះ ស្រឿង សារ៉េត ភេទប្រុស អាយុ ៣៧ឆ្នាំ រស់ភូមិបន្ទាយឆ្មារត្បូង ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ បើកបររថយន្តម៉ាករថយន្តម៉ាក់ Starex ពណ៌ទឹកប្រាក់ សេរីឆ្នាំ២០០៨ ពាក់ស្លាកលេខ ភ្នំពេញ 2BB.9491 ត្រូវបានកម្លាំងនគរបាលស្រុកស្វាយចេក និងកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៩១១ ចាប់ឃាត់ខ្លួន នៅវេលាម៉ោង ០៨និង៣០នាទីយប់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១ នៅចំណុចចន្លោះភូមិដំណាក់កកោះ និងភូមិល្បើកស្វាយយ ក្នុងភូមិសាស្រ្តឃុំស្វាយចេក ស្រុកស្វាយចេក ពីបទដឹកជញ្ជូនមនុស្សឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់ចំនួន១១នាក់ ក្នុងនោះក្មេង០៣នាក់ ។

លោកនាយការិយាល័យ បានបញ្ជាក់ថា៖ តាមចម្លើយសារភាពរបស់ឈ្មោះ សេន រច្ចនា និងឈ្មោះ យាម រិត ពួកគេពិតជាបាននាំមនុស្សឆ្លងដែនទៅថៃប្រាកមែន(មនុស្ស០២នាក់នាំម្នាក់០១) ចូលទៅទឹកដីថៃ ដោយគេយកលុយចំនួន៤០០បាត ។ ចំណែកឈ្មោះ ស្រឿង សារ៉េត បានសារភាពថា ខ្លួនពិតជាបានដឹកមនុស្សពីឃុំបន្ទាយឆ្មារ ស្រុកថ្មពួកទៅឲ្យមេខ្យល់នៅភូមិល្បើកស្វាយ ឃុំស្វាយចេក ស្រុកស្វាយចេក ចំនួន១១នាក់ ក្នុងនោះក្មេង០៣នាក់ ដើម្បីឆ្លងទៅថៃប្រាកដមែន ដោយមនុស្សម្នាក់យកថ្លៃដឹកចំនួន៤០០បាត ។

ដោយផ្អែកលើចម្លើយសារភាព និងមានវត្ថុតាងជាក់ស្តែងជនសង្ស័យ ត្រូវបានបញ្ជូនខ្លួនទៅសាលាដំបូងខេត្តដើម្បីចាត់ការតាមនីតិវិធីច្បាប់។ ចំណែកមនុស្សដែលជនសង្ស័យនាំបំរុងឆ្លងដែននិងដឹកជញ្ជូន បានបញ្ជូនទៅមណ្ឌលចត្តាឡីស័ក ៕

## ជនសង្ស័យជាមេខ្យល់ ២ នាក់ប្តីប្រពន្ធនាំមនុស្សឆ្លងដែនខុសច្បាប់ចូលដីថៃ កំពុងត្រូវបានសមត្ថកិច្ចសាកសួរ

https://www.postkhmer.com/ រ៉ន ដារ៉ា | Publication date 05 May 2021 | 13:39 ICT

**បាត់ដំបង:** ជនសង្ស័យ ២ នាក់ប្តីប្រពន្ធ ក្នុងបទល្មើសនាំមនុស្សចំនួន ១០ នាក់ ឆ្លងដែនខុសច្បាប់ចូលប្រទេសថៃ កំពុងត្រូវបានសមត្ថកិច្ចនគរបាលស្រុកកំរៀងសាកសួរ និងកសាងសំណុំរឿង បញ្ជូនទៅតុលាការក្រោយឃាត់ខ្លួនបានពេលកំពុងនាំពលករឆ្លងដែននៅចំណុចស្ពានបី ភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង កាលពីថ្ងៃទី៤ ឧសភា។

លោក ស្រី វុទ្ធី អធិការស្តីទី នៃអធិការដ្ឋាននគរបាលស្រុកកំរៀង ប្រាប់ភ្នំពេញប៉ុស្តិ៍នៅថ្ងៃទី៥ ឧសភានេះថា មេខ្យល់ជាប្តីប្រពន្ធចំនួន ២នាក់ ដែលសកម្មក្នុងការនាំពលករឆ្លងដែនខុសច្បាប់ ត្រូវបានកម្លាំងវរសេនាតូចលេខ ៥៣៣ កងពលតូចថ្មើរជើងលេខ ៥៣ ឃាត់ខ្លួនបាន នៅព្រឹកថ្ងៃទី៤ ខែឧសភា ខណៈពួកគេកំពុងដឹកនាំពលករឆ្លងដែនទៅប្រទេសថៃ ចំនួន ១០នាក់។ ក្នុងនោះប្រុសចំនួន ៥ នាក់ ស្រីចំនួន ៤ នាក់ និងកុមារចំនួន ១ នាក់ ត្រង់ភូមិសាស្រ្ត ចំណុចស្ពានបី ភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង។ លោកថ្លែងថា៖«ពេលនេះ យើងបានឃុំខ្លួនជនសង្ស័យទាំង ២នាក់ប្តី ប្រពន្ធនៅ អធិការដ្ឋាននគរបាលស្រុកកំរៀង ដើម្បីបន្តការសាកសួរ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ។ ក្រោយបញ្ចប់ការសាកសួរ យើងនឹងបញ្ជូនជនសង្ស័យទាំង ២ នាក់ទៅតុលាការល្ងាចនេះ [ថ្ងៃទី៥ ឧសភា] ដើម្បីទុកឱ្យតុលាការសម្រេចតាមនីតិវិធី»។ បើតាមលោក អធិការស្តីទី ក្រៅពី ប្តីប្រពន្ធ ២នាក់នេះ ដែលកំពុងត្រូវបានឃុំខ្លួន ដើម្បីសួរចម្លើយនោះ រីឯពលករ ១០នាក់ទៀត ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ នៅមណ្ឌលចត្តាឡីស័កស្រុកកំរៀង។

លោក រ៉េន ឌិន មេបញ្ជាការរងកងអនុសេនាធំទី៣ វរសេនាតូច ៥៣៣ កងពលតូចថ្មើរជើងលេខ៥៣ បានរាយការណ៍ថា ដោយអនុវត្តតាមបទបញ្ជាមេបញ្ជាការ លោកបានដឹកនាំកម្លាំងល្បាត ២៤ម៉ោងលើ ២៤ម៉ោង ដោយប្តូរវេនគ្នា។ ការចុះល្បាតនេះ សហការជាមួយកម្លាំងប៉ូលិសការពារព្រំដែនគោក លេខ៨១៩ និងកម្លាំងផ្នែកសឹករងស្រុកកំរៀង។ ប្រតិបត្តិការរួមគ្នានេះ គឺដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ១៩ មិនឲ្យចូលទៅក្នុងសហគមន៍។ លោកថ្លែងថា តាមរយៈការអនុវត្តសកម្មភាពល្បាតត្រួតពិនិត្យនេះ នៅម៉ោង៧ព្រឹក ថ្ងៃទី៤ ខែឧសភា ស្របពេលលោកកំពុងដឹកនាំកម្លាំងដើរល្បាត ក៏ជួបមេខ្យល់ប្តីប្រពន្ធ ២នាក់ បម្រុងនាំពលករឆ្លងដែនចេញទៅប្រទេសថៃ លោកក៏ចាប់ខ្លួនតែម្តងរួចបញ្ជូនទៅឲ្យអធិការដ្ឋាននគរបាលស្រុក កំរៀង ចាត់ការតាមផ្លូវច្បាប់។ បើតាមលោក រ៉េន ឌិន មេខ្យល់ដែលត្រូវបានចាប់ខ្លួន ឈ្មោះ ភោគ ធឿន (ហៅនាង) ភេទស្រី អាយុ ៣៥ ឆ្នាំ ជាប្រពន្ធ របស់ឈ្មោះ សៅ ធី ភេទប្រុស អាយុ ៣០ឆ្នាំ រស់នៅ ភូមិ ភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង៕

## ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១

### អង្គការភ្លែនអន្តរជាតិកម្ពុជា និងដៃគូធ្វើវេទិកាកុមារ និងយុវជន ដើម្បីពិភាក្សាលើផលប៉ះពាល់ពីការធ្វើទេសន្តរប្រវេសន៍

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 06 May 2021 | 18:22 ICT

**ភ្នំពេញៈ** អង្គការភ្លែនអន្តរជាតិកម្ពុជា និងដៃគូក្នុងប្រទេសកម្ពុជា និងប្រទេសថៃ នៅថ្ងៃទី ៦ ខែឧសភានេះ បានធ្វើវេទិកាកុមារ និងយុវជនតាមអនឡាញ ស្តីពីផលប៉ះពាល់ពីការធ្វើទេសន្តរប្រវេសន៍ ដើម្បីពិភាក្សាគ្នាលើបញ្ហាចំណាកស្រុកក្រោមស្ថានភាពនៃការផ្ទុះឡើងនៃជំងឺកូវីដ ១៩ និងថ្លែងការណ៍រួមគ្នា ដើម្បីស្វែងរកមតិគាំទ្រពីអ្នកពាក់ព័ន្ធក្នុងបំណងឱ្យជួយគាំទ្រដល់ពួកគេ។

លោក យី គីមថាន នាយករងប្រចាំប្រទេសផ្នែកកម្មវិធីនៃអង្គការភ្លែនអន្តរជាតិកម្ពុជាថ្លែងនៅថ្ងៃនេះថា ការធ្វើវេទិកានាថ្ងៃនេះ គឺជាលើកទី២ ហើយបន្ទាប់ពីលើកទី១ បានធ្វើកាលពីខែមីនា ឆ្នាំ ២០២១ ដោយបានប្រមូលធាតុចូលពីក្រុមយុវជន និងកុមារដោយផ្ទាល់នៅថ្នាក់ក្រោមជាតិ។ លោកបានបន្តថា៖ «ការធ្វើវេទិកានេះ យើងមានគោលបំណងពង្រឹងចំណងមិត្តភាពរវាងកុមារកម្ពុជា និងកុមារ ដែលកំពុងធ្វើចំណាកស្រុករស់នៅក្នុងប្រទេសថៃ។ តាមរយៈវេទិកានេះកុមារនៃប្រទេសទាំង ២ បានឯកភាពគ្នាធ្វើសេចក្តីថ្លែងការណ៍រួមមួយស្តីអំពីបញ្ហាដែលកំពុងជួបប្រទះ និងស្វែងរកការគាំទ្រ ដើម្បីជួយដល់ពួកគាត់។ សេចក្តីថ្លែងការណ៍របស់កុមារនេះ នឹងធ្វើទៅរាជរដ្ឋាភិបាលនៃប្រទេសទាំង ២ (កម្ពុជា និងថៃ)»។

លោក គីមថាន បានឱ្យដឹងថា តាមរយៈវេទិកានេះ កុមារបានពិភាក្សាអំពីបញ្ហារបស់កុមារធ្វើចំណាកស្រុកទៅរស់នៅប្រទេសថៃដែលបានជួបប្រទះ។ ក្រៅពីនោះកុមារក៏អាចចែករំលែកអំពីបញ្ហាផ្សេងៗរបស់ពួកគេផងដែរ។ លោកថ្លែងថា៖ «យើងឃើញបញ្ហាជាច្រើនដែលកុមារបានជួបប្រទះទាក់ទងទៅនឹងកង្វះការអប់រំ កុមារមិនទទួលបានសេវាអប់រំបានពេញលេញទេ ហើយកុមារក៏ប្រឈមនឹងបញ្ហាសុខភាព និងមិនទទួលបានសេវាគាំពារសង្គមកិច្ច»។

លោក John McGown នាយកប្រចាំប្រទេសនៃអង្គការភ្លែនអន្តរជាតិថៃ បានចែករំលែកបទពិសោធជាមួយកុមារ និងយុវជនតាមរយៈការធ្លាប់បានរៀបចំវេទិកានៅប្រទេសថៃ ជាមួយដោយដៃគូក្នុងស្រុក គឺបណ្តាញការពារការងារ (LPN) កាលពីខែមីនា និងខែមេសា ឆ្នាំនេះថា ជាការផ្តល់ឱ្យកុមារដែលបានធ្វើទេសន្តរប្រវេសន៍មានសុវត្ថិភាព និងមានបរិយាកាសរីករាយ។ ក្នុងនោះគេបានចែករំលែកបទពិសោធជីវិតរបស់ពួកគេជាមួយមិត្តភក្តិ និង

ប្រមូលសំឡេងរបស់ពួកគេរួមគ្នា ដើម្បីសិទ្ធិរបស់កុមារ និងទទួលបានសេវាកម្មកិច្ចគាំពារសង្គមមូលដ្ឋានតាមរយៈបណ្តាញសង្គម។ លោកថ្លែងថា៖ «ដំណើរការដែលខ្ញុំបានឃើញនៅក្នុងប្រទេសថៃ គឺអស្ចារ្យណាស់ដោយមានការសម្របសម្រួលបានល្អ ហើយជាលទ្ធផលមិនត្រឹមតែមានប្រសិទ្ធភាពដល់អ្នកកាន់កាតព្វកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចងមិត្តភាពដែលនឹងបន្តទៅមុខបានល្អទៀតផង»។

លោកស្រី គ្វីននេត វ៉ង នាយិកាប្រចាំប្រទេសនៃអង្គការភ្លែនអន្តរជាតិកម្ពុជាថ្លែងថា វេទិកានេះផ្តោតសំខាន់លើការកសាងទំនាក់ទំនងរវាងកុមារ និងយុវជនដែលរងផលប៉ះពាល់ដោយការធ្វើទេសន្តរប្រវេសន៍ពីប្រទេសកម្ពុជាទៅប្រទេសថៃ។ លោកស្រីថ្លែងថា៖ «វេទិកានេះ នឹងរួមចំណែកដល់ការបង្កើនការយល់ដឹងអំពីចន្លោះខ្វះខាតនៃសេវាកម្មលើផ្នែកតម្រូវការយេនឌ័រ កិច្ចគាំពារសង្គមសម្រាប់កុមារ និងយុវជនដែលរួមគ្នាបង្កើតសេចក្តីថ្លែងការណ៍រួមដើម្បីស្វែងរកមតិគាំទ្រពីអ្នកពាក់ព័ន្ធនានាទាក់ទងទៅនឹងការលើកកម្ពស់សិទ្ធិកុមារលើបញ្ហាការធ្វើទេសន្តរប្រវេសន៍»។

តាមរយៈការសិក្សាគម្រោងមួយដែលគាំទ្រដោយអង្គការភ្លែនបានរកឃើញថា មានកុមារកម្ពុជា ចំនួន ១.៣២២ នាក់ កំពុងសិក្សានៅប្រទេសថៃ ក្នុងខេត្តខ្លងយ៉ៃ ជាប់ព្រំប្រទល់នឹងខេត្តកោះកុង។ ក្នុងចំណោមសិស្ស ១ ៣២២ នាក់ (មានចំនួន ៥០០នាក់ កំពុងសិក្សាថ្នាក់ទី៤ និងទី៩ នៃសាលារដ្ឋរបស់ប្រទេសថៃ)។ ក៏ប៉ុន្តែចំនួននេះមានការថយចុះនៅពេលដែលកុមារកម្ពុជាមានអាយុច្រើន ដោយសារត្រូវត្រឡប់មកកម្ពុជាវិញជាមួយឪពុកម្តាយក្រោយពីផុតសិទ្ធិធ្វើការក្នុងប្រទេសថៃ៕

## នគរបាលជំនាញការិយាល័យ ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បញ្ជូនជនសង្ស័យចំនួន០៣នាក់ ក្នុងនោះ០២នាក់ជាមេខ្យល់ និងម្នាក់ទៀតជាអ្នកដឹកជញ្ជូន

http://cambodiapolice.com/policekh/ 10:54 am 5 ឧសភា 2021

បន្ទាយមានជ័យ៖ ជនសង្ស័យចំនួន០៣នាក់ ក្នុងនោះ០២នាក់ ជាមេខ្យល់ត្រូវបានកម្លាំងនគរបាលស្រុកអូរជ្រៅ ចាប់ឃាត់ខ្លួនពីបទនាំមនុស្សឆ្លងដែនទៅថៃ ដោយខុសច្បាប់និងម្នាក់ទៀត ត្រូវបានកម្លាំងនគរបាលស្រុកស្វាយចេកចាប់ខ្លួនបទបទដឹកជញ្ជូនមនុស្សឆ្លងដែនទៅថៃ ដោយខុសច្បាប់ ត្រូវបានកម្លាំងនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បញ្ជូនខ្លួនទៅសាលាដំបូងខេត្តបន្ទាយមានជ័យ នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១ ដើម្បីចាត់ការតាមនិតិវិធីច្បាប់ ។

យោងតាមរបាយការណ៍របស់ លោកវរសេនីយ៍ឯក ឡាយ គឹមលួន នាយការិយាល័យនគរបាលប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានឲ្យដឹងថា ជនសង្ស័យទាំង០៣នាក់ ៖ ១ ឈ្មោះ សេន វច្ចនា ភេទប្រុស អាយុ៣១ឆ្នាំ នៅភូមិសិលាខ្មែរ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។ ២ ឈ្មោះយាម រិត ភេទប្រុស អាយុ៤៣ឆ្នាំ នៅភូមិទំនប់ដាច់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។ ជនសង្ស័យទាំង០២នាក់នេះត្រូវបានកម្លាំងនគរបាលស្រុកអូរជ្រៅ ចាប់ឃាត់ខ្លួននៅវេលាម៉ោង១០និង៣០នាទី កាលពីព្រឹកថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១ នៅចំណុចច្រករបៀងឃុំអូរបីជាន់ ស្រុកអូរជ្រៅពីបទនាំមនុស្សឆ្លងដែនដោយខុខច្បាប់ទៅប្រទេសថៃ ។

ចំណែកម្នាក់ទៀត ឈ្មោះ ស្រឿង សារ៉េត ភេទប្រុសអាយុ៣៧ឆ្នាំ រស់ភូមិបន្ទាយឆ្មារត្បូង ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ បើកបររថយន្តម៉ាករថយន្តម៉ាក់Starex ពណ៌ទឹកប្រាក់ សេរីឆ្នាំ២០០៨ពាក់ស្លាកលេខភ្នំពេញ2BB.9491 ត្រូវបានកម្លាំងនគរបាលស្រុកស្វាយចេកនិងកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៩១១ ចាប់ឃាត់ខ្លួន នៅវេលាម៉ោង០៨និង៣០នាទីយប់ថ្ងៃទី០៣ខែឧសភា ឆ្នាំ២០២១ នៅចំណុចចន្លោះភូមិដំណាក់កកោះនិងភូមិល្បើកស្វាយយ ក្នុងភូមិសាស្រ្តឃុំស្វាយចេក ស្រុកស្វាយចេក ពីបទដឹកជញ្ជូនមនុស្សឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់ចំនួន១១នាក់ ក្នុងនោះក្មេង០៣នាក់ ។

លោកនាយការិយាល័យ បានបញ្ជាក់ថា៖ តាមចម្លើយសារភាពរបស់ឈ្មោះ សេន រច្ចនា និងឈ្មោះ យាម រិត ពួកគេពិតជាបាននាំមនុស្សឆ្លងដែនទៅថៃប្រាកមែន(មនុស្ស០២នាក់នាំម្នាក់០១) ចូលទៅទឹកដីថៃ ដោយគេយកលុយចំនួន៤០០បាត ។ ចំណែកឈ្មោះ ស្រឿង សារ៉េត បានសារភាពថាខ្លួនពិតជាបានដឹកមនុស្សពីឃុំបន្ទាយឆ្មារ ស្រុកថ្មពួកទៅឲ្យមេខ្យល់នៅភូមិល្បើកស្វាយ ឃុំស្វាយចេក ស្រុកស្វាយចេក ចំនួន១១នាក់ ក្នុងនោះក្មេង០៣នាក់ ដើម្បីឆ្លងទៅថៃប្រាកដមែន ដោយមនុស្សម្នាក់យកថ្លៃដឹកចំនួន៤០០បាត ។

ដោយផ្អែកលើចម្លើយសារភាព និងមានវត្ថុតាងជាក់ស្តែងជនសង្ស័យ ត្រូវបានបញ្ជូនខ្លួនទៅសាលាដំបូងខេត្តដើម្បីចាត់ការតាមនិតិវិធីច្បាប់។ ចំណែកមនុស្សដែលជនសង្ស័យនាំបំរុងឆ្លងដែននិងដឹកជញ្ជូន បានបញ្ជូនទៅមណ្ឌលចត្តាលីស័ក ៕

## ប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៣២នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃព្រហស្បតិ៍ ទី០៦ ខែឧសភា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៣២នាក់ ស្រី ១៦នាក់ ក្នុងនោះ កុមារា ០០នាក់ កុមារី ៤នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១១នាក់ ស្រី ៧នាក់ កុមារា ០០នាក់ កុមារី ២នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៤នាក់ ស្រី ២នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ១៧នាក់ ស្រី ៧នាក់ កុមារា ០០នាក់ កុមារី ២នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ប្រុសចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៣២នាក់ ស្រី ១៦នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## កម្លាំងនគរបាលស្រុកស្វាយចេក សហការជាមួយកម្លាំងយោធាឃាត់រថយន្តចំនួន០២គ្រឿង ដឹកមនុស្សទៅថៃចំនួន១៧នាក់

http://cambodiapolice.com/policekh/ 1:36 pm 7 ឧសភា 2021

បន្ទាយមានជ័យ ៖ រថយន្តចំនួន០២គ្រឿង ដឹកមនុស្សចំនួន១៧នាក់ (កុមារ០២នាក់) ដើម្បីឆ្លងដែនចូលទៅប្រទេសថៃ ត្រូវបានកម្លាំងនគរបាលស្រុកស្វាយចេក សហការជាមួយកម្លាំងយោធាធ្វើការល្បាតស្ទាក់ឃាត់នៅ

វេលាម៉ោង០៣ និង២៥ នាទីរសៀលថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២១ ចំណុចចំការស្វាយច័ន្ទីនៅខាងជើងឈៀងខាងកើតភូមិតេជោភ្នំធ័ត្រ ស្ថិតនៅភូមិតេជោភ្នំធ័ត្រ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ។

លោកវរសេនីយ៍ឯក ជា ស្លួញ អធិការនគរបាលស្រុកស្វាយចេក បានឲ្យដឹងថា៖ រថយន្តទាំង០២គ្រឿងត្រូវបានកម្លាំង កម្លាំអធិការដ្ឋាននគរបាលស្រុកស្វាយចេកដែលឈរជើងនៅខ្លោងទ្វារភូមិតេជោភ្នំធ័ត្រ សហការជាមួយកម្លាំងយោធា បានធ្វើការស្ទាក់ឃាត់ នៅវេលាម៉ោង០៣និង២៥នាទីរសៀលថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២១ ត្រួតពិនិត្យរកឃើញថាមានដឹកមនុស្សបម្រុងឆ្លងដែនចូលទៅប្រទេសថៃ ចំនួន១៧នាក់ (កុមារី០២នាក់) ក្នុងនោះ ៖

១-ឈ្មោះ រ៉ម ហុង ភេទប្រុស អាយុ២៣ឆ្នាំ នៅភូមិណាំតៅ ឃុំណាំតៅ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ បើកបររថយន្តម៉ាក់កាមរី ពណ៌បៃតងចាស់ ពាក់ផ្លាកលេខ 2B-1130 ដឹកមនុស្ស០៥នាក់ ស្រី០១នាក់ ។

២-ឈ្មោះ គង់ ណោក ភេទប្រុស អាយុ៥០ឆ្នាំ នៅភូមិណាំតៅ ឃុំណាំតៅ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ បើកបររថយន្តម៉ាកសាំយ៉ុង ពណ៌សរ ពាក់ផ្លាកលេខ 2B-5662 ដឹកមនុស្សចំនួន១២នាក់ ស្រី១០នាក់ កុមារ០២នាក់ (ស្រី០១នាក់) ។ ក្នុងនោះ មកពីកំពង់ចាម០៦នាក់ បាត់ដំបង១០នាក់ បន្ទាយមានជ័យ០១នាក់ ។

លោកអធិការនគរបាលស្រុកស្វាយចេក បានបញ្ជាក់ថា៖ តាមចម្លើយសារភាពរបស់អ្នកបើកបររថយន្តទាំង០២នាក់ មនុស្សដែលគេដឹក ដើម្បីឆ្លងដែនទៅថៃទាំង១៧នាក់នោះគឺតាមមេខ្យល់បានកំណត់ ដោយគេយកតម្លៃតាមជិត តាមឆ្ងាយ មាន២៥០បាត ,៣០០បាត, ៤០០បាត ។ លោកវរសេនីយ៍ឯក ជា ស្លួញ បានបញ្ជាក់ទៀតថា អ្នកបើកបររថយន្តទាំង០២នាក់ កម្លាំងនគរបាលជំនាញ អធិការដ្ឋាននគរបាលស្រុកស្វាយចេក កំពុងរៀបចំសំណុំរឿងបញ្ជូនខ្លួទៅស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការបន្តតាមនីតិវិធីច្បាប់។ ដោយឡែកពលករទាំង១៧នាក់ កុមារ០២នាក់ បញ្ជូនទៅមណ្ឌលចត្តាឡីស័ក វិទ្យាល័យស្វាយចេក ៕

# ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១

## លោកស្រី ជូ ប៊ុនអេង៖ ការជួញដូរមនុស្សមានការកើនឡើងអំឡុងពេលកម្ពុជាជាប់ដៃប្រយុទ្ធនឹងជំងឺកូវីដ១៩

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 09/05/2021 - 07:54

រយៈពេល៣ខែក្នុងឆ្នាំ២០២១នេះ ការជួញដូរមនុស្សនៅកម្ពុជា មានការកើនឡើងខ្ពស់រហូតដល់ទៅ៨៥ករណី បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០ ដែលមានត្រឹម២៧ករណី។ ប៉ុន្តែយ៉ាងណាក៏ដោយ ចំនួន៨៥ករណី ត្រូវបានសមត្ថកិច្ចកម្ពុជាទប់ស្កាត់ និងបង្ក្រាបទាន់ពេល។ នេះជាតួលេខបណ្ដោះអាសន្ន ដែលត្រូវបានឲ្យដឹងដោយ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

ថ្លែងប្រាប់វិទ្យុបារាំងអន្តរជាតិ RFI នៅថ្ងៃអាទិត្យទី០៩ ឧសភានេះ លោកស្រី ជូ ប៊ុនអេង បានគូសបញ្ជាក់ថា មូលហេតុមួយដែលធ្វើឲ្យការជួញដូរមនុស្ស មានការកើនឡើងដល់ទៅ៨៥ករណីត្រឹមតែរយៈពេល៣ខែ គឺដោយសារតែមេខ្យល់យល់ថា រដ្ឋាភិបាលកំពុងជាប់ដៃប្រយុទ្ធនឹងជំងឺកូវីដ១៩ មិនបាននឹកគិតដល់ការចរាចរមនុស្សក្នុងទម្រង់នៃការជួញដូរមនុស្សនេះ។ តែផ្ទុយមកវិញ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានបង្ក្រាបករណីជួញដូរមនុស្សនេះបានចំនួន៨៥ករណី និងបានឃាត់ខ្លួនជនសង្ស័យ៨៣នាក់។ ក្នុងចំណោម៨៥ករណីនៃការជួញដូរមនុស្ស អ្នកជំនាញបានញែកជាពីរផ្នែក ពោលគឺ៥៤ករណីជាទម្រង់មួយនៃការជួញមនុស្សឆ្លងដែន និងរៀបឆ្លងដែន តែរូបភាពទាំងនេះត្រូវបានសមត្ថកិច្ចបង្ក្រាបទាន់ពេលវេលាដូចគ្នា។

ចំណែក៣១ករណី ក្នុងចំណោម៨៥ករណី គឺជាទម្រង់នៃការជួញដូរផ្លូវភេទនិងបានឃាត់ខ្លួនជនសង្ស័យចំនួន ៣១នាក់។ ជនរងគ្រោះទាំងនោះមានទាំងខ្មែរនិងបរទេស។ បើតាមលោកស្រី ជូ ប៊ុនអេង នៅក្នុងប្រតិបត្តិការជួយសង្គ្រោះមនុស្សពីក្រញាំនៃការជួញដូរធ្វើឡើងភ្លាមៗ ដោយមិនបណ្តោយឲ្យជនទាំងនោះធ្លាក់ខ្លួនជាជនរងគ្រោះមុននោះទេ។

នៅចំពោះមុខបញ្ហានេះ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ លោកស្រី ជូ ប៊ុនអេង ក៏បានស្នើឱ្យពលរដ្ឋពិចារណាមុនធ្វើចំណាកស្រុក កុំឱ្យចាញ់បោកជនជួញដូរមនុស្ស ព្រោះការធ្វើចំណាកស្រុកពេលនេះ គឺជាការផ្សងព្រេងដ៏ប្រថុយប្រថាន ដែលអាចទទួលបានត្រឹមតែការខាតបង់ប្រាក់កាសប៉ុណ្ណោះ។ ចំណែកគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក៏ដូចជាក្រសួងមហាផ្ទៃ នឹងបន្តវិធានការសំខាន់ៗ២ចំនុច ក្នុងនោះ ទី១ ជាការអនុវត្តច្បាប់ និងទី២គឺការស៊ើបរកជនជួញដូរមនុស្ស ដោយមានការស្នើឱ្យអាជ្ញាធរនៅជាប់ព្រំដែនអនុវត្តវិធានការតឹងរឹង បិទការធ្វើចរាចរណ៍តាមច្រករបៀងនានា និងតាមមធ្យោបាយអប់រំផ្សព្វផ្សាយផងដែរ ដែលការផ្សព្វផ្សាយនេះ ធ្វើឲ្យពលករចំណាកស្រុក១២ម៉ឺននាក់បានយល់និងត្រូវបានទប់ស្កាត់៕

## ពលករខ្មែរ២០នាក់ លួចឆ្លងពីថៃចូលខ្មែរ ត្រូវកម្លាំងចម្រុះឃាត់បញ្ជូនទៅធ្វើចត្តាឡីស័ក១៤ថ្ងៃ

https://www.kampucheathmey.com/ ថ្ងៃសៅរ៍ ៨ ឧសភា ២០២១ ដោយ Kang Tola

បន្ទាយមានជ័យ ៖ ពលករខ្មែរចំនួន២០នាក់ លួចឆ្លងដែនពីប្រទេសថៃចូលមកខ្មែរ តាមច្រករបៀងត្រូវកម្លាំងចំរុះឃាត់បានទាំងយប់បញ្ជូនទៅធ្វើចត្តាឡីស័ក១៤ថ្ងៃនៅយប់ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២១ នៅចំណុចគោលដៅទំនប់ដាច់ ភូមិសូរិយា ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

លោកវរសេនីយ៍ទោ យូ សុគន្ធភក្តី មេបញ្ជាការ វរសេនាតូចថ្មើរជើងលេខ៥១៣ បានប្រាប់ឲ្យដឹងថា ដោយអនុវត្ត តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍មេបញ្ជាការកងពលតូចថ្មើរជើងលេខ៥១ លោកបានដឹកនាំកម្លាំងសហការជាមួយកម្លាំងព្រំដែន៥០៣ និង ប៉ូលិស ៩១១ ចេញល្បាតនៅចំណុចគោលដៅទំនប់ដាច់បានប្រទះឃើញពលករខ្មែរចេញពីប្រទេសថៃមាន ប្រុស ស្រី២០នាក់បានឃាត់សួរនាំ។ កម្លាំងចំរុះបានប្រាប់អ្នកយកព័ត៌មានឲ្យដឹងបន្តទៀតថា ពលករខ្មែរទាំង២០នាក់នេះក្រោយពីសមត្ថកិច្ចសួរនាំពួកគាត់បានប្រាប់ឲ្យដឹងថា ពួកគាត់មកពីប្រទេសថៃក្រោយពីអាជ្ញាធរថៃធ្វើការរឹតបណ្តឹងនៅកន្លែងធ្វើការងារស្របពេលកូវីដ.១៩ កំពុងឆ្លងខ្លាំងផងទើបពួកខ្លួនវិលត្រឡប់មកស្រុកកំណើតវិញតាមច្រករបៀងសំណាងណាស់តម្រួតថៃមិនបានកាត់។ បន្ទាប់ពីធ្វើការសាកសួររួចកម្លាំងសមត្ថកិច្ចចម្រុះបានប្រគល់ពួកគាត់ជូនផ្នែកជំនាញបញ្ជូនទៅធ្វើចត្តាឡីស័ក នៅកន្លែងបានកំណត់ឲ្យគ្រប់១៤ថ្ងៃទើបអាចឲ្យវិលទៅផ្ទះវិញបាន៕ *ដោយ ៖ វ៉ាន់ ណាង*

## កម្ពុជាវិភាយសហការជាមួយភាគីអាមេរិក ក្នុងការលើកកម្ពស់លក្ខខណ្ឌការងារនិងលុបបំបាត់ការប្រើប្រាស់ពលកម្មកុមារ

https://www.kampucheathmey.com/ ថ្ងៃសុក្រ ៧ ឧសភា ២០២១ ដោយ Kang Tola

ភ្នំពេញ ៖ លោក ហេង សួរ រដ្ឋលេខាធិការ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានលើកឡើងថា កម្ពុជាស្វាគមន៍ចំពោះកិច្ចសហការជាមួយតំណាងពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក (USTR) ក្នុងក្របខ័ណ្ឌនិយោគនិងពាណិជ្ជកម្មរវាងកម្ពុជា និងសហរដ្ឋអាមេរិក (TIFA)ក្នុងការចូលរួមលើកកម្ពស់លក្ខខណ្ឌការងារ និងលុបបំបាត់ការប្រើប្រាស់ពលកម្មកុមារនៅក្នុងប្រទេសកម្ពុជា។ ការលើកឡើងរបស់លោកហេង សួរ នេះបានធ្វើឡើងនៅក្នុងឱកាសដែលលោកបានដឹកនាំប្រតិភូចូលរួមកិច្ចប្រជុំជាមួយតំណាងពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក (USTR) ដោយមានការចូលរួមពីតំណាងក្រសួងពាណិជ្ជកម្ម តាមរយៈប្រព័ន្ធវីដេអូ (Virtual Meeting) ។

នៅក្នុងកិច្ចប្រជុំនេះ លោកបានលើកឡើងអំពីគោលបំណងនៃការធ្វើវិសោធនកម្មច្បាប់ស្តីពីសហជីព ក្នុងការចូលរួមលើកកម្ពស់ការអនុវត្តសេរីភាពអង្គការវិជ្ជាជីវៈ តាមរយៈការផ្តល់លក្ខខណ្ឌកាន់តែងាយស្រួលដល់បងប្អូនកម្មករនិយោជិតក្នុងការបង្កើតនិងចុះបញ្ជីសហជីព និងការចូលរួមសកម្មភាពសហជីពដើម្បីដោះស្រាយវិវាទការងាររួមៗ លោករដ្ឋលេខាធិការបានបញ្ជាក់ជូនដំណាង USTR និងបានលើកទឹកចិត្តឱ្យភាគីពាក់ព័ន្ធដាក់ពាក្យបណ្តឹងមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីដែលមានការរើសអើងសហជីព ដើម្បីក្រសួងអាចដោះស្រាយបានទាន់ពេលវេលា។ លោកក៏បានបង្ហាញអំពីវឌ្ឍនភាពការងារនានា ពាក់ព័ន្ធនឹងការចុះបញ្ជីអង្គការវិជ្ជាជីវៈ ការដោះស្រាយវិវាទការងារដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល ការចុះធ្វើអធិការកិច្ចការងារក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ និងកិច្ចសហការជាមួយគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (ILO-BFC) ក្នុងការពង្រីកវិសាលភាពអនុវត្តចំពោះរោងចក្រផ្នែកផលិតផលិតផលធ្វើដំណើរនិងកាបូបផងដែរ។

លោកហេង សួរ បានបន្តទៀតថា ការលុបបំបាត់ពលកម្មកុមារនៅតែជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលក្នុងនោះ ក្រសួងការងារបាននឹងកំពុងបន្តចុះធ្វើអធិការកិច្ច និងយុទ្ធនាការផ្សព្វផ្សាយដើម្បីទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ លើកកម្ពស់ការយល់ដឹងអំពីហានិភ័យនៃគ្រោះថ្នាក់នៅពេលកុមារចូលក្នុងកន្លែងការងារ និងពង្រឹងការអនុវត្តច្បាប់ឱ្យកាន់តែមានប្រសិទ្ធភាព។ លោកហេង សួរ ក្នុងនាមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះកិច្ចសហការជាមួយតំណាងពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក (USTR) ក្នុងក្របខ័ណ្ឌវិនិយោគនិងពាណិជ្ជកម្មរវាងកម្ពុជា និងសហរដ្ឋអាមេរិក (TIFA) ដោយសហការជាមួយដៃគូពាក់ព័ន្ធក្នុងការចូលរួមលើកកម្ពស់លក្ខខណ្ឌការងារ និងលុបបំបាត់ការប្រើប្រាស់ពលកម្មកុមារនៅក្នុងព្រះរាជាណាចក្រកម្ពុជា៕ *ដោយ ៖ សំអឿន*

## ប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៣៣នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃសៅរ៍ ទី០៨ ខែឧសភា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៣៣នាក់ ស្រី ១៥នាក់ ក្នុងនោះកុមារា ២នាក់ កុមារី ០០នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ២នាក់ ស្រី ១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៥នាក់ ស្រី ២នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៧នាក់ ស្រី ០០នាក់ កុមារា ២នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ១៣នាក់ ស្រី ៩នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ៦នាក់ ស្រីចំនួន ៣នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ប្រុសចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៣៣នាក់ ស្រី ១៥នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៤៦នាក់

https://www.information.gov.kh ចេញផ្សាយ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃអាទិត្យ ទី០៩ ខែឧសភា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៤៦នាក់ ស្រី ២១នាក់ ក្នុងនោះកុមារ ៤នាក់ កុមារី ៣នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ៨នាក់ ស្រី ៣នាក់ កុមារ ១នាក់ កុមារី ១នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១៧នាក់ ស្រី ១០នាក់ កុមារ ៣នាក់ កុមារី ២នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ១៥នាក់ ស្រី ៦នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ៦នាក់ ស្រីចំនួន ២នាក់ កុមារចំនួន ០០នាក់ កុមារីចំនួន ០០នាក់.

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ប្រុសចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៤៦នាក់ ស្រី ២១នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## រដ្ឋបាលខេត្តបាត់ដំបង ៖ ពលករខ្មែរចំនួនពីរនាក់ មកពីថៃមានវិជ្ជមានកូវីដ១៩

https://cen-news.com/ ByPen Srey Neat May 8, 2021

ភ្នំពេញ ៖ រដ្ឋបាលខេត្តបាត់ដំបងបានឲ្យដឹងថា យោងតាមលទ្ធផលវិភាគវត្ថុសំណាករកវីរុសកូវីដ-១៩ នៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២១ បានរកឃើញអ្នកជំងឺកូវីដ-១៩ ដែលជាពលករវិលត្រឡប់មកពីទីក្រុងបាងកក ប្រទេសថៃ ចំនួន ២នាក់ ដែលមានរាយនាមដូចខាងក្រោម ៖

១-ឈ្មោះ គុ វីរៈ ភេទប្រុស អាយុ ៣៣ឆ្នាំ អាសយដ្ឋានរស់នៅភូមិអូរសំព័រ ឃុំអូរសំព័រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ មុខរបរ លក់ផ្កា នៅប្រទេសថៃ។

២-ឈ្មោះ សឺន សុង ភេទប្រុស អាយុ ៣០ឆ្នាំ អាសយដ្ឋានរស់នៅភូមិអូរសំព័រ ឃុំអូរសំព័រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ មុខរបរ លក់ផ្កា នៅប្រទេសថៃ។

រដ្ឋបាលខេត្តបាត់ដំបងបានបញ្ជាក់ថា អ្នកជំងឺកូវីដ-១៩ខាងលើ បានវិលត្រឡប់ពីទីក្រុងបាងកក ប្រទេសថៃ តាមច្រកទ្វារតំបន់ព្រំដែន អូរអន្លក់ ស្រុកកំរៀង ហើយត្រូវបញ្ជូនមកធ្វើចត្តាឡីស័កកម្រិត១ នៅក្នុងវិទ្យាល័យពេជ្រចិន្តា ស្រុកភ្នំព្រឹក និងបានយកសំណាកទៅវិភាគទទួលបានលទ្ធផលនៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២១ ឃើញថា៖ មានជំងឺ កូវីដ-១៩ ហើយបានបញ្ជូនទៅសំរាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តបាត់ដំបង ។ រដ្ឋបាលខេត្តបាត់ដំបង បានបញ្ជាក់ទៀតថា ចាប់ផ្តើមពីមានការ ផ្ទុកជំងឺកូវីដ-១៩ ខេត្តបាត់ដំបងមានអ្នកជំងឺកូវីដ-១៩ ចំនួន ៤២នាក់ បានព្យាបាលជាសះស្បើយ ២៨នាក់ និងកំពុងសម្រាកព្យាបាល ១៤នាក់៕ រក្សាសិទ្ធិ: ចេស្តារ

# រដ្ឋបាលខេត្តបាត់ដំបង ជូនដំណឹងពីការរកឃើញករណីវិជ្ជមានកូវីដ-១៩ ចំនួន ០៦នាក់ ដែល៥នាក់ ជាពលករមកពីប្រទេសថៃ និង១នាក់ ជាជនបរទេស

https://www.information.gov.kh/ AKP ភ្នំពេញ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១

រដ្ឋបាលខេត្តបាត់ដំបង នាថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២១នេះ បានចេញសេចក្តីជូនដំណឹង ស្តីពីការរកឃើញករណីវិជ្ជមានកូវីដ-១៩ថ្មី ចំនួន ០៦នាក់ ដែល០៥នាក់ ជាពលករមកពីប្រទេសថៃ និង០១នាក់ ជាជនបរទេស ធ្វើដំណើរមកពីខេត្តបន្ទាយមានជ័យ៕ សូមអានខ្លឹមសារទាំងស្រុងដូចខាងក្រោម៖

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តបាត់ដំបង

លេខ : ..........

**សេចក្តីប្រកាសព័ត៌មាន**

**រដ្ឋបាលខេត្តបាត់ដំបង** សូមជម្រាបជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋ និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា ៖ យោងតាមលទ្ធផលវិភាគវត្ថុសំណាករកវីរុសកូវីដ-១៩ នៅថ្ងៃទី០៩ ខែ**ឧសភា** ឆ្នាំ**២០២១** បានរកឃើញអ្នកជំងឺកូវីដ-១៩ ចំនួន **៦នាក់ ក្នុងនោះ** ជាពលករវិលត្រឡប់មកពីប្រទេសថៃ ចំនួន **៥នាក់ និងជនជាតិបរទេសចំនួន ១នាក់ ដែលមានរាយនាមដូចខាងក្រោម ៖**

១-ឈ្មោះ: ** លៀត ឆាំ** ភេទប្រុស អាយុ **២៦ឆ្នាំ** មានអាសយដ្ឋានរស់នៅភូមិពោធិ១ ឃុំតាគ្រាម ស្រុក**ហោងឫស្សី ខេត្តបាត់ដំបង** មុខរបរ **ពលករនៅប្រទេសថៃ**

២-ឈ្មោះ: **រៀម ស្រីណុច** ភេទស្រី អាយុ **២៥ឆ្នាំ** មានអាសយដ្ឋានរស់នៅភូមិ**កំពង់ចម្លងលើ** ឃុំតាគ្រី ស្រុក**គំរៀង ខេត្តបាត់ដំបង** មុខរបរ **ពលករនៅប្រទេសថៃ**

៣-ឈ្មោះ: **ម៉ី សុវណ្ណា** ភេទស្រី អាយុ **២២ឆ្នាំ** ស្រី មានអាសយដ្ឋានរស់នៅភូមិ**កសិកម្ម** ឃុំតាពូង ស្រុក**ថ្មគោល ខេត្តបាត់ដំបង** មុខរបរ **ពលករនៅប្រទេសថៃ**

៤-ឈ្មោះ: **យូ បញ្ញា** ភេទប្រុស អាយុ **៣៨ឆ្នាំ** មានអាសយដ្ឋានរស់នៅភូមិ**គោកគ្លួច** ឃុំតាពូង ស្រុក**ថ្មគោល ខេត្តបាត់ដំបង** មុខរបរ **ពលករនៅប្រទេសថៃ**

៥-ឈ្មោះ: **វឿន វៀត** ភេទស្រី អាយុ **៣៥ឆ្នាំ** មានអាសយដ្ឋានរស់នៅភូមិ**គោកគ្លួច** ឃុំតាពូង ស្រុក**ថ្មគោល ខេត្តបាត់ដំបង** មុខរបរ **ពលករនៅប្រទេសថៃ**

៦-ឈ្មោះ: **THAPA RAM BAHADUR** ភេទប្រុស អាយុ **៦៧ឆ្នាំ** ជនជាតិ**នេប៉ាល់** ធ្វើដំណើរមកពីក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

អ្នកជំងឺកូវីដ-១៩ខាងលើ បានវិលត្រឡប់ពី**ប្រទេសថៃ** និងម្នាក់ទៀតជាជនបរទេស ធ្វើដំណើរពីក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងបានយកសំណាកទៅវិភាគទទួលបានលទ្ធផលនៅថ្ងៃទី០៩ ខែ**ឧសភា ឆ្នាំ២០២១**ឃើញថា៖ មានជំងឺកូវីដ-១៩ ហើយបានបញ្ជូនទៅសំរាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តបាត់ដំបង។ ចាប់ផ្តើមពីមានការឆ្លងរាលដាលជំងឺកូវីដ-១៩ ខេត្តបាត់ដំបងមានអ្នកជំងឺកូវីដ-១៩ ចំនួន **៤៨នាក់** បានព្យាបាលជាសះស្បើយ **២៩នាក់** និងកំពុងសម្រាកព្យាបាល **១៩នាក់** ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបងប្អូនប្រជាពលរដ្ឋ សាធារណជនមេត្តាជ្រាបជាព័ត៌មាន ។

ថ្ងៃអាទិត្យ **១៣រោច** ខែ**ពិសាខ** ឆ្នាំ**ឆ្លូវ** ត្រីស័ក ព.ស **២៥៦៥**

ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២១

**រដ្ឋបាលខេត្តបាត់ដំបង**

អាសយដ្ឋាន: ផ្លូវលេខ០១ (ទល់មុខស្ពានចាស់), ទូរស័ព្ទនិងទូរសារលេខ: ០៥៣ ៧៣៩ ៩៩៩ / ៧៣៩ ៩៩៩ គេហទំព័រ: www.battambang.gov.kh
Address : Road 01 (In front of old bridge), Telephone & Fax : 053 739 999 / 739 999 Website: www.battambang.gov.kh
Facebook Page រដ្ឋបាលខេត្តបាត់ដំបង : www.Facebook.com/រដ្ឋបាលខេត្តបាត់ដំបង

## ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១

### លោកស្រី ជូ ប៊ុនអេង៖ ការជួញដូរមនុស្សកើនឡើង ខណៈអាជ្ញាធរជាប់ដៃប្រយុទ្ធជំងឺកូវីដ-១៩

https://thmeythmey.com/ 10, May 2021 , 10:29 pm

ភ្នំពេញ៖ ៣ខែ ដើមឆ្នាំ២០២១ កម្ពុជាមានការជួញដូរមនុស្ស៨៥ករណី បើធៀបនឹងពេលដូចគ្នានៅឆ្នាំមុន គឺកើនឡើង៥៨ករណី ។ ករណីជួញដូរទាំងនេះ ត្រូវបានសមត្ថកិច្ចបង្ក្រាបទាន់ពេល ដោយឃាត់ខ្លួនអ្នកពាក់ព័ន្ធ ជាង១០០នាក់។ នេះបើតាមតួលេខបណ្ដោះអាសន្ន ដែលសារព័ត៌មានថ្មីៗទទួលបានពីលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

លោកស្រី ជូ ប៊ុនអេង អះអាងថា ការជួញដូរមនុស្សកើនឡើងនេះ ដោយសារមេខ្យល់គិតថា កម្លាំងអាជ្ញាធរជាប់ដៃប្រយុទ្ធប្រឆាំងកូវីដ-១៩ ដែលជាឱកាសសម្រាប់ពួកគេជួញដូរមនុស្ស។ បើតាមលោកស្រី ប៊ុនអេង កត្តាពលរដ្ឋខ្វះការយល់ដឹង ក៏នាំឱ្យករណីជួញដូរកើនឡើងដែរ។ តែយ៉ាងណា រដ្ឋលេខាធិការក្រសួងមហាផ្ទៃរូបនេះ អះអាងថា ជ្បិតការជួញដូរកើនឡើងក្ដី ប៉ុន្តែកម្លាំងអាជ្ញាធរបង្ក្រាបបាន អ្នកជាប់ពាក់ព័ន្ធនឹងករណីនេះ ជាង១០០នាក់ យកមកអនុវត្តច្បាប់។ «គាត់(មេខ្យល់) គិតថារដ្ឋាភិបាលជាប់ដៃប្រយុទ្ធប្រឆាំងហ្នឹងកូវីដ-១៩ មិនយកចិត្តទុកដាក់រឿងហ្នឹងទេ។ កត្តាទីពីរ ដោយពលរដ្ឋយើងមួយចំនួនគិតថាជាឱកាសគេចវេះ ហើយក៏សូវមិនស្ដាប់ការអប់រំរបស់រដ្ឋាភិបាលក្នុងការត្រឡប់ទៅវិញក្រៅប្រទេសវិញ អំពីបញ្ហាប្រឈមការឆ្លងកូវីដ-១៩ រួមទាំងបញ្ហាជួរដូរមនុស្ស ឬការចាញ់បោកមេខ្យល់ជាដើម។ នេះជាមូលហេតុនៃការកើនឡើងនៃការជួញដូរមនុស្សដែលលោកស្រី ជូ ប៊ុនអេង បានបន្ថែមថា ក្នុងចំណោល៨៥ករណីនេះ ភាគច្រើនគឺការជួញដូរពលករឆ្លងដែនខុសច្បាប់។

លោកស្រី ម៉ៅ ម៉ាប់ មន្ត្រីសមាគមការពារសិទ្ធិមនុស្ស អាដហុក ទទួលបន្ទុកស្ត្រី និងកុមារ បាននិយាយថា ការជួញដូរមនុស្សកើនឡើងនៅអំឡុងពេលកូវីដ-១៩នេះ ដោយសារពលរដ្ឋត្រូវបង្ខំចិត្តចំណាកស្រុក ដោយខុសច្បាប់ ដើម្បីស្វែងរកការងារធ្វើ។ ទន្ទឹមនឹងនេះ ការយល់ដឹងរបស់ពលរដ្ឋនៅតែមានកម្រិតក្នុងឆ្លងដែន ដែលធ្វើមេខ្យល់ងាយស្រួលក្នុងបោកប្រាស់។ «រដ្ឋាភិបាល រួមទាំងអាជ្ញធរមូលដ្ឋានត្រូវអនុវត្តច្បាប់ឲ្យស្មើភាពគ្នាលើអ្នកល្មើសច្បាប់ជួញដូរមនុស្ស។ ហើយការរៀបចំធ្វើឯកសារសម្រាប់ឆ្លងដែន ឬចំណាកស្រុកដោយស្របច្បាប់ ត្រូវរៀបចំដោយមានភាពងាយស្រួល មិនរើសអើង សម្រាប់ពលរដ្ឋគ្រប់រូប ដើម្បីងាយស្រួលក្នុងការឆ្លងដែនស្របច្បាប់និងមានការការពារខ្លួន។ លើសពីនេះ ត្រូវពង្រឹងការងារក្នុងស្រុកផងដែរ ពិសេសវិស័យកសិកម្ម ដើម្បីជួយសម្រួលជីវភាពដល់ពលរដ្ឋ»។ នេះបើតាមដំណោះស្រាយរបស់មន្ត្រីការពារសិទ្ធិមនុស្ស អាដហុក។

កន្លងមក សម្ដេច ស ខេង បានចាត់វិធានយ៉ាងតឹងរឹងនៅតាមច្រកព្រំដែន ពិសេសនៅតាមច្រករបៀង ដើម្បីទប់ស្កាត់ការឆ្លងដែនខុសច្បាប់។ លើសពីនេះ ក៏ចាត់វិធានការមិនរើសមុខ ទាំងអាជ្ញាធរ មន្ត្រីរាជការ រួមទាំងមេខ្យល់ ដែលយកកម្រៃពីពលរដ្ឋជាថ្នូរនៃការនាំពលរដ្ឋឆ្លងដែនខុសច្បាប់។

ចាប់ពីថ្ងៃទី២០ធ្នូ ឆ្នាំ២០២០ ដល់ពាក់កណ្ដាលខែមេសា ឆ្នាំ២០២១នេះ ពលរដ្ឋត្រឡប់មកពីថៃវិញ មានជាង៣ម៉ឺននាក់។ ជាមួយគ្នានេះ អាជ្ញាធរថៃ បានបញ្ជូនពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់ មកឲ្យអាជ្ញាធរកម្ពុជាវិញ ជិត៣ពាន់នាក់ផងដែរ។ នេះរបាយការណ៍ដែលសារព័ត៌មានថ្មីៗទទួលបានពីលោក កែវ វណ្ណថន អគ្គនាយករងនិងជាអ្នកនាំពាក្យអគ្គនាយកដ្ឋានអន្តោប្រវេសន៍៕

## ពលករខ្មែរចំនួន៤នាក់មកពីប្រទេសថៃ ត្រូវបានបញ្ជូនមកដល់ស្រុកកំណើតនៅស្រុកបុរីអូរស្វាយសែនជ័យខេត្តស្ទឹងត្រែង ហើយបន្តធ្វើចត្តាឡីស័ក

https://www.information.gov.kh/ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ វិទ្យុជាតិកម្ពុជា៖ គឹមហឿនស្ទឹងត្រែង

ស្ទឹងត្រែង៖ ក្រុមការងារស្រាវជ្រាវ និងតាមដានបុគ្គលសង្ស័យ បានទទួលយកបពលករមកពីប្រទេសថៃ ចំនួន៤នាក់ ដែលមានទីលំនៅ នៅភូមិកណ្ដាល ឃុំព្រះរំកិល ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង មកធ្វើចត្តាឡីស័កនៅមណ្ឌលកម្រិត១នាស្រុកកំណើតវិញ។

ក្នុងសកម្មភាពនាំបងប្អូនកម្មករ៤នាក់ មកធ្វើចត្តាឡីស័កកាលពីថ្ងៃទី០៩ ឧសភាកន្លងមកនេះ លោកវេជ្ជបណ្ឌិត ទន.រុទ្ធិ អនុប្រធាន មន្ទីរសុខាភិបាលខេត្ត និងជាប្រធានក្រុមការងារស្រាវជ្រាវ និងតាមដានបុគ្គលសង្ស័យ បានបញ្ជាក់ថា៖ នេះជាការអនុវត្តវិធានការ សុខាភិបាលយ៉ាងម៉ឺងម៉ាត់ ព្រោះបងប្អូនកម្មករយើងមកពីធ្វើការងារនៅប្រទេសថៃ ត្រូវតែទទួលធ្វើចត្តាឡីស័ក១៤ថ្ងៃ ដើម្បីតាមដាន សុខភាពខ្លួនឯង។ លោកវេជ្ជបណ្ឌិត បន្តថា៖ប្រជាពលរដ្ឋទាំង៤នាក់នោះរួមមាន៖ ទី ១ឈ្មោះ- ឡឹត លីណា ភេទប្រុស អាយុ ២៨ -ទី ២ ឈ្មោះ ខុម ចន្ទា ភេទស្រី អាយុ ២៧-ទី៣ឈ្មោះ រុន ផើង ភេទប្រុស អាយុ ២៥-និងទី ៤ រិន វត្ថែភេទ ស្រី អាយុ ២៥ អ្នកទាំងបួនមានទីលំនៅ នៅភូមិ ឃុំព្រះរំកិល ស្រុកបុរីអូរស្វាយសែនជ័យ ត្រូវបានរថយន្តកងកម្លាំងយុទ្ធពលខេមរភូមិប្រចាំនៅច្រកព្រំដែន ជូនមកដល់មូលដ្ឋានតែម្ដង។

លោក លី មីណា អភិបាលស្រុកបុរីអូស្វាយសែនជ័យ បានបញ្ជាក់ថា ប្រជាពលរដ្ឋទាំង៤នាក់នោះពិតជាមានទីលំនៅនៅភូមិកណ្ដាល ឃុំព្រះរំកិល ស្រុកបុរីអូរស្វាយ ខេត្តស្ទឹងត្រែងពិតប្រាកដមែន។ លោកបន្តថា៖ពួកគាត់ទាំង៤នាក់បានទៅធ្វើការចិញ្ចឹមមាន់នៅខេត្តប៉ាក់ជីនបុរី ប្រទេសថៃបានជាងពីរឆ្នាំ ទើបវិលត្រឡប់មកវិញ នៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២១ តាមច្រកអន្តរជាតិអូរបើជាន់ខេត្តបន្ទាយមានជ័យ ក៏ត្រូវបានកម្លាំងយោធាប្រចាំការនៅទីនោះ ជួយ បញ្ជូនមកគ្រូពេទ្យខេត្តស្ទឹងត្រែងដាក់ធ្វើចត្តាឡីស័កនៅប៉ុស្តិ៍ច្រកទ្វារអន្តរជាតិកម្រិតមួយ ៕

## យោធាតំបន់ប្រតិបត្តិរងបន្ទាយមានជ័យឃាត់ខ្លួនមេខ្យល់នាំពលករឆ្លងដែនខុសច្បាប់ចំនួន ២នាក់

http://nokorwatnews.com/ 10/05/2021

ខេត្តបន្ទាយមានជ័យ៖ មេខ្យល់ ២នាក់ ដែលធ្វើសកម្មភាពក្នុងការនាំពលករឆ្លងដែនខុសច្បាប់ ត្រូវបានកម្លាំង តំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យឃាត់ខ្លួនបាននៅ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១នេះ គ្រាដែលពួកគេកំពុងដឹកនាំពលករឆ្លងដែនទៅប្រទេសថៃ ចំនួន ២៥នាក់ ក្នុងនោះស្រី១៧នាក់ ក្មេង ២នាក់ ត្រង់ភូមិសាស្ត្រ អូរព្រំដែន ឃុំបឹងបេង ស្រុកម៉ាឡៃ ។

ក្រោមបញ្ជាផ្ទាល់របស់លោក ឧត្តមសេនីយ៍ ត្រី ជឹម ប៊ុនអាន មេបញ្ជាការ ចាត់តាំង លោក វរសេនីយ៍ឯក រិទ្ធ រ៉ែ មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ដឹកនាំកម្លាំងល្បាតជាប់ជាប្រចាំ ដោយអនុវត្តតាមបទបញ្ជា មេបញ្ជាការ លោកបានដឹកនាំកម្លាំងល្បាត២៤ម៉ោងលើ២៤ម៉ោង ដោយប្តូរវេនគ្នា សហការជាមួយកម្លាំងប៉ូលីសការពារព្រំដែនគោក និងកម្លាំងផ្នែកសឹករងម៉ាឡៃ ផ្នែកសឹករងប៉ោយប៉ែតរួមទាំងកងរាជអាវុធហត្ថស្រុក ដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ មិនឲ្យចូលទៅក្នុងសហគមន៍។ ជាក់ស្តែង វេលាម៉ោង ១៖៣០នាទី រហូតដល់ ម៉ោង ៣៖០០នាទី ទៀបភ្លឺ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ ខណៈលោកកំពុងដឹកនាំកម្លាំងដើរល្បាតបានជួបមេខ្យល់ ២នាក់ បម្រុងនាំពលករឆ្លងដែនចេញទៅ

ប្រទេសថៃ ហើយមេខ្យល់បានរត់ទៅសំងំក្នុងផ្ទះស្ថិតក្នុងឃុំម៉ាឡៃ លុះដល់វេលាម៉ោង ៧៖០០នាទីថ្ងៃដដែល ត្រូវបានកម្លាំងរាជអាវុធហត្ថធ្វើការឃាត់ខ្លួនបា ន ។

សូមបញ្ជាក់ថា មេខ្យល់ដែលត្រូវបានចាប់ខ្លួន ១ឈ្មោះ.ដឹប នុន ភេទប្រុស អាយុ៥២ឆ្នាំ រស់នៅភូមិចំបក់ ឃុំបឹងបេង ស្រុកម៉ាឡៃ និងទី២.ឈ្មោះ ម៉ៃ សែហុន ប្រុស ២១ឆ្នាំ រស់នៅ ភូមិភ្នំរូង ឃុំបឹងបេង ស្រុកម៉ាឡៃ ពួកគេកំពុងត្រូវបានឃុំខ្លួន ដើម្បីសួរចម្លើយនៅ ស្នាក់ការកងរាជអាវុធហត្ថស្រុកម៉ាឡៃ ចំណែកឯពលករទាំង ២៥នាក់ ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័កចំនួន១៤ថ្ងៃ នៅមណ្ឌលចត្តាឡីស័កស្រុកម៉ាឡៃ ៕

## ប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៤១នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃចន្ទ ទី១០ ខែឧសភា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៤១នាក់ ស្រី ១៨នាក់ ក្នុងនោះកុមារា ១នាក់ កុមារី ៣នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ៨នាក់ ស្រី ៣នាក់ កុមារា ១នាក់ កុមារី ១នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៤នាក់ ស្រី ២នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ១៧នាក់ ស្រី ៩នាក់ កុមារា ១នាក់ កុមារី ៣នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ២០នាក់ ស្រី ៧នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០៩នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ប្រុសចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៤១នាក់ ស្រី ១៨នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអស់ហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ឃាត់ខ្លួនបុរសមេខ្យល់ ២ នាក់ ខណៈកំពុងនាំពលករ ២៥ នាក់ បម្រុងឆ្លងព្រំដែនចូលទៅប្រទេសថៃ

https://www.postkhmer.com/ គឹម សារុំ | Publication date 10 May 2021 | 18:34 ICT

**បន្ទាយមានជ័យ៖** សមត្ថកិច្ចកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យនៅថ្ងៃទី ១០ ឧសភានេះ បានឃាត់ខ្លួនបុរសជាមេខ្យល់ ២ នាក់ និងពលករ ២៥ នាក់ទៀត នៅក្នុងឃុំ-ស្រុកម៉ាឡៃ ក្នុងនោះមានទាំងក្មេង ២ នាក់ផងខណៈពួកគេបម្រុងឆ្លងដែនចូលទៅប្រទេសថៃ។

លោកវរសេនីយ៍ទោ ព្រហ្ម ថេង ប្រធានមន្ទីរស្រាវជ្រាវ និងបង្ក្រាបបទល្មើសនៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យបានប្រាប់ ភ្នំពេញ ប៉ុស្តិ៍ នៅរសៀលថ្ងៃទី ១០ ឧសភានេះថា ផ្អែកតាមរបាយការណ៍ គឺ

កម្លាំងកងរាជអាវុធហត្ថដែលប្រចាំការនៅគោលដៅស្រុកម៉ាឡៃ បានឃាត់ខ្លួនបុរសមេខ្យល់បានចំនួន ២ នាក់ ដែលបម្រុងនាំពលករចេញទៅថៃ។ ក្នុងនោះម្នាក់ឈ្មោះ ជឹប នុន អាយុ ៥២ ឆ្នាំ រស់នៅភូមិចំបក់ ឃុំបឹងបេង ស្រុកម៉ាឡៃ និងឈ្មោះ ម៉ៃ សែហុន អាយុ ២១ ឆ្នាំ រស់នៅភូមិត្នោរ៉ូង ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ ចំណែកចំនួនពលករប៉ុន្មាននោះគឺលោកមិនទាន់ទទួលព័ត៌មានច្បាស់ការណ៍នៅឡើយទេ។ លោកបានប្រាប់ថា៖ « ករណីនេះ ខ្ញុំទើបតែទទួលបានរបាយការណ៍ គឺឃាត់ខ្លួនមេខ្យល់បាន ២ នាក់។ ចំពោះថា មានពលករប៉ុន្មានខ្ញុំមិនច្បាស់ទេ ដូច្នេះខ្ញុំមិនហ៊ាននិយាយព្រោះមិនទាន់ច្បាស់»។ លោកបញ្ជាក់ថា ទាំងមេខ្យល់ទាំងពលករកំពុងត្រូវសមត្ថកិច្ចសាកសួរនៅស្រុកម៉ាឡៃនៅឡើយ ដោយមិនទាន់បញ្ជូនមកបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តនោះទេ។ លោកបានបន្ថែមថា៖ «យើងនិយាយទៅមិនកើត ព្រោះអីមិនទាន់បញ្ជូនដល់ខេត្ត។ ការងារហ្នឹងការងារសហការជាមួយយោធាខ្ញុំមិនទាន់ថា យ៉ាងម៉េចកើត»។

ទោះជាយ៉ាងណា បើតាមមន្ត្រីកងរាជអាវុធហត្ថស្រុកម៉ាឡៃមួយរូបសុំមិនបញ្ចេញឈ្មោះប្រាប់នៅរសៀលថ្ងៃទី ១០ ឧសភានេះថា ការបង្ក្រាបមេខ្យល់ និងរំដោះបានពលករនេះ គឺធ្វើឡើងនៅម៉ោងជាង ៣ ទៀបភ្លឺ ឈានចូលថ្ងៃទី ១០ ឧសភា ខណៈកម្លាំងយោធាសឹករងខេត្តបន្ទាយមានជ័យដើរល្បាតនៅចំណុចអូរ ១ កន្លែង ស្ថិតក្នុងភូមិអូរព្រំដែន ឃុំ-ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ មន្ត្រីរូបនេះបន្តថា មេខ្យល់ទាំង ២ នាក់នោះបានឱ្យពលករជិះរថយន្តមកចាំនៅចំណុចគោលដៅ ដែលត្រូវឆ្លងទៅប្រទេសថៃនោះមុន។ រីឯពួកគេ (មេខ្យល់) ក៏ដេកនៅកន្លែងផ្ទះសំណាក់ក្នុងឃុំម៉ាឡៃ ដើម្បីត្រៀមចេញដំណើរនៅពេលយប់ តែដោយសមត្ថកិច្ចមានការដើរល្បាតក៏ប្រទះឃើញពួកគេកំពុងដើរហើយក៏ឃាត់ខ្លួនតែម្តង។ លោកបានឱ្យដឹងថា ក្រៅពីបុរស ២ នាក់នោះ គឺមានពលករសរុបមាន ២៥ នាក់ផងដែរ ក្នុងនោះមាន (មនុស្សពេញវ័យស្រី ១៧ នាក់ និងប្រុស ៦ នាក់)។ រីឯ ២ នាក់ទៀតជាកូនក្មេងតូចដែលត្រូវជាកូនរបស់ពលករទាំងនោះ។ មន្ត្រីរូបនោះបានបញ្ជាក់ថា៖ «ពលករទាំង ២៣ នាក់ និងក្មេង ២ នាក់ត្រូវសមត្ថកិច្ចបញ្ជូនទៅមណ្ឌលចត្តាឡីស័កនៅស្រុកម៉ាឡៃ។ ចំណែកមេខ្យល់នៅមិនទាន់បានបញ្ជូនទៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តនៅឡើយទេ»៕

## សមត្ថកិច្ចថៃចាប់ពលករខ្មែរ៦នាក់ ជនជាតិឥណ្ឌូនេស៊ីម្នាក់និងភរិយាជនជាតិថៃម្នាក់លួចឆ្លងដែនខុសច្បាប់

http://nokorwatnews.com/ 10/05/2021

ក្រុងប៉ោយប៉ែត៖ កម្លាំងទាហាន និងនគបាលស្រុកតាព្រះយ៉ា (ថៃ) បានចាប់ឃុំខ្លួនពលករខ្មែរ៦នាក់ ខណៈលួចឆ្លងដែនចូលប្រទេសថៃ ក្នុងទឹកដីស្រុកគោកឃ្យូង។ ដោយឡែកជនជាតិឥណ្ឌូនេស៊ី ព្រមទាំងភរិយាជាជនជាតិថៃ២នាក់ ដែលធ្វើការនៅកាស៊ីណូអនឡាញប៉ោយប៉ែត លួចឆ្លងដែនចូលប្រទេសថៃ ក្នុងទឹកដីឃុំប៉ារ៉ៃ ស្រុកអារញ្ញ ខេត្តស្រះកែវ ក៏ត្រូវសមត្ថកិច្ចថៃចាប់ឃាត់ខ្លួនដែរ។ ប្រតិបត្តិការនេះធ្វើឡើងបន្ទាប់ពីមន្ត្រីសុខាភិបាលដែលបង្កើតក្រុមការងារអាសន្ន សំដៅលើជនជាតិខ្មែរនៅផ្សាររោងគ្លឿ ដើម្បីទប់ស្កាត់កូវីដ-១៩។ នេះបើយោងតាមការចុះផ្សាយតាមគេហទំព័រក្នុងស្រុករបស់ថៃ( สระแก้ว-77 ข่าวเด็ด )។

អ្នកសារព័ត៌មានថៃកាលពីថ្ងៃទី៩ ឧសភា ២០២១ បានរាយការណ៍ថា ក្រោយពីក្រសួងមហាផ្ទៃថៃ បញ្ជូនលិខិតប្រញាប់បំផុត កាលពីថ្ងៃទី៧ ឧសភា ២០២១ ដល់អភិបាលខេត្តគ្រប់ខេត្ត បញ្ជាឲ្យខេត្តជាប់ព្រំដែន សហការជាមួយស្ថាប័នពាក់ពន្ធ័ ដើម្បីគ្រប់គ្រងការលួចឆ្លងដែនចូលប្រទេស និងការដឹកជញ្ជូនពលករបរទេសចូលថៃខុសច្បាប់។ ជាមួយនេះក៏ឲ្យបង្កើតប៉ុស្ត៍ត្រួតពិនិត្យ តាមបទបញ្ជារបស់លោកប្រាយុទ្ធ ចាន់អូចារ នាយករដ្ឋមន្ត្រី ក្នុងការគ្រប់គ្រង ការពារការរាតត្បាតជំងឺកូវីដ-១៩ ពីប្រទេសជិតខាង ផងដែរជាពិសេសការប្រតិបត្តិក្នុងតំបន់ព្រំដែន និងផ្ទៃក្នុងប្រទេស តាមទីប្រជុំជន។

ដោយឡែកខេត្តស្រះកែវ បាននាំទិន្នន័យរបស់បណ្តាញលួចឆ្លងដែនចូលប្រទេសថៃរបស់ពលករខ្មែរ នៅបរិវេណព្រំដែនកម្ពុជា-ថៃ មកបង្ហោះតាមបណ្តាញសង្គម ដោយបញ្ជាក់ថា ប្រជាជននៅមូលដ្ឋានមិនហ៊ានផ្តល់ទិន្នន័យដល់មន្ត្រីរដ្ឋបាល ដោយសារសមត្ថកិច្ចពាក់ពន្ធ័ នឹងមានចំណែកផងដែរ។ ជាមួយនេះក៏បានអំពាវនាវឲ្យអាជ្ញាធរដែនដី ផ្នែកសន្តិសុខ និងសមត្ថកិច្ចទទួលខុសត្រូវក្នុងមូលដ្ឋានអនុវត្ត ដោយនាំរូបភាពឃ្លីបវីដេអូខណៈក្រុមលួចនាំពលករបរទេសនៅភូមិណាង យ៉ាកែវ ស្រុកគោគឃ្យូង នាំយករថយន្តធុនតូចចំនួនរាប់គ្រឿង បើកចូលទៅទទួលពលករខ្មែរ នៅបរិវេណក្រោយភូមិណាង យ៉ាកែវ ព្រមទាំងចង់ឲ្យខាងផ្នែកសន្តិសុខ អាជ្ញាធរដែនដី ចុះទៅមើលទទួលខុសត្រូវ បើសិនអ្នកភូមិមានជំងឺកូវីដ១៩មករាត្បាតក្នុងភូមិ តើអ្នកណាទទួលខុសត្រូវ?

ចុងក្រោយ នៅថ្ងៃទី៩ ឧសភា សមត្ថកិច្ចទាហានឈុតខ្មៅ អង្គភាពចំពោះកិច្ចអារញ្ញ កងកម្លាំងបូផាបានចាប់ឃុំខ្លួនមនុស្សលួចឆ្លងដែនពីប្រទេសជិតខាង ចូលមកប្រទេសថៃ បានថែម២នាក់ទៀត ក្រោយពីត្រួតពិនិត្យរកឃើញបុរសជនជាតិឥណ្ឌូនេស៊ីម្នាក់នឹងភរិយាជនជាតិថៃម្នាក់ ដែលធ្វើការនៅកាស៊ីណូអនឡាញ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ បានលួចឆ្លងចូលប្រទេសថៃថាមច្រករបៀង ក្នុងឃុំប៉ារ៉ៃ ស្រុកអារញ្ញ ខេត្តស្រះកែវ ត្រូវបានឃាត់ខ្លួនដែរ។ សមត្ថកិច្ចថៃអះអាងថា ចំពោះពលករខ្មែរអាជ្ញាធរថៃកំពុងតែសាកសួរ និងធ្វើកំណត់ហេតុ ដើម្បីអនុវត្តតាមច្បាប់៕

## ពលករខ្មែរខុសច្បាប់នឹងប្រឈមបញ្ហាច្បាប់ធ្ងន់ធ្ងរ ខណៈដែលតំបន់ព្រំដែនប្រទេសថៃរឹតបន្តឹង

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 10/05/2021 - 13:44

ពលករខ្មែរ ដែលព្យាយាមចូលទៅប្រទេសថៃ ដោយខុសច្បាប់នៅពេលនេះ នឹងប្រឈមនឹងវិធានការច្បាប់ធ្ងន់ធ្ងរពីអាជ្ញាធរមានសមត្ថកិច្ចថៃ។ ពលករខុសច្បាប់ទាំងអស់នឹងត្រូវជាប់ពន្ធនាគារចំនួន២ឆ្នាំ និងពិន័យជាប្រាក់ចំនួន៤ម៉ឺនបាត ឬស្មើនឹងជាង៥លានរៀល។ បើតាមនាយកការិយាល័យអន្តោប្រវេសន៍ ការអនុវត្តវិធានការតឹងរឹងនេះ គឺដោយសារប្រទេសថៃកំពុងផ្ទុះឡើងនូវជំងឺកូវីដ-១៩រលកទី៣។ វិធានការរឹតបន្តឹងច្រកព្រំដែនដើម្បីបញ្ចៀសកុំមានការលួចចូលពីសំណាក់ពលករខុសច្បាប់នេះ ធ្វើឡើងបន្ទាប់ពីប្រទេសថៃកំពុងផ្ទុះជំងឺកូវីដ១៩ រលកទី៣ និងកំពុងដាក់ការសង្ស័យថា មានការឆ្លងនូវវីរុសកូវីដ-១៩ មានប្រភពមកពីប្រទេសឥណ្ឌា។

ថ្លែងប្រាប់កាសែតក្នុងស្រុកបាងកកប៉ុស្ត៍ លោក Sompong Chingduang នាយកការិយាល័យអន្តោប្រវេសន៍ បានគូសបញ្ជាក់ថា ពលករខុសច្បាប់ណាដែលព្យាយាមចូលមកប្រទេសថៃនៅពេលនេះ នឹងត្រូវផ្តន្ទាទោសតាមច្បាប់ ស្តីពីពលករអន្តោប្រវេសន៍ និងការដាក់ប្រទេសក្នុងគ្រាអាសន្ន។ បើតាមមន្ត្រីជាន់ខ្ពស់រូបនេះ អាជ្ញាធរនៅតាមព្រំដែនត្រូវរឹតបន្តឹងកុំឲ្យពលករខុសច្បាប់ចូលក្នុងប្រទេស នៅខណៈពេលប្រទេសនេះកំពុងមានការឆ្លងខ្លាំង។

បើតាមរបាយការណ៍ពីស្ថានភាពជំងឺកូវីដ-១៩ រយៈពេលបួនខែនៃឆ្នាំ២០២១នេះ អាជ្ញាធរថៃចាប់ខ្លួនពលករខុសច្បាប់ចូលប្រទេសខ្លួនប្រមាណ ១៥៣៧៨នាក់ ដោយពលករទាំងនោះរួមមាន កម្ពុជា ឡាវ ម៉ាឡេស៊ី និងភូមា។ ជាមួយគ្នានេះ កាលពីថ្ងៃអាទិត្យកន្លងទៅអាជ្ញាធរបានរកឃើញពលករខុសច្បាប់ចំនួន៥នាក់មានវិជ្ជមានកូវីដ-១៩ ដោយមាន២នាក់ជាជនជាតិថៃមកពីកម្ពុជាផងដែរ។

លោកវេជ្ជបណ្ឌិត Kiattiphum Wongrajit រដ្ឋលេខាធិការក្រសួងសុខាភិបាល បានលើកឡើងថា នៅថ្ងៃអាទិត្យម្សិលមិញ រកឃើញករណីឆ្លងថ្មីចំនួន២១០១នាក់ ដោយទីក្រុងបាងកកជាទីតាំងដែលមានការឆ្លងច្រើនជាងគេ ក្នុងចំនួន៩៨០នាក់ រីឯខេត្តសាមុតសាខន ដែលមានពលករចំណាកស្រុកធ្វើការច្រើន មានអ្នក

ឆ្លង១០៨នាក់។ ដោយឡែកនៅថ្ងៃនេះ ប្រទេសថៃរកឃើញករណីឆ្លងថ្មីចំនួន១៦០៣នាក់ និងមានករណីស្លាប់ចំនួន២២ នាក់។ នេះបើតាមរបាយការណ៍ស្ថានភាពជំងឺកូវីដ-១៩ CCSA។

គួរបញ្ជាក់ថា កាលពីថ្ងៃទី៣០ មេសាកន្លងទៅនេះ មានពលករខ្មែរនៅថៃ ម្នាក់ភេទប្រុសបានស្លាប់ដោយសារជំងឺកូវីដ-១៩ នៅឯមន្ទីរពេទ្យទីក្រុងបាងកក។ បើតាមរបាយការណ៍មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅកាត់ថា សង់ត្រាល់(Central) ឲ្យដឹងថា បច្ចុប្បន្នមានពលករខ្មែរទាំងស្របច្បាប់ និងមិនស្របច្បាប់ប្រមាណ១លាន ៨សែននាក់ (១.៨០០.០០០) កំពុងធ្វើការនៅប្រទេសថៃ៕

## ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១

### ការបង្ក្រាបការជួញដូរមនុស្សនៅដើមឆ្នាំនេះមានការកើនឡើង ខណៈមានការរឹតបន្តឹងការធ្វើដំណើរដើម្បីទប់ស្កាត់ការឆ្លងកូវីដ

https://www.postkhmer.com/ ឡាយ សាមាន | Publication date 11 May 2021 | 13:28 ICT

**ភ្នំពេញៈ** មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ បានឱ្យដឹងថា ក្នុងរយៈពេល ៣ ខែ ដើមឆ្នាំ ២០២១ សមត្ថកិច្ចបង្ក្រាបបទល្មើសជួញដូរមនុស្សបានចំនួន ៨៥ ករណី គឺមានការកើនឡើង ៦០ ករណី បើប្រៀបធៀបរយៈពេលដូចគ្នាកាលពីឆ្នាំមុន ខណៈមានការរឹតបន្តឹង ការធ្វើដំណើរ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ ១៩។

រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស លោកស្រី ជូ ប៊ុនអេង ប្រាប់ភ្នំពេញប៉ុស្តិ៍នៅថ្ងៃទី១១ ឧសភានេះថា ក្នុងត្រីមាសទី១ នេះការជួញដូរមនុស្សឆ្លងដែនខុសច្បាប់ក្នុងអំឡុងពេលកូវីដ១៩ ពុំមានការថយចុះឡើយ ប្រើប្រៀបកាលពីឆ្នាំ ២០២០ ដែលមានត្រឹមតែ ២៥ ករណីប៉ុណ្ណោះ។ លោកស្រីថាៈ «ក្នុងត្រីមាសទី១ ការជួញដូរមនុស្សអត់ថយចុះទេ ទិន្នន័យនៃការបង្ក្រាប និងចោទប្រកាន់រយៈពេល ៣ ខែ យើងបង្ក្រាបបាន ៨៥ ករណី ក្នុងចំណោម ៨៥ ករណី ភាគច្រើននាំចេញឆ្លងដែនខុសច្បាប់ដែលចូលទៅក្នុងបទអំពើជួញដូរមនុស្ស»។ មូលហេតុនៃការកើនឡើងអំពើជួញដូរមនុស្សក្នុងអំឡុងពេលរីករាលដាលនៃជំងឺកូវីដ១៩ គឺដោយសារកត្តាការយល់ដឹងរបស់ពលរដ្ឋ ខណៈមេខ្យល់បានឆ្លៀតឱកាសកេងចំណេញ។ លោកស្រីបញ្ជាក់ថាៈ «នៅពេលយើងកំពុងជាប់ដៃប្រយុទ្ធប្រឆាំងជំងឺកូវីដ ១៩ មេខ្យល់បានឆ្លៀតឱកាសជាពិសេសប្រជាពលរដ្ឋគាត់ខ្វះការយល់ដឹង មួយវិញទៀតដោយសារតែមានមេខ្យល់ជួញដូរនេះឯង ព្រោះគាត់រកផលចំណេញពីការជួញដូរនេះ អ៊ីចឹងនៅពេលដែលឱកាសគាត់មាន គាត់ធ្វើសកម្មភាព»។

ទន្ទឹមនឹងនេះដែរ រដ្ឋាភិបាលក៏ដូចជាស្ថាប័នសាមីបានដាក់ចេញនូវវិធានការជាបន្តបន្ទាប់ក្នុងការទប់ស្កាត់ករណីនេះ និងបានធ្វើសកម្មភាពជាច្រើន ក្នុងការរក្សាស្ថិរភាព ជីវភាពរបស់ប្រជាពលរដ្ឋ ដើម្បីកុំឱ្យពួកគាត់មានការព្រួយបារម្ភក្នុងអំឡុងពេលរីករាលដាលនៃជំងឺកូវីដ ១៩។ លោកស្រី ជូ ប៊ុនអេង មានប្រសាសន៍ទៀតថាៈ «យើងបានជម្រាបគាត់ (ពលករចំណាកស្រុក) ហើយតាំងពីគាត់ត្រឡប់មកវិញលើកដំបូងនៅចុងឆ្នាំ ២០១៩ ដើមឆ្នាំ ២០២០ គឺយើងណែនាំគាត់ថា ការធ្វើចំណាកស្រុកទៅក្រៅប្រទេសនាពេលនេះ មិនមែនស្ថិតនៅក្នុងស្ថានភាពដូចធម្មតាទេ ពីព្រោះពេលនេះមិនត្រឹមតែប្រឈមឆ្លងកូវីដ ១៩ ទេ អាចអត់ការងារធ្វើនៅប្រទេសគោលដៅដែលយើងចង់ទៅ»។ ពីព្រោះរឿងនេះវាពាក់ព័ន្ធនឹងការឆ្លងរាលដាលនៃជំងឺកូវីដ ១៩ ដូច្នេះហើយនៅប្រទេសគោលដៅក៏គេកំពុងរឹតបន្តឹង ដោយមិនអនុញ្ញាតឱ្យមានការចល័តសូម្បីតែនៅក្នុងប្រទេស រហូតបិទព្រំដែន បិទខេត្ត ដូចជានៅប្រទេសថៃ គេមានវិធានការច្រើន។ លោកស្រី ប៊ុនអ៊េង ឱ្យដឹងថា មេខ្យល់ដែលលួចនាំពលករឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ និងមានការឆ្លងដែនខុសច្បាប់មួយៗទៅប្រទេសចិន ដោយឆ្លងតាមព្រំដែនប្រទេសវៀតណាម។

អ្នកសម្របសម្រួលមជ្ឈមណ្ឌលសិទ្ធិមនុស្ស និងការងារនៃអង្គការសង់ត្រាល់ (CENTRAL)លោក ឃុន ថារ៉ូ មើលឃើញថា ខណៈពេលដែលកម្ពុជារងវិបត្តិកូវីដ១៩ គួបផ្សំអត្រាអត់ការងារធ្វើ ទើបធ្វើឱ្យពលរដ្ឋចង់ស្វែងរកការងារធ្វើនៅប្រទេសជិតខាង តាមរយៈការបញ្ចុះបញ្ចូលពីមេខ្យល់ដែលមានជំនាញនេះ។ លោកបញ្ជាក់ថា៖ «ក្រុមមេខ្យល់ដែលមានឯកទេសជំនាញក្នុងការធ្វើរឿងនេះ យកឱកាសកូវីដ ឈានដល់ការជួញដូរមនុស្ស ហើយទម្រង់នៃការជួញដូរ គឺការជួញដូរនៃកម្លាំងពលកម្មដែលមេខ្លោងសន្យាជួយរកការងារឱ្យធ្វើទើបនាំឱ្យមានការធ្វើចំណាកស្រុក»។ យ៉ាងនេះក្ដី លោកជំរុញឱ្យសមត្ថកិច្ចចាត់វិធានការម៉ឺងម៉ាត់ចំពោះមេខ្យល់ដែលនាំពលករឆ្លងដែនខុសច្បាប់ ដើម្បីកាត់បន្ថយការឆ្លងដែនខុសច្បាប់ទៅក្រៅប្រទេស។ លោកបន្ថែមថា៖ «ករណីជួញដូរមនុស្សនេះ សមត្ថកិច្ចត្រូវមានវិធានការអនុវត្តច្បាប់តឹងរ៉ឹងត្រូវដាក់ទោសទណ្ឌឱ្យបានធ្ងន់ធ្ងរទៅដល់ជនប្រព្រឹត្ត វាអាចជាសារមួយបង្ហាញទៅជនល្មើសផ្សេងៗទៀត ដែលមានចេតនាប្រព្រឹត្ត ឬបាននិងកំពុងប្រព្រឹត្តអាចមានការកាត់បន្ថយសកម្មភាពពួកគេ»។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោក ស ខេង កាលពីចុងខែមេសាឆ្នាំ ២០២១ បានណែនាំឱ្យអគ្គស្នងការនគរបាលជាតិត្រូវសហការជាមួយបណ្ដាខេត្តដែលនៅជាប់ព្រំដែនត្រូវយកចិត្តទុកដាក់ស្រាវជ្រាវបង្ក្រាប បណ្ដាញមេខ្លោង និងមេខ្យល់ក្នុងប្រទេស ដែលធ្វើសកម្មភាពនាំពលរដ្ឋកម្ពុជា និងជនបរទេសឆ្លងកាត់ព្រំដែនខុសច្បាប់។ ការណែនាំនេះត្រូវបានធ្វើឡើង បន្ទាប់ពីថ្នាក់ដឹកនាំនៃក្រសួងមហាផ្ទៃនៅតែកត់សម្គាល់ឃើញមានករណីនៃការនាំពលរដ្ឋកម្ពុជា និងជនបរទេស ឆ្លងកាត់ព្រំដែនដោយខុសច្បាប់នៅតែកើតមានជាបន្តបន្ទាប់ ក្នុងនោះ ក៏មានករណីមួយចំនួនមានក្រុមមេខ្លោង និងមេខ្យល់ក្នុងស្រុក ឃុបឃិតជាមួយក្រុមមេខ្លោង និងមេខ្យល់ពីខាងក្រៅ ដើម្បីរត់ពន្ធមនុស្សឆ្លងកាត់ព្រំដែនដោយខុសច្បាប់ផងដែរ៕

## អំឡុងឆ្នាំ២០២១ ខេត្តបន្ទាយមានជ័យបង្ក្រាបបទល្មើសលួចឆ្លងដែន៤៥ករណីឃាត់ខ្លួនមេខ្យល់៦៣នាក់ត្រូវបញ្ជូនទៅតុលាការ

https://kohsantepheapdaily.com.kh/ Banteay Meanchey ១១ ខែ ឧសភា ឆ្នាំ ២០២១ ម៉ោង ១៤:៥០

បន្ទាយមានជ័យ ៖ ក្នុងអំឡុងឆ្នាំ២០២១ ខេត្តបន្ទាយមានជ័យបង្ក្រាបបទល្មើសលួចឆ្លងដែនមានចំនួន៤៥ករណីឃាត់ខ្លួនមេខ្យល់ចំនួន៦៣នាក់ ត្រូវបញ្ជូនទៅតុលាការខេត្តបន្ទាយមានជ័យចាត់ការតាមច្បាប់ ។ លោកស្រីឧត្តមសេនីយ៍ត្រី ឌី សុជាតិ ស្នងការរងនគរបាលខេត្តបន្ទាយមានជ័យបានប្រាប់ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ថា នៅអំឡុងឆ្នាំ២០២១នេះ កម្លាំងនៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានបង្ក្រាបបទល្មើសលួចឆ្លងដែនដោយខុសច្បាប់មានចំនួន៣៧ករណី និងឃាត់ខ្លួនមេខ្យល់ចំនួន៥៦នាក់ ក្នុងនោះប្រុស៤៩នាក់ ស្រី៧នាក់ ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមច្បាប់និងពលករចំនួន២២៦នាក់ ស្រី១០២នាក់ ប្រុស១២៤នាក់ និងកុមារចំនួន២នាក់ ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ ។

លោកវរៈសេនីយ៍ទោ ព្រហ្ម ថេង ប្រធានមន្ទីរស្រាវជ្រាវ និងបង្ក្រាបបទល្មើសនៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យបានប្រាប់ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ថា ៖ កម្លាំងកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យនៅអំឡុងឆ្នាំ២០២១នេះ បង្ក្រាបបទល្មើសឆ្លងដែនខុសច្បាប់មានចំនួន៨ករណី ក្នុងនោះសហការកម្លាំងយោធាតំបន់ប្រតិបត្តិការសឹករង ខេត្តបន្ទាយមានជ័យបាន៥លើក ដែលត្រូវឃាត់ខ្លួនមេខ្យល់ចំនួន៧នាក់ ជាប្រុស និងមធ្យោបាយដឹកជញ្ជូនរថយន្ត៥គ្រឿង និងម៉ូតូកង់បី១គ្រឿង ត្រូវបានបញ្ជូនទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមច្បាប់ និងពលករចំនួន៧០នាក់ ស្រី៣៦នាក់ ប្រុស៣៤នាក់ កុមារចំនួន៦នាក់ ត្រូវបានបញ្ជូនទៅមណ្ឌលដើម្បីធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ ។

ក្រោយទទួលការណែនាំពីប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងសុខាភិបាល ដើម្បីទប់ស្កាត់ពលករចំណាក់ស្រុក ដោយខុសច្បាប់លួចឆ្លងដែនគេចវេសធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ រិធានការគណៈបញ្ជាការឯកភាពបានដាក់វិធានការ បង្ការទប់ស្កាត់កូវីដ១៩ មិនអោយរីករាលដាលក្នុងសហគមន៍ត្រូវអនុវត្តវិធាន ៣ការពារ និង៣កុំ ៕

## សមត្ថកិច្ចចម្រុះព្រំដែន ឃាត់ខ្លួនពលករខ្មែរ២៦នាក់ បម្រុងលួចឆ្លងដែនពីកម្ពុជា ចូលទៅប្រទេសថៃ

http://freshnewsasia.com/ 2021-05-11 11:21am

**(បន្ទាយមានជ័យ)៖** កម្លាំងអន្តរាគមន៍វរសេនាតូចថ្មើរជើងលេខ ៥១៤ រួមនឹងកងពលតូចថ្មើរជើងលេខ ៥១ ដឹកនាំដោយលោកវរសេនីយ៍ទោ ប៉ែន សុគន្ធ មេបញ្ជាការវរសេនាតូចថ្មើរជើងលេខ ៥១៤ សហការជាមួយកម្លាំងកងការពារព្រំដែនលេខ ៥០៣, នគរបាលព្រំដែនគោកលេខ ៩១១ និងនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំអូរបីជាន់ បានឃាត់ខ្លួនពលករខ្មែរចំនួន២៦នាក់ ដែលបម្រុងលួចឆ្លងដែនពីកម្ពុជា ទៅប្រទេសថៃដោយខុសច្បាប់។

ប្រតិបត្តិការបង្ក្រាបបទល្មើសលួចឆ្លងដែននេះ បានធ្វើឡើងនៅចំណុចគោលដៅភូមិជោគជ័យ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ នាយប់ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១។ ក្រោយឃាត់ខ្លួនរួចសមត្ថកិច្ចបានសួរនាំ និងនាំពលករទាំង២៦នាក់នោះ ទៅធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័ករយៈពេល១៤ថ្ងៃ៕

## សមត្ថកិច្ចស្រុកម៉ាឡៃឃាត់ខ្លួនពលករ២៥នាក់ ដែលបម្រុងឆ្លងដែនចូលប្រទេសថៃ ដោយខុសច្បាប់ ខណៈមេខ្យល់៣នាក់ទៀតត្រូវបញ្ជូនទៅតុលាការ

http://freshnewsasia.com/ 2021-05-11 07:40pm

**(បន្ទាយមានជ័យ)៖** កម្លាំងមូលដ្ឋានកងរាជអាវុធហត្ថស្រុកម៉ាឡៃ និងកម្លាំងតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ បានឃាត់ខ្លួនពលករខ្មែរពីរក្រុមមានគ្នាសរុប ២៥នាក់ រួមជាមួយមេខ្យល់ ៣នាក់ទៀត ខណៈដែលពួកគេកំពុងធ្វើដំណើរបម្រុងលួចឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់។ នេះបើតាមការបញ្ជាក់ពីសមត្ថកិច្ចស្រុកម៉ាឡៃ នាថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១នេះ។

ប្រភពដដែលបានបញ្ជាក់ថា នាវេលាម៉ោង ១៖៣០ នាទីរំលងអាធ្រាត ឈានចូលថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ កម្លាំងមូលដ្ឋានកងរាជអាវុធហត្ថស្រុកម៉ាឡៃ និងកម្លាំងតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ដឹកនាំដោយ លោកវរសេនីយ៍ឯក រិទ្ធ រ៉េម មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ទទួលទិសទី១ បានចុះល្បាតតាមបន្ទាត់ព្រំដែន ដើម្បីទប់ស្កាត់ការលួចចេញ-ចូលទៅប្រទេសថៃដោយខុសច្បាប់ ក្នុងភូមិសាស្ត្រភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ ក៏ប្រទះឃើញម៉ូតូកង់បីឥណ្ឌា ១គ្រឿង កំពុងដឹកពលករខ្មែរ៧នាក់ ពេលនោះកម្លាំងចម្រុះក៏បានឃាត់ ហើយសួរនាំ ទើបដឹងថាពលករទាំងអស់ត្រូវបានម្ចាស់ម៉ូតូកង់បីដឹកទៅបម្រុងឆ្លងដែនទៅប្រទេសថៃ។ បន្ទាប់មកទៀតនៅវេលាម៉ោង ៣៖៤០ នាទីទៀបភ្លឺ ថ្ងៃដដែល ក៏ទទួលបានព័ត៌មានពីប្រជាពលរដ្ឋថាមានមេខ្យល់បម្រុងនាំពលករឆ្លងដែនមួយក្រុមទៀត នៅភូមិសាស្ត្រដដែល តែទីតាំងផ្សេងគ្នា ភ្លាមនោះ កម្លាំងចម្រុះក៏បន្តធ្វើប្រតិបត្តិកាបង្ក្រាប និងឃាត់ខ្លួនមេខ្យល់ ២នាក់បន្ថែមទៀត និងពលករ ១៨នាក់ទៀតផងដែរ ហើយបញ្ជូនមកសាកសួរចម្លើយរួមគ្នានៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថស្រុកម៉ាឡៃ។

ក្រោយការឃាត់ខ្លួននេះហើយ សមត្ថកិច្ចបានបញ្ជូនពលករទាំង ២៥ នាក់ ទៅធ្វើចត្តាឡីស័កក្នុងវិទ្យាល័យស្រុកម៉ាឡៃ។ រីឯមេខ្យល់ទាំង៣នាក់នោះ ត្រូវបានកម្លាំងជំនាញការិយាល័យប្រឆាំងការជួញដូរមនុស្ស បញ្ជូនយកមកបញ្ជាការដ្ឋានអាវុធហត្ថខេត្ត ហើយបញ្ជូនទៅសាលាដំបូងខេត្តចាត់ការតាមនីតិវិធី។

មេខ្យល់ទាំងបីនាក់នោះ មានឈ្មោះ៖

***ទី១៖** សុខ វិបុល ភេទប្រុស អាយុ៣០ឆ្នាំ បច្ចុប្បន្នរស់នៅភូមិ និងសង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

***ទី២៖** ឌឹប នុន ភេទប្រុស អាយុ៥២ឆ្នាំ បច្ចុប្បន្នរស់នៅភូមិចំបក់ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

***ទី៣៖** ម៉ៃ សែហុង ភេទប្រុស អាយុ២១ឆ្នាំ បច្ចុប្បន្នរស់នៅភូមិត្នំរូង ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ៕

## ប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៥០នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃអង្គារ ទី១១ ខែឧសភា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៥០នាក់ ស្រី ១៧នាក់ ក្នុងនោះកុមារា ១ នាក់ កុមារី ៣នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ៣នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៣៤នាក់ ស្រី ១៣នាក់ កុមារា ១នាក់ កុមារី ៣នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ១៣នាក់ ស្រី ៤នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ប្រុសចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៥០នាក់ ស្រី ១៧នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ថៃចាប់បញ្ជូនមនុស្ស១៣នាក់ មកកម្ពុជាវិញ ក្រោយលួចឆ្លងដែនចូលខុសច្បាប់, អាជ្ញាធរយកមនុស្សទាំងនោះទៅពិនិត្យសំណាក និងធ្វើចត្តាឡីស័ក

http://freshnewsasia.com/ 2021-05-11 04:05pm

**(បន្ទាយមានជ័យ)៖** សេចក្តីរាយការណ៍បានឲ្យដឹងនៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១នេះថា អាជ្ញាធរថៃបានចាប់បញ្ជូនមនុស្ស១៣នាក់ ដែលលួចឆ្លងដែនដោយខុសច្បាប់ចូលទឹកដីថៃ ហើយបញ្ជូនមកកម្ពុជាវិញ ដើម្បីពិនិត្យសំណាក និងធ្វើចត្តាឡីស័ក នៅខេត្តបន្ទាយមានជ័យ។

សមត្ថកិច្ចបានបញ្ជាក់ថា មនុស្សទាំង១៣នាក់នេះ ត្រូវបានចាប់ខ្លួនដោយទាហានឈុតខ្មៅថៃ នៅ៣ទីតាំងផ្សេងគ្នា នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ម្សិលមិញ នៅចំណុចភូមិប៉ារ៉ៃ ឃុំប៉ារ៉ៃ ស្រុកអារញ្ញ ខេត្តស្រះកែវ។

ដោយឡែក ក្នុងប្រតិបត្តិការនេះកម្លាំងសមត្ថកិច្ចក៏បានចាប់ខ្លួនមេខ្យល់នាំពលករខុសច្បាប់ទៅប្រទេសថៃម្នាក់ផងដែរ ដើម្បីបញ្ជូនទៅផ្តន្ទាទោសតាមផ្លូវច្បាប់។ ខណៈពលករដែលឆ្លងដែនត្រូវបានបញ្ជូនមកកម្ពុជាវិញ តាមច្រកព្រំដែនអូរបីជាន់ ខេត្តបន្ទាយមានជ័យ ដើម្បីពិនិត្យសំណាក និងធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ ទើបអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## ប្រទេសថៃ រឹតបន្តឹងការត្រួតពិនិត្យនៅតាមព្រំដែន

https://www.information.gov.kh/ AKP ភ្នំពេញថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០២១

អាជ្ញាធរថៃបានបង្កើនប៉ុស្តិ៍ត្រួតពិនិត្យ និងល្បាតនៅតាមព្រំដែនដើម្បីការពារការចូលខុសច្បាប់ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។ អគ្គស្នងការនគរបាលជាតិនៃប្រទេសថៃ លោក Suwat Jangyodsuk បានបញ្ជាឱ្យអង្គភាពប៉ូលីសទាំងអស់បង្កើនការឃ្លាំមើលដើម្បីការពារការចូលរបស់ជនចំណាកស្រុកខុសច្បាប់ ខណៈដែលប្រទេសនេះនៅតែបន្តតស៊ូប្រយុទ្ធប្រឆាំងនឹងរលកឆ្លងទី ៤ នៃជំងឺកូវីដ-១៩។ លោក Damrongsak Kittiprapat អគ្គស្នងការរងនគរបាលជាតិបាននិយាយថា អង្គភាពប៉ូលីសទាំងអស់នឹងធ្វើការសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន និងភ្នាក់ងារសន្តិសុខដើម្បីទប់ស្កាត់ការឆ្លងដែនខុសច្បាប់ ដោយសារការព្រួយបារម្ភអំពីការផ្ទុះឡើងនៃមេរោគឆ្លងដែលអាចឆ្លងខ្លាំងពីប្រទេសជិតខាង។ លោកបានកត់សម្គាល់ថា ប៉ុស្តិ៍ត្រួតពិនិត្យមួយចំនួនក៏នឹងត្រូវបានបង្កើតឡើងនៅតាមបណ្តាខេត្តខាងក្នុង ដែលមានកម្លាំងពលកម្មដែលត្រូវបានបម្រុងទុក ដើម្បីធ្វើការនៅជុំវិញគ្រប់ជ្រុង ដើម្បីបញ្ឈប់ការដឹកជញ្ជូនជនចំណាកស្រុកខុសច្បាប់។

យោងតាមមជ្ឈមណ្ឌលគ្រប់គ្រងស្ថានការណ៍ជំងឺកូវីដ-១៩ របស់ប្រទេសថៃបានឱ្យដឹងថា ចាប់ពីថ្ងៃទី ១ ដល់ថ្ងៃទី ១០ ខែឧសភា ជនចំណាកស្រុកខុសច្បាប់ចំនួន ១១២៦នាក់ ត្រូវបានចាប់ខ្លួននៅក្នុងប្រទេសថៃពីបទឆ្លងដែនខុសច្បាប់។

កាលពីថ្ងៃទី ១១ ខែឧសភា ប្រទេសនេះបានកត់ត្រាករណីឆ្លងថ្មីចំនួន ១ ៩១៩នាក់ និងការស្លាប់ថ្មីចំនួន ៣១នាក់ ដែលនាំឱ្យចំនួនសរុបនៃករណីជំងឺកូវីដ-១៩ នៅក្នុងប្រទេសថៃរហូតមកដល់ពេលនេះមាន ៨៦ ៩២៤ នាក់ និងអ្នកស្លាប់ដោយសារជំងឺនេះសរុបចំនួន ៤៥២នាក់។ ប្រទេសនេះបានកត់ត្រាករណីឆ្លងចំនួន ៥៨ ០៦១ នាក់ចាប់តាំងពីការផ្ទុះលើកទី ៣ បានចាប់ផ្តើមកាលពីដើមខែមេសាមក៕ (ប្រភព VNA បកប្រែដោយលោក យាចិន្តាខន្តី) សម្រួលផ្សាយដោយ៖ ធូ កុសល

# ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១

## មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ មិនគាំទ្រដាច់ខាត ចំពោះអំពើស្មោគគ្រោក របស់អ្នកប្រព្រឹត្តិ

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១

(ភ្នំពេញ)៖ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) មានប្រសាសន៍ថា បណ្តឹងរវាងឧកញ៉ា ហេង សៀ និងកញ្ញា មាន ពេជ្ររីតា កំពុងតែមានការសើបអង្កេត ឱ្យបានត្រឹមត្រូវ ប៉ុន្តែលោកជំទាវមិនគាំទ្រដាច់ខាត ចំពោះអំពើស្មោគគ្រោករបស់អ្នកប្រព្រឹត្តិ។ មានប្រសាសន៍ជាមួយអង្គភាពសារព័ត៌មាន Swift News តាមប្រព័ន្ធទូរសព្ទ លោកជំទាវ ជូ ប៊ុនអេង ពន្យល់ថា« បើតាមបណ្តឹងរបស់កញ្ញា មាន ពេជ្ររីតា រឿងនេះមិនធម្មតាទេ ត្រូវស្រាវជ្រាវឱ្យបានច្បាស់លាស់ និងផ្តល់យុត្តិធម៌ ជូនគាត់ឱ្យបានត្រឹមត្រូវ យើងឃើញថា មានបណ្តឹង២ទន្ទឹមគ្នា ម្នាក់គេហៅថាគួរតែ

ជនល្មើស តែបែរជាប្ដឹងមុនទៅវិញ អញ្ចឹងហើយបានជាត្រូវការ សើបអង្កេតឱ្យបានច្បាស់លាស់ យើងនឹងសហការជាមួយផ្នែក នគបាលយុត្តិធម៌ ដើម្បីជំរុញការស៊ើបអង្កេត ឱ្យបានលឿន និងឱ្យបានច្បាស់ត្រឹមត្រូវ»។

តែយ៉ាងណាក៏ដោយ លោកជំទាវបញ្ជាក់ថា នៅតែចង់បានយុត្តិធម៌ ជូនជនរងគ្រោះ តែពេលនេះនៅមិនទាន់ដឹងថា អ្នកណាជាជនរងគ្រោះពិត ដែលសាច់រឿងដែលស្ដ្រីរងគ្រោះបានលើកឡើង បើសិនជារឿងនឹងមែន គឺលោកជំទាវមិនគាំទ្រដាច់ខាត ចំពោះអំពើឃោរឃៅគ្រោករបស់អ្នកប្រព្រឹត្តិ។ ក្នុងនាមជាអ្នកការពារ ដល់សីលធម៌សង្គម មិនចង់ឃើញអំពើនេះ កើតមាននៅសង្គមកម្ពុជាទេ និងមិនគាំទ្រដាច់ខាត ចំពោះជនល្មើស ដែលប្រព្រឹត្តិបែបនឹង ទោះអ្នកណាក៏ដោយ មិនមែនតែករណីនេះទេ។ លោកជំទាវនឹងចូលរួមជម្រុញ ឱ្យមានការសើបអង្កេតដ៏ត្រឹមត្រូវ។

ជាមួយគ្នានេះ លោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី មានប្រសាសន៍ថា ក្រសួងកិច្ចការនារីកំពុងធ្វើការងារ ទំនាស់រវាងឧកញ៉ា ហេង សៀ និងកញ្ញា មាន ពេជ្ររីតា ជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ។ ឯកឧត្តម គី តិច ប្រធានក្រុមមេធាវីរាជរដ្ឋាភិបាល និងជាប្រធានក្រុមមេធាវីស្ម័គ្រចិត្តសម្ដេចតេជោ មានប្រសាសន៍ថា ពេលនេះ មានមេធាវីជាស្ត្រីចំនួន២នាក់ កំពុងការពារក្ដី ឱ្យកញ្ញា មាន ពេជ្ររីតា។ ជាមួយគ្នានេះ ក៏នឹងដាក់ពាក្យសុំទៅកាន់សាលាដំបូង រាជធានីភ្នំពេញ ដើម្បីឱ្យកញ្ញា មាន ពេជ្ររីតា នៅក្រៅឃុំជាបណ្ដោះអាសន្ន។

ជុំវិញវិធានការនេះលោកជំទាវ ជូ ប៊ុនអេង បញ្ជាក់ថា សូមគាំទ្រចំពោះចំណាត់ការរបស់ប្រមុខរាជរដ្ឋាភិបាល និងបញ្ជាក់ថា ជាអំពើឃោរឃៅគ្រោក ដែលមិនគួរកើតមាននៅកម្ពុជា។

នៅល្ងាចថ្ងៃនេះដែរ ក្រុមអង្គការសង្គមស៊ីវិល ចំនួន២៦ និងប្រជាពលរដ្ឋ កំពុងធ្វើការលើកម្ពស់ស្ត្រី និងសមភាពយេនឌ័រនៅកម្ពុជា បានចេញលិខិតចំហ លើសំណើសុំចំណាត់ការតាមផ្លូវច្បាប់ ទៅលើករណីរបស់ ឧកញ៉ា ហេង សៀ អតីតឧកញ៉ា ឌួង ឆាយ និង លោក អ៊ុក កុសល អតីតស្នងការនគរបាលខេត្តកំពង់ធំ លើករណីអំពើហិង្សាក្នុងគ្រួសារការបៀតបៀន និងប្រើអំពើហិង្សាផ្លូវភេទលើស្ត្រី។ ក្នុងលិខិតចំហផ្ញើជូនសម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៅថ្ងៃទី១២ ខែឧសភានេះ បានអង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋសម្ដែងការខកចិត្តជាខ្លាំង ដែលស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ មិនបានអនុវត្តឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពតាមគោលការណ៍ច្បាប់ ទៅលើករណីហិង្សា និងការបៀតបៀនផ្លូវភេទកន្លងមក។

ជុំវិញបណ្ដាញសង្គមហ្វេសបុកវិញ នៅថ្ងៃនេះចាប់អារម្មណ៍រឿងក្ដីនេះខ្លាំងមែនទែន អ្នកខ្លះបញ្ចេញទស្សនៈរិះគន់លោកឧកញ៉ា ហេង សៀ និងអ្នកខ្លះលើកឡើង ជាទស្សនៈគាំទ្រកញ្ញា មាន ពេជ្ររីតា។ មតិគាំទ្រ បានជម្រុញឱ្យប្រព័ន្ធតុលាការដោះលែងរូបនាង ព្រោះករណីនេះមិនសមហេតុផល ចាប់នាងវ៉ៃខ្នោះដៃ និងបញ្ជូនខ្លួននាងទៅឃុំខ្លួននោះឡើយ។

ជាការឆ្លើយតបជុំវិញរឿងនេះ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងយុត្តិធម៌ ឯកឧត្តម គឹម សន្តិភាព បានអំពាវនាវដល់សាធារណៈជន មេត្តារក្សាភាពស្ងប់ស្ងាត់ និងទុកសមត្ថកិច្ច ជូនទៅស្ថាប័នតុលាការ ដំណើរការចំណាត់ការតាមនីតិវិធី ករណីទំនាស់រវាងឧកញ៉ា ហេង សៀ និងកញ្ញា មាន ពេជ្ររីតា។ ឯកឧត្តម គឹម សន្តិភាព បញ្ជាក់ថា ក្រសួងយុត្តិធម៌ បានតាមដានដោយយកចិត្តទុកដាក់ ចំពោះព័ត៌មាននេះ និងបានស្នើសុំឲ្យស្ថាប័នតុលាការ យកចិត្តទុកដាក់ក្នុងការស្រាវជ្រាវសំណុំរឿងទាំងពីរនេះ ឲ្យបានច្បាស់លាស់ ដើម្បីស្វែងរកការពិតនៃអង្គហេតុទំនាស់ និងផ្ដល់យុត្តិធម៌ដល់ភាគីពាក់ព័ន្ធ៕

# ជនសង្ស័យ ៣ នាក់ ពាក់ព័ន្ធនឹងការនាំមនុស្សឆ្លងដែនចូលដីថៃ ត្រូវបានបញ្ជូនទៅស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង

https://www.postkhmer.com/ អោម ប៊ុនធឿន | Publication date 12 May 2021 | 19:15 ICT

**បាត់ដំបង/បន្ទាយមានជ័យ:** ជនសង្ស័យជាមេខ្យល់ចំនួន ៣ នាក់ដែលជាមុខសញ្ញានាំមនុស្ស ១៥ នាក់ឆ្លងដែនចូលទៅប្រទេសថៃ ដោយខុសច្បាប់ ត្រូវបាននគរបាលស្រុកកំរៀងបញ្ជូនទៅស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង ដើម្បីចាត់ការបន្តតាមនីតិវិធីនៅថ្ងៃទី ១២ ខែឧសភានេះ។

លោក ស្រី វុទ្ធី អធិការស្តីទីនៃអធិការដ្ឋាននគរបាលស្រុកកំរៀងបានឲ្យដឹងថា ជនសង្ស័យទាំង ៣ នាក់ត្រូវបានបញ្ជូនទៅការិយាល័យជំនាញនៃស្នងការដ្ឋាននគរបាលខេត្ត ដើម្បីចាត់ការបន្ត ខណៈមនុស្សទាំង ១៥ នាក់ទៀត មានស្រីចំនួន ៥ នាក់ និងក្មេងម្នាក់ត្រូវបានដោះលែងវិញ។ លោកថ្លែងថា៖ «កម្លាំងយើងបានធ្វើសកម្មភាពពួនស្ទាក់ចាប់រថយន្ត ១ គ្រឿងម៉ាកសាំយ៉ុងពណ៌លឿង ដែលកំពុងធ្វើសកម្មភាពដឹកជញ្ជូនពលករខ្មែរ ១៤ នាក់រួមនឹងក្មេងម្នាក់ ទាំងអស់ ១៥ នាក់។ [ក្រៅពីនោះ] មានតែកុងឡានម្នាក់ និងមេខ្យល់ ២ នាក់។ ទោះបីមានម្នាក់ជាតែកុងឡាន ប៉ុន្តែពួកគេរួមគំនិតគ្នា អ៊ីចឹងយើងបញ្ជូនទៅតុលាការធ្វើការសម្រេចទាំងអស់»។

ស្នងការរងទទួលបន្ទុកផ្នែកយេនឌ័រនៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង លោកស្រី រស់ ជីវី ប្រាប់ភ្នំពេញប៉ុស្តិ៍នៅថ្ងៃនេះថា កម្លាំងជំនាញកំពុងកសាងសំណុំរឿងបញ្ជូនជនសង្ស័យទាំង ៣ នាក់ទៅតុលាការនៅថ្ងៃស្អែក។ លោកស្រីថ្លែងថា៖ «ដោយសារការបញ្ជូនជនសង្ស័យមកល្ងាចណាស់ទៅហើយ អ៊ីចឹងយើងកសាងសំណុំរឿងបញ្ជូនទៅមិនទាន់ទេ ព្រោះត្រូវមានការពិនិត្យឆ្លងឯកសារច្រើនដំណាក់កាលទៀត។ ប៉ុន្តែយ៉ាងណា ស្អែកនេះគឺអាចបញ្ជូនទៅបានហើយ»។ ជនសង្ស័យទាំង ៣ នាក់មានទី ១ ឈ្មោះ លី ប៊ិយ ភេទប្រុស អាយុ ៣៨ ឆ្នាំ [តៃកុងឡាន] ទី ២ ឈ្មោះ ហ៊ុន រ៉ាឌឿន ភេទប្រុសអាយុ ៣១ ឆ្នាំ [មេខ្យល់] និងទី ៣ ឈ្មោះ ជួន វណ្ណា ភេទប្រុស អាយុ ៣០ ឆ្នាំ [មេខ្យល់]។ អ្នកទាំង ៣ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួននៅភូមិបឹងរាំង ឃុំបឹងរាំង ស្រុកកំរៀង ខណៈពួកគេកំពុងបើកបររថយន្ត និងជិះរថយន្តបម្រុងនាំពលករខ្មែរឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃនៅយប់ថ្ងៃទី ១០ ខែឧសភា។

ស្រដៀងគ្នានេះនៅខេត្តបន្ទាយមានជ័យ នគរបាលស្រុកស្វាយចេកបានឃាត់ខ្លួនពលករខ្មែរ ៩ នាក់ដែលបម្រុងលួចឆ្លងដែនទៅប្រទេសថៃ ដោយខុសច្បាប់នៅយប់ថ្ងៃទី ១០ ខែឧសភា នៅក្នុងចម្ការស្វាយចន្ទី ក្បែរព្រំដែនក្នុងភូមិរបើកស្វាយ ឃុំស្វាយចេក ស្រុកស្វាយចេក។ អធិការនគរបាលស្រុកស្វាយចេកលោក ជា ឈ្លួញ ឲ្យដឹងថា មន្ត្រីនគរបាលស្រុកស្វាយចេកបានចេញល្បាតពេលយប់ប្រទះឃើញពលករខ្មែរចំនួន ៩ នាក់ ស្រី ២ នាក់ និងម៉ូតូ ៣ គ្រឿង ខណៈពួកគេបម្រុងលួចឆ្លងដែនទៅប្រទេសថៃ ក្នុងភូមិសាស្ត្រស្រុកស្វាយចេកក៏ធ្វើការឃាត់ខ្លួនពួកគេយកទៅសួរនាំនៅអធិការដ្ឋានតែម្តង។ លោកថ្លែងថា៖ «ពួកគាត់បម្រុងឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃ ដោយមេខ្យល់បានបោកពួកគាត់យកប្រាក់មួយចំនួន ហើយថា ជូនដល់កន្លែងធ្វើការនឹងរកការងារឲ្យធ្វើ។ ប៉ុន្តែនៅពេលដែលពួកគាត់ជិះម៉ូតូចេញពីចម្ការស្វាយចន្ទីក្បែរព្រំដែន ក៏ត្រូវបានកម្លាំងសមត្ថកិច្ចយើងឃាត់ខ្លួនតែម្តង»។ បើតាមលោកអធិការ ពលករខ្មែរទាំង ៩ នាក់ដែលបម្រុងលួចឆ្លងដែនខុសច្បាប់នោះ ក្រោយពីធ្វើកិច្ចសន្យាណែនាំហើយត្រូវបានបញ្ជូនទៅមណ្ឌលធ្វើចត្តាឡីស័កស្រុកស្វាយចេករយៈពេល ១៤ ថ្ងៃ៕

## ប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៤៦នាក់

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃពុធ ទី១២ ខែឧសភា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៤៦នាក់ ស្រី ១៨នាក់ ក្នុងនោះកុមារា ៤នាក់ កុមារី ៣នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ២នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ២៦នាក់ ស្រី ១៣នាក់ កុមារា ៤នាក់ កុមារី ៣នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៧នាក់ ស្រី ៣នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់៖ ចំនួន ១០នាក់ ស្រី ២នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង៖ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ៖ ចំនួន ៣នាក់ ប្រុសចំនួន ៣នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៤៦នាក់ ស្រី ១៨នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអស់ហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## កម្លាំងចម្រុះចុះល្បាតឃាត់ខ្លួនពលករ២៥នាក់ និងមេខ្យល់៣នាក់ ករណីមេខ្យល់ដឹកពលករតាមម៉ូតូកង់បីឥណ្ឌា

https://www.kampucheathmey.com/ ថ្ងៃអង្គារ ១១ ឧសភា ២០២១ ដោយ Kang Tola

បន្ទាយមានជ័យ ៖ កម្លាំងមូលដ្ឋានកងរាជអាវុធហត្ថស្រុកម៉ាឡៃ និងកម្លាំងតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ដឹកនាំដោយលោកវរសេនីយ៍ឯក រិទ្ធ រ៉េម មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ទទួលទិសទី១ បានចុះល្បាតតាមបន្ទាត់ព្រំដែន ស្រាប់តែប្រទះឃើញម៉ូតូកង់បីឥណ្ឌា១គ្រឿង កំពុងដឹកពលករចំនួន៧នាក់បម្រុងលួចឆ្លងដែនទៅប្រទេសថៃ កម្លាំងធ្វើការឃាត់ខ្លួនទាំងអស់ នៅវេលាម៉ោង១ និង៣០នាទី រំលងអាធ្រាតឈានចូលថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ ចំណុចភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ លោកវរសេនីយ៍ឯក រិទ្ធ រ៉េម បានប្រាប់អ្នកយកព័ត៌មានឲ្យដឹងថា ពលករទាំង៧នាក់ បានថា ម្ចាស់ម៉ូតូកង់បីបានបម្រុងដឹកពួកខ្លួនឆ្លងដែនទៅប្រទេសថៃ ហើយក្រោយពីឃាត់ខ្លួនហើយពលករទាំង៧នាក់នេះបានបញ្ជូនមកមូលដ្ឋានកងរាជអាវុធហត្ថស្រុកដើម្បីធ្វើការសាកសួរចម្លើយ។

បន្ទាប់មកទៀតនៅវេលាម៉ោង៣និង៤០នាទីទៀបភ្លឺ មានមេខ្យល់បម្រុងនាំពលករឆ្លងដែនមួយក្រុមទៀតទៅប្រទេសថៃ នៅចំណុចភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ តែទីតាំងផ្សេងគ្នាកម្លាំងចម្រុះបានធ្វើការបង្ក្រាប និងឃាត់ខ្លួនមេខ្យល់២នាក់បន្ថែមទៀត និងពលករចំនួន១៨នាក់ទៀតផងដែរ ហើយបញ្ជូនមកសាកសួរចម្លើយរួមគ្នានៅមូលដ្ឋានកងរាជអាវុធហត្ថស្រុកម៉ាឡៃនេះ។

លោកវរសេនីយ៍ទោ ព្រហ្ម ថេង ប្រធានមន្ទីរស្រាវជ្រាវ និងបង្ក្រាបបទល្មើស នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត បានឲ្យដឹងថា ករណីខាងលើនេះលោកឧត្តមសេនីយ៍ត្រី បោនប៊ិន មេបញ្ជាការកងរាជអាវុធហត្ថខេត្តបាន បញ្ជាឲ្យកម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស សហការជាមួយកម្លាំងមូលដ្ឋានកងរាជអាវុធហត្ថស្រុកម៉ាឡៃ សួរចម្លើយមេខ្យល់ និងពលករទាំងអស់នោះ។ លោកវរសេនីយ៍ទោ ព្រហ្ម ថេង បានឲ្យដឹងទៀតថា ពលករទាំងអស់ ក្រោយពីកម្លាំងជំនាញសាកសួរចម្លើយរួចមក បានឆ្លើយសារភាពថា ពួកគេចង់ទៅរកការងារធ្វើនៅប្រទេសថៃពិត ប្រាកដមែន ដោយមេខ្យល់ទាំងនោះប្រាប់ថា ពួកគេនឹងនាំឆ្លងដែនទៅប្រទេសថៃបានដោយយកតម្លៃជូនក្នុងម្នាក់ ៦.០០០បាទ។ ចំណែកមេខ្យល់ទាំង៣នាក់១ឈ្មោះសុខ វិបុល ភេទប្រុស អាយុ៣០ឆ្នាំ រស់នៅភូមិអូរអំបិល និង សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ២ឈ្មោះ ឌឹប នុន ភេទប្រុស អាយុ៥២ឆ្នាំរស់នៅភូមិ ចំបក់ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ៣ឈ្មោះម៉ៃ សៃហុង ភេទប្រុស អាយុ២១ឆ្នាំ រស់នៅភូមិត្នោត ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ អ្នកទាំង៣ ក្រោយពីកម្លាំងជំនាញសាកសួរចម្លើយរួចមក បានឆ្លើយ សារភាពថា ពួកគេបានទំនាក់ទំនងជាមួយពលករផ្សេងៗគ្នាដើម្បីនាំចេញទៅប្រទេសថៃពិតប្រាកដមែន។

ដោយផ្អែកចម្លើយសារភាពរបស់ជនសង្ស័យទាំង៣នាក់ ទើបកម្លាំងជំនាញការិយាល័យប្រឆាំងការជួញដូរ មនុស្សបញ្ជូនយកមកបញ្ជាការដ្ឋានអាវុធហត្ថខេត្ត ហើយបញ្ជូនទៅសាលាដំបូងខេត្តចាត់ការតាមនីតិវិធីច្បាប់ ចំណែកពលករទាំង២៥នាក់ ត្រូវបានដាក់ឲ្យនៅធ្វើចត្តាឡីស័កក្នុងវិទ្យាល័យស្រុកម៉ាឡៃឲ្យបានចំនួន១៤ ថ្ងៃទើប អាចឲ្យត្រឡប់ទៅផ្ទះវិញបាន៕ **ដោយ ៖ វ៉ាន់ ណាង**

## កម្លាំងចម្រុះល្បាតតាមព្រំដែនឃាត់ខ្លួនពលករខ្មែរ២៦នាក់លួចឆ្លងដែនចូលទៅថៃខុសច្បាប់

http://nokorwatnews.com/ 12/05/2021

ខេត្តបន្ទាយមានជ័យ៖ ពលករខ្មែរប្រុសស្រីចំនួន២៦នាក់បានចាញ់បោកមេខ្យល់រួចនាំគ្នាលួចឆ្លងដែនខុស ច្បាប់ចូលទឹកដីថៃកាលពីយប់ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១នេះត្រូវ កម្លាំងអន្តរាគមន៍ វរៈសេនាតូចថ្មើរជើងលេខ ៥១៤ រួមនឹងកងពលតូចថ្មើរជើងលេខ៥១ ដឹកនាំដោយលោកវរសេនីយ៍ទោ ប៉ែន សុគន្ធ មេបញ្ជាការ វរៈសេនាតូច ថ្មើរជើងលេខ៥១៤ សហការជាមួយកម្លាំង កងការពារព្រំដែនលេខ៥០៣ និង នគរបាលព្រំដែនគោកលេខ៩១១ និងនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំអូរបីជាន់ ចេញល្បាតនៅចំណុចគោលដៅ ភូមិជោគជ័យ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ប្រទះឃើញក៏បានធ្វើការឃាត់ខ្លួន។

មន្ត្រីយោធាដែលចូលរួមប្រតិបត្តិការតាមព្រំដែននេះបានឲ្យដឹងថាពលករខ្មែរប្រុសស្រីចំនួន ២៦នាក់ បាន ចាញ់បោកមេខ្យល់បម្រុងលួចឆ្លងដែនពីប្រទេសកម្ពុជា ចូលទៅប្រទេសថៃ តាមតំបន់ហាមឃាត់ ទើបសមត្ថកិច្ច ឃាត់ខ្លួននៃម្តង។ ក្រោយឃាត់ខ្លួនបានសួរនាំរួចរាល់មកពលករទាំងអស់នេះត្រូវកម្លាំងសមត្ថកិច្ចដឹកបញ្ជូនទៅធ្វើ ចត្តាឡីស័ក រយៈពេល១៤ថ្ងៃនៅស្រុកអូរជ្រៅដើម្បីរកមេរោគកូវីដ-១៩សិន៕

## សមត្ថកិច្ចបាត់ដំបង ឃាត់ខ្លួនមេខ្យល់ ០៣នាក់ បម្រុងនាំពលករ ១៤នាក់ លួចឆ្លងដែនទៅថៃ

https://news.btv.com.kh/ 05/11/2021 06:05 PM

បាត់ដំបង៖ កម្លាំងនគរបាលការពារព្រំដែនគោកលេខ៨១៩ បានចុះបង្ក្រាបបទល្មើសប្រុងលួចនាំពលករ ចំនួន ១៤នាក់ ឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ ចំនួន ០២ករណី នៅចំណុចភូមិសាស្ត្រស្រុកកំរៀង ខេត្តបាត់ ដំបង ដោយបានឃាត់ខ្លួនមេខ្យល់ចំនួន ០៣នាក់។

លោកវរសេនីយ៍ឯក ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៩ បានឲ្យដឹងថា ប្រតិបត្តិការណ៍លួចនាំពលករឆ្លងដែនខុសច្បាប់នេះ ធ្វើឡើងនៅវេលាម៉ោងជាង១០ យប់ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១។

លោកស្រី រស់ ជីវី ស្នងការរងនគរបាលខេត្តបាត់ដំបង ទទួលបន្ទុកការងារជួញដូរមនុស្ស បានឲ្យដឹងថា ក្រោយទប់ស្កាត់បាន កម្លាំងការពារព្រំដែន បានបញ្ជូនមកកាន់ស្នងការនគរបាលខេត្ត ដើម្បីរៀបចំសំណុំរឿងបញ្ជូនទៅកាន់តុលាការ ចាត់ការតាមច្បាប់៕ អត្ថបទ៖ បាន សុខរិទ្ធ

## ពលករ មកពីថៃ ៤នាក់ទៀត រកឃើញឆ្លងកូវីដ១៩ ពេលមកដល់ខេត្តបាត់ដំបង

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១

(ខេត្តបាត់ដំបង)៖ រដ្ឋបាលខេត្តបាត់ដំបង បានប្រកាសថា លទ្ធផលវិភាគវត្ថុសំណាក រកវីរុសកូវីដ១៩ នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ បានរកឃើញអ្នកជំងឺកូវីដ១៩ ចំនួន ៤នាក់ ជាពលករ វិលត្រឡប់មកពីប្រទេសថៃ។ ពលករទាំង ៤នាក់ មានអាយុចាប់ពី ២០ឆ្នាំ ដល់ ៥៩ឆ្នាំ មានស្រុកកំណើតនៅស្រុបវេល និងស្រុកសំពៅលូន ខេត្តបាត់ដំបង បានវិលត្រឡប់មកពីប្រទេសថៃ ហើយត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័កកម្រិត១ នៅក្នុងវិទ្យាល័យពេជ្រចិន្តា ក្នុងស្រុកភ្នំព្រឹក។ រដ្ឋបាលខេត្តបាត់ដំបង បានប្រកាសថា ចាប់ផ្តើមពីមានការឆ្លងរាលដាលជំងឺកូវីឌ១៩ ខេត្តបាត់ដំបង មានអ្នកជំងឺកូវីដ១៩ ចំនួន ៧១នាក់។ ក្នុងនោះ បានព្យាបាលជាសះស្បើយ ២៩នាក់ និងកំពុងសម្រាកព្យាបាល ៤២នាក់៕

## ថៃបញ្ជូនពលករចំណាកស្រុកកម្ពុជាចំនួន ១៣ នាក់មកកម្ពុជាវិញ បន្ទាប់ពីកងល្បាតតាមព្រំដែនចាប់ខ្លួនបាន

https://www.khmertimeskh.com/ ខ្មែរថាមស៍ May 12, 2021

កងល្បាតព្រំដែនថៃសហការជាមួយសមភាគីកម្ពុជា បានរកឃើញការឆ្លងដែនខុសច្បាប់របស់ពលករខ្មែរចំនួន ១៣ នាក់ដែលត្រូវបានគេរត់ពន្ធចូលទៅក្នុងប្រទេសថៃ។ ពលរដ្ឋខ្មែរទាំង ១៣ នាក់ត្រូវបានបញ្ជូនទៅធ្វើការនៅថ្ងៃទី ១១ ឧសភា នៅចំណុចភូមិប៉ារ៉ៃ ឃុំប៉ារ៉ៃ ស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ ប្រទេសថៃ។ ពលករទាំង ១៣ នាក់ឥឡូវត្រូវបានបញ្ជូនទៅកន្លែងធ្វើចត្តាឡីស័ក និងយកសំណាក របស់ពួកគេ ទៅធ្វើតេស្តរកកូវីដ-១៩ ។ ទោះបីមានការបិទព្រំដែនទាំងអស់រវាងប្រទេសថៃ និងកម្ពុជាក៏ដោយ ក៏អ្នករត់ពន្ធមនុស្សនៅតែព្យាយាមរត់ពន្ធពលករឆ្លងកាត់ព្រំដែនកម្ពុជាចូលទៅក្នុងប្រទេសថៃ និងពីប្រទេសថៃមកកម្ពុជា។ មនុស្សជាច្រើនត្រូវបានគេរកឃើញនិងចាប់បាន ហើយអ្នកខ្លះបានធ្វើតេស្តមានវិជ្ជមានកូវីដ-១៩៕

# ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១

## លោក ណុប ដារ៉ា ណែនាំកម្លាំងឈរជើង ប្រចាំការតាមច្រកព្រំដែនត្រូវពង្រឹងត្រួតពិនិត្យ ការចេញ-ចូលរបស់ពលរដ្ឋដើម្បីទប់ស្កាត់ការឆ្លងដែនខុសច្បាប់

https://dap-news.com/international/ BySS107 Posted on May 13, 2021

ភ្នំពេញ៖ ក្នុងកិច្ចប្រជុំពង្រឹងក្រុមការងារ ដែលឈរជើងត្រួតពិនិត្យការចេញ-ចូល របស់ប្រជាពលរដ្ឋនៅច្រកទ្វារព្រំដែនអន្តរជាតិដូង ស្ថិតនៅក្នុងស្រុកកំរៀង ខេត្តបាត់ដំបងនាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ លោក ណុប ដារ៉ា អភិបាលខេត្តបាត់ដំបង និងជាប្រធានគណៈកម្មការស្រាវជ្រាវបង្ក្រាបបទល្មើសឆ្លងដែនគ្រប់ប្រភេទ ក្នុងភូមិសាស្ត្រខេត្តបាត់ដំបង បានធ្វើការណែនាំកម្លាំងឈរជើងប្រចាំការ តាមច្រកព្រំដែនត្រូវពង្រឹងត្រួតពិនិត្យ ការចេញ-ចូល

របស់ពលរដ្ឋដើម្បីទប់ស្កាត់ការឆ្លងដែនខុសច្បាប់ ក៏ដូចជាការចូលរួមទប់ស្កាត់ការឆ្លងជំងឺកូវីដ-១៩ ពីប្រទេសជិតខាងមកប្រទេសកម្ពុជា ។

នៅក្នុងកិច្ចប្រជុំនេះលោក ណុប ដារ៉ា បានសង្កត់ធ្ងន់ថា «បើសិនជាស្រាវជ្រាវរកឃើញមន្ត្រីណាម្នាក់ ដែលឈរជើងនៅទីនេះមានការឃុបឃិតគ្នាជាមួយមេខ្យល់នាំពលករឆ្លងដែនខុសច្បាប់លោក នឹងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ ដើម្បីសុំការដកមន្ត្រីនោះយក ទៅអនុវត្តតាមច្បាប់ដោយគ្មានការលើកលែងឡើយ»។ បន្ទាប់ពីប្រជុំចប់លោកណុប ដារ៉ា បានអញ្ជើញចុះត្រួតពិនិត្យតាមច្រករបៀងក្នុងភូមិសាស្ត្រស្រុកកំរៀង ខេត្តបាត់ដំបង៕

## នគរបាលស្រុកសំឡូតនិងស្រុកកំរៀងចុះទប់ស្កាត់ករណី ឆ្លងដែនខុសច្បាប់ទៅថៃ២លើក ឃាត់ខ្លួនមេខ្យល់៤នាក់ និងពលរដ្ឋខ្មែរ២៣នាក់អប់រំណែនាំ

http://cambodiapolice.com/policekh/ 1:53 pm 13 ឧសភា 2021

បាត់ដំបង ៖ កម្លាំងអធិការដ្ឋាននគរបាលស្រុកភ្នំព្រឹក និងស្រុកកំរៀង បានធ្វើការទប់ស្កាត់ប្រជាពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់ទៅថៃ ចំនួន០២លើក ឃាត់ខ្លួនមេខ្យល់ចំនួន០៤នាក់ បញ្ជូនទៅសាលាដំបូងខេត្ត និងឃាត់ខ្លួនពលរដ្ឋខ្មែរចំនួន២៣នាក់ ស្រី៣នាក់ធ្វើការអប់រំ ។

ប្រតិបត្តិការនេះ សមត្ថកិច្ចធ្វើនៅចំណុចកងអនុសេនាតូចលេខ៣ ចំណុះផ្នែកសឹករងស្រុកភ្នំព្រឹក ស្ថិតក្នុងភូមិភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង វេលាម៉ោង០៥និង៥៥នាទី ដោយកម្លាំងនគរបាលស្រុកភ្នំព្រឹកសហការជាមួយកម្លាំងវរៈសេនាតូចនគរបាលការពារព្រំដែនគោក៨១៩ និងកម្លាំងផ្នែកសឹករងស្រុកភ្នំព្រឹក បានទទួលពលករលួចឆ្លងដែនខុសច្បាប់ ចំនួន ១៩នាក់ ស្រី ០១នាក់ និងបានបញ្ជូនទៅមណ្ឌលចត្តាឡីស័ក កម្រិត១ វិទ្យាល័យពេជ្រចិន្តា ស្រុភ្នំព្រឹក។ ក្រោយពីកម្លាំងសមត្ថកិច្ចយើងធ្វើការសាកសួរពលករ ទាំង១៩នាក់ខាងលើរួចសមត្ថកិច្ចបានឃាត់ខ្លួនជនសង្ស័យចំនួន ០១នាក់ឈ្មោះ ផូ ផាត ហៅ តែ ភេទប្រុស អាយុ៣៨ឆ្នាំ រស់នៅភូមិសាមគ្គី ឃុំព្រែកញ្ជៀ ស្រុកពារាំង ខេត្តព្រៃវែង ពាក់ព័ន្ធករណីនាំចេញដោយមិនស្របច្បាប់ ។

ឆ្លងតាមចម្លើយសារភាពរបស់ជនសង្ស័យឈ្មោះ ផូ ផាត ហៅ តែ ភេទប្រុស អាយុ៣៨ឆ្នាំ និងមានការអនុញ្ញាតផ្នែកនីតិវិធីពី ឯកឧត្តម គី ប៊ុណ្ណារ៉ា ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តបាត់ដំបង នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង១៨និង០០នាទី នៅចំណុចភូមិភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង កម្លាំងនគរបាលស្រុកបានបន្តឃាត់ខ្លួនជនសង្ស័យចំនួន០១នាក់ទៀតឈ្មោះ សា ផាត ភេទស្រី អាយុ ៦៤ឆ្នាំ មុខរបរកម្មករ រស់នៅភូមិភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ។

នៅថ្ងៃដដែល វេលាម៉ោង១៦និង៣០នាទី សមត្ថកិច្ចចម្រុះប្រចាំនៅគោលដៅតាមផ្លូវជាតិលេខ៥៩ ក្នុងភូមិស្វាយវែង ឃុំកំរៀង ស្រុកកំរៀង ខេត្តបាត់ដំបង បានប្រគល់ពលករចំនួន០៤នាក់ ស្រី០២នាក់ និងជនសង្ស័យចំនួន ០២នាក់ ម៉ូតូ០២ គ្រឿង ប្រគល់មកឱ្យជំនាញដើម្បីស្រាវជ្រាវបន្ត។

សមត្ថកិច្ចបានធ្វើការឃាត់ខ្លួនអប់រំពលករបំរុងនឹងឆ្លងដែនខុសច្បាប់ចំនួន ០៤នាក់ ១.ឈ្មោះ គ្រឹង ឆេងហ៊ាង ភេទប្រុស អាយុ ២៦ឆ្នាំ ២.ឈ្មោះ ចាន់ វិច្ឆ័រ៉ា ហោ ម៉ៅ ភេទស្រី អាយុ ១៨ឆ្នាំ ៣.ឈ្មោះ ស៊ីម យ៉េភេទស្រី អាយុ ១៩ឆ្នាំ អ្នកទាំងបីរស់នៅភូមិកំពង់រាប ឃុំកំពង់រាប ស្រុកព្រែកប្បាស ខេត្តតាកែវ និង៤.ឈ្មោះ ជុន ជីវៈ តាមរយៈមេខ្យល់នាំចេញមនុស្សខុសច្បាប់ចំនួន ២នាក់ ១.ឈ្មោះ ហ៊ុន យ៉ាត ភេទប្រុស អាយុ ៣៦ឆ្នាំ និង២.ឈ្មោះ ហែម សុផល ហៅ ប្រុញ ភេទប្រុស អាយុ ៥៥ឆ្នាំ រស់នៅភូមិផ្សារព្រំ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន។

ករណីខាងលើនេះ កម្លាំងនគរបាលជំនាញបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្តបាត់ដំបង ដើម្បីចាត់ការបន្តតាមនីតិវិធីច្បាប់ ៕

## សមត្ថកិច្ចនគរបាលជំនាញស្រុកភ្នំព្រឹកតាមប្រម៉ាញ់ស្រាវជ្រាវឃាត់ខ្លួនមេខ្យល់ ២នាក់ ក្រោយចំពានច្បាប់នាំពលករចំនួន ១៩នាក់ឆ្លងដែនចូលក្នុងទឹកដីថៃ

http://nokorwatnews.com/ 13-05-2021

ខេត្តបាត់ដំបង៖ លោក សុង សុភ័ក្រ្ត អភិបាលស្រុកភ្នំព្រឹក និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលស្រុក បានប្រាប់ឲ្យដឹងថា ក្រោយពីកម្លាំងចម្រុះដែលឈរជើងតាមខ្សែបន្ទាត់ព្រំដែនបានឃាត់ខ្លួនពលករ សរុបចំនួន ១៩នាក់មកសាកសួរ និងស្រាវជ្រាវទើបបែកធ្លាយដឹងថា ក្នុងចំណោមពលករខ្មែរទាំង ១៩នាក់ ខាងលើក៏មានមេខ្យល់ចំនួន ២នាក់ផងដែរ ដែលឃាត់ខ្លួនកាលពីថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០២១ ត្រង់ចំណុចភូមិភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។

ពលករខ្មែរដែលមានបំណងឆ្លងដែនចូលក្នុងទឹកដីថៃនេះត្រូវសមត្ថកិច្ចឃាត់ខ្លួនរួចបំពេញបែបបទបញ្ជូនទៅឲ្យធ្វើចត្តាឡីស័ក។ ចំណែកឯជនសង្ស័យជាមេខ្យល់មានឈ្មោះផូ ផាត ហៅតៃ ភេទប្រុស អាយុ ៣៨ឆ្នាំ រស់នៅក្នុងភូមិសាមគ្គី ឃុំព្រែកញ្ចៀ ស្រុកពាមាំង ខេត្តព្រៃវែង និងម្នាក់ទៀតឈ្មោះសា ផាត ភេទស្រី អាយុ ៦៤ឆ្នាំ មុខរបរកម្មករ មានទីលំនៅក្នុងភូមិភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង អ្នកទាំង ២នាក់ត្រូវបានសមត្ថកិច្ចជំនាញកសាងសំណុំរឿងបញ្ជូនទៅកាន់លាសាដំបូងខេត្តដើម្បីអនុវត្តតាមនីតិវិធី៕

## ពលករឆ្លងដែនខុសច្បាប់ចំនួន១៩នាក់ប្រុសស្រីបានចូលទៅប្រទេសថៃត្រូវសមត្ថកិច្ចឃាត់ខ្លួនសួរនាំរួចបញ្ជូនទៅមណ្ឌលចត្តាឡីស័កនៅវិទ្យាល័យពេជ្រចិន្តាស្រុកភ្នំព្រឹក

http://nokorwatnews.com/ 13-05-2021

ខេត្តបាត់ដំបង៖ យោងតាមរបាយការណ៍របស់សមត្ថកិច្ចឈរជើងតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃបានប្រាប់ឲ្យដឹងថា នៅវេលាម៉ោង ៤:០០នាទីទៀបភ្លឺ ថ្ងៃទី១២ ខែឧសភាឆ្នាំ២១២១ កម្លាំងចម្រុះឈរជើងតាមខ្សែបន្ទាត់ព្រំដែន សហការជាមួយសមត្ថកិច្ចថៃ បាននាំខ្លួនពលករប្រុសស្រីដែលនាំគ្នាឆ្លងដែនចូលទៅកាន់ប្រទេសថៃដោយខុសច្បាប់សរុបចំនួន ១៩នាក់ នៅត្រង់ចំណុចភូមិភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។

លោក សុង សុភ័ក្រ្ត អភិបាលស្រុកភ្នំព្រឹកបានបញ្ជាក់ឲ្យដឹងដែរថា៖ ពលករខ្មែរដែលឆ្លងដែនខុសច្បាប់ខាងលើនេះមានចំនួន ១៩នាក់ ក្នុងចំណោមនេះក៏មានស្ត្រី ១នាក់ផងដែរ។ អ្នកទាំងអស់គ្នាមកពីខេត្តត្បូងឃ្មុំចំនួន ៦នាក់. ខេត្តព្រៃវែង ៧នាក់ និងមកពីខេត្តកំពង់ឆ្នាំងចំនួន ៦នាក់។

គួររំលឹកដែរថា ក្រោយការសាកសួរអាជ្ញាធរមានសមត្ថកិច្ចបានប្រគល់ពលករទាំង ១៩នាក់ ទៅឲ្យក្រុមគ្រូពេទ្យ ដើម្បីបញ្ជូនទៅមណ្ឌលចត្តាឡីស័កកម្រិត ១ វិទ្យាល័យពេជ្រចិន្តា ស្រុកភ្នំព្រឹកពិនិត្យសុខភាព យកវត្ថុសំណាក ហើយនិងបន្តស្រាវជ្រាវរកមុខមេខ្យល់ បន្ថែមទៀតដើម្បីអនុវត្តតាមនីតិវិធី៕

## ប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ២០នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃព្រហស្បតិ៍ ទី១៣ ខែឧសភា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមាន

ជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ២០នាក់ ស្រី ១២នាក់ ក្នុងនោះ កុមារា ១នាក់ កុមារី ១នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១៤នាក់ ស្រី ៨នាក់ កុមារា ១នាក់ កុមារី ១នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់៖ ចំនួន ២នាក់ ស្រី ១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង៖ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារា ចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ៖ ចំនួន ៤នាក់ ប្រុសចំនួន ០០នាក់ ស្រីចំនួន ៣នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ២០នាក់ ស្រី ១២នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែន នីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## បញ្ជូនខ្លួនជនសង្ស័យ ០៥នាក់ ទៅសាលាដំបូងខេត្ត ពីបទនាំផ្លូវ ដឹកជញ្ជូនពលករឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ

https://www.gntimes.com/ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១

បន្ទាយមានជ័យ៖ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ នៅថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០២១ បានបញ្ជូនជនសង្ស័យ ០៥នាក់ ក្នុងនោះ ០២នាក់ ឃាត់ខ្លួននៅស្រុកអូរជ្រៅ និង ០៣នាក់ ទៀតឃាត់នៅស្រុកស្វាយចេក បញ្ជូនទៅសាលាដំបូងខេត្ត ។ ក្នុងចំណោមជនសង្ស័យទាំង ៥នាក់ នោះ ០២នាក់ ពីបទដឹកជញ្ជូននិងនាំជនជាតិថៃចំនួន ០៥នាក់ ស្រី ០១នាក់ ឆ្លងពីថៃគេចសមត្ថកិច្ចខ្មែរ នៅតាមបន្ទាត់ព្រំដែនទៅប៉ោយប៉ែត ដើម្បីបញ្ចៀសការធ្វើចត្តាឡីស័កនិង ០៣នាក់ទៀត ពីបទដឹកជញ្ជូនពលករខ្មែរចំនួន ០៦នាក់ ស្រី ០២នាក់ ដោយម៉ូតូចំនួន ០៣គ្រឿង ទៅថៃដោយខុសច្បាប់ ។

លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ បានប្រាប់ឲ្យបណ្ដាញ GNtimes ឲ្យដឹងថា៖ ជនសង្ស័យ ០២នាក់ ទី១-ឈ្មោះ ថូវ ឈឿង ហៅ តាឃ្វាលគោ ភេទប្រុសអាយុ ៦២ឆ្នាំ ពាក់ព័ន្ធនាំជនជាតិថៃចូលមកខ្មែរ និងទី២-ឈ្មោះ សោភ័ណ សតវត្ស ភេទប្រុស អាយុ ២១ឆ្នាំ បើកបររថយន្ត ០១ គ្រឿង ម៉ាកនីសាន់ ពណ៌ទឹកប្រាក់ ពាក់ស្លាកលេខ កំពង់ឆ្នាំង 2A-0130 បានទទួលដឹកជនជាតិថៃចំនួន ០៥នាក់ ពីឈ្មោះ ថូវ ឈឿង ទៅប៉ោយប៉ែត ដោយក្នុងម្នាក់ តម្លៃ ១,០០០បាត ។ ទាំងជនជាតិថៃ និងអ្នកនាំផ្លូវ រួមទាំងអ្នកដឹកជញ្ជូន ត្រូវបានកម្លាំងសមត្ថកិច្ចនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ ៩១១ ប្រចាំការគោលដៅសិលាខ្មែរ ក្នុង ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ឃាត់ខ្លួនតាំងពីថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០២១ ។

លោកស្នងការនគរបាលខេត្ត ក៏បានប្រាប់បន្តថា៖ ជនជាតិថៃទាំងនោះ ក្រោយពីឃាត់ខ្លួនបានប្រគល់ឲ្យសមត្ថកិច្ចថៃវិញ ។ រីឯជនសង្ស័យទាំង ០២នាក់ ឈ្មោះ ថូវ ឈឿង និងឈ្មោះ សោភ័ណ សតវត្ស ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័ក រយៈពេល ១៤ថ្ងៃ ក្រោយពីបញ្ចប់ធ្វើចត្តាឡីស័ក (ពុំមានមេរោគកូវីដ -១៩) នៅថ្ងៃទី ១១ ខែឧសភា ម្សិលមិញ ជនទាំង ០២នាក់ ត្រូវបញ្ជូនទៅការិយាល័យជំនាញប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ចាត់ចែងកសាងសំណុំរឿងតាមនិតិវិធីច្បាប់ ។ លោក ក៏បានបន្តឲ្យដឹងទៀតថា ដោយមានការសម្របសម្រួលពីឯកឧត្តម មាស ច័ន្ទពិសិទ្ធ ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ នៅថ្ងៃទី ១១ ខែ ឧស

ភា នេះ វេលាម៉ោងជាង ១១ព្រឹក កម្លាំងនគរបាល ស្រុកស្វាយចេក ឈរជើងនៅមុខក្លោងទ្វារចូលវត្តតេជោភ្នំធំត្រ បានសហការជាមួយកម្លាំងយោធាព្រំដែនគោក ធ្វើការឃាត់ខ្លួនជនសង្ស័យចំនួន ០៣នាក់ ម៉ូតូចំនួន ០៣គ្រឿង បានដឹកជញ្ជូនពលករខ្មែរចំនួន ០៦នាក់ (ស្រី០២នាក់) ដើម្បីឆ្លងដែនទៅប្រទេសថៃ ។

ជនសង្ស័យទាំង ០៣ នាក់ មានឈ្មោះ ១-រ៉ន ហ៊ីង ភេទប្រុស អាយុ ២៩ឆ្នាំ , ២- ឈ្មោះ សុខ អេង ភេទប្រុស អាយុ ២៧ឆ្នាំ នៅភូមិ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ , ៣-ឈ្មោះ មាស ង៉ែត ភេទប្រុសអាយុ ៣៦ឆ្នាំ នៅភូមិបន្ទាយថ្មី ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ជាមួយគ្នានោះដែរសមត្ថកិច្ចបានដកហូតម៉ូតូចំនួន ០៣គ្រឿង ដែលដឹកជញ្ជូនពលករផងដែរ ។ ក្រោយពីសួរចម្លើយជនសង្ស័យទាំង ០៣នាក់ បានសារភាពថា៖ ពួកគេធ្លាប់ដឹកពលករខ្មែរចំនួន ០៧លើក រួចមកហើយ មានពលករសរុប ១៤នាក់ (ស្រី ០៣នាក់) ពីភូមិសាស្ត្រភូមិអូរបីជាន់ ស្រុកអូរជ្រៅ មកចំណុចឃាត់ខ្លួន ក្នុងចំការស្វាយចន្ទី ក្នុងភូមិសាស្ត្រ ភូមិល្បើកស្វាយ ឃុំស្វាយចេក ស្រុកស្វាយចេកនេះ ដោយយកតម្លៃ ០១នាក់ ចំនួន ៥០,០០០រៀល ។ ក្នុងនោះ១-ឈ្មោះ រ៉ន ហ៊ីងបានសារភាពថា គេធ្លាប់ដឹកពលករខ្មែរទៅថៃចំនួន ០២លើករួចមកហើយ សរុប ០៤នាក់ និងទី២-ឈ្មោះ សុខ អេង បានសារភាពថា គេធ្លាប់ដឹកពលករខ្មែរទៅថៃចំនួន ០២លើក រួចមកហើយដែរ សរុប ០៤នាក់ ស្រី ០២នាក់ និងទី៣-ឈ្មោះ មាស ង៉ែត ក៏បានសារភាពថា គេធ្លាប់ដឹកពលករខ្មែរទៅថៃចំនួន ០៣លើក រួចមកហើយសរុប ០៦នាក់ (ស្រី០១នាក់) ។

ក្រោយពីសួរចម្លើយរួច នគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្ត បានបញ្ជូនខ្លួនជនសង្ស័យ ០៥នាក់ ទៅសាលាដំបូងខេត្តចាត់ការបន្តតាមនីតិវិធី ៕

## មេបញ្ជាការភូមិភាគ៥ជំរុញដល់កងកម្លាំងឈរជើងតាមបន្ទាត់ព្រំដែន ត្រូវពង្រឹងការទប់ស្កាត់ការចម្លងវីករាលដាល ជំងឺកូវីដ-១៩ មកពីក្រៅប្រទេស

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០២១ មន្ទីរព័ត៌មានខេត្តប៉ៃលិន

ប៉ៃលិន ៖ ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ ឯកឧត្តមឧត្តមសេនីយ៍ឯក ឯក សំអួន មេបញ្ជាការរងកងទ័ពជើងគោក និងជាមេបញ្ជាការ យោធភូមិភាគទី៥ និងលោក ហុក សុផល អភិបាលរងខេត្ត បានអញ្ជើញដឹកនាំកិច្ចប្រជុំត្រួតពិនិត្យការងារយោធា នៅទីបញ្ជាការមុខ ទិសទី៣ ប៉ៃលិន-សំឡូត ស្តីពីការពង្រឹងសន្តិសុខនៅតាមបន្ទាត់ព្រំដែន និងទប់ស្កាត់បទល្មើសឆ្លងដែនខុសច្បាប់នានា ជាពិសេស បេសកកម្មទប់ស្កាត់ការចម្លងរីករាលដាលជំងឺកូវីដ-១៩ ពីក្រៅប្រទេស។

លោក ហុក សុផល អភិបាលរងខេត្ត និងជាតំណាងដ៏ខ្ពស់របស់លោកជំទាវ បាន ស្រីមុំ អភិបាលខេត្តប៉ៃលិន បានមានប្រសាសន៍ លើកឡើងថា៖ បច្ចុប្បន្នរដ្ឋបាលខេត្តប៉ៃលិនបានយកចិត្តទុកដាក់ខ្ពស់លើវិធានការទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍ ព្រមទាំងការនាំចូលពីក្រៅប្រទេស ដោយបានដាក់កម្លាំងសមត្ថកិច្ចទាំងបីប្រភេទ និងក្រុមគ្រូពេទ្យជំនាញប្រចាំការ ២៤/២៤ម៉ោង ដើម្បីពង្រឹងសន្តិសុខនៅតាមបន្ទាត់ព្រំដែន និងទប់ស្កាត់រាល់បទល្មើសឆ្លងដែនខុសច្បាប់នានា ជាពិសេសបេសកកម្ម ទប់ស្កាត់ការចម្លងរីករាលដាលជំងឺកូវីដ-១៩ ពីក្រៅប្រទេស។

ឯកឧត្តមឧត្តមសេនីយ៍ឯក ឯក សំអួន មេបញ្ជាការរងកងទ័ពជើងគោក និងជាមេបញ្ជាការយោធភូមិភាគទី៥ បានមានប្រសាសន៍លើកឡើងថា៖ ការពង្រឹងសន្តិសុខ និងសមត្ថកិច្ចតាមព្រំដែន គឺជាការអនុវត្តន៍តាមការណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេចតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រី ឲ្យបណ្តាខេត្តដែលមានព្រំដែន ជាប់នឹងប្រទេសជិតខាង ត្រូវមានការយកចិត្តទុកដាក់ឲ្យបានខ្ពស់ ចំពោះ ការរីករាលដាលជំងឺឆ្លងកូវីដ-១៩ ពីក្រៅប្រទេស ជាពិសេសព្រំដែនកម្ពុជា-ថៃ ដែលមានហានិភ័យខ្ពស់ ចំពោះពលករខ្មែរចំណាកស្រុក ហើយកន្លងមក

ខេត្តប៉ៃលិន ក៏បានរកឃើញពលករដែលឆ្លងដែនមកពីប្រទេសថៃ មានវិជ្ជមានជំងឺកូវីដ-១៩ ផងដែរ។ ឯកឧត្តម ឧត្តមសេនីយ៍ឯក ក៏បានមានប្រសាសន៍ជំរុញដល់កម្លាំងចម្រុះទាំងអស់ និងមន្ត្រីប្រចាំការនៅតាមច្រកទ្វារព្រំដែន ត្រូវធ្វើយ៉ាង ណាខិតខំតាមដានរាល់សភាពការណ៍ នៃការឆ្លងដែនរបស់ពលករខ្មែរ និងត្រូវប្រចាំការ ២៤ម៉ោង/២៤ ម៉ោង តាមគោលដៅដែលខ្លួន ទទួលខុសត្រូវ ហើយបើមានពលករឆ្លងដែនមក មន្ត្រីជំនាញសុខាភិបាលត្រូវពិនិត្យ សុខភាព និងធ្វើចត្តាឡីស័ក ១៤ថ្ងៃសិន ដើម្បីទប់ស្កាត់ ការចម្លងរីករាលដាលជំងឺកូវីដ-១៩ មកពីក្រៅប្រទេស។

នៅក្នុងឱកាសនោះផងដែរ ឯកឧត្តម ឯក សំអួន បានកោតសរសើរដល់រដ្ឋបាលខេត្តប៉ៃលិន ដែលមាន លោកជំទាវ បាន ស្រីមុំ ជាអភិបាលខេត្ត បានជួយសម្របសម្រួល និងសហការល្អជាមួយកងកម្លាំង ដែលកំពុងឈរ ជើងតាម ខ្សែបន្ទាត់ព្រំដែន ព្រមទាំងបាន ជួយឧបត្ថម្ភគាំទ្រ និងលើកទឹកចិត្ត រួមសុខរួមទុក្ខ ជាមួយកងកម្លាំងគ្រប់ ពេលវេលា ដើម្បីបំពេញបេសកកម្មបម្រើជាតិ និងប្រជាជន។

បើតាមរបាយការណ៍របស់លោកឧត្តមសេនីយត្រី ទី សុខា មេបញ្ជាការទិសទី៣ ប៉ៃលិន-សំឡូត បានឲ្យដឹង ថា៖ កងកម្លាំងចម្រុះ បានប្រចាំការនៅតាមខ្សែបន្ទាត់ព្រំដែន និងតាមច្រកជម្មជាតិ ដើម្បីពង្រឹងសន្តិសុខនៅតាម បន្ទាត់ព្រំដែន និងទប់ស្កាត់បទល្មើស ឆ្លងដែនខុសច្បាប់នានា ជាពិសេសបេសកកម្មទប់ស្កាត់ការចម្លងរីករាលដាល ជំងឺកូវីដ-១៩ ពីក្រៅប្រទេស គឺមានចំនួន ២៥គោលដៅ ហើយប្រចាំការ ២៤/២៤ម៉ោង ដោយអនុវត្តយ៉ាងម៉ឺងម៉ាត់ តាមអនុសាសន៍របស់សម្តេចតេជោ ហ៊ុន សែន និងវិធានការនានា របស់ក្រសួង សុខាភិបាល៕

## ទទួលពលករខ្មែរ១៩នាក់ពីសមត្ថកិច្ចថៃ ដែលឆ្លងដែនខុសច្បាប់និងរកឃើញមេខ្យល់២នាក់

http://khmeread.com/ May 13, 2021 12:54PM

បាត់ដំបង ៖ កងកម្លាំងចម្រុះឈរជើងតាមខ្សែបន្ទាត់ព្រំដែន សហការជាមួយសមត្ថកិច្ចថៃបាននាំខ្លួនពល ករប្រុស-ស្រី ដែលនាំគ្នាឆ្លងដែនចូលទៅកាន់ប្រទេសថៃ ដោយខុសច្បាប់សរុប១៩នាក់ ចាប់ពីវេលាម៉ោង៥ រហូត ដល់ម៉ោង៦ល្ងាច ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ នៅចំណុចភូមិសាស្ត្រទទួលខុសត្រូវ ដោយកងអនុសេនាតូច លេខ៣ ចំណុះផ្នែកសឹករងស្រុកភ្នំព្រឹក ស្ថិតក្នុងភូមិភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ខណៈនៅ ប្រទេសថៃកំពុងឆ្លងរីករាលដាលជំងឺកូវីដ-១៩។ បន្ទាប់មកសមត្ថកិច្ចស្រាវជ្រាវរកឃើញមេខ្យល់២នាក់។

សមត្ថកិច្ចនិយាយថា ពលករខ្មែរដែលឆ្លងដែនខុសច្បាប់ខាងលើនេះមាន១៩នាក់ ក្នុងចំណោមនោះមាន ស្ត្រីម្នាក់។ អ្នកទាំងអស់គ្នាមកពីខេត្តត្បូងឃ្មុំ៦នាក់, ខេត្តព្រៃវែង ៧នាក់ និងមកពីខេត្តកំពង់ឆ្នាំង៦នាក់។ សមត្ថកិច្ច បានរកឃើញមនុស្សជាមេខ្យល់ ក្នុងការនាំឆ្លងដែនដោយខុសច្បាប់២នាក់រួមមាន ១-ឈ្មោះ ផូ ផាត ហៅតៃ ភេទ ប្រុស អាយុ៣៨ឆ្នាំ រស់នៅភូមិសាមគ្គី ឃុំព្រែកញ្ចៀ ស្រុកពារាំង ខេត្តព្រៃវែង និង២-ឈ្មោះ សា ផាត ភេទស្រី អាយុ ៦៤ឆ្នាំ មុខរបរកម្មកររស់នៅភូមិភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។

ក្រោយពេលសាកសួរ និងអនុវត្តតាមបទបញ្ជារបស់ លោក គី ប៊ុណ្ណារ៉ា ព្រះរាជអាជ្ញានៃអយ្យការអមសាលា ដំបូងខេត្តបាត់ដំបង ប៉ូលិសស្រុកភ្នំព្រឹក បានរៀបចំកសាងសំណុំរឿងបញ្ជូនអនុវត្តតាមផ្លូវច្បាប់, ឯពលករ១៧នាក់ បាននាំយកទៅកាន់មណ្ឌលចត្តាឡីស័កកម្រិតទី១ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង អនុវត្តតាមវិធានសុខាភិបាលមុន នឹងមានចំណាត់ការបន្ត៕

## ពលករ១២នាក់ត្រឡប់មកពីប្រទេសថៃតាមផ្លូវកាត់ ត្រូវសមត្ថកិច្ចនាំទៅធ្វើចត្តាឡីស័ក

https://cambodiaflashnews.com/ by Mr Ratanak May 14, 2021 ដោយៈព្រះអង្គខ្មៅ

បាត់ដំបងៈ ពលករខ្មែរ ១២នាក់ នាំគ្នាត្រឡប់មកពីប្រទេសថៃ តាមផ្លូវកាត់ច្រករបៀង ត្រូវសមត្ថកិច្ចនាំខ្លួនទៅណែនាំនិងធ្វើចត្តាឡីស័កទប់ស្កាត់ជំងឺកូវីដ-១៩។

នគរបាលការពារព្រំដែនបានបញ្ជាក់ប្រាប់ឲ្យដឹងថាៈ អនុវត្តតាមផែនការ ស្តីពីការត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់ តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ នៅថ្ងៃទី ១៤ ខែឧសភា ឆ្នាំ២០២១ កម្លាំងចម្រុះបានចុះល្បាតនាំខ្លួនពលករខ្មែរចំនួន ១៣នាក់ ទៅអនុវត្តវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ជំងឺកូវីដ-១៩ពីខាងក្រៅចូលមកក្នុងប្រទេស។ ពលករទាំង ១៣នាក់ នៅថ្ងៃខាងលើបាននាំគ្នាលួចឆ្លងដែនដោយចេញពីទឹកដីថៃ ហើយចូលមកប្រទេសកំណើតវិញកាត់តាមត្រង់ចំណុចភូមិសាស្ត្រភូមិគីឡូលេខ ៩ ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។ ពលករខ្មែរទាំងអស់សរុបចំនួន ១៣នាក់ រួមមានៈ បុរសចំនួន ៤នាក់ ស្ត្រីចំនួន ៦នាក់ និងក្មេងប្រុសចំនួន ៣ នាក់ផងដែរទៅតាមឪពុកម្តាយដែលនាំគ្នាព្យាយាមគេចវេះមិនចូលធ្វើចត្តាឡីស័កក៏ត្រូវសមត្ថកិច្ចនាំខ្លួនតែម្តង។

បន្ទាប់ពីការសាកសួរ និងណែនាំអប់រំរួចរាល់ កម្លាំងការពារគោលដៅតំបន់ព្រំដែនបានប្រគល់ពលករទាំង ១៣នាក់ទៅឲ្យក្រុមគ្រូពេទ្យដើម្បីនាំយកទៅធ្វើចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ តាមវិធានសុខាភិបាល ក៏ដូចជារាជរដ្ឋាភិបាល៕

## កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ទទួលពលរដ្ឋខ្មែរចំនួន១៣នាក់ ត្រឡប់មកពីប្រទេសថៃ បញ្ជូនទៅធ្វើចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២

http://cambodiapolice.com/policekh/ 3:53 pm 14 ឧសភា 2021

ខេត្តបាត់ដំបង ៖ នៅថ្ងៃសុក្រ ៣កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី ១៤ ខែឧសភាឆ្នាំ ២០២១ តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្តីពីការត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ-ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ លោកវរសេនីយ៍ឯក ពៅ ថាវុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពាព្រំដែនគោកលេខ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ ជាមេបញ្ជាការ បានចាត់តាំងកម្លាំងប៉ុស្តិ៍នគរបាលព្រំដែនគីឡូ៩ សហការជាមួយកម្លាំងយោធាផ្នែកសឹករង ស្រុកសំពៅលូន, កម្លាំងយោធាវរសេនាតូចលេខ៥៣៣ និងកម្លាំងយោធាវរសេនាតូចលេខ១ ទៅទទួលប្រជាពលរដ្ឋត្រឡប់មកពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ ពីយោធាថៃកងអនុសេនាធំ ១៣០៥ ត្រង់ចំណុចនៃភូមិសាស្ត្រភូមិគីឡូ៩ ឃុំជ្រៃសីមា ស្រុកសំពៅលូន ចំនួន ១៣នាក់, ស្រី ៦នាក់ ក្នុងនោះក្មេងប្រុស៣នាក់ ។ បន្ទាប់ពីធ្វើការសាកសួររួច ក៏ធ្វើការអប់រំណែនាំ និងបាន ប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ តាមការណែនាំរបស់ក្រសួងសុខាភិបាល៕

# ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១

## អភិបាលរងខេត្តបាត់ដំបងៈ បើសិនជាស្រាវជ្រាវរកឃើញមន្ត្រីណាម្នាក់មានការឃុបឃិតគ្នាជាមួយមេខ្យល់នាំពលករឆ្លងដែនខុសច្បាប់ នឹងអនុវត្តតាមច្បាប់ដោយគ្មានការលើកលែង

http://www.akp.gov.kh/kh/ AKP បាត់ដំបង ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១

លោក ណុប ដារ៉ា អភិបាលរងខេត្តបាត់ដំបង និងជាប្រធានគណៈកម្មការស្រាវជ្រាវបង្ក្រាបបទល្មើសឆ្លងដែនគ្រប់ប្រភេទ ក្នុងភូមិសាស្ត្រខេត្តបាត់ដំបងបានគូសបញ្ជាក់ថា បើសិនបើស្រាវជ្រាវរកឃើញមន្ត្រីណាម្នាក់ដែលឈរជើងនៅទីនេះមានការឃុបឃិតគ្នាជាមួយមេខ្យល់ នាំពលករឆ្លងដែនខុសច្បាប់លោកនឹងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ ដើម្បីសុំការដកមន្ត្រីនោះ នឹងអនុវត្តន៍ទៅតាមច្បាប់ដោយគ្មានការលើកលែងឡើយ។

ការគូសបញ្ជាក់របស់អភិបាលរងខេត្តនេះ បានធ្វើឡើងក្នុងកិច្ចប្រជុំពង្រឹងក្រុមការងារដែលឈរជើងត្រួតពិនិត្យការចេញ-ចូលរបស់ប្រជាពលរដ្ឋនៅច្រកទ្វារព្រំដែនអន្តរជាតិដូង ស្ថិតនៅក្នុង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១។ លោក ណុប ដារ៉ា បានសង្កត់ធ្ងន់ទៅលើបញ្ហាតួនាទី ភារកិច្ចរបស់កម្លាំងដែលកំពុងឈរជើងត្រួតពិនិត្យការចេញ-ចូលរបស់ប្រជាពលរដ្ឋដើម្បីចូលរួមទប់ស្កាត់ការឆ្លងដែនខុសច្បាប់ ក៏ដូចជាការចូលរួមទប់ស្កាត់ការឆ្លងជំងឺកូវីដ-១៩ពីប្រទេសជិតខាងមកប្រទេសកម្ពុជា ។ បន្ទាប់មក លោក ណុប ដារ៉ា ក៏បានអញ្ជើញចុះត្រួតពិនិត្យតាមច្រករបៀងក្នុងភូមិសាស្ត្រស្រុកកំរៀងខេត្តបាត់ដំបង បន្តទៀត ដែលចំណុចច្រករបៀងនេះគឺជាកន្លែងតែងតែមានការលួចឆ្លងដែនខុសច្បាប់ ៕

## ប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៤៦នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាបៈ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃសុក្រ ទី១៤ ខែឧសភា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៤៦នាក់ ស្រី ២៤នាក់ ក្នុងនោះកុមារា ២នាក់ កុមារី ១នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៣០នាក់ ស្រី ១៤នាក់ កុមារា ២នាក់ កុមារី ១នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ១៤នាក់ ស្រី ៨នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ២នាក់ ប្រុសចំនួន ០០នាក់ ស្រីចំនួន ២នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៤៦នាក់ ស្រី ២៤នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ខេត្តឧត្តរមានជ័យរកឃើញពលករ ៦នាក់ មានវិជ្ជមានកូវីដ-១៩

https://news.btv.com.kh/ 05/14/2021 07:05 PM

ឧត្តរមានជ័យ ៖ វេជ្ជបណ្ឌិត ឃ្លោក ហួត ទីប្រឹក្សាក្រសួងសុខាភិបាលនឹងជាប្រធានមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យលើកឡើងថា បច្ចុប្បន្ននេះអាត្រានៃការឆ្លងជំងឺកូវីដ-១៩លើពលករខ្មែរ ដែលធ្វើដំណើរឆ្លងដែនមកពីប្រទេសថៃចូលតាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ មន្ត្រីជំនាញចត្តាឡីស័កបានរកឃើញអ្នកវិជ្ជមានជំងឺកូវីដ-១៩ ចំនួន៦នាក់ដោយការធ្វើតេស្តរហ័ស Rapid test ។ លោកវេជ្ជបណ្ឌិត ឃ្លោក ហួត បានបន្តឲ្យដឹងថា គិតមកដល់ពេលនេះសំរាប់ខែឧសភា ពលករដែលឆ្លងដែនមកពីប្រទេសថៃក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យគឺមានចំនួន៦នាក់ហើយដែលរកឃើញវិជ្ជមានកូវីដ-១៩។ ក្នុងនោះដែរមន្ត្រីជំនាញសុខាភិបាលជួរមុខបានធ្វើការពិនិត្យរឹតបន្តឹងដោយម៉ត់ចត់ចំពោះពលករគ្រប់ៗគ្នា ដោយការប្រុងប្រយ័ត្នខ្ពស់បំផុត ដោយសារតែស្ថានភាពនៅឯប្រទេសថៃបានផ្ទុះឡើងសារជាថ្មីនូវជំងឺកូវីដ-១៩ នៅតាមបណ្តាខេត្តមួយចំនួន ពិសេសខេត្តដែលជាប់ព្រំប្រទល់ព្រំដែនខេត្តឧត្តរមានជ័យតែម្តង។

លោកវេជ្ជបណ្ឌិតបន្ថែមថា ចំពោះករណីរកឃើញអ្នកផ្ទុកជំងឺកូវីដ-១៩ ដែលជាពលករខ្មែរមកពីប្រទេសថៃនោះ មន្ត្រីសុខាភិបាលបានយកពួកគាត់មកសម្រាកព្យាបាលយកសំណាក ដើម្បីធ្វើតេស្តពិនិត្យបន្តនៅមន្ទីរពេទ្យបង្អែកខេត្ត នឹងមួយទីតាំង១ទៀតនៅផ្ទះសំណាក់ឧត្តមរង្សា ដើម្បីពិនិត្យព្យាបាលសុខភាពជូនពួកគាត់ផងដែរ។ ដោយឡែកចំពោះពលករដែលមានផ្ទុកវិរុសកូវីដ-១៩ ទាំង៦នាក់នេះដែលបច្ចុប្បន្នសុខភាពរបស់ពួកគាត់មិនមានសភាពធ្ងន់ធ្ងរអ្វីនោះឡើយ គឺរងចាំតែការធ្វើសំណាកគ្រប់៣ដងបើពិនិត្យទៅពុំមានបញ្ហាធ្ងន់ធ្ងរអ្វីនោះទេក្រុមគ្រូពេទ្យនឹងបញ្ជូនឲ្យពួកគាត់ឲ្យបន្តទៅធ្វើចត្តាឡីស័ក នៅឯផ្ទះបន្តទៀតដោយការពិនិត្យតាមដានពីមន្ត្រីសុខាភិបាលនៅនឹងមូលដ្ឋានពួកគាត់ផងដែរ។ លោកវេជ្ជបណ្ឌិតក៏បានក្រើនរំលឹកដល់ពលករគ្រប់រូបទាំងអស់ដែលឆ្លងមកពីប្រទេសថៃធ្វើយ៉ាងណាសូមកុំមានការគេចវេសឲ្យសោះត្រូវចូលរួមសហការណ៏ឲ្យបានល្អជាមួយក្រុមគ្រូពេទ្យជួរមុខដើម្បីទប់ស្កាត់ជំងឺកូវីដ-១៩ទាំងអស់គ្នា។ យើងអាចនឹងភ្លេចកូវីដប៉ុន្តែកូវីដមិនអាចភ្លេចយើងបានឡើយដូច្នេះត្រូវចូលរួមសំអាតអនាម័យឲ្យល្អជាប់ជាប្រចាំទើបយើងអាចជៀសផុតពីការឆ្លងកូវីដបាន៕ អត្ថបទ ៖ សារិទ្ធ

## សមត្ថកិច្ចនាំខ្លួនពលករប្រុសស្រីចំនួន ១៣នាក់ ដែលត្រឡប់ពីប្រទេសថៃប្រគល់ឲ្យគ្រូពេទ្យធ្វើចត្តាឡីស័ក ១៤ថ្ងៃ

https://www.gntimes.com/news/ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២១

បាត់ដំបង÷ យោងតាមនគរបាលការពារព្រំដែនបានបញ្ជាក់ប្រាប់ឲ្យដឹងថា ពលករខ្មែរចំនួន ១៣នាក់ ដែលបានត្រឡប់មកពីប្រទេសថៃត្រូវបានសមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០២១ ខណៈដែលពួកគេកំពុងធ្វើដំណើរចូលមកស្រុកកំណើតវិញ ក្នុងគោលបំណងគេចវេសពីការអនុវត្តចត្តាឡីស័កតាមវិធានការរបស់ក្រសួងសុខាភិបាលក៏ដូចជារាជរដ្ឋាភិបាល។ ការឃាត់ខ្លួនពលករទាំងអស់ខាងលើនេះដែរ ធ្វើឡើងខណៈដែលកម្លាំងចម្រុះនៅតាមបន្ទាត់ព្រំដែនបានចុះល្បាតនៅតាមបណ្តាច្រកតូចៗ នៅតាមព្រំដែន ដើម្បីអនុវត្តតាមវិធានការស្តីពីការត្រួតពិនិត្យពលករឆ្លងដែន និងមេខ្យល់នាំពលករចេញចូលប្រទេសថៃដោយខុសច្បាប់ ។ ប្រភពដដែល

បានបន្តថាៈ ពលករទាំង១៣នាក់ នៅថ្ងៃខាងលើបាននាំគ្នាលួចឆ្លងដែនដោយចេញពីទឹកដីថៃ ហើយចូលមកប្រទេសកំណើតវិញកាត់តាមត្រង់ចំណុចភូមិសាស្ត្រភូមិគីឡូលេខ៩ ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។ ពលករខ្មែរទាំងអស់សរុបចំនួន ១៣នាក់ក្នុងនោះបុរសចំនួន ៤នាក់ ស្ត្រីចំនួន ៦នាក់ និងក្មេងប្រុស ចំនួន ៣នាក់ ផងដែលពួកគេនាំគ្នាព្យាយាមគេចវេសមិនចូលធ្វើចត្តាឡីស័កក៏ត្រូវសមត្ថកិច្ចនាំខ្លួនតែម្តង។ បន្ទាប់ពីការសាកសួរ និងណែនាំអប់រំរួចរាល់កម្លាំងការពារគោលដៅតំបន់ព្រំដែនបានប្រគល់ពលករទាំង ១៣នាក់ ទៅឲ្យក្រុមគ្រូពេទ្យដើម្បីនាំយកទៅធ្វើចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ ៣២ តាមវិធានសុខាភិបាល៕

## មេខ្យល់២នាក់ ត្រូវឃាត់ខ្លួន ខណៈកំពុងតែដឹកពលករឆ្លងដែនទៅប្រទេសថៃ

https://kohsantepheapdaily.com.kh/ Banteay Meanchey ១៥ ខែ ឧសភា ឆ្នាំ ២០២១ ម៉ោង ១៥:៤៩

ខេត្តបន្ទាយមានជ័យ ៖ មេខ្យល់ចំនួន០២នាក់ ដែលសកម្មក្នុងការនាំពលករឆ្លងដែនខុសច្បាប់ ត្រូវបានកម្លាំងតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យឃាត់ខ្លួនបាន នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២១នេះ ខណៈពេលដែលពួកគេកំពុងដឹកនាំពលករឆ្លងដែនទៅប្រទេសថៃចំនួន១០នាក់ ក្នុងនោះស្រីចំនួន០៥នាក់ ត្រង់ចំនុចភូមិសាស្ត្រ អូរព្រំដែន ភូមិភ្នំរូង ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

ក្រោមបញ្ជាផ្ទាល់របស់លោក ឧត្តមសេនីយ៍ ត្រី ជឹម ប៊ុនអាន មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ បានចាត់តាំង លោកវរសេនីយ៍ឯក រិទ្ធ រ៉ម មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ដឹកនាំកម្លាំងល្បាតជាប់ជាប្រចាំដោយអនុវត្តតាមបទបញ្ជា មេបញ្ជាការ លោកបានដឹកនាំកម្លាំងល្បាត២៤ម៉ោងលើ២៤ម៉ោង ដោយប្តូរវេនគ្នា សហការជាមួយកម្លាំងនគរបាលការពារព្រំដែនគោក និងកម្លាំងផ្នែកសឹករងម៉ាឡៃ ផ្នែកសឹករងប៉ោយប៉ែត និងកងរាជអាវុធហត្ថស្រុក ដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ មិនឲ្យចូលទៅក្នុងសហគមន៍ ។ ជាក់ស្តែង វេលាម៉ោង១២:៣០នាទី យប់ ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ ខណៈលោក វរសេនីយ៍ឯក រិទ្ធ រ៉ម មេបញ្ជាការរង កំពុងដឹកនាំកម្លាំងដើរល្បាតក៏ជួបមេខ្យល់ចំនួន០២នាក់ បម្រុងនាំពលករឆ្លងដែនចេញទៅប្រទេសថៃ ត្រូវបានកម្លាំងតំបន់ប្រតិបត្តិការសឹករងខេត្ត បន្ទាយមានជ័យ ឃាត់ខ្លួនបានតែម្តង ។

សូមបញ្ជាក់ថា មេខ្យល់ដែលត្រូវឃាត់ខ្លួនទី១ ឈ្មោះ វណ្ណៈ វណ្ណ ភេទ ប្រុស អាយុ២៩ឆ្នាំ រស់នៅភូមិ តាគ្រី ឃុំគ្រី ស្រុកកំរៀង ខេត្តបាត់ដំបង និងទី២ ឈ្មោះ អៀន ហ៊ើន ភេទប្រុស អាយុ៤៩ឆ្នាំ រស់នៅភូមិ ជ្រៃ ឃុំ បឹងបេង ស្រុកម៉ាឡៃ បច្ចុប្បន្នពួកគាត់ទាំងពីរនាក់កំពុងត្រូវបានឃុំខ្លួន ដើម្បីសួរចម្លើយនៅ ស្នាក់ការកងរាជអាវុធហត្ថស្រុកម៉ាឡៃ ។ ចំណែកឯពលករទាំង ១០នាក់ ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ នៅមណ្ឌលចត្តាឡីស័កស្រុកម៉ាឡៃ ៕

## គិតត្រឹមថ្ងៃទី១៥ ខែឧសភានេះពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃមាន៤៦នាក់

https://kohsantepheapdaily.com.kh/ Siem Reap ១៥ ខែ ឧសភា ឆ្នាំ ២០២១ ម៉ោង ២១:២០

ខេត្តសៀមរាប ៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២១ នេះបានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រក

ដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៤៦នាក់ ស្រី២៣នាក់ ក្នុងនោះកុមារ ៦នាក់ កុមារី ២នាក់ មានដូចខាងក្រោម ៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត ៖ ចំនួន ៧នាក់ ស្រី ៤នាក់ កុមារ ០០នាក់ កុមារី ២នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៣១នាក់ ស្រី ១៤នាក់ កុមារ ៦នាក់ កុមារី ១នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៣នាក់ ស្រី ២នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ៥នាក់ ប្រុសចំនួន ០០នាក់ ស្រីចំនួន ៣នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៤៦នាក់ ស្រី ២៣នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអស់ហើយ ៕

## សាលាដំបូងខេត្តសៀមរាប សម្រេចចោទប្រកាន់បុរសម្នាក់ នៅស្រុកពួក ពីបទការនាំចេញដោយមិនស្របច្បាប់ដោយឆ្លងដែនទៅប្រទេសថៃ !

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាប៖ លោកវរសេនីយ៍ឯក ជា ហេង នាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប បានឱ្យដឹងថា កាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ ម្សិលមិញនេះ ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្ត បានសម្រេចធ្វើការចោទប្រកាន់ បុរសម្នាក់ឈ្មោះ រិន រ៉ា អាយុ ៣៩ឆ្នាំ មានទីលំនៅភូមិជួយចក្រី ឃុំត្រីញ័រ ស្រុកពួក ខេត្តសៀមរាប ពីបទការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន ព្រមទាំងបង្គាប់ឲ្យឃុំខ្លួនទៀតផង ខណៈដែលបុរសរូបនោះ ជាប់សង្ស័យជាមេខ្យល់នាំពលករខ្មែរទៅធ្វើការនៅប្រទេសថៃ ដោយខុសច្បាប់ ដែលប្រព្រឹត្តទៅកាលថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ កន្លងទៅនេះ នៅចំណុចម្តុំច្រករបៀងក្បែរអូរបីជាន់ ក្នុងខេត្តបន្ទាយមានជ័យ ។

លោក ជា ហេង បានឱ្យដឹងទៀតថា កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ មានប្រជាពលរដ្ឋចំនួន ១៩នាក់ បានធ្វើចំណាកស្រុកដោយខុសច្បាប់ទៅប្រទេសថៃ ហើយត្រូវបានកម្លាំងនគរបាលការពារព្រំដែន និងទាហានការពារព្រំដែនខេត្តបន្ទាយមានជ័យចាប់ខ្លួនបាន។ ប្រជាពលរដ្ឋទាំងអស់នេះ ត្រូវបានបញ្ជូនត្រឡប់មកធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័កវិទ្យាល័យសម្តេចឪ ខេត្តសៀមរាប ប៉ុន្តែដោយមានការសង្ស័យថាមានមេខ្យល់នាំឆ្លងដែនខុសច្បាប់ លេខាធិការដ្ឋានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត បានស្នើសុំគោលការណ៍ឯកឧត្តម អភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីធ្វើការស្រាវជ្រាវដោយជួបផ្ទាល់ជាមួយពលករទាំង១៩នាក់ នៅមណ្ឌលចត្តាឡីស័ក ឈានដល់កំណត់បានជនសង្ស័យជាមុខសញ្ញានាំឆ្លងដែន មានឈ្មោះ រិន រ៉ា ភេទប្រុស អាយុ៣៩ឆ្នាំនេះ ។

លោកវរសេនីយ៍ឯក បានឱ្យដឹងបន្ថែមទៀតថា ក្នុងចំណោមប្រជាពលរដ្ឋទាំង១៩នាក់ មានប្រជាពលរដ្ឋចំនួន១០នាក់នៅភូមិជួយចក្រី ឃុំត្រីញ័រ ត្រូវជនសង្ស័យឈ្មោះ រិន រ៉ា នាំពួកគាត់ឆ្លងដែនចូលទៅធ្វើការនៅក្នុងទឹកដីប្រទេសថៃ ដោយក្នុងម្នាក់ៗត្រូវបង់លុយចំនួន ៤,១០០បាត សម្រាប់ការនាំចូលទៅដល់កន្លែងធ្វើការមួយក្នុងចម្ការម្ចាស់នៃប្រទេសថៃ និងត្រូវចំណាយលុយថ្លៃថយន្តពីផ្ទះដល់ព្រំដែនរៀងខ្លួនៗផងដែរ ។ ផ្អែកតាមការបំភ្លឺប

ស់ពលករទាំង១០នាក់ និងស្តាប់ចម្លើយសារភាពរបស់ជនសង្ស័យជាមេខ្យល់ ព្រមទាំងផ្អែកតាមការពិនិត្យស្ថានភាពជាក់ស្តែង ក្នុងការឃាត់បានពេលកំពុងធ្វើដំណើររៀបឆ្លងដែននោះ ឈ្មោះ រិន រ៉ា ពិតជាបានធ្វើសកម្មភាពនាំប្រជាពលរដ្ឋ ដើម្បីលួចឆ្លងដែនតាមច្រករបៀងដោយខុសច្បាប់ ទៅរកការងារធ្វើនៅប្រទេសថៃពិតមែន។

លោកស្រី យូ សុភា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងការជួញដូរមនុស្សខេត្តសៀមរាប បានមានប្រសាសន៍ថា អនុវត្តតាមបទបញ្ជា និងអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃកម្ពុជា ស្តីពីការរឹតបន្តឹងនៅតាមច្រកព្រំដែន ដូចជាការនាំចេញនាំចូលពលករទៅក្រៅប្រទេសដោយខុសច្បាប់ ក្នុងដំណាក់កាលដែលប្រទេសជាប់ព្រំដែនមានការបិទខ្ទប់ ដោយសារការឆ្លងរាលដាលជាសកល នៃជំងឺកូវីដ-១៩នេះ ឯកឧត្តមអភិបាលខេត្តសៀមរាប និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត តែងតែបានធ្វើការណែនាំ និងចង្អុលបង្ហាញដល់លេខាធិការដ្ឋានប្រយុទ្ធប្រឆាំងការជួញដូរមនុស្សខេត្ត និងអ្នកពាក់ព័ន្ធទាំងអស់ក្នុងខេត្ត ឱ្យបង្កើនការគ្រប់គ្រង ការស្រាវជ្រាវ និងការបង្ក្រាបបទល្មើស នៃការនាំចេញនាំចូលប្រជាពលរដ្ឋដោយខុសច្បាប់តាមរយៈមេខ្យល់ រួមទាំងការស្រាវជ្រាវរកមេខ្យល់ឲ្យឃើញ ដើម្បីនាំខ្លួនយកមកផ្តន្ទាទោសតាមនីតិវិធីច្បាប់ ។

លោកស្រី បានបន្ថែមទៀតថា ក្រោមកិច្ចសហប្រតិបត្តិការល្អរវាងរដ្ឋបាលខេត្តសៀមរាប និងរដ្ឋបាលខេត្តបន្ទាយមានជ័យ បានទប់ស្កាត់ និង បង្ក្រាបទាន់ពេលវេលា នូវការឆ្លងដែនដោយខុសច្បាប់ អ្នកដែលស្វែងរកការងារនៅក្រៅប្រទេស ខណៈដែលកន្លងមក យើងបង្ក្រាបបានជាច្រើនករណី និងបញ្ជូនជនជាប់សង្ស័យជាមេខ្យល់ទៅតុលាការចាត់ការតាមនីតិវិធីច្បាប់។ក្នុងឱកាសនេះដែរ លោកស្រីអភិបាលរងខេត្ត បានធ្វើការអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ សូមធ្វើការពិចារណាឲ្យបានល្អិតល្អន់ និងហ្មត់ចត់ជាមុនសិន មុននឹងសម្រេចចិត្តចង់ស្វែងរកការងារធ្វើនៅក្រៅប្រទេស ក្នុងដំណាក់កាលដែលជំងឺកូវីដ-១៩ កំពុងតែឆ្លងរាលដាលជាសកលយ៉ាងខ្លាំងក្លានៅឡើយនោះ ចៀសវាងការចាញ់បោកមេខ្យល់ ព្រោះវាមានហានីភ័យខ្ពស់ចំពោះខ្លួនយើង ហេតុនេះចូរព្យាយាមស្វែងរកការងារធ្វើនៅក្នុងប្រទេសយើងវិញ វាមានសុវត្ថិភាពសម្រាប់ខ្លួនយើង ។

សូមបញ្ជាក់ថា នេះជាករណីលើកទី២ ហើយសម្រាប់ឆ្នាំ២០២១នេះ ដែលសម្រេចបានក្នុងការងារគ្រប់គ្រងស្រាវជ្រាវ និងបង្ក្រាបបទល្មើសនៃការនាំចេញនាំចូលប្រជាពលរដ្ឋដោយខុសច្បាប់តាមរយៈមេខ្យល់ រួមទាំងការស្រាវជ្រាវរកមេខ្យល់ និងនាំខ្លួនយកមកផ្តន្ទាទោសតាមនីតិវិធី នៃច្បាប់ ខណៈដែលឆ្នាំ២០២០ បង្ក្រាបបានចំនួន៧ករណី ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## អាជ្ញាធរថៃបង្កើនរឹតបន្តឹងតំបន់ព្រំដែនជាប់កម្ពុជា ទប់ស្កាត់ការរាតត្បាតកូវីដ១៩

https://www.rfa.org/ ដោយ ម៉ៅ សុជានី 2021-05-13

អាជ្ញាធរថៃបង្កើនការរឹតបន្តឹងកាន់តែខ្លាំងនៅតាមព្រំដែនជាប់កម្ពុជា ហាមឃាត់មិនឱ្យពលករខ្មែរឆ្លងដែនទៅប្រទេសថៃ ដោយខុសច្បាប់ ដើម្បីទប់ស្កាត់ការរាតត្បាតជំងឺកូវីដ១៩។ មន្ត្រីសង្គមស៊ីវិល យល់ថា ពលករខ្មែរឆ្លងដែនទៅប្រទេសថៃអំឡុងពេលនេះប្រឈមនឹងគ្រោះច្រើនជាងពេលមុនៗ។

ក្រសួងមហាផ្ទៃរបស់ថៃបានបញ្ជាទៅអាជ្ញាធរខេត្តជាប់ព្រំដែនកម្ពុជា ឱ្យបង្កើនការរឹតបន្តឹងនៅតំបន់ព្រំដែនដោយហាមដាច់ខាតមិនឱ្យពលករខ្មែរឆ្លងដែលចូលទៅប្រទេសថៃដោយខុសច្បាប់អំឡុងពេលនេះ។ក្រសួងមហាផ្ទៃថៃបានជំរុញទៅអាជ្ញាធរមូលដ្ឋាននៅតំបន់ព្រំដែនទាំងអស់ឱ្យសហការជាមួយពលរដ្ឋថៃ ទប់ស្កាត់មិនឱ្យពលករបរទេសលួចឆ្លងដែនចូលទៅប្រទេសថៃជាដាច់ខាត។ បន្ថែមពីនេះសមត្ថកិច្ចថៃ ឲ្យស្នើឲ្យពលរដ្ឋថៃ ប្រសិនបើពួកគេ ប្រទះឃើញពលករបរទេសលួចឆ្លងដែនខុសច្បាប់ឱ្យរាយការណ៍ទៅអាជ្ញាធរថៃភ្លាមៗ។

គិតចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី១០ ឧសភា អាជ្ញាធរថៃ ចាប់ពលករបរទេស រួមមាន ខ្មែរ ឡាវ (Lao) និង មីយ៉ាន់ម៉ា ឬភូមា (Myanmar) បាន ១.១២៦នាក់ ដែលបានលួចឆ្លងដែនចូលប្រទេសថៃ ដោយខុសច្បាប់ ក្នុងនោះពលករភូមា (Myanmar) និងកម្ពុជាច្រើនជាងគេ៖ «នៅទីប្រជុំគណៈកម្មការទប់ស្កាត់ការរាតត្បាតជំងឺកូវីដ ១៩ ថ្ងៃនេះ ក៏មានការពិភាក្សាគ្នា ដោយជំរុញឱ្យអាជ្ញាធរតាមដាន ការលបឆ្លងដែនចូលក្នុងប្រទេសតាមព្រំដែន ដោយសង្កត់ធ្ងន់លើការធ្វើការងាររបស់អាជ្ញាធររដ្ឋ យើងជ្រាបច្បាប់ថា ពួកគាត់ធ្វើការងារធ្ងន់រួចមកហើយ តែនៅពេលនេះសុំបង្កើនការពារតឹងតែងជាងមុន។ អ្វីដែលសំខាន់នោះសុំឱ្យការចូលរួមសហការពីពលរដ្ឋថៃ ដែលត្រូវការវិលត្រឡប់ប្រទេស សុំឱ្យចេញចូលប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋ ដែលមានស្តង់ដារ»។

នៅថ្ងៃទី១២ ឧសភា អាជ្ញាធរថៃចាប់ខ្លួនពលករខ្មែរចំនួន១៧នាក់ទៀត នៅតំបន់ព្រំដែនខេត្តស្រះកែវ (Sra Kaeo) ជាប់កម្ពុជា ដោយសារពួកគេលួចឆ្លងដែនដោយខុសច្បាប់។ ពលករខ្មែរទាំងនោះត្រូវបានអាជ្ញាធរថៃបញ្ជូនទៅត្រួតពិនិត្យជំងឺកូវីដ១៩ នៅខេត្តស្រះកែវ មុននឹងបញ្ជូនពួកគេត្រឡប់ទៅកម្ពុជាវិញ។ សារព័ត៌មានរបស់ថៃ (77kaoded) ចុះផ្សាយនៅថ្ងៃទី១៣ ឧសភាថា អាជ្ញាធរថៃនឹងចាត់វិធានការតាមច្បាប់ ចំពោះពលករបរទេសណាដែលឆ្លងដែនចូលទឹកដីថៃចម្ងាយលើសពី១០គីឡូម៉ែត្រពីព្រំដែន ហើយប្រសិនបើក្រោម ១០គីឡូម៉ែត្រនឹងបញ្ជូនត្រឡប់ទៅប្រទេសកំណើតវិញ។

ទាក់ទងនឹងបញ្ហានេះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ លោក សិទ្ធ ឡោះ ប្រាប់អាស៊ីសេរីថា លោកមិនទាន់ទទួលព័ត៌មានអំពីពលករខ្មែរដែលថៃចាប់ខ្លួនទាំងនោះនៅឡើយទេ។ លោកថា អាជ្ញាធរកម្ពុជា ក៏រឹតបន្តឹងនៅតំបន់ព្រំដែនជាប់ប្រទេសថៃដែរ ដើម្បីទប់ស្កាត់ការរាលដាលជំងឺកូវីដ១៩។ លោកបញ្ជាក់ថា កងកម្លាំងការពារព្រំដែនខេត្តបន្ទាយមានជ័យឃាត់ខ្លួនពលករខ្មែរចំនួន២៦នាក់ ដោយសារពួកគេលបឆ្លងដែនចូលទៅប្រទេសថៃដោយខុសច្បាប់នៅថ្ងៃទី១២ ឧសភា៖ «យើងនៅតែបន្តការរឹតបន្តឹងមិនឱ្យឆ្លងដែនខុសច្បាប់ ហើយទី២យើងបង្ការទប់ស្កាត់ការរីករាលដាលជំងឺកូវីដទាំងចេញទាំងចូល ព្រោះស្ថានភាពបច្ចុប្បន្ននេះកម្ពុជាក៏ដូចជាពិភពលោកដែរកំពុងតែប្រយុទ្ធ ប្រឆាំងជំងឺកូវីដ១៩។ អីចឹងយើងនៅតែបន្តរឹតបន្តឹងទៀត» ។

ជុំវិញរឿងនេះមន្ត្រីអង្គការសង់ត្រាល់ (Central) ទទួលបន្ទុកផ្នែកពលករលោក ឌី ថេហូយ៉ា យល់ថា មូលហេតុ ដែលពលករខ្មែរនៅតែបន្តលួចឆ្លងដែនទៅប្រទេសអំឡុងពេលនេះ ដោយសារពួកគាត់ជីវភាពក្រីក្រ និងគ្មានការងារធ្វើនៅក្នុងស្រុក ហើយពលករមួយចំនួនចាញ់បោកក្រុមមេខ្យល់។ លោកបញ្ជាក់ថា ការឆ្លងដែនអំឡុងពេលនេះប្រឈមនឹងគ្រោះថ្នាក់ច្រើនជាពេលកន្លងទៅ មានដូចជា ប្រឈមនឹងអាជ្ញាធរថៃចាប់ខ្លួនដាក់ពន្ធនាគារ ទាហានថៃបាញ់ស្លាប់ និងប្រឈមការឆ្លងជំងឺកូវីដ១៩ ជាដើម៖ «ខ្ញុំគិតថា ទោះបីជាក្នុងកាលៈទេសៈការរឹត បន្តឹងការចេញយ៉ាងណាក៏ដោយ ក៏នៅតែមានមេខ្យល់នាំចេញនាំចូលដដែល។ ប្រសិនបើថៃក្រពុលមុខ ដោយថ្មីៗ នេះមជ្ឈដ្ឋានមួយចំនួនបានលើកឡើងថា ការរីករាលដាលមេរោគហ្នឹង ព្យាបាលទម្លាក់កំហុសដល់ពលករឆ្លងដែនចេញចូលខុសច្បាប់ហ្នឹងហើយ ដែលអ្នកនាំពេគ ហើយអាការឃោសនាបែបនេះធ្វើឱ្យមានការខឹងសម្បារមានការរើសអើង និងអាចឈានទៅដល់ប្រើប្រាស់ហិង្សា»។ លោក ឌី ថេហូយ៉ា បន្តថា ដើម្បីដោះស្រាយបញ្ហានេះ រដ្ឋាភិបាលខ្មែរគួរតែផ្តល់ស្បៀងអាហារជូនដល់ពលរដ្ឋ ដែលរងគ្រោះដោយសារការរាតត្បាតជំងឺកូវីដ១៩ ឱ្យបានដល់ដៃគ្រប់គ្នា។ បន្ថែមពីនេះលោកថា រដ្ឋាភិបាលក៏គួរទប់ស្កាត់កុំឱ្យបន្លែបរទេសហូរចូលមកកម្ពុជាតាមអំពើចិត្តដូចសព្វថ្ងៃទៀត ដើម្បីជួយដល់កសិករក្នុងស្រុកដែលគ្មានការងារធ្វើអាចដាំដុះបន្លែលក់រកប្រាក់ចំណូលដោះស្រាយជីវភាពគ្រួសារ។

ជាមួយគ្នានេះក្រសួងសុខាភិបាល ប្រកាសនៅថ្ងៃទី១៣ ឧសភាថា អ្នកជំងឺកូវីដ-១៩ ចំនួន ៦នាក់បន្ថែមទៀតបានស្លាប់ ដែលធ្វើឲ្យចំនួនអ្នកស្លាប់កើនដល់ចំនួន ១៤២នាក់។ ចំណែកករណីឆ្លងថ្មីវិញ ក្រសួងបញ្ជាក់ថា

មានចំនួន ៤៤១នាក់ ក្នុងនោះមាន ១៥នាក់ ជាករណីនាំចូល ហើយក្រៅពីនេះសុទ្ធតែជាករណីឆ្លងក្នុងសហគមន៍។ នៅថ្ងៃដដែលនេះ អ្នកជំងឺ ៩៨០នាក់ផ្សេងទៀតបានជាសះស្បើយ៕

## ទាហានថៃចាប់ពលករខ្មែរឆ្លងដែនខុសច្បាប់៦នាក់ រួមទាំងមេខ្យល់ជនជាតិថៃម្នាក់ទៀត បញ្ជូនទៅកាត់ក្ដីនៅតុលាការថៃ

http://freshnewsasia.com/ 2021-05-13 07:12pm

**(បន្ទាយមានជ័យ)៖** សមត្ថកិច្ចកម្ពុជាដែលប្រចាំការនៅព្រំដែនរវាងខេត្តបន្ទាយមានជ័យ និងខេត្តស្រះកែវ ប្រទេសថៃ បានឱ្យដឹងថា សមត្ថកិច្ចថៃបានឃាត់ខ្លួនពលករខ្មែរ ៦នាក់ រួមនឹងមេខ្យល់ជនជាតិថៃម្នាក់ទៀត ក្នុងពេលពួកគេលួចឆ្លងដែនខុសច្បាប់ចូលទឹកដីថៃ ដោយសមត្ថកិច្ចថៃបានកសាងសំណុំរឿងបញ្ជូនទៅតុលាការ។ ខាងភាគីកម្ពុជាបានស្នើសុំប្រជាពលរដ្ឋទាំងនេះត្រឡប់មកកម្ពុជាវិញដែរប៉ុន្តែភាគីថៃមិនអនុញ្ញាតឲ្យមកជាដាច់ខាត។

នគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨០៧ បានឲ្យដឹងថា នាវេលាម៉ោង ៣ រសៀល ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ មានកម្លាំងសមត្ថកិច្ចថៃបានឃាត់ពលករខ្មែរ ៦នាក់ (ស្រី ៣នាក់) ដែលបានលួចឆ្លងដែនចូលទឹកដីថៃនៅចំណុចប៉ុស្តិ៍លេខ ៣ ស្ថិតក្នុងភូមិសូន្យសាម ឃុំថាប់ថៃ ស្រុកតាប្រាយ៉ា ខេត្តស្រះកែវ ទល់នឹងភូមិសាស្ត្រប៉ុស្តិ៍ប្រាសាទត្បែង ភូមិប្រាសាទត្បែង ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ ប្រភពដដែលបានបញ្ជាក់ទៀតថា ពលករខ្មែរទាំង៦នាក់នេះ គឺមកពីខេត្តសៀមរាប ៥នាក់ និងខេត្តបន្ទាយមានជ័យ ១នាក់។

ពាក់ព័ន្ធនឹងការឃាត់ខ្លួនពលករទាំង៦នាក់នេះ ក្រុមការងារទំនាក់ទំនងការងារព្រំដែនកម្ពុជា-ថៃ បានទំនាក់ទំនងស្នើសុំប្រជាពលរដ្ឋខាងលើឱ្យត្រឡប់មកកម្ពុជាវិញដែរ ប៉ុន្តែខាងភាគីថៃមិនអនុញ្ញាតតាមសំណើរបស់ភាគីកម្ពុជាជាដាច់ខាត។ តាមការឲ្យដឹងពីសមត្ថកិច្ចថៃ គេបានស្រាវជ្រាវរកឃើញមេខ្យល់ ១នាក់ ជាជនជាតិថៃ និងបានកសាងសំណុំរឿងបញ្ជូនទៅកាត់ក្តីនៅតុលាការថៃទាំង៧នាក់តែម្តង៕

## អាជ្ញាធរថៃចាប់ពលរដ្ឋខ្មែរចំនួន 23នាក់ លួចឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់

https://www.facebook.com/Khmer.Channel.kh/ ថ្ងៃទី 13 ឧសភា ទឹកចិត្តពលករឆ្លងដែន

ពេលខ្ញុំចង់ចេញពីប្រទេសថៃចង់ព្រះអង្គណាណែនាំក៏មិនស្តាប់ដែរ សំខាន់ឡានម៉ៅសេវាដឹករហ័សទាន់ចិត្តដល់ព្រំដែនទៀត ពេលខ្ញុំចង់ចូលមកវិញចង់ព្រះអង្គណាណែនាំក៏មិនស្តាប់ដែរខ្ញុំលួចចូលផ្លូវកាត់ មានមេខ្យល់គេប្រាប់ថាទៅបាន បងប្អូនខ្ញុំចឹង។ អាជ្ញាធរថៃចាប់ពលរដ្ឋខ្មែរចំនួន 23នាក់ លួចឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់នៅត្រង់ចំណុចភូមិថាប់សៀម ឃុំ/ស្រុកតាប្រាក់យ៉ា ខេត្តស្រះកែវ។ ហេតុការណ៍វេលាម៉ោង 07៖00នាទី ព្រឹកថ្ងៃទី13 ខែឧសភា ឆ្នាំ2021។

# ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១

## ស្នងការនគរបាលខេត្តបាត់ដំបង ស្នើឲ្យមន្ត្រីក្រោមឱវាទបំពេញតួនាទីរបស់ខ្លួនឲ្យបានម៉ត់ចត់ និងបង្ក្រាបការជួញដូរមនុស្សឆ្លងដែនខុសច្បាប់

https://cen-news.com/ ByPen Srey Neat May 17, 2021

បាត់ដំបង ៖ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង បានធ្វើការផ្ដាំផ្ញើដល់លោកស្នងការរង លោកអធិការក្រុងស្រុក និងលោកនាយការិយាល័យទើបប្រកាសផ្ទេរភារកិច្ច តែងតាំងមុខតំណែងថ្មី ត្រូវស្វែងយល់ពីការងារស្នូល និងបំពេញតួនាទីរបស់ខ្លួនឲ្យបានម៉ត់ចត់ទាន់ពេលវេលា។ លោកឧត្តមសេនីយ៍ទោ បានថ្លែងបែបនេះ នៅព្រឹកថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១ ក្នុងពិធីប្រកាសផ្ទេរភារកិច្ច តែងតាំងមុខ

តំណែង ជូនដល់មន្ត្រីនគរបាលជាន់ខ្ពស់ នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង ចំនួន១២នាក់ នៅសាលប្រជុំស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង ។ ក្នុងឱកាសនោះ លោកឧត្តមសេនីយ៍ទោស្នងការ បានក្រើនរំលឹកដល់មន្ត្រីនគរបាលជាន់ខ្ពស់ ទើបទទួលមុខតំណែងថ្មី ត្រូវយកចិត្តទុកដាក់លើការងារធំ៤ គឺ ៖

ទី១.ចូលរួមអនុវត្តផ្សព្វផ្សាយភូមិឃុំមានសុវត្ថិភាព ទាំង៧ចំណុចឲ្យមានប្រសិទ្ធភាពខ្ពស់។

ទី២.បង្ក្រាបបទល្មើសគ្រឿងញៀន ដែលជាបញ្ហាសកល និងច្បាមរាល់មុខសញ្ញាជួញដូរ ចែកចាយ រក្សាទុក ឬប្រើប្រាស់សារធាតុញៀនខុសច្បាប់។

ទី៣.បង្ក្រាបការជួញដូរមនុស្សឆ្លងដែនខុសច្បាប់ តាមរយៈមេខ្យល់ទាំងក្នុងនិងក្រៅប្រទេស។

និងទី៤.ការរឹតបណ្តឹងច្បាប់ចរាចរណ៍ផ្លូវគោក ក្នុងខណៈពេលប្រទេសកំពុងបិទខ្ទប់ ដោយការរីករាលដាលមេរោគកូវីដ១៩៕រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ទទួលពលរដ្ឋខ្មែរចំនួន១៣នាក់ ត្រឡប់មកពីប្រទេសថៃ បញ្ជូនទៅធ្វើចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២

http://cambodiapolice.com/policekh/ 3:53 pm 14 ឧសភា 2021

ខេត្តបាត់ដំបង ៖ នៅថ្ងៃសុក្រ ៣កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី ១៤ ខែឧសភាឆ្នាំ ២០២១ តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្តីពីការត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ-ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ លោកវរសេនីយ៍ឯក ពៅ ថាវុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពព្រំដែនគោកលេខ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ ជាមេបញ្ជាការ បានចាត់តាំងកម្លាំងប៉ុស្តិ៍នគរបាលព្រំដែនគីឡូ៩ សហការជាមួយកម្លាំងយោធាផ្នែកសឹករង ស្រុកសំពៅលូន, កម្លាំងយោធាវរសេនាតូចលេខ៥៣៣ និងកម្លាំងយោធាវរសេនាតូចលេខ១ ទៅទទួលប្រជាពលរដ្ឋត្រឡប់មកពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ ពីយោធាថៃកងអនុសេនាធំ ១៣០៥ ត្រង់ចំណុចនៃភូមិសាស្ត្រភូមិគីឡូ៩ ឃុំជ្រៃសីមា ស្រុកសំពៅលូន ចំនួន ១៣នាក់, ស្រី ៦នាក់ ក្នុងនោះក្មេងប្រុស៣នាក់។ បន្ទាប់ពីធ្វើការសាកសួររួច ក៏ធ្វើការអប់រំណែនាំ និងបានប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២តាមការណែនាំរបស់ក្រសួងសុខាភិបាល៕

## ប៉េអឹម បញ្ជូនមេខ្យល់ម្នាក់ ទៅតុលាការ ករណីនាំពលករលួចឆ្លងដែនទៅថៃ , ពលករទាំង៨នាក់ ត្រូវបញ្ជូនមកធ្វើចត្តាឡីស័ក

https://cen-news.com/ ByPen Srey Neat May 16, 2021

បន្ទាយមានជ័យ៖ សមត្ថកិច្ចខេត្តបន្ទាយមានជ័យ នៅព្រឹកថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២១នេះ បានបញ្ជូនបុរសមេខ្យល់ម្នាក់ទៅកាន់សាលាដំបូងខេត្ត ក្រោយបង្ក្រាបបានក្នុងករណីនាំពលករចំនួន៨នាក់ លួចឆ្លងដែនទៅធ្វើការប្រទេសថៃ ដោយខុសច្បាប់។ ដោយឡែកពលករទាំង៨នាក់ ត្រូវបានបញ្ជូនមកធ្វើចត្តាឡីស័ក នៅវិទ្យាល័យស្រុកម៉ាឡៃ រយៈពេល១៤ថ្ងៃ។

នៅវេលាម៉ោង២០និង០០នាទី ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២១ កម្លាំងមូលដ្ឋានកងរាជអាវុធហត្ថស្រុកម៉ាឡៃ ដឹកនាំដោយលោកវរសេនីយ៍ត្រី តាំង សុខហេង មេបញ្ជាការមូលដ្ឋានកងរាជអាវុធហត្ថស្រុក សហការជាមួយកម្លាំងតំបន់ប្រតិបត្តិការ សឹករងបន្ទាយមានជ័យ ដឹកនាំដោយលោកវរសេនីយ៍ឯក រិទ្ធ រ៉េម មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ទទួលទិសទី១ បានចុះល្បាតតាមបន្ទាត់ព្រំដែន ដើម្បីទប់ស្កាត់ការលួចចេញ-ចូល ទៅប្រទេសថៃដោយខុសច្បាប់ ពេលល្បាតដល់ចំណុចភូមិភ្នំរូង ឃុំបឹងបេង ស្រុកម៉ាឡៃ ក៏ប្រទះឃើញពលករ

ចំនួន០៨នាក់ ក្នុងនោះស្ត្រីចំនួន០៥នាក់ បម្រុងលួចឆ្លងដែនចូលទៅប្រទេសថៃដោយខុសច្បាប់ ហើយកម្លាំងចម្រុះ ក៏បានឃាត់ខ្លួនយកមកសួរនាំ នៅមូលដ្ឋានកងរាជអាវុធហត្ថស្រុកម៉ាឡៃតែម្តង ។

លោកវរសេនីយ៍ត្រី តាំង សុខហេង បានឱ្យដឹងថា ក្រោយពីសួរនាំពលករទាំង០៨នាក់រួច ទើបកម្លាំងចម្រុះធ្វើប្រតិបត្តិការឃាត់ខ្លួនមេខ្យល់ម្នាក់ ឈ្មោះ វណ្ណៈ វណ្ណន ភេទប្រុស អាយុ២៩ឆ្នាំ និងដកហូតរថយន្ត០១គ្រឿង ម៉ាកកាមេរីឆ្លាម ពណ៌ប្រផេះ ពាក់ផ្លាកលេខ ភ្នំពេញ 2A-5019 នៅចំណុចភូមិអូរសំព័រ ឃុំអូរសំព័រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ហើយបញ្ជូនមកមូលដ្ឋានកងរាជអាវុធហត្ថស្រុក ដើម្បីសាកសួរចម្លើយ ។ លោកវរសេនីយ៍ត្រី តាំង សុខហេង បានឱ្យដឹងទៀតថា ចំពោះមេខ្យល់ខាងលើ ក្រោយពីកម្លាំងជំនាញ សាកសួរចម្លើយរួចមក បានឆ្លើយសារភាពថា រូបគេជាអ្នករត់តាក់ស៊ី ហើយបានដឹកពលករចំនួន០៦នាក់ ពីខេត្តបាត់ដំបង មកស្រុកម៉ាឡៃ ពិតប្រាកដមែន តាមរយៈអ្នករត់តាក់ស៊ីម្នាក់ទៀត ឱ្យខ្លួនដឹកដោយយកលុយពីពួកគាត់ ក្នុងម្នាក់៥០,០០០រៀលផងដែរ កាលពីថ្ងៃទី១៤ ឧសភា ២០២១ ស្អែកឡើងថ្ងៃទី១៥ ស្រាប់តែសមត្ថកិច្ចចម្រុះ មកឃាត់ខ្លួនគេតែម្តង ។ ដោយផ្អែកលើចម្លើយរបស់ពលករ និងចម្លើយសារភាព របស់មេខ្យល់ កម្លាំងជំនាញមូលដ្ឋានកងរាជអាវុធហត្ថស្រុកម៉ាឡៃ បានកសាងសំណុំរឿង បញ្ជូនមកបញ្ជាការដ្ឋាន កងរាជអាវុធហត្ថខេត្តចាត់ការបន្ត ចំណែកពលករទាំង០៨នាក់ ត្រូវបានកម្លាំងបញ្ជូន ទៅធ្វើចត្តាឡីស័ក នៅវិទ្យាល័យស្រុកម៉ាឡៃហើយ ។

លោកវរសេនីយ៍ទោ ព្រហ្ម ថេង ប្រធានមន្ទីរស្រាវជ្រាវ និងបង្រ្កាបបទល្មើស បានឱ្យដឹងថា ការឃាត់ខ្លួនមេខ្យល់ឈ្មោះវណ្ណៈ វណ្ណន លោកក៏បានគោរពរាយការណ៍ ជូនលោកឧត្តមសេនីយ៍ត្រី បោន ប៊ិន មេបញ្ជាការកងរាជអាវុធហត្ថខេត្តផងដែរ បច្ចុប្បន្ន មេខ្យល់រូបនេះត្រូវកម្លាំងការិយាល័យប្រឆាំង ការជួញដូរមនុស្ស នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត បញ្ជូនទៅសាលាដំបូងខេត្ត ហើយនៅព្រឹកថ្ងៃអាទិត្យ ទី១៦ ខែឧសភា ឆ្នាំ២០២១នេះ ៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## កម្លាំងនគរបាល សហការជាមួយកម្លាំងយោធាទប់ស្កាត់ប្រជាពលរដ្ឋចំនួន ០៦នាក់ បំរុងលួចឆ្លងដែនចូលទឹកដីថៃ

http://cambodiapolice.com/policekh/ 9:37 am 17 ឧសភា 2021

ខេត្តបាត់ដំបង ៖ នៅថ្ងៃអាទិត្យ ៥កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២១ តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្តីពីការត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ-ចូលខុសច្បាប់ តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ លោកវរសេនីយ៍ឯក ពៅ ថាវុធ ស្នងការរង ទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨ ១៧ បានចាត់តាំងកម្លាំងប៉ុស្តិ៍នគរបាលព្រំដែនគីឡូ១៣ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨ ១៧ សហការជាមួយកម្លាំងសឹករងស្រុកសំពៅលូន និងកម្លាំងយោធាវរសេនាតូចលេខ៥៣៣ ទប់ស្កាត់ប្រជាពលរដ្ឋបំរុងលួចឆ្លងដែនចូលទឹកដីថៃ ត្រង់ចំណុចនៃភូមិសាស្ត្រភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ចំនួន ០៦នាក់ (ស្រី ០២នាក់) ក្នុងនោះក្មេងប្រុស ២នាក់ ។ បន្ទាប់ពីធ្វើការសាកសួរ និងកត់ត្រាឈ្មោះរួច ក៏ធ្វើការអប់រំណែនាំ ហើយបានប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យ ដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ តាមការណែនាំរបស់ក្រសួងសុខាភិបាល ៕

## កម្លាំងប៉ុស្តិ៍នគរបាលបឹងសាគូ នៃវរសេនាតូចនគរបាលព្រំដែនគោក៩១១ ឃាត់បានពលរដ្ឋ ២នាក់ លួចឆ្លងដែនពីថៃចូលមកកម្ពុជា

http://nokorwatnews.com/ 18/05/2021

ខេត្តបន្ទាយមានជ័យ៖ កម្លាំងប៉ុស្តិ៍នគរបាលបឹងសាគូ នៃវរសេនាតូចនគរបាលព្រំដែនគោក៩១១ ឃាត់បានពលរដ្ឋ២នាក់ លួចឆ្លងដែនពីថៃចូលមកកម្ពុជាដោយខុសច្បាប់បញ្ជូនទៅធ្វើចត្តាឡីស័ក កាលពីរំលងអធ្រាត្រ ឈានចូលថ្ងៃទី១៧ ខែ ឧសភា ឆ្នាំ ២០២១។

លោក រស់ ពិសិដ្ឋ នាយប៉ុស្តិ៍បឹងសាគូ បានឲ្យដឹងថា ពលរដ្ឋទាំងពីរនាក់នេះ ១.ឈ្មោះ ផត ត្រា ភេទប្រុស អាយុ២០ឆ្នាំ រស់នៅភូមិបាលិលេយ្យ១ សង្កាត់ប៉ោយប៉ែត.ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និង២.ឈ្មោះ សាំង រតនា ភេទប្រុស អាយុ១៨ឆ្នាំ រស់នៅក្នុងភូមិប្រជាធម្មកើត សង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ លោក រស់ ពិសិដ្ឋ បានប្រាប់ថា ខណៈដែលកម្លាំងប៉ុស្តិ៍នគរបាលបឹងសាគូ នៃវរសេនាតូចនគរបាលព្រំដែនគោក៩១១ ចុះល្បាតតាមបន្ទាត់ព្រំដែនកម្ពុជា.ថៃ ទប់ស្កាត់បទល្មើស ជាពិសេសការទប់ស្កាត់ពលករលួចឆ្លងដែនដោយខុសច្បាប់ ដើម្បីការពារការរាតត្បាតនៃជំងឺកូវីដ-១៩ ក៏ប្រទះឃើញពលរដ្ឋពីរនាក់ ដើរក្នុងសួនសត្វស្ថិតនៅក្នុងភូមិព្រៃព្រិច សង្កាត់.ក្រុងប៉ោយប៉ែត ឃាត់ខ្លួនសួរនាំទើបដឹងថាពួកគាត់លួចចុះមកពីប្រទេសថៃមកកម្ពុជា។ លោកបញ្ជាក់ថា ក្រោយពីសួរនាំរួច បញ្ជាក់ថា ពលរដ្ឋទាំងពីរនាក់ ពិតជាបានលួចឆ្លងដែនពីថៃមកកម្ពុជាពិតប្រាកដមែន ទើបទំនាក់ទំនងខាងផ្នែកកងទ័ពទាហាន នាំពួកគាត់ទៅធ្វើចត្តាឡីស័ក នៅវិទ្យាល័យនិមិត្តក្រុងប៉ោយប៉ែត៕

## ប្រជាពលរដ្ឋមកពីប្រទេសថៃ ចូលតាមច្រកអន្តរជាតិសម្រាប់ខេត្តសៀមរាប សរុបចំនួន២៤នាក់

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាប៖ គិតចាប់ពីម៉ោង ០៦៖០០នាទីល្ងាច ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ រហូតដល់ម៉ោង ០៦៖០០ នាទីល្ងាច ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២១ របស់ក្រុមការងារប្រចាំការ (នៅច្រកអន្តរជាតិប៉ោយប៉ែត ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ) មានប្រជាពលរដ្ឋមកពីប្រទេសថៃ សម្រាប់ខេត្តសៀមរាប សរុបចំនួន ២៤នាក់ ស្រី ១១នាក់ កុមារា ០២នាក់ កុមារី ០២នាក់ ដូចខាងក្រោម៖

១-ម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ សរុបចំនួន ០៧នាក់ ស្រី ០២នាក់ កុមារា ០១នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ សរុបចំនួន ១៤នាក់ ស្រី ០៧នាក់ កុមារា ០១នាក់ កុមារី ០២នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ សរុបចំនួន ០៣នាក់ ស្រី ០២នាក់ កុមារា ០០នាក់ កុមារី ០០នាក់។ សរុបរួមចំនួន ២៤នាក់ ស្រី ១១នាក់ កុមារា ០២នាក់ កុមារី ០២នាក់។

សូមបញ្ជាក់៖ គាត់ទាំង ២៤នាក់ ក្រុមគ្រូពេទ្យបញ្ជូនទៅមណ្ឌលចត្តាឡីស័ក មកសាលាគរុកោសល្យ និងវិទ្យាល័យសម្តេចឪ ខេត្តសៀមរាប៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធួ កុសល

## កងកំលាំងទាហានបូរ៉ាផា សហការជាមួយអាជ្ញាធរប៉ូលីសប៉ុស្តិ៍តាប្រាក់យ៉ា ចាប់ពលករខ្មែរ ចំនួន12 នាក់

https://www.facebook.com/Khmer.Channel.kh/ ទឹកចិត្តពលករឆ្លងដែន ថ្ងៃទី16 ឧសភា 2021

ថ្ងៃទី16 ខែឧសភា ឆ្នាំ2021 វេលាម៉ោង06៖00នាទីព្រឹក កងកំលាំងទាហានបូរ៉ាផា សហការជាមួយអាជ្ញាធរប៉ូលីសប៉ុស្តិ៍តាប្រាក់យ៉ា ចាប់ពលករខ្មែរចំនួន12នាក់ លួចឆ្លងដែនចូលប្រទេសថៃ ដោយខុសច្បាប់នៅក្នុងស្រុកតាប្រាក់យ៉ា ខេត្តស្រះកែវ។ ពលករទាំងអស់ត្រូវបានបញ្ជូនទៅកាន់អធិការស្រុកតាប្រាក់យ៉ាដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

## កងកំលាំងទាហានប៉ូរ៉ាផា បានចាប់ពលករខ្មែរចំនួន6នាក់ លួចឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់

https://www.facebook.com/Khmer.Channel.kh/ ទឹកចិត្តពលករឆ្លងដែន ថ្ងៃទី 16 ឧសភា 2021

ថ្ងៃទី16 ខែឧសភា ឆ្នាំ2021 វេលាម៉ោង05៖30នាទីព្រឹក កងកំលាំងទាហានប៉ូរ៉ាផា បានចាប់ពលករខ្មែរចំនួន6នាក់ លួចឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់នៅក្នុងភូមិខៅឳន ឃុំខ្លងហាត ស្រុកខ្លងហាត ខេត្តស្រះកែវ។ ពលករទាំងអស់ត្រូវបានប្រគល់ឲ្យទាហានកម្ពុជាទទួលយកទៅចាត់វិធានការបន្ត។

# ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១

## ប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៣៤នាក់

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃអាទិត្យ ទី១៦ ខែឧសភា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៣៤នាក់ ស្រី ១៧នាក់ ក្នុងនោះកុមារ ០០នាក់ កុមារី ០០នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៣នាក់ ស្រី ២នាក់ កុមារ ១នាក់ កុមារី ២នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ២នាក់ ស្រី ១នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ១៤នាក់ ស្រី ៨នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ៦នាក់ ស្រីចំនួន ៣នាក់ កុមារចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ៦នាក់ ប្រុសចំនួន ៣នាក់ ស្រីចំនួន ៣នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៣១នាក់ ស្រី ១៧នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## តុលាការខេត្តឃុំខ្លួនបុរសម្នាក់ ពាក់ព័ន្ធនឹងការនាំពលករ ៨ ម្នាក់បម្រុងឆ្លងដែនចូលប្រទេសថៃ

https://m.postkhmer.com/ គឹម សារុំ 17 May 2021 | 18:17 ICT

**បន្ទាយមានជ័យ៖** បុរសជាមេខ្យល់ម្នាក់ដែលនាំពលករឆ្លងដែនទៅថៃ ត្រូវបានតុលាការខេត្តបន្ទាយមានជ័យឃុំក្នុងពន្ធនាគារកាលពីថ្ងៃទី ១៦ ឧសភា បន្ទាប់ពីសមត្ថកិច្ចចាប់ខ្លួនបាន ១ ថ្ងៃ នៅក្នុងភូមិត្នោតរលួង ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ខណៈពលករប្រុសស្រី ៨ នាក់ទៀត ត្រូវនាំយកទៅធ្វើចត្តាឡីស័ក។

លោកវរសេនីយ៍ទោ ព្រហ្ម ថេង ប្រធានមន្ទីស្រាវជ្រាវ និងបង្ក្រាបបទល្មើសនៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យប្រាប់នៅថ្ងៃទី ១៧ ឧសភាថា បុរសមេខ្យល់នោះឈ្មោះ វណ្ណៈ វណ្ណ អាយុ ២៩ ឆ្នាំ រស់នៅភូមិតាគ្រី ឃុំគ្រី ស្រុកកំរៀង ខេត្តបាត់ដំបង។ បុរសរូបនេះត្រូវបានថៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តបន្ទាយមានជ័យ ចេញដីកាឃុំខ្លួននៅពន្ធនាគារខេត្ត កាលពីថ្ងៃទី ១៦ ឧសភា។ ចំណែកពលករ ៨ នាក់ ត្រូវបានបញ្ជូនទៅទីតាំងធ្វើចត្តាឡីស័កក្នុងខេត្ត។ លោកបានថ្លែងថា៖ «ជនសង្ស័យត្រូវបានចោទពីបទនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែនតាមបញ្ញត្តិមាត្រា១១ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ»។

មាត្រា១១ នៃច្បាប់នេះចែងថា ជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ក្នុងគោលដៅឬនាំយកទៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧ទៅ ១៥ ឆ្នាំ។ ដូច្នេះបើតុលាការរកឃើញថាជននេះពិតជាបានប្រព្រឹត្តមែននោះនឹងត្រូវជាប់ពន្ធនាគារដូចដែលច្បាប់បានបញ្ញត្តិខាងលើប្រាកដ។ លោក ព្រហ្ម ថេង បានរំឭកប្រាប់ថា ការឃាត់ខ្លួននេះ បានធ្វើឡើងកាលពីយប់រំលងអធ្រាត្រឈានចូលថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០២១ ខណៈជនសង្ស័យជាមេខ្យល់រូបនេះកំពុងនាំផ្លូវពលករបម្រុងឆ្លងដែនទៅប្រទេសថៃ ត្រង់ចំណុចភូមិសាស្ត្រ អូរព្រំដែន ភូមិត្នំរូង ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ ការបង្ក្រាបនេះក្រោមការបញ្ជាផ្ទាល់ពីលោក ឧត្តមសេនីយ៍ ត្រី ជឹម ប៊ុនអាន មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្តបន្ទាយមានជ័យ។

បើតាមលោក ព្រហ្ម ថេង ដែលបានស្រង់សម្ដីលោកវរសេនីយ៍ឯក រិទ្ធ រ៉ម មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងខេត្តបន្ទាយមានជ័យបានឲ្យដឹងថា សមត្ថកិច្ចបានឃាត់ខ្លួនជនសង្ស័យជាមេខ្យល់ម្នាក់នេះនិងរថយន្ត១គ្រឿង ជាមួយពលករប្រុសស្រីចំនួន៨នាក់ទៀត (ប្រុស ៣ ស្រី ៥ នាក់) ខណៈកំពុងបម្រុងឆ្លងដែនចូលទៅដីថៃ។ លោកបញ្ជាក់ប្រាប់ថា កិច្ចប្រតិបត្តិការនេះ គឺកម្លាំងកងរាជអាវុធហត្ថរបស់លោកបានសហការជាមួយកម្លាំងនគរបាលការពារព្រំដែនគោក និងសមត្ថកិច្ចស្រុកម៉ាឡៃ ដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់បំណងទប់ស្កាត់ការឆ្លងជំងឺកូវីដ ១៩។ លោក ព្រហ្ម ថេង បានបញ្ជាក់បន្ថែមថា ជាញឹកញាប់គេសង្កេតឃើញថា នៅភូមិសាស្ត្រឃុំបឹងបេង ក្នុងស្រុកម៉ាឡៃ គឺមេខ្យល់តែងនាំពលករឆ្លងដែនចូលប្រទេសថៃ ពីព្រោះតំបន់នោះនៅជាប់ព្រំដែនកម្ពុជា-ថៃ ហើយជាដីគោកផង។ ហេតុដូច្នេះហើយទើបបង្កលក្ខណៈងាយស្រួលដល់មេខ្យល់ក្នុងការនាំមនុស្សចូលទៅក្នុងដីថៃ។ តែក៏ត្រូវបានកម្លាំងសមត្ថកិច្ចដែលយាមកាមចាប់ខ្លួនបានជាបន្តបន្ទាប់ផងដែរ៕

## ពលករខ្មែរ ត្រឡប់ពីប្រទេសថៃ ចូលតាមច្រកអូរបីជាន់ និងច្រកបឹងត្រកួន ១ថ្ងៃ ជាង ១០០នាក់

https://kohsantepheapdaily.com.kh/ Banteay Meanchey ១៨ ខែ ឧសភា ឆ្នាំ ២០២១ ម៉ោង ២២:៣៣

បន្ទាយមានជ័យ៖ ពលករខ្មែរត្រឡប់ពីប្រទេសថៃ បានចូលតាមច្រកអូរបីជាន់ និងច្រកបឹងត្រកួន រយៈពេល ១ថ្ងៃ មានចំនួន ១១៨នាក់ នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១នេះ។

លោក លី សុវណ្ណារិទ្ធ អភិបាលស្រុកអូរជ្រៅ បានប្រាប់ថា នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១នេះ ក្រុមការងារមណ្ឌលសំចតច្រកអូរបីជាន់ ក្នុងឃុំអូរបីជាន់ ស្រុកអូរជ្រៅ បានទទួលប្រជាពលរដ្ឋខ្មែរ ជាពលករខ្មែរ ដែលត្រឡប់ពីប្រទេសថៃ មានចំនួន ១០៨នាក់ ស្រី ៤នាក់ ក្នុងនោះ មានប្រជាពលរដ្ឋ ខេត្តបន្ទាយមានជ័យ ៦០នាក់ ខេត្តបាត់ដំបង ៨នាក់ ខេត្តកំពង់ធំ ១១នាក់ ខេត្តកំពត ២នាក់ ខេត្តពោធិ៍សាត់ ៤នាក់ ខេត្តសៀមរាប ៣នាក់ ខេត្តតាកែវ ២នាក់ ខេត្តឧត្តរមានជ័យ ៧នាក់ ខេត្តប៉ៃលិន ម្នាក់។

លោក អែម សុខា អភិបាលស្រុកថ្មពួក បានបញ្ជាក់ថា ក្រុមការងារមណ្ឌលសំចតច្រកបឹងត្រកួន ស្រុកថ្មពួក បានទទួលប្រជាពលរដ្ឋខ្មែរជាពលករត្រឡប់ពីប្រទេសថៃ តាមច្រកតំបន់ព្រំដែនបឹងត្រកួន ស្រុកថ្មពួក នៅថ្ងៃទី

១៧ ខែឧសភា ឆ្នាំ២០២១នេះ មានចំនួន ១០នាក់ ស្រី ៦នាក់ រស់នៅខេត្តសៀមរាប ៤នាក់ ខេត្តស្វាយរៀង ៣នាក់ ខេត្តតាកែវ ២នាក់ ខេត្តបាត់ដំបង ម្នាក់។

អភិបាលស្រុកទាំងពីរ បានប្រាប់ថា ចំពោះប្រជាពលរដ្ឋខ្មែរ ដែលត្រឡប់ពីប្រទេសថៃ តាមច្រកអូរបីជាន់ ស្រុកអូរជ្រៅ និងច្រកតំបន់ព្រំដែនបឹងត្រកួន ស្រុកថ្មពួក ដែលត្រូវបានក្រុមការងារ នៅមណ្ឌលសំចត ទទួលពិនិត្យសុខភាព ហើយអប់រំណែនាំ និងជូនអាហារពួកគាត់ រួចត្រូវបានដឹកជញ្ជូនតាមរថយន្តក្រសួងការពារជាតិ ទៅដាក់តាមមណ្ឌល ដើម្បីធ្វើចត្តាឡីស័ក រយៈពេល ១៤ថ្ងៃ៕ ប៊ុន ធឿន

## ឃាត់បានតែពលករប្រុសស្រី ២៦នាក់ បម្រុងឆ្លងដែន ទៅប្រទេសថៃ តែមេខ្យល់ ចាប់មិនទាន់

https://kohsantepheapdaily.com.kh/ ១៨ ខែ ឧសភា ឆ្នាំ ២០២១ ម៉ោង ២៣:១៩

បន្ទាយមានជ័យ៖ ប៉ូលិសឃាត់បានពលករប្រុសស្រី ២៦នាក់ ដែលបម្រុងឆ្លងដែនទៅប្រទេសថៃ តែមេខ្យល់ ចាប់មិនទាន់បាន។ គេសង្ឃឹមថា មិនអោយមេខ្យល់រួចខ្លួនឡើយ។ ពលករទាំងនោះ ត្រូវបានឃាត់ខ្លួន នៅវេលាម៉ោង ៤ និង៤៥នាទី ល្ងាចថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១ តាមបន្ទាត់ព្រំដែនភូមិសាស្រ្តឃុំអូរបីជាន់ ស្រុកអូរជ្រៅ។

លោកវរៈសេនីយ៍ឯក សូរ ចាន់រី មេបញ្ជាការនគរបាលវរៈការពារព្រដែនគោកលេខ៩១១ បានប្រាប់ថា ការឃាត់ខ្លួនពលករទាំងនេះ ធ្វើឡើងតាមការណែនាំ និងវិធានការពីលោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ ដើម្បីពង្រឹងការទប់ស្កាត់បទល្មើសតាមបន្ទាត់ព្រំដែននិងទប់ស្កាត់ពលករលួចឆ្លងខុសច្បាប់ ហើយគេចវេះធ្វើចត្តាឡីស័ក។ វិធានការនេះ ដើម្បីបង្ការ និងទប់ស្កាត់កូវីដ១៩ មិនអោយរីករាលដាលក្នុងសហគមន៍។ លោកបានបញ្ជាក់ថា កម្លាំងនគរបាលវរៈការពារព្រំដែនគោកលេខ៩១១ បានសហការជាមួយមន្រ្តីនគរបាលប៉ុស្តិ៍អូរបីជាន់ និងកម្លាំងយោធាការពារព្រំដែនលេខ៥០៣ បានចេញល្បាតតាមបន្ទាត់ព្រំដែន ក៏បានប្រទះឃើញប្រជាពលរដ្ឋចំនួន ២៦នាក់ (ស្រី ១៣នាក់) ជាពលករ បម្រុងលួចឆ្លងដែនទៅប្រទេសថៃ ដោយខុសច្បាប់ តាមច្រករបៀងក្នុងភូមិសាស្រ្ត ឃុំអូរបីជាន់ ស្រុកអូរជ្រៅ។

លោកវរៈសេនីយ៍ឯក សូរ ចាន់រី បានបញ្ជាក់ថា ក្រោយឃាត់ខ្លួន ពលករប្រុសស្រីចំនួន ២៦នាក់នេះ ជាប្រជាពលរដ្ឋ មកពីខេត្តកំពង់ធំ ៦នាក់ ខេត្តបាត់ដំបង ១១នាក់ (ស្រី ៨នាក់) ខេត្តតាកែវ ម្នាក់ ខេត្តបន្ទាយមានជ័យ ៨នាក់ (ស្រី ៤នាក់)។ អ្នកទាំងនោះ ត្រូវបានបញ្ជូនទៅសាកសួរ ហើយតាមចម្លើយពួកគាត់ គោលបំណងឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃ តាមរយៈមេខ្យល់ ដោយយកថ្លៃ ម្នាក់ ៥០០០ បាត ធានាជូនដល់កន្លែងធ្វើការ និងរកការងារអោយធ្វើ។ តែពួកគាត់ មិនបានស្គាល់ឈ្មោះ មេខ្យល់ឡើយ។ ក្រោយពេលសាកសួរហើយ ពលករទាំងនោះ ត្រូវបានបញ្ជូន ទៅដាក់មណ្ឌលធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃ៕ ប៊ុន ធឿន

## មេបញ្ជាការយោធភូមិភាគទី៥ អញ្ជើញចុះសួរសុខទុក្ខ កងកម្លាំងឈរតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់ និងទប់ស្កាត់ការឆ្លងរីករាលដាល នៃជំងឺកូវីដ-១៩ក្នុង ទិសទី១ ខេត្ត បន្ទាយមានជ័យ

http://nokorwatnews.com/ 18/05/2021

ខេត្តបន្ទាយមានជ័យ៖ នៅព្រឹកថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១ ឧត្តមសេនីយ៍ឯក ឯក សំអួន មេបញ្ជាការរងកងទ័ពជើងគោក មេបញ្ជាការយោធភូមិភាគទី៥ រួមដំណើរមាន ឧត្តមសេនីយ៍ទោ សេង ធារិន មេបញ្ជាការរងនាយសេនាធិការ; មេបញ្ជាការទិសទី១ មេបញ្ជាការអង្គភាពស្នងការនគរបាល មេបញ្ជាការកងរាជអាវុធហត្ថខេត្ត និងអាជ្ញាធរខេត្ត ក្រុង បានអញ្ជើញចុះសួរសុខទុក្ខ សំណេះសំណាល និងចែកអំណោយដល់កងកម្លាំងប្រដាប់

អាវុធគ្រប់ប្រភេទ ដែលកំពុងបំពេញភារកិច្ចទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់ និងទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ នៅតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រយោធភូមិភាគទី៥ ។ នៅក្នុងឱកាសនោះឧត្តមសេនីយ៍ឯក ឯក សំអួន មេបញ្ជាការរងកងទ័ពជើងគោក មេបញ្ជាការយោធភូមិភាគទី៥ បានមានប្រសាសន៍ថា ក្នុងបេសកកម្មរបស់លោកនៅពេលនេះ គឺមានគោលបំណង៥៖

គោលបំណងទី១ គឺលោកចុះមកដើម្បីសាកសួរសុខទុក្ខកងកម្លាំង ដែលកំពុងបំពេញភារកិច្ចទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់ និងទប់ស្កាត់ការឆ្លងរីករាលដាល នៃជំងឺកូវីដ-១៩ នៅតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ។ លោកបានកោតកោតសរសើរខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការរបស់កងកម្លាំងទាំង៣ប្រភេទ ដែលបានសហការគ្នាល្អដែលក្នុងទីតាំងឈរជើងតាមបន្ទាត់ព្រំដែន។ នេះគឺជាបេសកកម្មដ៏ពិសេសដែលថ្នាក់លើប្រគល់ជូន ជាពិសេសសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលសម្តេចមានការព្រួយបារម្ភខ្លាំងចំពោះការឆ្លងរីករាលដាល នៃជំងឺកាចសាហាវកូវីដ-១៩ចូលទៅក្នុងប្រទេស ហើយសម្តេចក៏បានបញ្ជាដាក់ពង្រាយកម្លាំងតាមខ្សែបន្ទាត់ព្រំដែនទប់ស្កាត់ជំងឺឆ្លងនេះតាមរយៈពលករឆ្លងដែនខុសច្បាប់ឲ្យខានតែបាន។ មេបញ្ជាការរងកងទ័ពជើងគោកនិងជា មេបញ្ជាការយោធភូមិភាគទី៥ បានបន្តថា

គោលបំណងទី២ គឺក្តាប់សភាពការណ៍រួមទិសទី១យោធភូមិភាគទី៥ ចំពោះកងទ័ពកងទ័ពដាច់ខាត គឺមិនត្រូវមានមនោសញ្ចេតនា និងទទួលយកផលលាភ របស់ពួកមេខ្យល់ និងបងប្អូនពលករដែលមានបំណងវិលត្រឡប់មកចូលក្នុងទឹកដីកម្ពុជា គឺមូលហេតុដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺ កូវីដ-១៩។

គោលបំណងទី៣ ទាក់ទងទៅនឹង ជម្រក សូមឲ្យប្តូរពីការប្រក់តង់មកជា ជារោងសង្ក័សី ។

គោលបំណងទី៤ សំណូមពរឲ្យបងប្អូនកងទ័ពរក្សាសុខភាពឲ្យបានល្អ ហើយសូមអនុវត្តន៍ឲ្យបាននិងប្រកាន់ខ្ជាប់ទៅនឹងការអនុវត្ត ៣ការពារនិង ៣កុំ ។

គោលបំណងទី៥ ចូលរួមបន្តមានទំនាក់ទំនងល្អជាមួយប្រទេសជិតខាង និងស្វែងរកវិធីសាស្រ្តដ៏ល្អដើម្បីទប់ស្កាត់ពលករដែលវិលត្រឡប់មកចូលប្រទេសកម្ពុជា។

ជាចុងក្រោយលោកមេបញ្ជាការសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់សប្បុរសជនដែលបានឧបត្ថម្ភដល់បងប្អូនកងកម្លាំងទាំង៣ប្រភេទ នៅទិសទី ១ ខេត្តបន្ទាយមានជ័យ , ចំពោះអំណោយរបស់សប្បុរសជនរួមមានមី ៥៦កេសធំ ,ទឹកសុទ្ធ ១៦០០ យួរ ,ត្រីខកំប៉ុង ៥០កេស,ទឹកត្រីទឹកស៊ីអ៊ីវ ២៥០យួរ និង ទឹកប្រាក់ចំនួន ៥លានរៀល ដែលបានឧបត្ថម្ភ ដោយ អភិបាលខេត្តបន្ទាយមានជ័យ ចំនួន ៣លានរៀល , មេបញ្ជាការកងរាជអាវុធហត្ថ ១លានរៀល , ស្នងការនគរបាលខេត្ត ១លានរៀល ផងដែរ៕

## ប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ២៨នាក់

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃអង្គារ ទី១៨ ខែឧសភា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ២៨នាក់ ស្រី ១៤នាក់ ក្នុងនោះកុមារា ១នាក់ កុមារី ២នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ១នាក់ ស្រី ១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១៥នាក់ ស្រី ៨នាក់ កុមារា ១នាក់ កុមារី ២នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ២នាក់ ស្រី ១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ១០នាក់ ស្រី ៨នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារា ចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ប្រុសចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ២៨នាក់ ស្រី ១៤នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## មេខ្យល់២នាក់ ត្រូវបានឃាត់ខ្លួន ខណៈលួចនាំពលករឆ្លងដែនចូលទឹកដីថៃខុសច្បាប់

https://www.kampucheathmey.com/ ថ្ងៃអង្គារ ១៨ ឧសភា ២០២១ ដោយ Kang Tola

បាត់ដំបង ៖ មេខ្យល់នាំពលករចូលទៅប្រទេស ដោយខុសច្បាប់ចំនួន២នាក់ ត្រូវបានកម្លាំងកងពលតូចថ្មើរជើងលេខ៥៣ បានចុះល្បាតប្រទះឃើញឃាត់ខ្លួន នៅថ្ងៃទី១៧ ខែឧសភាម្សិលមិញខណៈ ដែលពួកគេកំពុងនាំពលករឆ្លងដែនចូលប្រទេសថៃ ដែលទង្វើនេះ បានផ្គើននិងវិធានការទប់ស្កាត់ជំងឺកូវីដ-១៩របស់រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងសុខាភិបាលផង។

លោកវរសេនីយ៍ឯក សុខ ដែន មេបញ្ជាការរងកងពលតូចថ្មើរជើងលេខ៥៣ បានឲ្យដឹងនៅថ្ងៃទី១៨ ខែឧសភានេះថា ការបង្ក្រាបករណីខាងលើកងកម្លាំងខិតខំបំពេញភារកិច្ចតាមបទបញ្ជាដែលថ្នាក់ដឹកនាំកំពូលៗពីថ្នាក់ជាតិបានដាក់ចេញនូវវិធានការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ ក៏ដូចជាទប់ស្កាត់រាល់បទល្មើសមួយចំនួនទៀត និងស្របជាមួយនឹងបទបញ្ជារបស់លោកឧត្តមសេនីយ៍ត្រីកែវ សេង មេបញ្ជាការកងពលផងដែរ ដែលតែងជំរុញឲ្យដល់បណ្តាកងកម្លាំងតាមគោលដៅតំបន់ព្រំដែនទាំងអស់ ត្រូវរឹតបន្តឹងនូវបញ្ហាសន្តិសុខព្រំដែនឲ្យកាន់តែមានប្រសិទ្ធភាព។ ប្រភពខាងលើបន្តថា ជនសង្ស័យជាមេខ្យល់ទាំង២នាក់មានឈ្មោះ មាន រឿន ភេទប្រុស អាយុ ៣៤ឆ្នាំ និងម្នាក់ឈ្មោះ សេង តាក់ ភេទប្រុស អាយុ៣៤ឆ្នាំ ទាំង២នាក់រស់នៅក្នុងភូមិបឹងរាំងឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង ឃាត់ខ្លួនបាននៅចំណុចដើមអំពិលទឹកបិតក្នុងភូមិសាស្ត្រភូមិស្វាយ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង ខណៈដែលពួកគេកំពុងធ្វើសកម្មភាពនាំពលករ។

លោកវរសេនីយ៍ឯក សុខ ដែន បានបញ្ជាក់បន្តថា ដោយមានការអនុវត្តភារកិច្ចចុះល្បាតតាមបន្ទាត់ព្រំដែនដើម្បីពង្រឹងនូវវិធានការទប់ស្កាត់ការរីករាលដាលជំងឺកូវី១៩ គឺ២៤ម៉ោងលើ២៤ម៉ោង គិតចាប់តាំងពីទទួលផែនការពង្រឹងវិធានការទប់ស្កាត់នូវជំងឺកូវីដ១៩មក កម្លាំងកងពលតូចថ្មើរជើងលេខ៥៣ បានបំពេញកាតព្វកិច្ចបើកការស្រាវជ្រាវនាំខ្លួនមេខ្យល់មកដល់ពេលនេះបានចំនួន១៣នាក់ បញ្ជូនបន្តអនុវត្តតាមនីតិវិធី។ ចំណែកប្រជាពលរដ្ឋដែលជាពលករបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កបានចំនួនជិត១០.០០០នាក់ផងដែរ៕ *ដោយ ៖ សៅ សារិទ្ធ*

## វៀតណាមនឹងចាត់វិធានការ បណ្តេញពលករបរទេសខុសច្បាប់ចេញ

https://thmeythmey.com/ 18, May 2021 , 8:29 pm

ជាតិ៖ រដ្ឋាភិបាលវៀតណាម នឹងចាត់វិធានការផ្លូវច្បាប់បណ្តេញពលករបរទេសខុសច្បាប់ ដែលកំពុងធ្វើការនៅក្នុងប្រទេសខ្លួន ដើម្បីជៀសវាងការប្រើប្រាស់ពលករខុសច្បាប់។ លើសពីនេះ អាជ្ញាធរមូលដ្ឋានវៀតណាម នឹងពង្រឹងការត្រួតពិនិត្យលិខិតអនុញ្ញាតការងារ នៅតាមសហគ្រាស និងគ្រឹះស្ថាននានា។ នេះបើតាមសេចក្តីជូនដំណឹងរបស់ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំវៀតណាមចេញថ្ងៃទី១៧ ឧសភា។

ក្រសួងការងារយុទ្ធជន និងសង្គមកិច្ចវៀតណាម បានស្នើអាជ្ញាធរខេត្ត និងក្រុងនានារបស់ខ្លួន ឲ្យពិចារណាលើការបណ្តេញពលករបរទេស ដែលគ្មានលិខិតអនុញ្ញាតធ្វើការងារត្រឹមត្រូវ ឬមិនគោរពវិធានការចេញចូល។ ស្ថានទូតកម្ពុជាបានបញ្ជាក់យ៉ាងដូច្នេះថា៖ «ករណីនេះ អាជ្ញាធរមូលដ្ឋាន និងទីភាក់ងារពាក់ព័ន្ធនានា នឹងពង្រឹងការត្រួតពិនិត្យលិខិតអនុញ្ញាតការងារ និងចំនួនពលករបរទេសនៅតាមសហគ្រាស និងគ្រឹះស្ថាននានា ដោយអនុវត្តតាមនីតិវិធីជាធរមាន ដើម្បីជៀសវាងការប្រើប្រាស់ពលករខុសច្បាប់នៅវៀតណាម»។

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជាក់ប្រាប់សារព័ត៌មានថ្មីៗ តាមទូរស័ព្ទនៅថ្ងៃទី១៨ ឧសភាថា នៅប្រទេសវៀតណាម ពុំមានពលករខ្មែរខុសច្បាប់ធ្វើការ និងរស់នៅឡើយ។ ដូច្នេះ ចំណាត់ការរបស់ប្រទេសវៀតណាមនេះ លោក កុយ គួង ថា មិនមានបញ្ហាប្រឈមដល់ពលករកម្ពុជាទេ។ «ខ្ញុំទទួលព័ត៌មានពីខាងស្ថានទូតយើងនៅទីនោះ គឺយើងអត់មានពលករខុសច្បាប់ទៅធ្វើការវៀតណាមទេកន្លងមក គឺកម្រមានពលករយើងទៅធ្វើខុសច្បាប់ណាស់នៅវៀតណាម។ ប៉ុន្តែក្រែងយើងភ្លាប់ព័ត៌មានមិនឬចន្លោះអី មានតិចតួចយើងមិនដឹងអី។ ប៉ុន្តែមានពលរដ្ឋយើងមួយចំនួនតិចតួចទៅរស់នៅទីនោះ។ ដូច្នេះ មិនមានបញ្ហាប្រឈមឡើយ នៅពេលវៀតណាមចាត់វិធាការនេះ(បណ្តេញពលករខុសច្បាប់)»។ នេះជាការលើកឡើងរបស់អ្នកនាំពាក្យក្រសួងការបរទេស ដោយអះអាងថា កន្លងមក អាជ្ញាធរវៀតណាម ធ្លាប់ជូនដំណឹងពីពលរដ្ឋខុសច្បាប់ទៅវៀតណាម ហើយមន្ត្រីទូតកម្ពុជាក៏ជួយសម្របសម្រួលដោះស្រាយហើយដែរ។ ប៉ុន្តែករណីនេះ គឺមានចំនួនតិចតួចបំផុត ពោលគឺត្រឹម២ឬ៣ករណីប៉ុណ្ណោះ៕

# ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១

## ឃាត់ខ្លួនមេខ្យល់ម្នាក់ និងពលករ០៦នាក់ទៀតដែលនាំគ្នាលួចឆ្លងដែនចូលទឹកដីថៃ

https://www.kampucheathmey.com/ ថ្ងៃពុធ ១៩ ឧសភា ២០២១ដោយ Sokhom Khon

នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១ កម្លាំងសមត្ថកិច្ចបានស្ទាក់ចាប់មេខ្យល់ចំនួនម្នាក់ ដែលល្មើសច្បាប់នាំពលករខ្មែរជាច្រើននាក់ ឆ្លងដែនចូលក្នុងទឹកដីថៃដោយខុសច្បាប់ ល្មើសវិធានការ ការទប់ស្កាត់ជំងឺកូវីដ១៩ ពីខាងក្រៅ ខណៈប្រទេសថៃកំពុងប្រឈមខ្លាំង។ សមត្ថកិច្ចដែលបានចុះអនុវត្តបញ្ជាក់ឲ្យដឹងនៅថ្ងៃទី១៩ ខែឧសភានេះថា កិច្ចប្រតិបត្តិការបង្ក្រាបករណីខាងលើនេះ ធ្វើឡើងខណៈដែលកម្លាំងចម្រុះតំបន់ព្រំដែនបានចុះល្បាតដើម្បីត្រួតពិនិត្យនិងពង្រឹងបទល្មើសតាមបណ្តាច្រកតូចធំ តាមបន្ទាត់ព្រំដែន ហើយប្រទះឃើញក៏ធ្វើការឃាត់ខ្លួនមេខ្យល់១នាក់ ខណៈកំពុងនាំពលករឆ្លងដែនចូលប្រទេសថៃ។

ជនសង្ស័យមានឈ្មោះ អ៊ុល ផេន ភេទប្រុស អាយុ២៥ឆ្នាំ មានទីលំនៅភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យស្រុកសំពៅលូន ខេត្តបាត់ដំបង និងជាមុខសញ្ញាចាស់។ នៅថ្ងៃកើតហេតុបានធ្វើសកម្មភាពលួចនាំមនុស្សចំនួន០៦នាក់ឆ្លងអូរព្រំដែនកម្ពុជា-ថៃ សំដៅចូលទៅក្នុងទឹកដីថៃ កាត់តាមច្រករបៀងជាប់ភូមិសាស្រ្តចំណុចភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន។ ក្រោយកម្លាំងសមត្ថកិច្ចបានឃាត់ខ្លួនមេខ្យល់១នាក់ រួមនឹងពលករ០៦នាក់ ខាងលើ

សមត្ថកិច្ចបានធ្វើការអប់រំណែនាំដល់ពលករ ហើយពិនិត្យសុខភាពចំណែកឯជនសង្ស័យជាមេខ្យល់ខាងលើ ត្រូវកម្លាំងចម្រុះអនុវត្តកសាងសំណុំរឿងដើម្បីបញ្ជូនបន្តទៅកាន់ការិយាល័យជំនាញ ចាត់ការតាមនីតិវិធី៕ សៅ សារិទ្ធ

## លោក ណុប ដារ៉ា អភិបាលរង ខេត្តបាត់ដំបង ក្រើនរំលឹកដល់មន្ត្រី តាមច្រកព្រំដែន ត្រូវពង្រឹងសមត្ថភាព ការងារបង្ក្រាប បទល្មើសឆ្លងដែន ខុសច្បាប់គ្រប់ប្រភេទ

https://dap-news.com/ ByPH104 Posted on May 19, 2021

ភ្នំពេញ ៖ លោក ណុប ដារ៉ា អភិបាលរងខេត្តបាត់ដំបង នាព្រឹកថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១ បានអញ្ជើញដឹកនាំកិច្ចប្រជុំ ពិភាក្សាស្តីពីការបង្ក្រាបបទល្មើសឆ្លងដែនខុសច្បាប់គ្រប់ប្រភេទ នៅក្នុងភូមិសាស្ត្រស្រុកកំរៀង ស្រុកភ្នំព្រឹក ស្រុកសំពៅលូន និងស្រុកសំឡូត ដែលមានការចូលរួម ពីអភិបាលស្រុកពាក់ព័ន្ធ និងប្រធានច្រកពាក់ព័ន្ធ និងកម្លាំងគ្រប់ប្រភេទ ប្រចាំការនៅតាមបន្ទាត់ព្រំដែន ។ ក្នុងឱកាសនោះដែរ លោក ណុប ដារ៉ា បានក្រើនរំលឹកដល់មន្ត្រី ដែលមានតួនាទីភារកិច្ច នៅព្រំដែនឱ្យពង្រឹងសមត្ថភាពការងាររបស់ខ្លួន ជាពិសេសត្រូវគោរពឱ្យបាននូវបទបញ្ជាផ្ទៃក្នុងរបស់អង្គភាព និងផែនការរបស់ថ្នាក់ដឹកនាំខេត្តដាក់ឱ្យ អនុវត្តក្នុងការទប់ស្កាត់ឱ្យបានរាល់បទល្មើសឆ្លងដែនខុសច្បាប់គ្រប់ប្រភេទ ជាពិសេសត្រូវចាប់មេខ្យល់ ដែលនាំពលករចេញ-ចូលក្នុងប្រទេស និងអ្នកពាក់ព័ន្ធឱ្យបាន ដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាលទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ។ លោកបានបន្តទៀតថា បើសិនជាលោកស្រាវជ្រាវ រកឃើញមន្ត្រីណាម្នាក់ ដែលឈរជើងនៅទីនោះ មានការឃុបឃិត ឬពាក់ព័ន្ធគ្នាជាមួយមេខ្យល់នាំ ពលករឆ្លងដែនខុសច្បាប់ លោកនឹងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ ដើម្បីសុំការផ្លាស់ប្តូរមន្ត្រីនោះចេញ ឬ អាចនឹងត្រូវទទួលខុស ត្រូវចំពោះមុខច្បាប់ទៀតផង ៕

## សមត្ថកិច្ចព្រំដែនកម្ពុជា-ថៃជួបពិភាក្សារកដំណោះស្រាយទប់ស្កាត់ការឆ្លងដែនខុសច្បាប់របស់ប្រជាពលរដ្ឋ

http://cambodiapolice.com/policekh/ 1:09 pm 19 ឧសភា 2021

ខេត្តបាត់ដំបង ៖ នាព្រឹកថ្ងៃពុធ ៨កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០២១ ដោយបានការអនុញ្ញាតពីលោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការគរបាលខេត្តបាត់ដំបង លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់តាំងកម្លាំងប៉ុស្តិ៍នគរបាលព្រំដែនភ្នំព្រឹក ដឹកនាំដោយលោកអនុសេនីយ៍ទោ មួន លន នាយរងប៉ុស្តិ៍ សហការជាមួយកម្លាំងយោធាកងអនុសេនាធំទី៣, វរសេនាតូចលេខ១ ដឹកនាំដោយលោកវរសេនីយ៍ត្រី អ៊ួន សុឃឿន ជាមេបញ្ជាការ «គ» បានជួបពិភាក្សាជាមួយភាគីយោធាថៃកងអនុសេនាធំលេខ១៣០៣ដឹកនាំដោយលោកអនុសេនីយ៍ឯក ភិស៊ីត-ប៉ាក់វ៉ាក់វ៉ាត់ស៊ុកស៊ីន (មេបញ្ជាការ)នៅវេលាម៉ោង ៩:០០នាទីព្រឹក។

ក្នុងកិច្ចជួបពិភាក្សានេះ ខាងភាគីថៃសំណូមពរសុំឲ្យកម្លាំងខាងភាគីកម្ពុជា ជួយទប់ស្កាត់ប្រជាពលរដ្ឋកុំឲ្យចូលលួចដឹករ៉ែមាស និងកាប់ឈើក្នុងទឹកដីរបស់ថៃបន្តទៀត ។ ចំណែកខាងភាគីកម្ពុជាបានសំណូមពរទៅខាងភាគីថៃ បើមានប្រជាពលរដ្ឋឆ្លងដែនពីប្រទេសថៃចូលមកកម្ពុជា សូមជួយ ផ្តល់ដំណឹងឲ្យភាគីកម្ពុជាផង ។ ភាគីទាំងពីរបានឯកភាពលើសំណូមពរទាំង២ ។

កិច្ចជំនួបពិភាក្សានេះធ្វើឡើងនៅមាត់អូរព្រំដែនត្រង់ចំណុចភូមិសាស្ត្រភូមិគគី ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង បានបញ្ចប់នៅវេលាម៉ោង៩និង៤០ នាទីនាថ្ងៃខែឆ្នាំដដែលដោយភាពស្និទ្ធស្នាលបំផុត ៕

# សាលាដំបូងខេត្តបាត់ដំបង បានសាកសួរបុរសជាមេខ្យល់ម្នាក់ រឿងនាំពលរដ្ឋខ្មែរឆ្លងដែនទៅថៃ

https://www.postkhmer.com/ គីម សារុំ | Publication date 19 May 2021 | 18:54 ICT

**បាត់ដំបង:** អយ្យការអមសាលាដំបូងខេត្តបាត់ដំបង នៅថ្ងៃទី១៩ ខែឧសភានេះ បានសាកសួរបុរសជាមេខ្យល់ម្នាក់ រឿងគម្រោងនាំពលរដ្ឋខ្មែរ៦នាក់ ចេញទៅប្រទេសថៃ តាមច្រករបៀងព្រំដែន ក្នុងតំបន់ ស្រុកសំពៅលូន ខេត្តបាត់ដំបង។ លោក ផាន់ រតនា អ្នកនាំពាក្យសាលាដំបូងខេត្តបាត់ដំបង មិនអាចទាក់ទង ដើម្បីសុំការបញ្ជាក់ពីចំណាត់ការរបស់តុលាការបានទេនៅថ្ងៃទី១៩ឧសភានេះ។

ទោះជាយ៉ាងណាក៏ដោយ លោក ប៊ិន វណ្ណារ៉ា ប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង បានថ្លែងឱ្យដឹងនៅថ្ងៃទី១៩ ឧសភាថា ជនសង្ស័យឈ្មោះ អ៊ុល ផេន ភេទប្រុស អាយុ២៥ឆ្នាំ រស់នៅភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង។ លោក វណ្ណា ថ្លែងថា៖«តុលាការកំពុងសាកសួរបុរសមេខ្យល់នោះហើយ ព្រោះគាត់ជាប់ពាក់ព័ន្ធបទល្មើសជួញដូរមនុស្ស។ នៅក្នុងកំណត់ហេតុបញ្ជូនទៅតុលាការ គឺខ្ញុំចោទបឋមពីបទការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែនតាមមាត្រា១១ នៃច្បាប់ស្ដីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ បើយោងតាមបញ្ញត្តមាត្រា១១ នៃច្បាប់នេះ អាចនឹងត្រូវជាប់ពន្ធនាគារពី៧ទៅ១៥ឆ្នាំ»។ លោក វណ្ណា ថ្លែងថា លោក សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង តែងតែដាក់បទបញ្ជាយ៉ាងម៉ឺងម៉ាត់ក្នុងការទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់ ដើម្បីបង្ការការឆ្លងរាលដាលជំងឺកូវីដ១៩។

ជាក់ស្ដែងកាលពីថ្ងៃទី១៨ខែឧសភា កម្លាំងចម្រុះសឹករងស្រុកសំពៅលូន ឈរជើងការពារតាមខ្សែបន្ទាត់ព្រំដែនក្នុងស្រុកសំពៅលូន ដូចជាវរសេនាតូចលេខ៨១៧និង៥៣៣និងកម្លាំងមូលដ្ឋាន បានធ្វើការឃាត់ខ្លួនបានមេខ្យល់ម្នាក់និងពលករជាមនុស្សពេញវ័យ ស្រី២នាក់និងប្រុសម្នាក់ រួមកូនៗរបស់ពួកគេ មានក្មេងប្រុស២នាក់ និងក្មេងស្រីម្នាក់ អំឡុងពេលដែលពួកគេ បម្រុងឆ្លងដែនចូលប្រទេសថៃ តាមច្រករបៀងជាប់ភូមិសាស្រ្តចំណុចភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន។ លោកបន្ថែមថា ក្រោយឃាត់ខ្លួន សមត្ថកិច្ចបាននាំក្រុមជនរងគ្រោះទៅសាកសួរ នៅអធិការដ្ឋាននគរបាលស្រុកសំពៅលូននិងនាំយកទៅមណ្ឌលចត្តាឡីស័ក ចំណែកបុរសជាមេខ្យល់ឈ្មោះ អ៊ុល ផេន បានបញ្ជូនទៅស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង។

ដោយឡែកកាលពីល្ងាចថ្ងៃទី១៧ ឧសភា នៅឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ សមត្ថកិច្ចចម្រុះប្រចាំការនៅស្រុកអូរជ្រៅ បានឃាត់ខ្លួនពលករប្រុសស្រីចំនួន២៦នាក់ បម្រុងឆ្លងដែនចូលប្រទេសថៃ ក្នុងនោះមានមនុស្សស្រីចំនួន១៣នាក់។

លោក ម៉ាន់ ធី អធិការរងនគរបាលស្រុកអូរជ្រៅ បានឱ្យដឹងនៅថ្ងៃទី១៩ ឧសភាថា ពលករប្រុសស្រីទាំង២៦នាក់នោះ គ្មានមេខ្យល់ណាជាអ្នកនាំផ្លូវនោះទេ គឺពួកគាត់ប្រមូលផ្ដុំគ្នាបម្រុងឆ្លងដែនចូលប្រទេសថៃដោយខ្លួនឯងទេ។ ប៉ុន្តែដោយសារមានបុរសម្នាក់ជាអ្នកឃ្វាលគោឃើញពួកគេ កំពុងអង្គុយប្រមូលផ្ដុំគ្នាលាក់ខ្លួនក្បែរគុម្ពឫស្សីស្ថិតក្បែរច្រករបៀងក្នុងភូមិសាស្រ្តឃុំអូរបីជាន់ ស្រុកអូរជ្រៅ ហើយពលរដ្ឋរូបនោះ បានរាយការណ៍ប្រាប់សមត្ថកិច្ចតែម្ដង។ លោកបន្ថែមថាពលករប្រុសស្រីទាំង២៦នាក់ ពួកគេមកពីខេត្តកំពង់ធំ បាត់ដំបង បន្ទាយមានជ័យ និងខេត្តតាកែវ ដែលពួកគេត្រូវបានបញ្ជូនទៅតាមខេត្តរៀងៗខ្លួនវិញអស់ហើយ ដើម្បីធ្វើចត្តាឡីស័ក៕

## គ្រប់ផ្នែកពាក់ព័ន្ធ ត្រូវរួមគ្នាលុបបំបាត់អំពើហិង្សា ព្រមទាំងការរំលោភបំពានលើស្ត្រី និងកុមារ

https://www.rasmeinews.com/ 19 May, 20210

**ដោយៈ បូកគោ/កំពត:** *អំពើហិង្សាក្នុងគ្រួសារ ក៏ដូចជាការរំលោភបំពានផ្លូវភេទ នៅតែបន្តកើតមាន ហើយជនរងគ្រោះភាគច្រើនជាស្ត្រី និងអនីតិជន។ ដូច្នេះ គ្រប់សមត្ថកិច្ចពាក់ព័ន្ធត្រូវរួមសហការគ្នា ដើម្បីលុបបំបាត់ឱ្យអស់ចំពោះរូបភាពដែលសង្គមស្អប់ខ្ពើមទាំងនោះ។ នេះជាការអំពាវនាវរបស់អភិបាលខេត្តកំពត នៅព្រឹកថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១ ក្នុងពិធីប្រកាសតែងតាំងប្រធានមន្ទីរកិច្ចការនារីខេត្ត។*

លោក ជាវ តាយ បានមានប្រសាសន៍ថា បច្ចុប្បន្នអំពើហិង្សាក្នុងគ្រួសារ និងការរំលោភបំពានផ្លូវភេទនៅតែបន្តកើតមានជាហូរហែ។ ទាំងនេះ បានបង្កក្តីកង្វល់យ៉ាងធ្ងន់ធ្ងរសម្រាប់សង្គមជាតិ។ ក្នុងនោះភាគច្រើននៃជនរងគ្រោះ គឺកុមារីជាអនីតិជន និងស្ត្រី។ ដូច្នេះ មន្ត្រីនៃមន្ទីរកិច្ចការនារីត្រូវសហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ កងកម្លាំងសមត្ថកិច្ច ក៏ដូចជាគ្រប់ផ្នែកពាក់ព័ន្ធលើកិច្ចការស្ត្រី និងកុមារក្នុងការរួមគ្នាបំបាត់ឱ្យអស់នូវរូបភាពអវិជ្ជមានទាំងនោះ។ លោកអភិបាលខេត្តបានបន្តថា ដើម្បីទទួលបានភាពជោគជ័យសម្រាប់ផែនការសកម្មភាពខាងលើ មន្ទីរកិច្ចការនារីដែលជាអង្គភាពជំនាញត្រូវបង្កើនការផ្សព្វផ្សាយច្បាប់ស្តីពីកិច្ចការពារស្ត្រី និងអនីតិជនឱ្យបានទូលំទូលាយដល់គ្រប់មូលដ្ឋានទូទាំងខេត្តបន្ថែមទៀត។ ពិសេសត្រូវតាមដានឃ្លាំមើលឱ្យគ្រប់ជ្រុងជ្រោយចំពោះស្ត្រី និងកុមារដែលងាយទទួលរងនូវការរំលោភបំពាន ក៏ដូចជាប្រឈមនឹងអំពើហិង្សានានា។

តាមរបាយការណ៍បានបញ្ជាក់ថា កន្លងមក មន្ទីរកិច្ចការនារីខេត្តកំពត បានខិតខំយកចិត្តទុកដាក់ក្នុងការកសាងសមត្ថភាព ក៏ដូចជាការពារចំពោះស្ត្រី និងកុមារ។ ជាក់ស្តែង ក្នុងឆ្នាំ២០២០ កន្លងទៅ មន្ទីរកិច្ចការនារីបានអន្តរាគមន៍អំពើហិង្សាក្នុងគ្រួសារបានចំនួន៨ករណី ដោយបញ្ជូនទៅតុលាការ៥ករណី និងសម្របសម្រួលក្រៅប្រព័ន្ធតុលាការចំនួន៣ករណី។ ជាមួយគ្នានោះ ក៏បានអន្តរាគមន៍ចំពោះអំពើរំលោភបំពានផ្លូវភេទ៥ករណី រួចបញ្ជូនទៅតុលាការតាមនីតិវិធី៕

## ប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៣៥នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃពុធ ទី១៩ ខែឧសភា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៣៥នាក់ ស្រី ២០នាក់ ក្នុងនោះកុមារា ០០នាក់ កុមារី ០០នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៦នាក់ ស្រី ៤នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ២២នាក់ ស្រី ១២នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង៖ ចំនួន ៦នាក់ ស្រីចំនួន ៤នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ១នាក់ ប្រុសចំនួន ០០នាក់ ស្រីចំនួន ១នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៣៥នាក់ ស្រី ២០នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអស់ហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## លោកណុប ដារ៉ា ចុះពិនិត្យបញ្ហាប្រឈមទូទៅ នៅតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ

https://dap-news.com/ Posted on May 20, 2021

ភ្នំពេញ៖ លោក ណុប ដារ៉ា អភិបាលរងខេត្តបាត់បំបង និងជាប្រធានក្រុមការងារ ស្រាវជ្រាវបង្ក្រាបបទល្មើសឆ្លងដែនគ្រប់ភេទ តំណាងឱ្យលោក ងួន រតនៈ អភិបាលខេត្ត និងជាប្រធាន គណៈបញ្ជាការឯកភាពខេត្តបាត់ដំបង នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ បានអញ្ជើញចុះពិនិត្យមើល បញ្ហាប្រឈមទូទៅ និងកងកម្លាំងគ្រប់ប្រភេទដែល ឈរជើង តាមខ្សែរបន្ទាត់ព្រំដែន ក្នុងភូមិសាស្ត្រច្រកអន្តរជាតិភ្នំដី ស្រុកសំពៅលូន ដោយមានការចូលរួមពី លោកអភិបាលស្តីទីស្រុក ប្រធានស្នាក់ការច្រកភ្នំដី និង មេបញ្ជាការ នៃកងកម្លាំង គ្រប់ប្រភេទផងដែរ។

សូមជម្រាបថាលោក ណុប ដារ៉ា បានអញ្ជើញចុះផ្ទាល់ក្នុងភូមិសាស្ត្រ ច្រកអន្តរជាតិភ្នំដី ស្រុកសំពៅលូន ដើម្បី រកបញ្ហាប្រឈមទូទៅនៅតំបន់នោះ ដែលកន្លងមកមានករណីមេខ្យល់នាំពលករចេញ-ចូល ក្នុងប្រទេសខុសច្បាប់ និងបទល្មើសផ្សេងគ្រប់រូបភាព និងជាពិសេសពិនិត្យ មើលជីវភាព រស់នៅរបស់ កងកម្លាំង គ្រប់ប្រភេទ ដែលឈរជើង នៅទីនោះ ២៤ម៉ោងលើ ២៤ម៉ោង ដែលមានការខ្វះខាតស្បៀង ជម្រកថ្នាំ ព្យាបាល និងទឹកប្រើប្រាស់ប្រចាំថ្ងៃ ផងដែរ។ ជាចុងក្រោយលោក ណុប ដារ៉ា បានកោតសរសើរដល់ កងកម្លាំង ជួរមុខគ្រប់ប្រភេទដែល បានលះបង់ កម្លាំងកាយចិត្ត និង ឃ្លាតឆ្ងាយពីគ្រួសារ ជាទីស្រលាញ់ ដើម្បីជាតិមាតុភូមិ ហើយដោយ ឃើញផ្ទាល់ នូវទុក្ខលំបាក របស់កងកម្លាំង ជួរមុខ លោកមានប្រសាសន៍ថា នឹងពាំនាំបញ្ហាប្រឈមទាំង នេះ ជូនថ្នាក់ដឹកនាំខេត្ត ដើម្បី ដោះស្រាយជូនក្នុងពេល ឆាប់ៗនេះ។

## ទាហានថៃ ចាប់ពលករខ្មែរ ១២នាក់បញ្ជូនមកកម្ពុជាវិញ ខណៈលួចឆ្លងដែនខុសច្បាប់

http://nokorwatnews.com/ 20/05/2021

ក្រុងប៉ោយប៉ែត៖ កងកម្លាំងទាហានបូផារបស់ថៃ បានចាប់ឃុំពលករខ្មែរលួចឆ្លងដែនខុសច្បាប់ចំនួន១២នាក់ នៅព្រំដែនស្រុកតាព្រះយ៉ា ខេត្តស្រះកែវ ខណៈពួកគេបានសារភាពថាលួចឆ្លងដែនទៅធ្វើការនៅក្នុងខេត្តនគររាជសីម៉ា ។ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ នេះអ្នកសារព័ត៌មានថៃរាយការណ៍ថា ដោយមានបញ្ជាពីមេបញ្ជាការកងកម្លាំងបូផា(ថៃ) ឲ្យទប់ស្កាត់ពលករខ្មែរ ដែលលួចឆ្លងចូលប្រទេសដោយខុសច្បាប់ រួមទាំងការពារការរាតត្បាតរបស់ជំងឺកូវីដ-១៩ កងកម្លាំងសមត្ថកិច្ច តាព្រះយ៉ា បានចាត់កម្លាំងល្បាតតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ នឹងឃ្លាំមើលនៅបរិវេណភូមិ ទ័ពសៀម ឃុំតាព្រះយ៉ា ស្រុកតាព្រះយ៉ា ខេត្តស្រះកែវ ហើយបានពិនិត្យឃើញពលករខ្មែរមួយក្រុមកំពុងធ្វើដំណើរតាមច្រករបៀង ពីខាងប្រទេសកម្ពុជាចូល ត្រង់បរិវេណបង្គោលឡាក់48P TA 584361 ភូមិទ័ព សៀម ឃុំតា ព្រះយ៉ា ទើបសមត្ថកិច្ចចាប់ឃុំខ្លួនសួរនាំតែម្តង។

ក្រោយធ្វើពីការត្រួតពិនិត្យ រកឃើញថា ពួកនេះជាជនជាតិខ្មែរទាំងអស់មានគ្នា១២នាក់ ក្នុងនោះប្រុស៥ ស្រី៥ និងក្មេង២នាក់ ។ ក្រោយពីសួរនាំជំហានដំបូងជនទាំងនេះបានសារភាពថា ពួកគាត់ត្រូវទៅស៊ីឈ្នួលធ្វើការចំការដំឡូង ក្នុងទឹកដីខេត្តនគរ រាជសីម៉ា។ ម្លោះហើយទើបសមត្ថកិច្ចនាំខ្លួនទៅសួរនាំនៅទីបញ្ជាការកងវរយទី៣និងបានអនុវត្តតាមវិធានការសុខាភិបាល វាស់កម្តៅ តែជាលទ្ធផលត្រួតពិនិត្យឃើញធម្មតាទាំង១២នាក់។ បន្ទាប់មកសមត្ថកិច្ចបានធ្វើកំណត់ហេតុបញ្ជូនឲ្យវិលត្រឡប់មកប្រទេសកម្ពុជាវិញ តាមប៉ុស្តិ៍ត្រួតពិនិត្យ ៨.38 ភូមិ ណូន ម៉ាកមុន ស្រុកគោកឃ្សូង ប្រកអូរបីជាន់ ខេត្តបន្ទាយមានជ័យ ហើយសមត្ថកិច្ចកម្ពុជានៅទីនោះបានទទួលយកទៅធ្វើចត្តាឡីស័កផងដែរ ៕

## សមត្ថកិច្ចចម្រុះល្បាតការពារសន្តិសុខ ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ- ចូលខុសច្បាប់តាមខ្សែបន្ទាត់ក្នុងស្រុកសំពៅលូន

http://cambodiapolice.com/policekh/ 7:05 pm 20 ឧសភា 2021

ខេត្តបាត់ដំបង ៖ ដោយទទួលបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន និងការត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ-ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ។

ជាក់ស្តែង នៅថ្ងៃព្រហស្បតិ៍ ៩កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០២១ លោកវរសេនីយ៍ឯក ពៅ ថាវុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពាព្រំដែនគោកលេខ ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ ជាមេបញ្ជាការ បានចាត់តាំងកម្លាំងប៉ុស្តិ៍នគរបាលព្រំដែនកូនភ្នំ ដឹកនាំដោយលោកអនុសេនីយ៍ទោ ខៀវ-រ៉ាត់ នាយប៉ុស្តិ៍ស្តីទី រួមជាមួយកម្លាំងផ្នែកស៊ើបការណ៍ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ សហការជាមួយកម្លាំងយោធាកងអនុសេនាធំគាំទ្រ, វរសេនាតូច៥៣៣ ដឹកនាំដោយលោកវរសេនីយ៍ត្រី ប៉ាត ណារ៉ុង មេបញ្ជាការកងអនុសេនាធំគាំទ្រ, កម្លាំងយោធាកងអនុសេនាធំទី១, វរសេនាតូចលេខ១ លោកអនុសេនីយ៍ទោ ស៊ឹង ស៊ិត មេបញ្ជាការរង-គ បានចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ចាប់ពីចំណុចនិយាមកា ០២១៤២៦២-១៤៨៥៩២២ ដល់ ០២១៤២៦៩-១៤៨៦២១៨ ក្នុងភូមិសាស្ត្រស្រុកសំពៅលូន ៕

## ពលករចំណាកស្រុក កំពុងស្វែងរកជំនួយពីស្ថានទូតកម្ពុជាក្នុងប្រទេសថៃ

https://www.khmertimeskh.com/ យិន សឿម / ខ្មែរថាមស៍

ពលករចំណាកស្រុកកម្ពុជានៅប្រទេសថៃ កំពុងស្វែងរកជំនួយពីស្ថានទូតកម្ពុជាប្រចាំទីក្រុងបាងកកដើម្បីជួយដល់ការរស់នៅប្រចាំថ្ងៃរបស់ពួកគេក្នុងកំឡុងពេលជំងឺរាតត្បាតកូវីដ-១៩។

លោក នន់ សារិន ដែលធ្វើការនៅក្នុងរោងចក្រត្រីខកំប៉ុងនៅខេត្តសាមុតប្រាកាន ប្រទេសថៃ បាននិយាយកាលពីម្សិលមិញថា គាត់កំពុងតស៊ូដើម្បីរស់បន្ទាប់ពីបានឆ្លងជំងឺកូវីដ-១៩។ ក្នុងអំឡុងពេលនៃការព្យាបាល ក្រុមគ្រួសាររបស់គាត់មិនមានប្រាក់ចំណូលហើយរោងចក្រមិនបានផ្តល់ជំនួយ ដូច្នេះទើបគាត់ស្នើសុំជំនួយពីស្ថានទូតកម្ពុជា។ គាត់បាននិយាយថា៖«សូមជួយរកដំណោះស្រាយសម្រាប់ពលករចំណាកស្រុកដែលកំពុងជាប់គាំង»។ គាត់មានដើមកំណើតមកពីស្រុកកំចាយមារ ខេត្តព្រៃវែង បាននិយាយថាកន្លែងដែលគាត់រស់នៅសព្វថ្ងៃនេះមានពលករចំណាកស្រុកជាច្រើនកំពុងប្រឈមនឹងបញ្ហាដូចគាត់។

លោក គុយ បូរ៉ា ដែលធ្វើការនៅរោងចក្រជាមួយគាត់បាននិយាយថា រោងចក្របានបិទទ្វារកាលពីសប្តាហ៍មុនដោយសារជំងឺរាតត្បាតនេះ ហើយឥឡូវនេះគាត់អាចមានលទ្ធភាពទិញអង្ករនិងស៊ុតសម្រាប់គ្រួសាររបស់គាត់ប៉ុណ្ណោះ។

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេសបានប្រាប់កាសែតខ្មែរថាមស៍ថា ពលករខ្មែរនៅប្រទេសថៃចាំបាច់ត្រូវរាយការណ៍ព័ត៌មាននេះទៅស្ថានទូតជាមុនសិន។ ទោះយ៉ាងណាលោកនឹងពិនិត្យជាមួយស្ថានទូតដើម្បីដឹងថាតើស្ថានទូតបានទទួលសំណើណាមួយពីពលករចំណាកស្រុកដែរឬទេ។ លោកបាននិយាយថា៖«យើងមានសមត្ថភាពជួយកម្មកររបស់យើងដើម្បីដោះស្រាយបញ្ហា»។

មន្ត្រីកម្មវិធីការងារធ្វើចំណាកស្រុករបស់មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស (CENTRAL) លោកឌី ថេហូយ៉ា បាននិយាយថាលោកមិនបានដឹងថាតើមានពលករចំណាកស្រុកប៉ុន្មាននាក់នៅក្នុងប្រទេសថៃបានធ្វើតេស្តរកកូវីដ-១៩នោះឡើយ ដូច្នេះលោកមិនអាចអត្ថាធិប្បាយអំពីបញ្ហានេះបានទេ៕

## នគរបាល៩១១ប៉ុស្តិ៍ព្រៃគប់ ឃាត់ខ្លួនពលករខ្មែរ៥នាក់ ពីរគោលដៅផ្សេងគ្នា

https://www.facebook.com/FridayDailyNews/ 21/05/2021

បន្ទាយមានជ័យ÷ នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង០៤:៣០នាទី កំលាំងប៉ុស្តិ៍ព្រៃគប់ ដឹកនាំដោយលោក អនុសេនីយ៍ឯក ស៊ា សៅឌី នាយប៉ុស្តិ៍ និងកំលាំងយោធាកងពលតូចថ្មើរជើងលេខ៥១ ប្រចាំការណ៍នៅគោលដៅ ប៉ុស្តិ៍តូច២ ស្ថិតនៅភូមិ ព្រៃគប់ សង្កាត់ ផ្សារកណ្តាល ក្រុងប៉ោយប៉ែត បានឃាត់ខ្លួនប្រជាពលរដ្ឋ០៤នាក់ ដែលគាត់ទៅធ្វើជាកម្មករ ដាំអំពៅ ដក-ដាំជំឡូង នៅភូមិ ណាំគាង ឃុំ ប៉ារ៉ៃ ស្រុក អរញ្ញ ខេត្ត ស្រះកែវ ហើយបានលួចឆ្លងដែនពីថៃ មកខ្មែរ៖

១-ឈ្មោះ ហែម ហឿន ភេទ ប្រុសអាយុ៦០ ឆ្នាំ(កំដៅ៣៦.៦) ២-ឈ្មោះ រី ចេក ភេទ ប្រុស អាយុ ៤៨ឆ្នាំ (កំដៅ៣៦.៥) ៣-ឈ្មោះ សុទ្ធ រស្មី ភេទ ប្រុស អាយុ ២៤ ឆ្នាំ (កំដៅ៣៧.៤) ៤-ឈ្មោះ វឿន ដាលិ ភេទ ប្រុស អាយុ ១៧ឆ្នាំ (កំដៅ៣៦.៩) អ្នកទាំង០៤នាក់រស់នៅភូមិ ទំនប់ក៥ សង្កាត់ប៉ោយប៉ែត ក្រុង ប៉ោយប៉ែត ។

ក្នុងនោះនៅថ្ងៃដដែលវេលាម៉ោង៦:០០នាទី នគរបាលប៉ុស្តិ៍ព្រៃគប់ បានឃាត់ខ្លួនយុវជនម្នាក់ទៀត ជាកម្មករដាំជំឡូង-ដកជំឡូង និងដាំអំពៅ នៅភូមិថងខាំម៉ាន់ ខេត្តស្រះកែវ លួចឆ្លងដែនពី ថៃ ចូល កម្ពុជា ឈ្មោះ ស៊ីម សែន ភេទប្រុស អាយុ២១ឆ្នាំ មានកម្តៅ ៣៦.៩ រស់នៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត បន្ទាប់មកកំលាំងនគរបាល៩១១ប៉ុស្តិ៍ព្រៃគប់ និងយោធាកងពល៥១ បានបញ្ជូនពលករខ្មែរទាំង០៥នាក់នោះ ទៅមណ្ឌល ចត្តាឡីសក្តិ៍ វិទ្យាល័យនិមិត្ត សង្កាត់ និមិត្ត នៅព្រឹកថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ ។

## រដ្ឋបាលខេត្តឧត្តរមានជ័យ រកឃើញជំងឺកូវីដ១៩ លើពលករខ្មែរ១២ករណីទៀត ដែលឆ្លងដែនពីថៃចូលកម្ពុជា

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ២០ ឧសភា ២០២១ដោយ Kang Tola

ឧត្តរមានជ័យ ៖ រដ្ឋបាលខេត្តឧត្តរមានជ័យ នៅយប់ថ្ងៃទី២០ ខែឧសភានេះ បានចេញសេចក្តីប្រកាសព័ត៌មាន ស្តីពីការរកឃើញជំងឺកូវីដ១៩ លើពលករខ្មែរចំនួន១២ករណី បន្ថែមទៀតដែលបានឆ្លងដែនពីប្រទេសថៃចូលមកប្រទេសកម្ពុជា។ នេះបើតាមសេចក្តីប្រកាសព័ត៌មាន ដែលបណ្តាញព័ត៌មាន យើងទទួលបាន៕ *ចាន់ ជី*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តឧត្តរមានជ័យ**

# សេចក្ដីប្រកាសព័ត៌មាន
# ស្ដីពី
# ការរកឃើញជំងឺកូវីដ-១៩ លើពលករខ្មែរចំនួន ១២ករណីបន្ថែមទៀត ដែលបានឆ្លងដែនពីប្រទេសថៃចូលមកប្រទេសកម្ពុជា

រដ្ឋបាលខេត្តឧត្តរមានជ័យ មានកិត្តិយសសូមជម្រាបជូនសាធារណជន និងបងប្អូនប្រជាពលរដ្ឋក្នុងខេត្តឧត្តរមានជ័យ មេត្តាជ្រាបថា យោងតាមលទ្ធផលធ្វើតេស្តរហ័ស(RAPID TEST) របស់ក្រុមការងារឆ្លើយតបបន្ទាន់របស់មន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្ត បានរកឃើញវិជ្ជមានកូវីដ-១៩ ចំនួន **១២ករណីបន្ថែមទៀត** លើពលករខ្មែរដូចខាងក្រោម៖

១.ស្ត្រីពលករខ្មែរឈ្មោះ **ហ៊ាត ចន្ទី** អាយុ ៣៤ឆ្នាំ រស់នៅភូមិត្រពាំងថ្លាន់ ឃុំព្រាល ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ជាពលករធ្វើការនៅខេត្តសាមុតប្រាកាន ប្រទេសថៃ បានឆ្លងដែនចូលកម្ពុជានៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ ២០២១ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងត្រូវបានបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្ត។ ដោយឡែកបុរសជាប្ដីឈ្មោះ ឈឿន រ៉ា អាយុ ៣៨ឆ្នាំ (មានអាការៈក្អក ហៀរសំបោរ) ដែលបានធ្វើដំណើរមកជាមួយគ្នាត្រូវបានបញ្ជូនទៅតាមដានសុខភាព និងធ្វើចត្តាឡីស័កនៅមណ្ឌលចត្តាឡីស័ក ផ្ទះសំណាក់ឧត្ដមរដ្ឋា (QC2) និងពលករឈ្មោះ ពៅ ចាន់ណា ភេទស្រី អាយុ ២២ឆ្នាំ រស់នៅភូមិស្ពានទំនាប ឃុំឫស្សី ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលបានរួមដំណើរមកជាមួយមានអាការៈទន់ដៃ ទន់ជើង ត្រូវបានបញ្ជូនទៅថែទាំព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្ត ក្រោយទទួលបានលទ្ធផលតេស្តរហ័ស (RAPID TEST) អវិជ្ជមានទាំងពីរនាក់។

២.ពលករខ្មែរវិលត្រឡប់ពីខេត្តសាមុតប្រាកាន ប្រទេសថៃបានឆ្លងដែនចូលមកប្រទេសកម្ពុជានៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងត្រូវបានបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តចំនួន ១១នាក់ រួមមាន៖

- ឈ្មោះ ស្រស់ រិទ្ធ ភេទស្រី អាយុ ៣៤ឆ្នាំ មានទីលំនៅភូមិខ្នា ឃុំគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប
- ឈ្មោះ ទូច ចាន់នី ភេទស្រី អាយុ ៤៧ឆ្នាំ មានទីលំនៅភូមិ២ សង្កាត់២ ក្រុងខេមរៈភូមិន្ទ ខេត្តកោះកុង
- ឈ្មោះ ណាង សុភាព ភេទស្រី អាយុ ៣៧ឆ្នាំ មានទីលំនៅភូមិសង្គម ឃុំដំរីស្លាប់ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ
- ឈ្មោះ រឿន រ៉ាត់ ភេទប្រុស អាយុ ៣៨ឆ្នាំ មានទីលំនៅភូមិបឹងល្ងៀស សង្កាត់អូរកន្ធរ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ

- ឈ្មោះ គី វណ្ណនី ភេទស្រី អាយុ ៣៣ឆ្នាំ មានទីលំនៅភូមិបឹងលៀស សង្កាត់អូរកន្ធរ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ
- ឈ្មោះ ផ ធុយ ភេទប្រុស អាយុ ៣១ឆ្នាំ មានទីលំនៅភូមិសង្គម ឃុំដំរីស្លាប់ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ
- ឈ្មោះ ណាង សុខា ភេទស្រី អាយុ ៣១ឆ្នាំ មានទីលំនៅភូមិសង្គម ឃុំដំរីស្លាប់ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ
- ឈ្មោះ វ៉ាញ ណៃ ភេទស្រី អាយុ ២៨ឆ្នាំ មានទីលំនៅភូមិគោកគ្រប់ ឃុំតាម៉ឺន ស្រុកថ្មគោល ខេត្តបាត់ដំបង
- ឈ្មោះ រឹម ប៊ុនឡេង ភេទប្រុស អាយុ ២២ឆ្នាំ មានទីលំនៅភូមិព្រៃខ្លា ឃុំស្រវ៉ា ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង
- ឈ្មោះ ហ៊ិន ឡូត ភេទស្រី អាយុ ៤៣ឆ្នាំ មានទីលំនៅភូមិព្រៃខ្លា ឃុំស្រវ៉ា ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង
- ឈ្មោះ អ៊ី ធីតា ភេទប្រុស អាយុ ៣៥ឆ្នាំ មានទីលំនៅភូមិឬស្សីសាញ់ ឃុំឬស្សីសាញ់ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង

ចំពោះអ្នកពាក់ព័ន្ធផ្សេងទៀត ត្រូវបានបញ្ជូនទៅតាមដានសុខភាព និងធ្វើចត្តាឡីស័កមណ្ឌលចត្តាឡីស័កពហុកីឡដ្ឋានខេត្ត។ បច្ចុប្បន្នក្រុមការងារខេត្តកំពុងតាមដាន និងស្រាវជ្រាវប្រវត្តិធ្វើដំណើររួមជាមួយអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីចាត់ចែងតាមនីតិវិធី។

សូមបញ្ជាក់ជូនថា មកទល់ពេលនេះ ខេត្តឧត្តរមានជ័យមានអ្នកជំងឺកូវីដ-១៩ ចំនួន **២២នាក់ ករណីនាំចូលពីបរទេសចំនួន ២០នាក់ និងករណីពាក់ព័ន្ធព្រឹត្តិការណ៍ "សហគមន៍ ២០ កុម្ភៈ" ចំនួន ២នាក់** បានព្យាបាលជាសះស្បើយចំនួន **៣នាក់** និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តចំនួន **១៩នាក់** ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងបងប្អូនប្រជាពលរដ្ឋជ្រាបជាព័ត៌មាន។ រដ្ឋបាលខេត្ត សង្ឃឹមយ៉ាងមុតមាំថា បងប្អូនប្រជាពលរដ្ឋទាំងអស់នឹងបន្តចូលរួមអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការនានារបស់ក្រសួងសុខាភិបាល និងវិធានការ "**៣ការពារ៖ ត្រូវពាក់ម៉ាស់ ត្រូវលាងដៃជាមួយសាប៊ូ ឬជែល និងត្រូវរក្សាគម្លាត ៣កុំ៖ កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញ-ចូល កុំទៅកន្លែងមានមនុស្សច្រើនកុះករ និងកុំប៉ះពាល់គ្នា**" ស្របតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្ដេចតេជោនាយករដ្ឋមន្ត្រី។

ថ្ងៃព្រហស្បតិ៍ ៩ កើត ខែ[illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ខេត្តឧត្តរមានជ័យ ថ្ងៃទី [illegible] ខែមេសា ឆ្នាំ២០២១

**រដ្ឋបាលខេត្តឧត្តរមានជ័យ**

## ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១
## កម្លាំងសមត្ថកិច្ចចម្រុះឃាត់ខ្លួនម៉ូតូឌុបម្នាក់ដឹកជនជាតិថៃលួចឆ្លងដែន

http://nokorwatnews.com/ 22/05/2021

ខេត្តបន្ទាយមានជ័យ៖ កម្លាំងសមត្ថកិច្ចចម្រុះប្រចាំការនៅលើកំណាត់ផ្លូវជាតិលេខ៥៨ បានឃាត់ខ្លួនម៉ូតូឌុបម្នាក់ ដែលដឹកជនជាតិថៃឆ្លងដែននៅវេលាម៉ោង៥ នឹង១៥នាទី ព្រឹកថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ នៅចំណុចគោលដៅត្រួតពិនិត្យទប់ស្កាត់ប្រជាពលរដ្ឋលួចឆ្លងដែនដោយខុសច្បាប់ លើកំណាត់ផ្លូវជាតិលេខ៥៨ (មុខប៉ុស្តិ៍)។

នគរបាលប្រចាំការនៅចំណុចប៉ុស្តិ៍ខាងលើប្រាប់ថា: ដោយកម្លាំងប៉ុស្តិ៍ចំនួន ៦នាក់ ដឹកនាំដោយលោកវរសេនីយ៍ត្រី ប៉ាក់ សារ៉ាត់ នាយប៉ុស្តិ៍ ការពារព្រំដែនគោក៩១១ បានធ្វើការឃាត់ខ្លួនអ្នកម៉ូតូឌុប១នាក់ ដែលបានដឹក ជនជាតិថៃចំនួន២នាក់ និងវត្ថុតាងម៉ូតូ១គ្រឿង បន្ទាប់ពីការស្រាវជ្រាវនឹងសហការជាមួយកម្លាំងប្រជាការពារអាជ្ញាធរភូមិសិលាខ្មែរនៅថ្ងៃដដែលបានឃាត់ខ្លួនជនជាតិថៃចំនួន២នាក់ស្រីម្នាក់ បន្ថែមទៀត ដែលម៉ូតូឌុប បើកគេចពីកម្លាំងសមត្ថកិច្ច យកទៅទំលាក់ចោលក្នុងភូមិសិលាខ្មែរ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ បានលួចឆ្លងដែនដោយខុសច្បាប់ពីប្រទេសថៃ ចូលមក ទឹកដីកម្ពុជា ។ ក្រោយពីឃាត់ខ្លួនបានភ្លាម និងដោយទទួលបានបទបញ្ជា របស់លោក មេបញ្ជាការ កម្លាំងប៉ុស្តិ៍សិលាខ្មែរ បានយក អ្នកបើកម៉ូតូឌុបជនជាតិខ្មែរ និងជនជាតិថៃទាំង៤នាក់ សរុបចំនួន៥ នាក់ ស្រីម្នាក់ និងវត្ថុតាង ម៉ូតូ១គ្រឿង បញ្ជូនទៅទីបញ្ជាការវរៈ ដើម្បីស្រាវជ្រាវ សួរនាំតាមនីតិវិធីបន្ត ។ បញ្ហាខាងលើនេះលោក សូ ចាន់ណារី មេបញ្ជាការនគរបាលវរៈការពារព្រំដែនគោក៩១១ មានប្រសាសន៍តាមទូរស័ព្ទនៅថ្ងៃដដែលនេះថា ចំពោះជនជាតិថៃនឹងអ្នកម៉ូតូឌុបលោកបានធ្វើកំណត់ហេតុរួចបានបញ្ជូនមកអធិការដ្ឋានក្រុងប៉ោយប៉ែតហើយ ។

## កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការទទួលពលករខ្មែរ៣នាក់ ត្រឡប់មកពីប្រទេសថៃ

http://cambodiapolice.com/policekh/ 12:53 pm 21 ឧសភា 2021

ខេត្តបាត់ដំបង៖ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន ព្រមទាំងការត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ។ ជាក់ស្តែង នៅថ្ងៃសុក្រ ១០កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ លោកវរសេនីយ៍ឯក ពៅ ថាវុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់តាំងកម្លាំងប៉ុស្តិ៍នគរបាលព្រំដែនគីឡូ១៣ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ដឹកនាំដោយលោកអនុសេនីយ៍ទោ ម៉ឹង ម៉េត នាយប៉ុស្តិ៍ស្តីទី សហការជាមួយកម្លាំងយោធាផ្នែកសឹករងស្រុកសំពៅលូន ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន មេបញ្ជាការ .ខ និងកម្លាំងយោធាវរសេនាតូចលេខ ៥៣៣ ដឹកនាំដោយលោកអនុសេនីយ៍ឯក ឯក អំផន មេបញ្ជាការ .គ បានទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ពីយោធាថៃកងអនុសេនាធំលេខ១៣០៥ ត្រង់ចំណុចនៃភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ចំនួន ៣នាក់, ស្រី១នាក់ ។

បន្ទាប់ពីធ្វើការសាកសួរ និងកត់ត្រាឈ្មោះ ធ្វើការអប់រំណែនាំរួច ប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ តាមការណែនាំរបស់ក្រសួងសុខាភិបាល ៕

## ប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៨៥នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃសុក្រ ទី២១ ខែឧសភា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៨៥នាក់ ស្រី ៣៤នាក់ ក្នុងនោះកុមារា ៨នាក់ កុមារី នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ៥នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ២៩នាក់ ស្រី ១៥នាក់ កុមារា ៤នាក់ កុមារី ៣នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៣១នាក់ ស្រី ១៣នាក់ កុមារា ៤នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ១៦នាក់ ស្រី ៦នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ១នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ៣នាក់ ប្រុសចំនួន ៣នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៨៥នាក់ ស្រី ៣៤នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអស់ហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ពលករខ្មែរ៩នាក់លួចចេញទៅប្រទេសថៃត្រូវខាំខយប់ ត្រូវសមត្ថកិច្ចចាប់បានជាមួយមេខ្យល់ម្នាក់ទៀត

https://www.kampucheathmey.com/ ថ្ងៃសៅរ៍ ២២ ឧសភា ២០២១ ដោយ deth leng

ពលករខ្មែរប្រុសស្រី ចំនួន០៩នាក់ ដោយក្នុងនោះមានមេខ្យល់ម្នាក់ផងបានកំពុងធ្វើដំណើរលួចចូលទៅប្រទេសថៃ ដោយខុសច្បាប់នៅយប់រំលងអាធ្រាត្រទៀបភ្លឺត្រូវបានកងកម្លាំងផ្នែកសឹករងស្រុកសំពៅលូនឃាត់ខ្លួន។

មន្ត្រីយោធាវរ:សេនាតូចលេខ៥៣៣ បានឲ្យដឹងថា កិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសខាងលើអនុវត្តឡើងដោយកម្លាំងឈរជើងការពារទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់ នៅយប់ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង០២:១០នាទី បានសហការជាមួយកម្លាំងយោធាផ្នែកសឹករង ស្រុកសំពៅលូន បានទប់ស្កាត់និងឃាត់ខ្លួនពលករខ្មែរបានចំនួន០៩នាក់ក្នុងនោះស្រី០៤នាក់ក្មេងស្រី០១នាក់និងអ្នកនាំផ្លូវម្នាក់ផង(មេខ្យល់)។ ប្រភពខាងលើបន្តថា ក្រោយបានណែនាំអប់រំ និងធ្វើកំណត់ហេតុរួច កម្លាំងបានប្រគល់ពលករខ្មែររួមទាំងមេខ្យល់ឲ្យទៅកម្លាំងជំនាញនៃអធិការដ្ឋាននគបាលស្រុកសំពៅលូនដើម្បីចាត់ការបន្តតាមនីតិវិធី។

សមត្ថកិច្ចនៃអធិការស្រុកបានឲ្យដឹងដែរថា ក្រោយធ្វើការអប់រំណែនាំពលករទាំងអស់ ត្រូវបានអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះវិញ ដោយសារតែពលករទាំងនោះមិនទាន់ចូលដល់ទឹកដីថៃនៅឡើយ និងបានពិនិត្យត្រឹមត្រូវមិនមានបញ្ហាលើសុខភាព។ ចំណែកស្ត្រីមេខ្យល់ម្នាក់ ឈ្មោះ ថាង គៀច អាយុ៣៩ឆ្នាំ រស់នៅភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង សមត្ថកិច្ចកំពុងបន្តនីតិវិធីចាត់ការតាមផ្លូវច្បាប់៕ សៅ សារិទ្ធ

## ប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៥១នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃសៅរ៍ ទី២២ ខែឧសភា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៥១នាក់ ស្រី ២២នាក់ ក្នុងនោះកុមារា ០០នាក់ កុមារី ៣នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ១២នាក់ ស្រី ៦នាក់ កុមារា ០០នាក់ កុមារី ២នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៧នាក់ ស្រី ២នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៤នាក់ ស្រី ២នាក់ កុមារា ០០នាក់ កុមារី ១នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ២៨នាក់ ស្រី ១២នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ប្រុសចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៥១នាក់ ស្រី ២២នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ពលករមកពីថៃ តាមច្រកព្រំដែនខេត្តឧត្តរមានជ័យ ត្រូវបានរកឃើញមានផ្ទុកកូវីដ-១៩ ជាបន្តបន្ទាប់

https://news.btv.com.kh/ 05/21/2021 12:05 PM

ឧត្តរមានជ័យ ៖ ប្រធានមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យ បានឱ្យដឹងថា មានការរកឃើញវិជ្ជមានកូវីដ-១៩ជាបន្តបន្ទាប់ ក្នុងចំណោមពលករ ដែលបានវិលត្រឡប់មកពីប្រទេសថៃ មួយរយៈចុងក្រោយនេះ ដែលនេះជាក្ដីបារម្ភមួយ ដែលតម្រូវឱ្យអាជ្ញាធរ ត្រូវតែមានការប្រុងប្រយ័ត្នត្រួតពិនិត្យឱ្យបានហ្មត់ចត់។

លោកវេជ្ជបណ្ឌិត ឃ្លោក ហួត ប្រធានមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យ បានឱ្យដឹងថា បច្ចុប្បន្ននេះ មានកំណើនពលករខ្មែរឆ្លងដែនមកពីថៃវិញ ដែលកាលពីម្សិលមិញ ពលករជាង១០០នាក់ បានឆ្លងកាត់ព្រំដែនខេត្តនេះ ហើយក្នុងចំនួននេះ គឺរកឃើញវិជ្ជមានកូវីដ-១៩ ចំនួន១១នាក់។ លោកវេជ្ជបណ្ឌិត បានបន្តថា ការរកឃើញវិជ្ជមានកូវីដ-១៩ ជាបន្តបន្ទាប់ ក្នុងចំណោមពលករខ្មែរ ដែលវិលមកពីថៃ បង្កជាក្ដីបារម្ភមួយ ដែលទាមទារឱ្យគ្រប់ស្ថាប័នពាក់ព័ន្ធរិតបន្តឹងបន្ថែមទៀត លើការត្រួតពិនិត្យឲ្យបានហ្មត់ចត់ និងដាក់ពួកគេឱ្យធ្វើចត្តាឡីស័ក ឱ្យបានត្រឹមត្រូវ

តាមការកំណត់។ មួយរយៈពេលមុន ច្រកទ្វារព្រំដែនក្នុងខេត្តឧត្តរមានជ័យ ក៏មានលំហូរចូលនៃពលករខ្មែរមកពីថៃច្រើនគួរសមដែរ តែភាគច្រើនគឺពុំមានអ្នកផ្ទុកជំងឺកូវីដ-១៩នោះទេ៕ អត្ថបទ ៖ ឃិន សារិទ្ធ

## កម្លាំងអន្តរាគមន៍តំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ឃាត់ខ្លួនជនជាតិខ្មែរប្រុស-ស្រី ០៣នាក់ និង ជនជាតិ០១នាក់ប្រុងឆ្លងដែនទៅប្រទេសថៃ ..!!

https://www.facebook.com/neakmeasnews/ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២១ ដីវ័ន្ត គេហទំព័រ នាគមាស

ក្រុងប៉ោយប៉ែត÷ នៅវេលាម៉ោង០៤:១០នាទី ទៀបភ្លឺចូលថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២១ កម្លាំងតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ដឹកនាំដោយវរសេនីយ៍ឯក មាស ប៊ុនរុន មេបញ្ជាការរងនាយសេនាធិការតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ឃាត់ខ្លួនជនជាតិខ្មែរប្រុស-ស្រី ០៣នាក់ ជនជាតិចិន ០១នាក់ បន្ទាប់ពីនាំគ្នាប្រុងឆ្លងដែនទៅប្រទេសថៃ ។ សូមបញ្ជាក់ថា ពលរដ្ឋខ្មែរប្រុស-ស្រី ០៣នាក់ និងជនជាតិចិនម្នាក់ ដែលឃាត់ខ្លួនបានមានឈ្មោះដូចខាងក្រោម:

១:ឈ្មោះ លី ពីងស៊ីង ភេទប្រុស អាយុ២៦ ជនជាតិចិន មកពីខេត្តកំពង់សោម ប្រុងឆ្លងដែនតាមថៃនិងបន្តទៅភូមា។

២:ឈ្មោះ សឿន ផាន់នី ភេទប្រុស អាយុ ២៤( ខ្មែរ) មកពីខេត្តកំពង់ធំ។

៣:ឈ្មោះ គឹក វុទ្ធី ភេទប្រុស អាយុ១៦ ឆ្នាំ( ខ្មែរ) មកពីខេត្តកំពង់ធំ។

៤:ឈ្មោះ ប៉ា ពិសី ភេទស្រី អាយុ២០( ខ្មែរ) រស់នៅភូមិ មិត្តភាព សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ។

តាមចំលើយសារភាពរបស់ពលរដ្ឋខ្មែរបានឲ្យដឹងថា ពួកគាត់ប្រុងឆ្លងដែនទៅធ្វើការនិងលក់ដូរនៅផ្សារលុងគ្មឿ ដោយមេខ្យល់យកម្នាក់៤០០០ (បួនពាន់បាត) សំរាប់ពលរដ្ឋខ្មែរ និងជនជាតិចិន០១នាក់ ៥០០០ (ប្រាំពាន់បាត) ។

នៅព្រឹកថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២១នេះ លោកវរសេនីយ៍ឯក មាស ប៊ុនរុន មេបញ្ជាការរងនាយសេនាធិការតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ បានឲ្យដឹងថា កម្លាំងរបស់លោកបានឃាត់ខ្លួនជនជាតិខ្មែរប្រុស-ស្រី ០៣នាក់ និងជនជាតិចិន០១នាក់សរុបទាំងអស់០៤នាក់ នៅចំណុចចំការជំឡូងខាងក្រោយប៉ុស្តិ៍ដើម កកោះព្រៃគប់ ឋិតក្នុងភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត បន្ទាប់មកកម្លាំងរបស់លោកបាននាំជនជាតិចិន និងជនជាតិខ្មែរទាំងនោះមកសឹករងក្រុងប៉ោយប៉ែត ដើម្បីធ្វើកំណត់ហេតុ និង រងចាំបញ្ជូនទៅឲ្យជំនាញចាត់ការបន្តព្រមទាំងធ្វើចត្តឡីស័ក ផងដែរ ។

# ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១

## សម្តេចតេជោ បញ្ជាឱ្យអាជ្ញាធរលុបបំបាត់ ការជួញដូរមនុស្ស និងរូបភាពអាសអាភាសកុមារ តាមប្រព័ន្ធអនឡាញ

https://dap-news.com/national/ By KD102 Posted on May 24, 2021

ភ្នំពេញ ៖ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានអំពាវនាវដល់ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ គ្រួសារ និងសហគមន៍ ត្រូវលើកកម្ពស់ បង្ការទប់ស្កាត់ លុបបំបាត់ការជួញដូរមនុស្ស និងរូបភាពអាសអាភាសកុមារតាមប្រព័ន្ធអនឡាញ ដើម្បីធានាសុវត្ថិភាព ស្របតាមគោលការណ៍ ឧត្តមប្រយោជន៍ របស់កុមារ។

តាមរយៈសារលិខិតរបស់ រាជរដ្ឋាភិបាល ក្នុងឱកាសខួបលើកទី៧២ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី២០ ទិវាពិភពលោក ប្រឆាំងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០២១ ចេញផ្សាយនាពេលថ្មីៗនេះ សម្តេចតេជោ ហ៊ុន សែន បានឱ្យដឹងថា រាជរដ្ឋាភិបាល បន្តប្តេជ្ញាចិត្ត លើកកម្ពស់ការគោរពសិទ្ធិកុមារ និងផ្តល់

កិច្ចការពារយ៉ាងពេញទំហឹ ងនៅគ្រប់ស្ថានភាព ដោយបានបង្កើតនូវ យន្តការជាច្រើន ក្នុងការគ្រប់គ្រង និងផ្តល់សេវាដល់មុខសញ្ញាកុមារ ទូទៅ កុមារ ងាយរងគ្រោះនិងកុមាររងគ្រោះ។ សម្តេចតេជោ បន្តថា តែទោះបីជាមានការខិតខំប្រឹងប្រែង យ៉ាងនេះហើយក៏ដោយ ក៏នៅមានកុមារមួយចំនួន កំពុងរស់នៅ ក្នុងស្ថានភាពងាយរងគ្រោះ និងរងគ្រោះ ព្រោះតែឪពុកម្តាយ ឬអាណាព្យាបាល ធ្វើទេសន្តរប្រវេសន៍ និងបោះបង់ចោលរយៈពេលយូរ និងជាពិសេស ក្នុងការរស់នៅក្នុង ស្ថានភាពនៃការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ ដែលត្រូវការការគាំទ្រ និងអន្តរាមន៍ ជាចាំបាច់ ដោយជំរុញ ការអនុវត្ត នូវគោលនយោបាយ និងបទដ្ឋាននានា ដែលផ្តោតលើកិច្ចការពារ និងការគោរពសិទ្ធមូលដ្ឋានរបស់កុមារ ក្នុងគោលដៅការពារ ឧត្តមប្រយោជន៍ របស់កុមារ។

សម្តេចតេជោ មានប្រសាសន៍ថា «ខ្ញុំសូមស្នើដល់អាជ្ញាធរមូលដ្ឋាន គ្រប់លំដាប់ថ្នាក់ទាំងអស់ បន្តពង្រឹងយន្តការ សម្របសម្រួល ក្នុងការបង្ការទប់ស្កាត់ អន្តរាគមន៍ និងការឆ្លើយតប លើករណីកុមារ ដើម្បីលើកកម្ពស់ និងផ្តល់សេវាយុត្តិធម៌សង្គម ដោយធានាឱ្យមានសមភាព រវាងកុមារា និងកុមារី ព្រមទាំង បង្កើនឱកាស ស្មើភាពគ្នា ក្នុងកម្លាំងចលករ សង្គម សម្រាប់ជីវភាព សាធារណៈ ជីវភាពនយោបាយ សកម្មភាព សង្គម វប្បធម៌ សិល្បៈ សាសនា និងសកម្មភាពផ្សេងៗទៀត។ សម្តេចតេជោ បញ្ជាក់ថា «អាជ្ញាធរមានសមត្ថកិច្ច គ្រប់លំដាប់ថ្នាក់ គ្រួសារ សហគមន៍ ត្រូវចូលរួមលើកកម្ពស់ការបង្ការ ទប់ស្កាត់ លុបបំបាត់ ការជួញដូរមនុស្ស និងរូបភាព អាសអាភាសកុមារ តាមរយៈក្នុងប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអន ឡាញក្នុងសហគមន៍ ដើម្បីធានាសុវត្ថិភាព ស្របតាមគោលការណ៍ឧត្តមប្រយោជន៍របស់កុមារ»។ ជាងនេះទៅទៀត សម្តេចតេជោ ហ៊ុន សែន ក៏បានលើកឡើងថាគ្រប់ក្រសួង-ស្ថាប័ន ព្រមទាំង អាជ្ញាធរមានសមត្ថកិច្ច គ្រប់លំដាប់ថ្នាក់ ត្រូវបង្កើនសិទ្ធិអំណាចដល់កុមារ ជាពិសេស កុមារី និងសហគមន៍ ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរ សំខាន់ៗ ដែលអាចដោះស្រាយ ឫសគល់នៃការរើសអើង ការផាត់ចេញពីសង្គម និងភាពរងគ្រោះ និងងាយរងគ្រោះរបស់កុមារ (កុមារី កុមារ ជាជនជាតិដើមភាគតិច កុមារ មានពិការភាព)៕

## ប្រមុខរាជរដ្ឋាភិបាលអំពាវនាវ ៩ចំណុចដើម្បីកុមារទទួលបានសិទ្ធិពេញលេញ

https://www.kampucheathmey.com/ ថ្ងៃចន្ទ ២៤ ឧសភា ២០២១ដោយ KC Virak

ភ្នំពេញ៖ ក្នុងឱកាសខួបលើកទី៧២ ទិវាកុមារអន្តរជាតិ ១មិថុនា ខួបលើកទី២០ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២១ ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ ២០២១ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើការអំពាវនាវ ៩ចំណុចដើម្បីលើកកម្ពស់សិទ្ធិកុមារ និងឱ្យពួកគេទទួលបានសិទ្ធិពេញលេញដូចមានចែងក្នុងច្បាប់ជាតិនិងអន្តរជាតិ។ សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្វើការអំពាវនាវ ៩ចំណុចដូចតទៅ៖

១-គ្រប់ក្រសួងស្ថាប័ន ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ត្រូវបង្កើនសិទ្ធិអំណាចដល់ កុមារជាពិសេសកុមារី និងសហគមន៍ ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរសំខាន់ៗដែលអាចដោះស្រាយឫសគល់នៃការរើសអើង ការផាត់ចេញពីសង្គម និងភាពរងគ្រោះ និងងាយរងគ្រោះរបស់កុមារ (កុមារី កុមារជាជនជាតិដើមភាគតិច កុមារមានពិការភាព)។

២-គ្រប់ក្រសួង ស្ថាប័ន ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ជំរុញឱ្យមានការផ្លាស់ប្តូរក្នុងការអនុវត្តនិងគោលនយោបាយនៅក្នុងកម្រិតមូលដ្ឋាន និងកម្រិតជាតិតាមរយៈសកម្មភាពចុះផ្ទាល់ក្នុងការចែករំលែកចំណេះដឹង បទពិសោធន៍ស្តីពីតថភាពរបស់កុមារដែលកំពុងជួបប្រទះ។

៣-សូមលើកទឹកចិត្តដល់កុមារ និងសហគមន៍ ដើម្បីត្រៀមខ្លួន និងឆ្លើយតបទៅនឹងវិបត្តិ ព្រមទាំងជម្នះរាល់ការលំបាកនានា។

៤-គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់គ្រួសារ សហគមន៍ សូមចូលរួមគាំទ្រ ឱ្យកុមារទទួលបានការអភិវឌ្ឍប្រកបដោយសុវត្ថិភាព និងជោគជ័យចាប់ពីពេលចាប់កំណើតរហូតដល់ពេញវ័យដោយបន្តពង្រឹងសេវាគាំពារ និងអភិវឌ្ឍកុមារតូច អាហារូបត្ថម្ភ សុខភាពបន្តពូជយុវវ័យ ការបណ្តុះបណ្តាល ជំនាញ វិជ្ជាជីវៈ និងបំណិន ជីវិត។

៥-អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ គ្រួសារ សហគមន៍ សូមចូលរួមលើកកម្ពស់ការបង្ការទប់ស្កាត់លុបបំបាត់ការជួញដូរមនុស្ស និងរូបភាពអាសអាភាសកុមារតាមរយៈក្នុងប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអនឡាញក្នុងសហគមន៍ដើម្បីធានាសុវត្ថិភាពស្របតាមគោលការណ៍ឧត្តមប្រយោជន៍របស់កុមារ។

៦-គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ គ្រួសារសហគមន៍ ត្រូវចូលរួមលើកកម្ពស់ការយល់ដឹងនិងផ្លាស់ប្តូរឥរិយាបថសង្គមក្នុងការប្រព្រឹត្តបែបវិជ្ជមាន ចំពោះកុមារនៅក្នុងសហគមន៍ជាពិសេសផ្តល់ឱកាសឱ្យកុមារចូលរួមក្នុងការផ្លាស់ប្តូរសហគមន៍របស់ពួកគេ។

៧-សូមពិនិត្យលទ្ធភាពក្នុងការវិនិយោគចំនួនមន្ត្រី/ភ្នាក់ងារសង្គមកិច្ចនៅតាមឃុំនីមួយៗដើម្បីបង្កួតការផ្តល់សេវាសង្គមកិច្ចឱ្យកាន់តែកៀកទៅកុមារ និងសហគមន៍ ជាពិសេសកុមាររងគ្រោះដោយឪពុកម្តាយទុកចោល កុមារដែលទទួលរងអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់រូបភាព។

៨-គ្រប់ក្រសួងស្ថាប័នអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ត្រូវបន្តជំរុញការរៀបចំ និងអនុវត្តប្រព័ន្ធកិច្ចការពារកុមារឱ្យមានលក្ខណៈប្រទាក់ក្រឡាជាពហុវិស័យនៅក្នុងសហគមន៍ជាពិសេសការជួយដល់កុមារគ្រប់វិស័យ។

៩-គ្រប់ក្រសួងស្ថាប័នព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ត្រូវលើកកម្ពស់ការអភិវឌ្ឍ ធនធានមនុស្សតាមរយៈការបង្កើនការអប់រំ ផ្សព្វផ្សាយ ពង្រឹងកិច្ចការពារ និងពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ។

នៅក្នុងសារលិខិតនោះប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់មន្ត្រីរាជការនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រុមការងារដើម្បីកុមារ ក្រសួង ស្ថាប័ន ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ រាជធានី ខេត្ត កាកបាទក្រហមកម្ពុជា អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិដៃគូអភិវឌ្ឍ វិស័យឯកជន គ្រួសារនិងសហគមន៍រួមទាំងកុមារខ្លួនឯង ដែលបានយកអស់កម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី និងធនធានប្រកបដោយការទទួលខុសត្រូវខ្ពស់ក្នុងការរួមចំណែកលើកកម្ពស់សិទ្ធិកុមារដើម្បីឱ្យពួកគេទទួលបានសិទ្ធិពេញលេញដូចមានចែងក្នុងច្បាប់ជាតិ និងអន្តរជាតិ៕ អត្ថបទ៖ ណារី

## មេខ្យល់នាំពលករលួចឆ្លងដែនចំនួន២នាក់ទៀត ត្រូវបានចាប់ខ្លួនដោយកងកម្លាំងកងពលតូចថ្មើរជើងលេខ៥១

https://www.facebook.com/fridaydailynew/ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២១

(បន្ទាយមានជ័យ) ថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០២១ អនត្តន៍តាមបទបញ្ជាមេបញ្ជាការយោធភូមិភាគទី៥ និងគណៈបញ្ជាការឯកភាពខេត្តបន្ទាយមានជ័យ ទប់ស្កាត់ការនាំពលករលួចឆ្លងដែនក្នុងភូមិសាស្ត្រខេត្ត ដោយមានការដឹកនាំបញ្ជាផ្ទាល់ពីលោកឧត្តមសេនីយ៍ត្រី សឹង្ហ ទុំ មេបញ្ជាការ កងពលតូចថ្មើរជើងលេខ៥១ រួមជាមួយលោកវរសេនីយ៍ទោ ប៉ែន សុគន្ធ មេបញ្ជាការ វរសេនាតូចថ្មើរជើងលេខ៥១៤ កំពុងឈរជើងនៅតាមបន្ទាត់ព្រំដែន ក្នុងការរឹតបន្តឹងសន្តិសុខព្រំដែនទប់ស្កាត់ពលករលួចឆ្លងដែន ជាពិសេសបានចាត់តាំកម្លាំងចុះស៊ើបអង្កេតស្វែងរកមុខសញ្ញាមេខ្យល់ ចាប់ខ្លួនបញ្ជូនឲ្យសមត្ថកិច្ចជំនាញចាត់ការតាមផ្លូវច្បាប់។

ជាក់ស្តែងមេខ្យល់ចំនួន២នាក់ ត្រូវបានចាប់ខ្លួន មេខ្យល់ទី១ មានឈ្មោះ ពៅ បូរី ភេទប្រុស អាយុ៤១ឆ្នាំ រស់នៅភូមិជោគជ័យ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ និងមេខ្យល់ទី២ ឈ្មោះ ម៉ៅ ដែន ភេទប្រុស អាយុ២៦ឆ្នាំ រស់នៅភូមិបឹងប្រាសាទ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។ មេខ្យល់ត្រូវបានចាប់ខ្លួននៅចំណុចភូមិជោគជ័យ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ រួមជាមួយពលករខ្មែរចំនួន១៦នាក់ ប៉ុនប៉ងលួចឆ្លងដែនចូលប្រទេសថៃ ដឹកនាំដោយវរសេនីយ៍ទោ ប៉ែន សុគន្ធ មេបញ្ជាការ វរសេនាតូចលេខ៥១៤ កងពលតូចថ្មើរជើងលេខ៥១ សហការជាមួយកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំអូរបីជាន់ និងកងរាជអាវុធហត្ថស្រុកអូរជ្រៅ។

សូមបញ្ជាក់ថា ចាប់តាំងពីកងកម្លាំង កងពលតូចថ្មើរជើងលេខ៥១ ត្រូវបានបញ្ជូនទៅបំពេញប្រតិបត្តិការសហការជាមួយកម្លាំងចម្រុះ ទប់ស្កាត់ពលករលួចឆ្លងដែន និងទប់ស្កាត់ការឆ្លងរីករាលដាល នៃជំងឺកូវីដ-១៩ បានឃាត់ខ្លួនពលករឆ្លងដែនបញ្ជូនទៅមណ្ឌលចត្តាឡីស័កជាបន្តបន្ទាប់ និងឃាត់ខ្លួនមេខ្យល់បានមួយចំនួន បញ្ជូនទៅសមត្ថកិច្ចជំនាញចាត់វិធានការតាមផ្លូវច្បាប់។

លោកឧត្តមសេនីយ៍ត្រី សឹង្ហ ទុំ បានគូសបញ្ជាក់ថា កងកម្លាំងរបស់កងពលតូចថ្មើរជើងលេខ៥១ បានដាក់ពង្រាយតាមបន្ទាត់ព្រំដែនជាច្រើនចំណុចសហការជាមួយកម្លាំងចម្រុះ ក្នុងគោលបំណងទប់ស្កាត់អោយខានតែបានការនាំពលករឆ្លងដែនខុសច្បាប់ ដោយកន្លងមកកងកម្លាំងជួរមុខនេះបានឃាត់ពលករឆ្លងចេញ-ចូលជាង ១០០០នាក់ និងឃាត់បានមេខ្យល់ជាច្រើននាក់ផងដែរ៕

## សមត្ថកិច្ចកំពុងសាកសួរមេខ្យល់ ២ នាក់ ពាក់ព័ន្ធករណីនាំពលករ ១៧ នាក់ បម្រុងឆ្លងដែន

https://www.postkhmer.com/ គឹម សារុំ | Publication date 23 May 2021 | 18:24 ICT

**បន្ទាយមានជ័យ៖** សមត្ថកិច្ចកំពុងសាកសួរបុរសជាមេខ្យល់ ២ នាក់ ខណៈពលករប្រុសស្រី ១៧ នាក់ផ្សេងទៀត ត្រូវបញ្ជូនទៅមណ្ឌលចត្តាឡីស័ក បន្ទាប់ឃាត់ខ្លួនកាលពីយប់ថ្ងៃទី ២២ ឧសភា នៅភូមិជោគជ័យ ឃុំអូរ៣ជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ នៅពេលបម្រុងនាំគ្នាឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ។

លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ ប្រាប់នៅរសៀលថ្ងៃទី ២៣ ឧសភាថា មេខ្យល់ទាំង ២ នាក់ នោះ ទី១- ឈ្មោះ ពៅ បូរី អាយុ ៤១ ឆ្នាំ រស់នៅភូមិជោគជ័យ ឃុំអូរ៣ជាន់ ស្រុកអូរជ្រៅ និងទី២- ឈ្មោះ ម៉ៅ ដែន អាយុ ២៦ ឆ្នាំ រស់នៅភូមិបឹងប្រាសាទ ឃុំអូរ ៣ ជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។ លោកថ្លែងថា៖ «បុរសមេខ្យល់ទាំង ២ នាក់នេះ កំពុងត្រូវមន្ត្រីជំនាញសាកសួរ ដើម្បីរៀបចំសំណុំរឿងបញ្ជូនទៅតុលាការចាត់ការតាមច្បាប់ហើយ»។

ដោយឡែក លោក ម៉ាន់ ធី អធិការរងស្រុកអូរជ្រៅ និងជាសមាជិកគណៈកម្មការទប់ស្កាត់ពលករឆ្លងដែន ឱ្យដឹងនៅរសៀលថ្ងៃទី ២៣ ឧសភាថា កាលពីយប់ថ្ងៃទី ២២ ឧសភា ខណៈកម្លាំងសមត្ថកិច្ចចម្រុះប្រចាំការនៅចំណុចគោលដៅស្ថិតនៅភូមិជោគជ័យឃុំអូរ ៣ ជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ បានឃើញមនុស្ស ១ ក្រុមបាននាំគ្នាលួចដើរឆ្លងកាត់គោលដៅរបស់សមត្ថកិច្ចបម្រុងឆ្លងដែនចូលទៅប្រទេសថៃ។ នៅពេលនោះកម្លាំងសមត្ថកិច្ចបានស្ទាក់ចាប់បានមនុស្សប្រុសស្រីរួមទាំងក្មេងតូចម្នាក់សរុប ១៧ នាក់ និងមានបុរស ២ នាក់ ជាមេខ្យល់ផង។ លោកបន្តថា ក្រោយឃាត់ខ្លួនសមត្ថកិច្ចបានរាប់ចំនួនឃើញមានមនុស្សស្រីចំនួន ៨ នាក់ (រាប់ទាំងក្មេងស្រីតូចម្នាក់ផង) និងប្រុស ១១ នាក់ ក្នុងនោះមានទាំងមេខ្យល់ ២ នាក់ផង។ លោកប្រាប់ថា៖ «ចំពោះពលករទាំង ១៧ នាក់ គឺសមត្ថកិច្ចចម្រុះយើងបានបញ្ជូនទៅមណ្ឌលចត្តាឡីស័កនៅស្រុកអូរជ្រៅហើយ។ ពលករយើងមិនបានចាប់ពួកគាត់បញ្ជូនទៅតុលាការទេ ព្រោះពួកគាត់ចាញ់បោកគេដែរ»។

ពាក់ព័ន្ធនឹងចំនួនពលករសរុប ដែលលួចឆ្លងដែនខុសច្បាប់ និងចំនួនមេខ្យល់ ដែលត្រូវឃាត់ខ្លួនបញ្ជូនទៅតុលាការ ភ្នំពេញប៉ុស្ដិ៍មិនអាចទាក់ទងលោកស្រី រស់ សុផានី អភិបាលរងខេត្តបន្ទាយមានជ័យ និងជាប្រធានគណៈ

កម្មការត្រួតពិនិត្យពលករឆ្លងដែនខុសច្បាប់បានទេ នៅរសៀលថ្ងៃទី ២៣ ឧសភា ដោយសារទូរស័ព្ទលោកស្រីគ្មានអ្នកទទួល៕

## កម្លាំងនគរបាលជំនាញបញ្ជូនជនសង្ស័យចំនួន២នាក់ទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ពីបទនាំមនុស្សឆ្លងដែនខុសច្បាប់

http://nokorwatnews.com/ 23/05/2021

ខេត្តបន្ទាយមានជ័យ៖ ជនសង្ស័យចំនួន២នាក់ ត្រូវបានកម្លាំងនគរបាលការិយាល័យ ប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បញ្ជូនខ្លួនទៅសាលាដំបូខេត្តបន្ទាយមានជ័យ នៅរសៀលថ្ងៃទី២៣ខែឧសភា ឆ្នាំ២០២១នេះក្នុងករណីនាំមនុស្សឆ្លងដែនដោយខុសច្បាប់ ទៅប្រទេសជិតខាង ។

លោក សែស វិបុល អធិការនគរបាលស្រុកអូរជ្រៅ បានឲ្យដឹងថា នៅរសៀលថ្ងៃទី២៣ខែ ឧសភា ឆ្នាំ២០២១ កម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំអូរបីជាន់ បានល្បាតក្នុងព្រៃឫស្សី ក្នុងភូមិសាស្រ្ត ភូមិប្រាសាទ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ស្រាប់តែបានប្រទះឃើញពលករខ្មែរលួចឆ្លងដែនទៅប្រទេសថៃ ចំនួន១៩នាក់ ក្នុងនោះស្រី៨នាក់ ហើយបាននាំពលករទាំងនោះមកប៉ុស្តិ៍រដ្ឋបាលដើម្បីសួរនាំ ។ក្រោយពីធ្វើការសួរនាំ ពលករទាំង១៩នាក់នោះមកសមត្ថកិច្ចបានស្រាវជ្រាវរកឃើញមុខសញ្ញាជាមេខ្យល់ ចំនួន២នាក់ ដែលពាក់ព័ន្ធក្នុងចំណោមពលករខ្មែរទាំង១៩នាក់ ត្រូវឃាត់ខ្លួនបញ្ជូនទៅស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យក្នុងនោះ ម្នាក់មាន ឈ្មោះ ម៉ៅ ដៃ ភេទប្រុសអាយុ២៦ឆ្នាំ នៅភូមិប្រាសាទ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ និងម្នាក់ទៀតឈ្មោះ ពៅ បូរី ភេទប្រុសអាយុ២៨ឆ្នាំ នៅភូមិជោគជ័យ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ។ចំណែកពលករចំនួន១៧នាក់ (ស្រី៨នាក់)ត្រូវបានប្រគល់ឲ្យក្រុមការងារចម្រុះមណ្ឌលសំចតប្រចាំការនៅប្រកអូរបីជាន់ ដើម្បីត្រួតពិនិត្យនិងធ្វើចត្តាឡីស័ករកមេរោគកូវីដ-១៩៕

## វរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ទប់ស្កាត់ករណីលួចឆ្លងដែនខុសច្បាប់ ឃាត់ខ្លួនមេខ្យល់១នាក់ និងពលរដ្ឋ៩នាក់

http://cambodiapolice.com/policekh/ 9:14 am 23 ឧសភា 2021

ខេត្តបាត់ដំបង ៖ តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន ព្រមទាំងមេខ្យល់នាំពលករចេញ- ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ។

ជាក់ស្តែង លោកវរសេនីយ៍ឯក ពៅ ថាវុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពាព្រំដែនគោកលេខ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ ជាមេបញ្ជាការ នៅវេលាម៉ោង ២និង១០នាទីព្រឹកថ្ងៃសៅរ៍ ១១កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២១កម្លាំងប៉ុស្តិ៍នគរបាលព្រំដែនគីឡូ១៣ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ដឹកនាំដោយលោកអនុសេនីយ៍ទោ ម៉ឹង ម៉េត នាយប៉ុស្តិ៍ស្តីទី សហការជាមួយកម្លាំងយោធាផ្នែកសឹករងស្រុកសំពៅលូន ដឹកនាំដោយលោកវរសេនីយ៍ត្រី ឈឹម សំណាង មេបញ្ជាកាផ្នែកសឹករង និងកម្លាំងយោធាវរសេនាតូច៥៣៣ ដឹកនាំដោយលោកអនុសេនីយ៍ឯក ឯក អាំផន មេបញ្ជាការ-គ បានធ្វើសកម្មភាពទប់ស្កាត់ប្រជាពលរដ្ឋបម្រុងលួចឆ្លងដែនចូលទឹកដីថៃត្រង់ចំណុចនៃភូមិសាស្រ្តភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ចំនួន៩នាក់ , ស្រី៣នាក់ (ក្មេងប្រុសចំនួន២នាក់ និងក្មេងស្រី១នាក់) និងឃាត់មុខសញ្ញានាំមនុស្សឆ្លងដែនដែន(មេខ្យល់) ម្នាក់ឈ្មោះ ថាង គៀច ភេទស្រីអាយុ៣៩ឆ្នាំ មានទីលំនៅ ផ្ទះលេខ៤៤៩ ក្រុមទី១២ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ។ បន្ទាប់ពីធ្វើ

ការសាកសួរ និងកត់ឈ្មោះ ព្រមទាំងអប់រំណែនាំរួច កម្លាំងបានប្រគល់បងប្អូនទាំងអស់ឲ្យទៅកម្លាំងនគរបាលនៃអធិការដ្ឋាននគរបាលស្រុកសំពៅលូនចាត់ការតាមច្បាប់បន្ត ៕

## ប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៦៧នាក់

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃអាទិត្យ ទី២៣ ខែឧសភា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៦៧នាក់ ស្រី ៣១នាក់ ក្នុងនោះកុមារ ៤នាក់ កុមារី ១នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ១២នាក់ ស្រី ៦នាក់ កុមារ ០០នាក់ កុមារី ២នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៤នាក់ ស្រី ២នាក់ កុមារ ១នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ១៥នាក់ ស្រី ៥នាក់ កុមារ ៣នាក់ កុមារី ១នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៤៤នាក់ ស្រី ២១នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ៤នាក់ ប្រុសចំនួន ០០នាក់ ស្រីចំនួន ៣នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៦៧នាក់ ស្រី ៣១នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## បញ្ជូនមេខ្យល់ម្នាក់ ទៅតុលាការខេត្ត ករណីនាំពលករឆ្លងដែន ទៅប្រទេថៃ

http://www.arey-news.com/ (ថ្ងៃទី 22 May 2021 ម៉ោង 4:08 pm)

បាត់ដំបង: នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២១ នេះ បញ្ជូនមេខ្យល់ម្នាក់ ទៅតុលាការខេត្ត ដើម្បីចាត់ការតាមច្បាប់ ពាក់ព័ន្ធករណីនាំពលករខ្មែរ ចំនួន ៩ នាក់ ( ស្រី៤នាក់) ឆ្លងដែនខុសច្បាប់ ទៅប្រទេថៃ ក្រោយពេលកម្លាំងសមត្ថកិច្ចចំរុះ ក្នុងនោះមាន កម្លាំងយោធាផ្នែកសឹករង ស្រុកសំពៅលូន កម្លាំងយោធា វរៈសេនាតូច៥៣៣ បានឃាត់ខ្លួនបាន នៅវេលាវិលងអធ្រាត្រ ឈានចូលថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២១ ។ មេខ្យល់មានឈ្មោះ ថាង កៀច ភេទស្រី អាយុ ៣៩ ឆ្នាំ នៅផ្ទះលេខ៤៤៩ ក្រុមទី១២ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន បាននាំពលករខ្មែរ លួចឆ្លងដែនខុសច្បាប់ ចូលក្នុងទឹកដីថៃ ត្រង់ចំណុចភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង។ សមត្ថកិច្ចជំនាញ បានបញ្ជូនមេខ្យល់ ទៅតុលាការ ចាត់ការតាមច្បាប់។ ចំណែកពលករទាំង ៩ នាក់ សមត្ថកិច្ច បានណែនាំ អប់រំហើយបញ្ជូនទៅធ្វើចត្តាឡីស័ក ចំនួន ១៤ ថ្ងៃជាមុនសិន ទើបអនុញ្ញាតឲ្យវិលត្រឡប់ ទៅលំនៅដ្ឋាននៅវិញ៕

## ពលករខ្មែរត្រឡប់ទៅផ្ទះ ត្រូវបានទាហានថៃ ចាប់នៅជាយដែនអូបីជាន់ គេពិន័យជាប្រាក់ 15000 បាត

https://www.facebook.com/CambodiaBuddy/ ថ្ងៃទី ឧសភា 20 នៅម៉ោង 4:19 PM ·

ពលករខ្មែរត្រឡប់ទៅផ្ទះ ត្រូវបានទាហានថៃចាប់នៅជាយដែនអូបីជាន់ គេពិន័យជាប្រាក់ 15000 បាទ បើគ្មានប្រាក់គេបញ្ជូនទៅជាប់ពន្ធនាមួយខែខំរត់ចេញពីកូវីដទៅជាប់គុក ចំនួន 27 នាក់ បងប្អូនមុននឹងសម្រេចចិត្តទៅខ្មែរគិតមើលសិន ខ្ញុំក៏អត់ដែលឮដែរ តែពេលនេះចាប់មែន កម្មចុយម្រាយហើយកូនខ្មែរ។ ទី 17 ខែ 5.21 ពេលនេះថៃហាមមិនឲ្យបន្លាស់ទីទេបងប្អូននៅឲ្យស្ងៀមសិនទៅ។ បងប្អូនដែលចង់ទៅខ្មែរវិញនៅក្នុងកំឡុងពេលនេះ ពុំគួរទៅទេ ព្រោះពេលនេះប៉ូលីស និងទាហានថៃ ចាប់ផ្តើមអនុវត្តច្បាប់យ៉ាងតឹងរឹង ដោយមិនអនុញ្ញាតអោយមានការចល័តពលករទេ។ ដូច្នេះបងប្អូនដែលធ្វើការ ស្នាក់នៅកន្លែងណារ ត្រូវនៅកន្លែងហ្នឹងសិន។

# ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១

## កម្លាំងនគរបាល សហការគ្នាជាមួយកម្លាំងយោធា ទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ

http://cambodiapolice.com/policekh/ 10:13 pm 24 ឧសភា 2021

ខេត្តបាត់ដំបង ៖ នៅថ្ងៃចន្ទ ១៣កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០២១ តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ លោកវរសេនីយ៍ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពាព្រំដែនគោកលេខ ៨ ១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨ ១៧ បានចាត់តាំងកម្លាំងប៉ុស្តិ៍នគរបាលព្រំដែនគីឡូ៩ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨ ១៧ ដឹកនាំដោយលោកអនុសេនីយ៍ទោ កុន-ហ៊ាង (នាយប៉ុស្តិ៍ស្តីទី) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនដឹកនាំដោយលោកអនុសេនីយ៍ទោ ឡាក់ ឌី(មេបញ្ជាការរង គ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ពីយោធាថៃកងអនុសេនាធំ១៣០៥ ត្រង់ចំណុចនៃភូមិសាស្ត្រភូមិគីឡូ៩ ឃុំជ្រៃសីមា ស្រុកសំពៅលូន ចំនួន២នាក់, ស្រី១នាក់ ។ បន្ទាប់ពីធ្វើការសាកសួរ និងកត់ត្រាឈ្មោះរួច ក៏ធ្វើការអប់រំណែនាំ ហើយកម្លាំងយើងបានប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ តាមការណែនាំរបស់ក្រសួងសុខាភិបាល ៕

## កម្លាំងប៉ុស្តិ៍នគរបាលព្រំដែនភ្នំព្រឹក សហការជាមួយកម្លាំងយោធា ចុះចេញល្បាតតាមខ្សែបន្ទាត់ព្រំដែន

http://cambodiapolice.com/policekh/ 6:36 pm 24 ឧសភា 2021

ខេត្តបាត់ដំបង ៖ នៅថ្ងៃចន្ទ ១៣កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០២១ តាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ លោកវរសេនីយ៍ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពាព្រំដែនគោកលេខ ៨ ១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការ

វរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨ ១៧ បានចាត់តាំងកម្លាំងប៉ុស្តិ៍នគរបាលព្រំដែនភ្នំព្រឹក ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨ ១៧ ដឹកនាំដោយលោកអនុសេនីយ៍ទោ មួន លន(នាយរងប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាកងអនុសេនាធំទី៣,វរសេនាតូចលេខ១ ដឹកនាំដោយលោកវរសេនីយ៍ត្រី អ៊ួន-សុខឿន (មេបញ្ជាការ គ) បានចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនចាប់ពីចំណុចនិយាមកា០២១៣៩២៩_១៤៧១៨៥២ ទៅចាប់ដៃជាមួយកម្លាំងប៉ុស្តិ៍ព្រំដែនចំការស្រូវត្រង់ចំណុចនិយាមកា ០២១៣៧១៧_១៤៧៤៧៥២ ដឹកនាំដោយអនុសេនីយ៍ឯក មី សុខា (មន្ត្រីប៉ុស្តិ៍) ក្នុងភូមិសាស្ត្រស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ។

## កម្លាំងនគរបាល សហការជាមួយកម្លាំងយោធា បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ពីភាគីយោធាថៃកងអនុសេនាធំ១៣០៥ ត្រង់ចំណុចនៃភូមិសាស្ត្រភូមិពោធិ៍ជ្រៃ

http://cambodiapolice.com/policekh/ 6:20 pm 24 ឧសភា 2021

ខេត្តបាត់ដំបង ៖ នៅថ្ងៃចន្ទ ១៣កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១ តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ លោកវរសេនីយ៍ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពាព្រំដែនគោកលេខ ៨ ១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨ ១៧ បានចាត់តាំងកម្លាំងប៉ុស្តិ៍នគរបាលព្រំដែនគីឡូ១៣ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨ ១៧ ដឹកនាំដោយលោកអនុសេនីយ៍ទោ ម៉ឹង-ម៉េត (នាយប៉ុស្តិ៍ស្ដីទី) សហការជាមួយកម្លាំងយោធាផ្នែកសឹករង ដឹកនាំដោយលោកវរសេនីយ៍ត្រី វ៉ាន់-សុផល (មេបញ្ជាការផ្នែកសឹករង) និងកម្លាំងយោធាវរសេនាតូច៥៣៣ ដឹកនាំដោយលោកអនុសេនីយ៍ឯក ឯក-អាំផន(មេបញ្ជាការ គ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ពីភាគីយោធាថៃកងអនុសេនាធំ១៣០៥ ត្រង់ចំណុចនៃភូមិសាស្ត្រភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ចំនួន ២នាក់ប្រុស ។ បន្ទាប់ពីធ្វើការសាកសួរ និងកត់ត្រាឈ្មោះរួច ក៏ធ្វើការអប់រំណែនាំ ហើយកម្លាំងយើងបានប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ តាមការណែនាំរបស់ក្រសួងសុខាភិបាល ។

## ពលករខ្មែរ ដែលត្រឡប់ពីប្រទេសថៃ តាមច្រកភូមិសាស្ត្រ ស្រុកម៉ាឡៃ និងច្រកអូរបីជាន់ ស្រុកអូរជ្រៅ ក្នុង១ថ្ងៃ ជិត ១០០នាក់

https://kohsantepheapdaily.com.kh/ Banteay Meanchey ២៤ ខែ ឧសភា ឆ្នាំ ២០២១ ម៉ោង ២០:២០

បន្ទាយមានជ័យ៖ ពលករខ្មែរ ដែលត្រឡប់ពីប្រទេសថៃ តាមច្រកភូមិសាស្ត្រស្រុកម៉ាឡៃ និងច្រកអូរបីជាន់ស្រុកអូរជ្រៅ ក្នុង ១ថ្ងៃ ជិត ១០០នាក់ នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២១។

លោក ឡៅ ឈួន អភិបាលស្រុកម៉ាឡៃ បានប្រាប់ថា នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២១ នេះ ពលករខ្មែរដែលត្រឡប់ពីប្រទេសថៃ ចូលមកកម្ពុជាវិញ មានតាមច្រកចំបក់ ស្ថិតក្នុងភូមិសាស្ត្រស្រុកម៉ាឡៃ ចំនួន ២៨នាក់ (ស្រី១១នាក់ កុមារ ៥នាក់) ក្នុងនោះ រួមមានប្រជាពលរដ្ឋ ដែលមានស្រុកកំណើតនៅខេត្តបន្ទាយមានជ័យ ចំនួន ១២នាក់ ខេត្តសៀមរាបចំនួន ៩នាក់ ខេត្តបាត់ដំបងចំនួន ៣នាក់ ខេត្តស្វាយរៀង មានចំនួន ៤នាក់។

លោក លី សុវណ្ណារិទ្ធិ អភិបាលស្រុកអូរជ្រៅ បានបញ្ជាក់ថា នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២១ មានពលករខ្មែរ ដែលត្រឡប់ពីប្រទេសថៃ ចូលមកកម្ពុជាវិញ មានចំនួន ៥៣នាក់ ( ស្រី ២០នាក់) ក្នុងនោះ មានប្រជាពលរដ្ឋ នៅខេត្តបន្ទាយមានជ័យ ចំនួន ២៤នាក់ ខេត្តបាត់ដំបង មានចំនួន ៥នាក់ ខេត្តកំពត មានចំនួន ម្នាក់ ខេត្តកោះកុង មានចំនួន ម្នាក់ ខេត្តព្រៃវែង មានចំនួន ៨នាក់ ខេត្តពោធិ៍សាត់ ៣នាក់ ខេត្តសៀមរាប ចំនួន ៤នាក់ ខេត្តតាកែវ ចំនួន ៣នាក់។

អភិបាលស្រុកទាំង ២ បានបញ្ជាក់ថា ពលករខ្មែរ ដែលត្រឡប់ពីប្រទេសថៃ ចូលតាមច្រកភូមិសាស្ត្រស្រុកម៉ាឡៃ និងច្រកអូរបីជាន់ស្រុកអូរជ្រៅ ត្រូវក្រុមការងារពិនិត្យសុខភាព និងផ្តល់នូវអាហារសម្រន់ ១ពេល ហើយបានដឹកតាមរថយន្តក្រសួងការពារជាតិ ដើម្បីដាក់នៅមណ្ឌលចត្តាឡីស័ករយៈពេល ១៤ថ្ងៃ ដើម្បីបង្ការទប់ស្កាត់កូវីដ ១៩ មិនអោយរីករាលដាល ក្នុងសហគមន៍៕ ប៊ុន ធឿន

## ចាប់មេខ្យល់២នាក់បម្រុងនាំពលករខ្មែរឆ្លងដែនខុសច្បាប់

http://nokorwatnews.com/ 25/05/2021

ខេត្តបន្ទាយមានជ័យ៖ មេខ្យល់ចំនួន ០២នាក់ ដែលសកម្មក្នុងការនាំពលករឆ្លងដែនខុសច្បាប់ ត្រូវបានកម្លាំងកងពលតូចថ្មើរជើងលេខ៥១ ឃាត់ខ្លួនបាននៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១នេះ ខណៈពេលដែលពួកគេកំពុងដឹកនាំពលករឆ្លងដែនទៅប្រទេសថៃ ចំនួន ៨នាក់ ក្នុងនោះស្រី ចំនួន ០១នាក់ ត្រង់ចំនុចភូមិសាស្ត្រ ផ្លូវចូលក្រុមហ៊ុនឧកញ៉ា សំផាន់ណារិទ្ធ ខេត្តបន្ទាយមានជ័យ ។ ក្រោមបញ្ជាផ្ទាល់របស់លោក ឧត្តមសេនីយ៍ត្រី សឹង្ហ ទុំ មេបញ្ជាការកងពលតូចថ្មើរជើងលេខ៥១ បាន ចាត់តាំង លោក វរសេនីយ៍ទោ ប៉ែន សុគន្ធ មេបញ្ជាការ វរសេនាតូចថ្មើរជើងលេខ៥១៤ ដឹកនាំកម្លាំងល្បាតជាប់ជាប្រចាំ ដោយអនុវត្តតាមបទបញ្ជា មេបញ្ជាការ លោកបានដឹកនាំកម្លាំងល្បាត២៤ម៉ោងលើ២៤ម៉ោង ដោយប្តូរវេនគ្នា សហការជាមួយកម្លាំងចម្រុះ ដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ មិនឲ្យចូលទៅក្នុងសហគមន៍។

ជាក់ស្តែង ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១ ខណៈលោក វរសេនីយ៍ទោ ប៉ែន សុគន្ធ មេបញ្ជាការ កំពុងដឹកនាំកម្លាំងដើរល្បាតក៏ជួប មេខ្យល់ចំនួន ០២នាក់ បម្រុងនាំពលករឆ្លងដែនចេញទៅប្រទេសថៃ ត្រូវបានកម្លាំងវរសេនាតូចថ្មើរជើងលេខ៥១៤ កងពលតូចថ្មើរជើងលេខ៥១ ឃាត់ខ្លួនបានតែម្តង ។

សូមបញ្ជាក់ថា មេខ្យល់ដែលត្រូវឃាត់ខ្លួន ទី១ ឈ្មោះ លឹម ហួត ភេទ ប្រុស អាយុ ៣៨ឆ្នាំ រស់នៅ ភូមិព្រៃចាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ និងទី២ ឈ្មោះ ជួត សុខជ័យ ភេទ ប្រុស អាយុ ១៨ឆ្នាំ រស់នៅភូមិបន្ទាយថ្មី ឃុំអូរបីជាន់ ស្រុកអូរជ្រៅ បច្ចុប្បន្នពួកគាត់ទាំងពីរនាក់កំពុងត្រូវបានឃុំខ្លួនដើម្បីសួរចម្លើយនៅ រដ្ឋបាលបុស្តិ៍ ។ ចំណែកឯពលករទាំង ៨នាក់ ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ នៅមណ្ឌលចត្តាឡីស័ក ខេត្តបន្ទាយមានជ័យ ៕

## ប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ២៩នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃចន្ទ ទី២៤ ខែឧសភា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និង

ច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ២៩នាក់ ស្រី ១៤នាក់ ក្នុងនោះកុមារា ៤ នាក់ កុមារី ១នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ២នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៣នាក់ ស្រី ១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ២៣នាក់ ស្រី ១៣នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ១នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ប្រុសចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ២៩នាក់ ស្រី ១៤នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ឃាត់ខ្លួនពលករនិងមេខ្យល់៤នាក់លួចឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់

https://www.kampucheathmey.com/ ថ្ងៃអង្គារ ២៥ ឧសភា ២០២១ដោយ Sokhom Khon

ពលករខ្មែរ៣នាក់ និងមេខ្យល់១នាក់ ជាអ្នកនាំផ្លូវទៅប្រទេសថៃដោយខុសច្បាប់ ត្រូវកម្លាំងចម្រុះនគរបាលនិងយោធាឃាត់ខ្លួនបាននៅវេលាម៉ោង១២យប់ រំលងអាធ្រាត្រ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០២១ ខណៈបម្រុងឆ្លងដែនទៅប្រទេសថៃនៅគោលដៅដើមស្តុកស្តោរ ភូមិសាស្ត្រប៉ុស្តិ៍ការពារព្រំដែនអូរសោយ ភូមិត្រពាំងសំរោង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។

លោកវរសេនីយ៍ឯក ឡុង សំណាង មេបញ្ជាការនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨០៧ បានឲ្យដឹងថា ពលករ៣នាក់មាន១ឈ្មោះ គុណ ណាង ភេទប្រុសអាយុ៤៤ឆ្នាំ រស់នៅភូមិរូងអំពិលឃុំខ្នាចរមាស ស្រុកបវិលខេត្តបាត់ដំបង។ ២ឈ្មោះ រឿន ស្រីកែវ ភេទស្រីអាយុ២២ឆ្នាំ រស់នៅភូមិរូងអំពិល ឃុំខ្នាចរមាស ស្រុកបវិលខេត្តបាត់ដំបង។ ៣ឈ្មោះ ឆេង ជឿន ភេទប្រុសអាយុ៣៤ឆ្នាំ រស់នៅភូមិព្រៃទទឹង ឃុំបវិលស្រុកបវិល ខេត្តបាត់ដំបង។ ៤មេខ្យល់មានឈ្មោះ គុយ ចាន់ ភេទប្រុសអាយុ២៣ឆ្នាំរស់នៅ ភូមិត្រពាំងសំរោង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។លោកមេបញ្ជាការបានបញ្ជាក់ឲ្យដឹងទៀតថា ក្រោយពីឃាត់ខ្លួននិងសួរនាំ ឈ្មោះ គុយ ចាន់ បានឆ្លើយថា គេអ្នកស៊ីឈ្នួលជូនពលករឆ្លងដែនទៅប្រទេសថៃ បន្តពីប្រពន្ធរបស់ឈ្មោះ យិន សៀវអ៊ុយ រស់នៅភូមិត្រពាំងសំរោង ឃុំគោករមៀតស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ក្នុង១នាក់ឈ្នួលជូនក្នុងតម្លៃម្នាក់៤០០បាតតែប៉ុណ្ណោះ ។

ដោយផ្អែកលើចម្លើយសារភាពរបស់ជនសង្ស័យ និងការបំភ្លឺពីពលករទាំង៣នាក់ប្រាប់សមត្ថកិច្ចថា មេខ្យល់បានសន្យាជាមួយពួកគាត់ពេលជូនទៅដល់គោលដៅ យកក្នុងម្នាក់៤០០បាត ទើបពួកខ្លួនឲ្យជូន។ មេខ្យល់ឈ្មោះ គុយ ចាន់ សមត្ថកិច្ចចម្រុះបានប្រគល់ឲ្យនគរបាលប៉ុស្តិ៍រដ្ឋដើម្បីចាត់ការបន្តចំណែកពលករទាំង៣នាក់ ត្រូវសមត្ថកិច្ចចម្រុះបញ្ជូនទៅមណ្ឌលចត្តាឡីស័កនៅស្រុកថ្មពួកឲ្យគ្រប់១៤ថ្ងៃទើបឲ្យវិញទៅផ្ទះវិញ៕ វ៉ាន់ ណាង

# មេខ្យល់នាំពលករខ្មែរឆ្លងដែនខុសច្បាប់ជាង២០០នាក់ ត្រូវបានសមត្ថកិច្ចចាប់បញ្ជូនទៅតុលាការ

https://www.kampucheathmey.com/ ថ្ងៃអង្គារ ២៥ ឧសភា ២០២១ដោយ Sokhom Khon

រហូតមកដល់ពេលនេះ មានមេខ្យល់ដែលនាំពលករខ្មែរឆ្លងដែនខុសច្បាប់ ចេញ ចូលប្រទេសកម្ពុជាជាង២០០នាក់ត្រូវបានសមត្ថកិច្ចចាប់បញ្ជូនទៅតុលាការ ដើម្បីធ្វើការផ្តន្ទាទោសទៅតាមផ្លូវច្បាប់។

លោកឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន អគ្គស្នងការរង និងជាអ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិ បានប្រសាសន៍នៅរសៀលថ្ងៃទី២៥ ខែឧសភានេះថា ចាប់ពីថ្ងៃទី១៣ ខែកុម្ភៈ រហូតមកដល់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១នេះ សមត្ថកិច្ចបានចាប់មេខ្យល់ដែលនាំពលករខ្មែរឆ្លងដែនខុសច្បាប់ចេញ ចូលប្រទេសកម្ពុជា ចំនួន២២២នាក់ ស្រី១៥នាក់ បញ្ជូនទៅតុលាការ។ លោកឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន បានបន្តថា ការចាប់មេខ្យល់ទាំងនោះ ភាគច្រើននាំពលករចេញ ចូលប្រទេសកម្ពុជា និងថៃ។ ចំណែកមេខ្យល់នាំពលករចេញចូលកម្ពុជា និងវៀតណាមវិញមានចំនួនតិចតួចទេ។

យ៉ាងណាក៏ដោយ ចាប់តាំងពីរាជរដ្ឋាភិបាលបានបញ្ចប់ការបិទខ្ទប់ការធ្វើដំណើរឆ្លងកាត់រាជធានី-ខេត្តទូទាំងប្រទេសមក ឃើញថាសកម្មភាពការនាំចូលពលករខ្មែរទៅប្រទេសថៃបានកើតមានជាបន្តបន្ទាប់ ទោះបីជាអាជ្ញាធរថៃបានបន្តបិទព្រំដែនដោយសារការផ្ទុះជំងឺកូវីដ១៩ក៏ដោយ។ ជាក់ស្តែងអាជ្ញាធរខេត្តបន្ទាយមានជ័យក៏ដូចជាខេត្តបាត់ដំបងបានធ្វើការឃាត់ខ្លួនមេខ្យល់ និងពលករខ្មែរដែលបម្រុងចេញទៅប្រទេសថៃជាបន្តបន្ទាប់ ហើយបញ្ជូនមេខ្យល់ទាំងនោះ ទៅកាត់ទោសតាមផ្លូវច្បាប់ផងដែរ។

លោកឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន បានអំពាវនាវដល់ពលករទាំងអស់ សូមបញ្ឈប់ការឆ្លងដែនខុសច្បាប់ និងកុំចាញ់បោកបញ្ឆោតក្រុមមេខ្យល់ទាំងនោះ ដើម្បីចៀសវាងការទទួលការផាកពិន័យនិងទោសទណ្ឌតាមផ្លូវច្បាប់៕ អត្ថបទ ៖ សំអឿន

# ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១

## កង្វល់ជីវភាព ធ្វើឲ្យពលករខ្មែរនៅតែប្រថុយនឹងគ្រោះថ្នាក់ ទម្លុះរនាំងនៃការរឹតបន្តឹងបិទខ្ទប់ព្រំដែនឆ្លងទៅរកការងារធ្វើនៅថៃ

https://www.rasmeinews.com/ 25 May, 2021

**ដោយ: ភ្នំស្វាយ / ព្រំដែនកម្ពុជា-ថៃ:** *កង្វល់ឬផលប៉ះពាល់លើជីវភាព ដែលបង្កពីការរីករាលដាលជំងឺកូវីដ១៩ បានធ្វើឲ្យពលករខ្មែរនៅតែប្រថុយប្រថាននឹងគ្រោះថ្នាក់ ហើយហ៊ានទម្លុះរនាំងនៃការរឹតបន្តឹងបិទខ្ទប់ព្រំដែនរបស់កងយោធា កងនគរបាលការពារព្រំដែន នៃប្រទេសកម្ពុជា និងប្រទេសថៃ ហើយជៀតលួចឆ្លងដែនខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃ ។*

ពេលគឺ បើទោះបីជាមានពលករខ្មែរចំនួនពី១៥០ទៅ២៥០នាក់ ក្នុង១ថ្ងៃៗ ត្រូវបានអាជ្ញាធរមានសមត្ថកិច្ចថៃចាប់បញ្ជូនមកកម្ពុជា តាមព្រំដែនដោយឡែក នៃភូមិសាស្ត្រខេត្តបន្ទាយមានជ័យក្តី។ នេះបើយោងពលករខ្មែរនិងកងកម្លាំងការពារព្រំដែនថៃ នៅខេត្តស្រះកែវ បានប្រាប់សារព័ត៌មានក្នុងស្រុករបស់ថៃ នៅថ្ងៃទី២៥ខែឧសភាឆ្នាំ២០២១។

វេបសាយក្នុងស្រុកថៃបានផ្សាយថា ទោះបីជាស្ថានភាពជំងឺកូវីដ១៩ នៅតែបន្តរាតត្បាតខ្លាំងក្លាមិនទាន់មានការថមថយ ទាំងនៅក្នុងប្រទេសថៃ និងប្រទេសជិតខាង រួមទាំងកម្ពុជាក្តី ក៏នៅតែមាន ពលករខ្មែរ និងបរទេស

ផ្សេងទៀតមួយចំនួន នៅតែត្រូវចាញ់បោកមេខ្យល់ ហើយបន្តលួចជ្រៀតឆ្លងដែនខុសច្បាប់ ហើយមានហានិភ័យខ្ពស់ ហើយត្រូវកងកម្លាំងសមត្ថកិច្ចចម្រុះថៃ ចាប់បានជាបន្តបន្ទាប់។

ជាក់ស្តែង កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១ ពលករខ្មែរចំនួន១៤នាក់ ត្រូវបានកម្លាំងការពារព្រំដែនភាគីថៃ ធ្វើការចាប់ខ្លួនពីគោលដៅ២ផ្សេងគ្នា។ គឺនៅក្នុងស្តូមិសាស្ត្រស្រុកអារញ្ញ ខេត្តស្រះកែវ។ គេហទំព័រ និងកាសែតក្នុងស្រុកថៃ បានបង្ហាញរូបភាពកងកម្លាំងការពារព្រំដែនថៃនិងកម្ពុជា បានទទួលនិងសម្រួលការត្រួតពិនិត្យពលករ អនុវត្តន៍វិធានបង្ការការពារជំងឺកូវីដ១៩ មុននឹងបញ្ជូនទៅមណ្ឌលចត្តាឡីស័ក និងធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាវិញ៕

## ប៉ូលិស បញ្ជូនមេខ្យល់ ២ នាក់ ទៅតុលាការ និងពលករឆ្លងដែន ខុសច្បាប់ ១៨ នាក់ ទៅមណ្ឌលចត្តាឡីស័ក

https://www.rasmeinews.com/ 25 May, 2021

**ដោយៈ គ្រញូង / បាត់ដំបងៈ** *កាលពីព្រឹកថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ កម្លាំងនគរបាល ការិយាល័យព្រហ្មទណ្ឌកម្រិតស្រាលខេត្ត បានបញ្ជូនជនសង្ស័យ ២ នាក់ ជាមេខ្យល់នាំមនុស្ស ឆ្លងដែនខុសច្បាប់ ទៅតុលាការខេត្ត ដើម្បីចាត់ការតាមច្បាប់។ ចំណែកពលករឆ្លងដែនខុសច្បាប់ ចំនួន ១៨ នាក់ ត្រូវបញ្ជូនទៅមណ្ឌលចត្តាឡីស័ក ស្រុកកំរៀង។*

មេខ្យល់ និងពលករឆ្លងដែន ខុសច្បាប់ ទាំង២០នាក់នេះ មានបំណងឆ្លងដែន ទៅធ្វើការនៅ ប្រទេសថៃ ហើយត្រូវបានលោក ន រស្មី ស្នងការរងរួមជាមួយលោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការ វរសេនាតូច នគរបាលការពារព្រំដែនគោក លេខ៨១៩ បានដឹកនាំកងកម្លាំង ក្នុងអង្គភាព សហការជាមួយ សមត្ថកិច្ចពាក់ព័ន្ធ នៅចំណុចឈរជើង ព្រមទាំងអាជ្ញាធរថៃ បានធ្វើការ ទប់ស្កាត់ករណី នាំចេញ ដោយមិនស្របច្បាប់ នៅចំណុចភូមិសាស្ត្រទទួលខុសត្រូវ ក្នុងស្រុកកំរៀង ខេត្តបាត់ដំបង។

គួរបញ្ជាក់ថា ក្នុងស្ថានភាពដែលប្រទេសថៃ កំពុងមានកំណើន ឆ្លងជម្ងឺកូវីដ១៩ រាល់ថ្ងៃ និងមានបងប្អូនប្រជាពលករ ដែលកំពុងធ្វើការ នៅប្រទេសថៃ បានចាកចេញ ពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ រាល់ថ្ងៃដែលក្នុងនោះ បានរកឃើញថា ពួកគាត់មួយចំនួន បាននាំយក នូវវីរុសកូវីដ១៩ មកជាមួយផងដែរ។ ទន្ទឹមនោះ ក៏ឃើញមានប្រជាពលរដ្ឋ មួយចំនួន បាននិងកំពុងព្យាយាម ចាកចេញពីប្រទេសកម្ពុជា ចូលទៅក្នុងប្រទេសថៃដោយមិនស្របច្បាប់ តាមរយៈការអូសទាញរបស់មុខសញ្ញា ជាមេខ្យល់ ដែលស្ថានភាពបែបនេះ ពួកគាត់កំពុងប្រថុយ ប្រថាន យ៉ាងខ្លាំង ទាំងករណីឆ្លងជម្ងឺកូវីដ១៩ផង និងចំពោះ អំពើល្មើសច្បាប់ផង ។

ទិដ្ឋភាពចំនួនពីរ ក្នុងពេលតែមួយ ដូចខាងលើនេះ តម្រូវឱ្យសមត្ថកិច្ចនគរបាល និងអាជ្ញាធរពាក់ព័ន្ធ ដែលកំពុងឈរជើងបំពេញភារកិច្ច នៅចំណុចជួរមុខ បង្កើនសកម្មភាពទ្វេដង ទាំងការស្វែងរក ពួកគាត់ ដែលឆ្លងចូលមកពីប្រទេសថៃ តាមច្រករបៀង ដើម្បីនាំទៅធ្វើចត្តាឡីស័ក តាមវិធាន សុខាភិបាលផង និងស្វែងរកពួកគាត់ នៅក្នុងភូមិសាស្ត្រ ទទួលខុសត្រូវ ដើម្បីរារាំង ទប់ស្កាត់ ឱ្យបាននូវករណីនាំចេញ ដោយខុសច្បាប់ ពីប្រទេសកម្ពុជា ទៅកាន់ប្រទេសថៃផង។ បន្ទាប់ពីបានធ្វើការឃាត់ខ្លួន រួចហើយ ទាំងមេខ្យល់ និងពលករឆ្លងដែនខុសច្បាប់ ទាំង២០នាក់ ត្រូវបាននាំទៅប្រគល់ ជូនសមត្ថកិច្ចនគរបាល នៃអធិការដ្ឋាននគរបាល ស្រុកកំរៀង ដើម្បីធ្វើការ សាកសួរ និងអនុវត្តបន្ត តាមនីតិវិធី៕/V.mara

# ទាហានថៃបាញ់បុរសខ្មែរម្នាក់របួស ខណៈពេលកំពុងឆ្លងដែនចូលកាប់ឈើគ្រញូង

https://www.postkhmer.com/ ឃុត សុភចរិយា | Publication date 25 May 2021 | 18:00 ICT

**ពោធិ៍សាត់៖** មន្ត្រីយោធាការពារព្រំដែនកម្ពុជា-ថៃ បានប្រាប់ ភ្នំពេញប៉ុស្ដិ៍ នៅរសៀលថ្ងៃទី ២៥ ខែឧសភា នេះថា ពលករខ្មែរម្នាក់ក្នុងចំណោមគ្នា ៦ នាក់ ត្រូវបានក្រុមទាហានឈុតខ្មៅថៃបាញ់បណ្ដាលឲ្យរងរបួសបាក់ជើងម្ខាង ខណៈពេលពួកគេកំពុងលួចឆ្លងដែនចូលទៅកាប់ឈើគ្រញូងនៅក្នុងទឹកដីថៃដោយខុសច្បាប់។

លោក សួន សំបូរ នាយរងការិយាល័យទំនាក់ទំនងកិច្ចការព្រំដែនកម្ពុជា-ថៃ នៃតំបន់ភូមិភាគ៥ បាននិយាយថា នៅព្រឹកថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០២១ ក្រុមការងាររបស់លោកបានទទួលសេចក្ដីរាយការណ៍ពីមន្ត្រីយោធានៃកងពលតូចលេខ ៥៣៧ ដែលឈរជើងនៅជាប់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រស្រុកវាលវែងថា ទាហានឈុតខ្មៅថៃបានផ្ដល់ដំណឹងអំពីការចាប់ឃាត់ខ្លួនពលរដ្ឋខ្មែរម្នាក់ក្រោយពីបាញ់ឲ្យរងរបួស ក្នុងបទល្មើសលួចកាប់ឈើគ្រញូងខុសច្បាប់ក្នុងទឹកដីរបស់ពួកគេហើយបានប្រទូសរ៉ាយជាមួយជាមួយនឹងពួកគេថែមទៀត។ លោក សំបូរ បានបញ្ជាក់ថា៖«ខ្ញុំនិងក្រុមការងារ រួមទាំងកម្លាំងកងពលតូចលេខ ៥៣៧ បានទាក់ទងទៅភាគីថៃ ដើម្បីស្នើសុំយកជនរងគ្រោះដែលជាពលរដ្ឋខ្មែរយើងមកព្យាបាលនិងចាត់វិធានការតាមនីតិវិធីច្បាប់ដោយអាជ្ញាធរខ្មែរយើងវិញ ហើយភាគីថៃក៏បានអនុញ្ញាត បន្ទាប់ពីមានកិច្ចពិភាក្សាអស់រយៈពេលជាង៣ម៉ោង»។

បើតាមលោក សំបូរ បុរសរងគ្រោះ ដោយការបាញ់ប្រហារពីទាហានឈុតខ្មៅថៃនោះឈ្មោះលាន ណាត អាយុ ៣១ ឆ្នាំ មានស្រុកកំណើតនៅភូមិគោកដូង ឃុំគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប និងបានស្នាក់នៅបន្ទប់ជួលមួយក្នុងឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។ លោកថា បច្ចុប្បន្នជនរងគ្រោះកំពុងព្យាបាលនៅមន្ទីរពេទ្យបង្អែកស្រុកវាលវែង ខេត្តពោធិ៍សាត់ ក្រោមការឃ្លាំមើលពីមន្ត្រីនគរបាលមូលដ្ឋានប៉ុស្តិ៍ថ្មដា។

ចំណែកលោក លន់ លាង មេបញ្ជាការនគរបាលវរៈការពារព្រំដែនលេខ ៨២៥ បានប្រាប់ ភ្នំពេញ ប៉ុស្តិ៍ថា តាមរបាយការណ៍ពីមន្ត្រីយោធាព្រំដែនថៃ ដែលលោកទទួលបាន នៅរសៀលថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០២១ នោះ បានបញ្ជាក់ថា ពួកគេបានប្រទះឃើញពលករខ្មែរមួយក្រុមមានគ្នាជិត ១០ នាក់ កំពុងដើរស្ពាយឈើគ្រញូងនៅក្នុងព្រៃនៃទឹកដីថៃ ដែលមានចម្ងាយប្រមាណ ៨០០ ម៉ែត្រ ពីព្រំដែនកម្ពុជា។ លោក លាង បានបន្តថា៖ «ក្នុងរបាយការណ៍នោះ ភាគីទាហានឈុតខ្មៅថៃបានសរសេរថា ក្រុមពលករខ្មែរ បានព្យាយាមរត់គេច ហើយជនរងគ្រោះដែលស្ពាយឈើគ្រញូង ១០ ដុំ ត្រូវបានកម្លាំងយោធាថៃព័ទ្ធជាប់ ហើយក្នុងខណៈនោះជនរងគ្រោះបានព្យាយាមតដៃដោយគប់ពូថៅតម្រង់មកមន្ត្រីយោធាម្នាក់ដែលតាមប្រកិតគាត់។ បន្ទាប់មកបានស្ទុះទៅវាយតប់ជាមួយទាហានថៃនោះ ទើបក្រុមទាហានថៃផ្សេងទៀតបាញ់បំបាក់ជើងតែម្ដងទៅ»។ លោកបានបន្ថែមថា តាមរយៈចម្លើយសារភាពរបស់ជនរងគ្រោះ ពួកគេបានចូលទៅក្នុងទឹកដីថៃនោះ គឺតាមរយៈមេខ្យល់ម្នាក់ឈ្មោះ ស៊ុច អាយុ ៤៥ ឆ្នាំ ជាអ្នករស់នៅក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់។ នៅពេលប្រទះឃើញក្រុមទាហានថៃ ឈ្មោះ ស៊ុច ក៏បានរត់គេចខ្លួនបាត់ទៅ ចំណែកអ្នកផ្សេងទៀត ក៏បានរត់បែកផ្លូវគ្នាអស់ទៅ ៕

# ទាហានថៃចាប់ពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់ ចំនួន១៤នាក់ នៅ២គោលដៅផ្សេងគ្នា ក្នុងថ្ងៃតែមួយ

http://nokorwatnews.com/ 25/05/2021

ក្រុងប៉ោយប៉ែត៖ ទាហានឈុតខ្មៅថៃ ក្នុងអង្គភាពឈុតខ្មៅទី១៣ បានចាប់ពលរដ្ឋខ្មែរលួចឆ្លងដែនខុសច្បាប់ចំនួន១១នាក់ នៅបរិវេណភូមិ ថាប់ ព្រិក ស្រុកអារញ្ញ ខេត្តស្រះកែវ។ ក្រោយពីសមត្ថកិច្ចថៃចាប់បានពួកគេបានសារភាពថា ចង់ទៅធ្វើការផ្នែកសំណង់ នៅក្នុងខេត្តឈុនបុរី នឹងក្រុងបាងកក។

តាមព័ត៌មានក្នុងស្រុកថៃរាយការណ៍ថា កាលពីវេលាម៉ោង១៣ និង៣០នាទី ថ្ងៃទី២៤ ឧសភា ២០២១ ទាហានឈុតខ្មៅថៃបានចាប់ឃុំខ្លួនពលរដ្ឋខ្មែរ ដែលលួចចូលទៅទឹកដីថៃនៅព្រំដែនខេត្តស្រះកែវ តាមវិធានការរឹតបន្តឹង និងទប់ស្កាត់ពលករបរទេសដែលលួចឆ្លងចូលប្រទេសដោយខុសច្បាប់ ក្នុងពេលមានស្ថានការណ៍ការរាតត្បាតជំងឺកូវីដ-១៩។ ដោយហេតុនេះសមត្ថកិច្ចទាហានឈុតខ្មៅ អង្គភាពទី១៣ ក៏បានត្រួតពិនិត្យឃើញ អ្នកលួចឆ្លងដែនចូលប្រទេសថៃ ដោយខុសច្បាប់គឺជនជាតិខ្មែរចំនួន១១នាក់ ចូលតាមច្រកភូមិថាប់ព្រិក ឃុំថាប់ព្រិក ស្រុកអារញ្ញ ខេត្តស្រះកែវ ទើបចាប់ឃុំខ្លួនយកមកសួរនាំ ។

ក្រោយពីសួរនាំបានឲ្យដឹងថា ពលរដ្ឋខ្មែរទាំងអស់ធ្វើដំណើរមកពីខេត្តបាត់ដំបង និងសៀមរាប ប្រទេសកម្ពុជា ចូលមកប្រទេសថៃតាមច្រករបៀងដើម្បីធ្វើដំណើរទៅធ្វើការខាងសំណង់នៅក្នុងខេត្តឈុនបុរីនិងក្រុងបាងកក។ សមត្ថកិច្ចថៃបានធ្វើការឃុំខ្លួននិងធ្វើកំណត់ហេតុ ដោយអនុវត្តតាមវិធានការសុខាភិបាល មុននឹងទំនាក់ទំនងមកភាគីកម្ពុជា ដើម្បីបណ្តេញត្រឡប់ទៅប្រទេសដើមវិញ។ព័ត៌មានថៃរាយការណ៍ទៀតថាក្នុងថ្ងៃដដែលនោះដែរ សមត្ថកិច្ចកងកម្លាំងបូរផា បានស្កាត់ចាប់ពលរដ្ឋខ្មែរ៣នាក់ផ្សេងទៀតសុទ្ធតែប្រុសទាំងអស់ នៅបរិវេណភូមិប៉ារ៉ៃថ្មី ឃុំប៉ារ៉ៃ ស្រុកអារញ្ញ ខេត្តស្រះកែវ ។ ក្រោយសួរនាំពលរដ្ឋខ្មែរខាងលើបានឲ្យដឹងថា ពួកគេចង់ធ្វើដំណើរចូលមកប្រទេសថៃ ដើម្បីទៅស៊ីឈ្នួលនៅផ្សារដិចក្នុងផ្សាររោងគ្លឿប្រទេស(ថៃ)។ពេលទទួលបានចម្លើយនេះ ទើបសមត្ថកិច្ចនាំខ្លួនទៅអនុវត្តតាមវិធានការផ្នែកសុខាភិបាល នៅទីបញ្ជាការដ្ឋានកងរយ១២០៥ ដើម្បីចាត់ការបន្តតាមច្បាប់៕

## កម្លាំងនគរបាលកម្ពុជា សហការជាមួយភាគីថៃ ឃាត់ខ្លួនមេខ្យល់ ចំនួន២នាក់ និងពលករ ចំនួន១២នាក់

http://cambodiapolice.com/policekh/ 11:47 am  25 ឧសភា 2021

**បាត់ដំបង៖** នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរៈសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៩ បានដឹកនាំកម្លាំង សហការជាមួយភាគីថៃ បានឃាត់ខ្លួនមេខ្យល់ ចំនួន២នាក់ និងពលករ ចំនួន១២នាក់ (ស្រី៤នាក់, ក្មេង២នាក់) បានបញ្ជូនទៅអធិការដ្ឋាននគរបាលស្រុកកំរៀងអនុវត្តតាមផ្លូវច្បាប់បន្ត។ លោកវរសេនីយ៍ឯក ម៉ង់ ស៊ី បានឱ្យដឹងថា ការបង្ក្រាប និងឃាត់ខ្លួនមេខ្យល់ខាងលើធ្វើឡើងដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករ ចេញ-ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្រោមការដឹកនាំបញ្ជាផ្ទាល់ដោយលោកវរសេនីយ៍ ឯក ស៊ិន ប៊ុនរស្មី ស្នងការរងទទួលការងារវរៈសេនាតូចនគរបាលការពាព្រំដែនគោកលេខ៨១៩ ៕

## ប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ២៨នាក់

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃអង្គារ ទី២៥ ខែឧសភា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និង

ច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ២៨នាក់ ស្រី ១១នាក់ ក្នុងនោះកុមារា ០០នាក់ កុមារី ០០នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ២១នាក់ ស្រី ៨នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ៤នាក់ ស្រីចំនួន ៣នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ៣នាក់ ប្រុសចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ២៨នាក់ ស្រី ១១នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## តុលាការសម្រេចឃុំខ្លួនមេខ្យល់ ២ នាក់ ខណៈសមត្ថកិច្ចចាប់ខ្លួនបាន ២ នាក់ទៀត

https://www.postkhmer.com/ គឹម សារុំ | Publication date 25 May 2021 | 10:32 ICT

**បន្ទាយមានជ័យៈ** តុលាការខេត្តបន្ទាយមានជ័យបានសម្រេចឃុំខ្លួនបុរសមេខ្យល់ ២ នាក់ ក្នុងពន្ធនាគារខេត្តនៅរសៀលថ្ងៃទី ២៣ ខែឧសភា ខណៈជនសង្ស័យដែលជាមេខ្យល់ ២ នាក់ផ្សេងទៀត ត្រូវបានចាប់ខ្លួននៅយប់ក្នុងថ្ងៃដដែល និងសង្គ្រោះពលករបាន ១៧ នាក់ នៅពេលពួកគេបម្រុងលួចឆ្លងដែនចូលទៅប្រទេសថៃ ស្ថិតក្នុងភូមិព្រៃចាន់ ឃុំអូរពាជាន់ ស្រុកអូរជ្រៅ។

លោកស្រីឧត្ដមសេនីយ៍ត្រី ឌី សុជាតិ ស្នងការរងទទួលផែនការការងារនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្តបន្ទាយមានជ័យ ប្រាប់ភ្នំពេញប៉ុស្ដិ៍នៅថ្ងៃទី ២៤ ឧសភាថា បុរសឈ្មោះ ពៅ បូរី ភេទប្រុស អាយុ ៤១ ឆ្នាំ រស់នៅភូមិជោគជ័យ ឃុំអូរពាជាន់ ស្រុកអូរជ្រៅ និងឈ្មោះ ម៉ៅ ដែន ភេទប្រុស អាយុ ២៦ ឆ្នាំ រស់នៅភូមិបឹងប្រាសាទ ឃុំអូរពាជាន់ ស្រុកអូរជ្រៅ ត្រូវបានចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តបន្ទាយមានជ័យចេញដីកាឃុំនៅពន្ធនាគារហើយកាលពីរសៀលថ្ងៃទី ២៣ ឧសភា។ លោកស្រីបញ្ជាក់ថា៖ «បុរសទាំង ២ នាក់ត្រូវចោទពីបទការនាំចេញដោយមិនស្របច្បាប់ សម្រាប់នាំឆ្លងដែនតាមមាត្រា ១១ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ»។ យោងបញ្ញត្តិមាត្រា ១១ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនេះ បើសិនជាតុលាការរកឃើញថា ជនត្រូវចោទទាំង ២ នាក់ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែននោះ នឹងត្រូវជាប់ពន្ធនាគារពី ៧ ទៅ ១៥ ឆ្នាំ។

លោក ម៉ាន់ ជី អធិការរងស្រុកអូរជ្រៅ និងជាសមាជិកគណៈកម្មការទប់ស្កាត់ពលករឆ្លងដែនប្រាប់ភ្នំពេញប៉ុស្ដិ៍កាលពីរសៀលថ្ងៃទី ២៣ ឧសភាថាពលករប្រុសស្រី ១៧ នាក់ (ក្មេងស្រីតូចម្នាក់) និងមេខ្យល់ ២ នាក់ត្រូវសមត្ថកិច្ចជួយសង្គ្រោះ និងចាប់ខ្លួនកាលពីយប់ថ្ងៃទី ២២ ឧសភា ដោយកម្លាំងសមត្ថកិច្ចចម្រុះប្រចាំការនៅចំណុចគោលដៅស្ថិតនៅភូមិជោគជ័យ ឃុំអូរពាជាន់ ស្រុកអូរជ្រៅ។ អ្នកទាំងនោះបាននាំគ្នាលួចដើរឆ្លងកាត់គោលដៅរបស់សមត្ថកិច្ចបម្រុងឆ្លងដែនចូលទៅប្រទេសថៃ។ ក្រោយឃាត់ខ្លួនសមត្ថកិច្ចបានរាប់ចំនួនឃើញមានមនុស្សស្រីចំនួន ៨ នាក់ (រាប់ទាំងក្មេងស្រីតូចម្នាក់ផង) និងប្រុសចំនួន ៩ នាក់ បូក និងបុរសជាមេខ្យល់ ២ នាក់ទៀត មានចំនួន ១៩ នាក់។ ក្រុមពលករទាំងអស់ត្រូវបាននាំទៅមណ្ឌលចត្តាឡីស័ក។

ដោយឡែកកាលពីយប់ថ្ងៃទី ២៣ ឧសភាបើយោងតាម បណ្ដាញទំនាក់ទំនងសង្គមរបស់ឃោធភូមិភាគទី ៥ នៅខេត្តបន្ទាយមានជ័យសរសេរថា កងពលតូចថ្មើរជើងលេខ ៥១ បានដឹកនាំកម្លាំងដើរល្បាតដោយលោកវរសេនីយ៍ទោ ប៉ែន សុគន្ធ មេបញ្ជាការវរសេនាតូចថ្មើរជើងលេខ ៥១៤ នៅយប់ថ្ងៃទី ២៣ ឧសភា បានឃាត់ខ្លួនមេខ្យល់ ២ នាក់ និងជួយសង្គ្រោះពលករបានចំនួន ៨ នាក់ (ស្រីម្នាក់)។ មេខ្យល់ទាំង ២ នាក់ ម្នាក់ឈ្មោះ លឹម ហួត ភេទប្រុស អាយុ ៣៨ ឆ្នាំរស់នៅភូមិព្រៃចាន់ ឃុំអូរពាជាន់ ស្រុកអូរជ្រៅ និងម្នាក់ទៀត ឈ្មោះ ជួត សុខជ័យ ភេទប្រុស អាយុ ១៨ ឆ្នាំ រស់នៅភូមិបន្ទាយថ្មី ឃុំអូរពាជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

លោកស្រី ឌី សុជាតិ បានឱ្យដឹងនៅថ្ងៃទី ២៤ ឧសភាថា ចំពោះមេខ្យល់ ២ នាក់ដែលសមត្ថកិច្ចឃាត់ខ្លួននោះ មិនទាន់បញ្ជូនដល់ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យនៅឡើយទេ នៅព្រឹកថ្ងៃទី ២៤ ឧសភា។ ជនសង្ស័យដែលជាមេខ្យល់នាំមនុស្សឆ្លងដែនទាំងនោះ ពួកគេត្រូវតែប្រឈមនឹងផ្លូវច្បាប់៕

## ពលករខ្មែរ០៦នាក់និងកុមារ០២នាក់ ដែលជាប់គាំងនៅម៉ាឡេស៊ី នឹងត្រឡប់មកកម្ពុជាល្ងាចនេះ

http://freshnewsasia.com/ 2021-05-26 10:28am

**(ភ្នំពេញ)៖** ដោយមានកិច្ចអន្តរាគមន៍របស់ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី ពលករពលការិនីខ្មែរ ០៦នាក់ និងកុមារ ០២នាក់ នឹងធ្វើដំណើរត្រឡប់កមមាតុប្រទេសវិញតាមជើងយន្ត ហោះលេខ SQ158 ថ្ងៃ ទី ២៦ ខែ ឧសភា ឆ្នាំ ២០២១ វេលា ម៉ោង ០៥:៣៥នាទី ល្ងាច។ នេះបើតាម លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។ លោក កុយ គួង បានបញ្ជាក់ថា ករណីនេះ ស្ថានទូតបានចេញលិខិតធ្វើដំណើរបណ្ដោះអាសន្ន ចំពោះអ្នកដែលគ្មានលិខិតឆ្លងដែន និង ជូនទៅធ្វើតេស្ត កូវីដ ១៩ ព្រមទាំង ជូនដំណើរពួកគាត់ ទៅអាកាសយានដ្ឋាន អន្តរ ជាតិ KLIA ផង ដែរ៕

## ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១

## ត្រឹមជាង៣ខែ ពលករខ្មែរជិត៧ពាន់នាក់ត្រូវបានឃាត់ខ្លួនពីបទគេចវេះចត្តាឡីស័ក

https://www.kampucheathmey.com/ ថ្ងៃពុធ ២៦ ឧសភា ២០២១ ដោយ KC Virak

ភ្នំពេញ៖ រហូតមកដល់ពេលនេះសមត្ថកិច្ចបានធ្វើការឃាត់ខ្លួនពលករខ្មែរដែលគេចវេះពីការធ្វើចត្តាឡីស័កប្រមាណជិត៧ពាន់នាក់ហើយនៅទូទាំងប្រទេស។

លោក ឧត្តមសេនីយ៍ឯក ឆាយ គីមខឿន អគ្គស្នងការរង និងជាអ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិ បានប្រសាសន៍នៅថ្ងៃទី២៦ ខែឧសភា នេះថា ចាប់ពីថ្ងៃទី១៣ ខែកុម្ភៈ រហូតមកដល់ថ្ងៃទី២៦ ខែឧសភាឆ្នាំ ២០២១នេះ សមត្ថកិច្ចបានធ្វើការឃាត់ខ្លួនពលករខ្មែរដែលគេចវេះពីការធ្វើចត្តាឡីស័កបានចំនួន៦,៨៤៦នាក់ ក្នុងនោះមានស្រី១,៨៤៥នាក់ និងបានបញ្ជូនពួកគេឱ្យទៅធ្វើចត្តាឡីស័កនៅតាមមូលដ្ឋានរៀងៗខ្លួនវិញផងដែរ។ លោកឧត្តមសេនីយ៍ឯកបានបន្តថា ក្នុងចំណោមពលករគេចវេះពីការធ្វើចត្តាឡីស័កជិត៧ពាន់នាក់នោះ ពួកគេបានឆ្លងពីប្រទេសថៃ និងប្រទេសវៀតណាមចូលកម្ពុជាដោយមានមេខ្យល់ជាអ្នកនាំផ្លូវ។ លោកឧត្តមសេនីយ៍ឯក ឆាយ គីមខឿន បានបន្តទៀតថា មកដល់ពេលនេះសមត្ថកិច្ចបានចាប់មេខ្យល់ដែលនាំពលករខ្មែរឆ្លងដែនខុសច្បាប់ចេញចូលប្រទេសកម្ពុជាបានចំនួន២២២នាក់ ក្នុងនោះមានស្រី១៥នាក់ និងបានបញ្ជូនទៅតុលាការដើម្បីធ្វើការផ្តន្ទាទោសទៅតាមច្បាប់។ លោក ឧត្តមសេនីយ៍ឯក ឆាយ គីមខឿន បានអំពាវនាវដល់ពលករទាំងអស់សូមបញ្ឈប់ការឆ្លងដែនខុសច្បាប់ និងកុំព្យាយាមគេចវេះពីការធ្វើចត្តាឡីស័កដើម្បីចៀសវាងការទទួលការផាកពិន័យ និងទោសទណ្ឌតាមផ្លូវច្បាប់។

យោងតាមច្បាប់ជនណាដែលនាំអ្នកដទៃ គេចវេះពីការធ្វើចត្តាឡីស័កនឹងទទួលពិន័យប្រាក់ពី១០លានរៀលដល់៥០លានរៀល និងអ្នកគេចវេះមិនចូលធ្វើចត្តាឡីស័ក និងអ្នកគេចចេញពីការធ្វើចត្តាឡីស័ក ក្នុងអំឡុងកំពុងធ្វើចត្តាឡីស័ក នឹងត្រូវពិន័យប្រាក់ពី១លានរៀលដល់៥លានរៀល។ អត្ថបទ៖ សំអឿន

## បញ្ជូនមេខ្យល់៣នាក់ទៅតុលាការ ករណីនាំពលករ៤នាក់ឆ្លងដែនខុសច្បាប់

https://www.kampucheathmey.com/ ថ្ងៃពុធ ២៦ ឧសភា ២០២១ដោយ Kang Tola

បន្ទាយមានជ័យ ៖ មេខ្យល់៣នាក់ក្នុងនោះមានស្រីម្នាក់ ត្រូវអាវុធហត្ថបញ្ជូនទៅតុលាការ ចំណែកពលករ៤នាក់ កម្លាំងអាវុធហត្ថបញ្ជូនទៅមណ្ឌលចត្តាឡីស័កនៅខេត្តបន្ទាយមានជ័យ។ តាមការអះអាងរបស់គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុងក្រុងប៉ោយប៉ែតបានប្រាប់អ្នកយកព័ត៌មានថា មានពលករ១ក្រុមរៀបចំបម្រុងឆ្លងដែនទៅប្រទេសថៃ ដោយខុសច្បាប់ទើបកម្លាំងមូលដ្ឋានកងរាជអាវុធហត្ថក្រុងប៉ោយប៉ែតសហការជាមួយកម្លាំងរដ្ឋបាលក្រុងប៉ោយប៉ែតចុះទៅដល់កន្លែងឃាត់ខ្លួនពលករបានចំនួន៤នាក់ នៅចំណុចភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាលក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ នៅវេលាម៉ោង១០យប់ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ ហើយនាំយកមកមូលដ្ឋានកងរាជអាវុធហត្ថក្រុង ដើម្បីសួរនាំ។

លោកវរសេនីយ៍ត្រី នួន នីណារ៉ូ មេបញ្ជាការមូលដ្ឋានកងរាជអាវុធហត្ថក្រុងប៉ោយប៉ែតបានប្រាប់ឲ្យដឹងថា ក្រោយពីសួរនាំពលករទាំង៤នាក់រួច ទើបឈានដល់ឃាត់ខ្លួនបានមេខ្យល់៣នាក់៖ ១ឈ្មោះ ជួន ចំណាប់ ភេទប្រុស អាយុ២៨ឆ្នាំ ២ឈ្មោះ ចាន់ ស្រី ភេទស្រី អាយុ៣៧ឆ្នាំ ៣ឈ្មោះ វី ចិត្រា ភេទប្រុស អាយុ៣២ឆ្នាំ និងដកហូតវត្ថុតាងរួមមាន ម៉ូតូចំនួន២គ្រឿង និងទូរសព្ទដៃចំនួន៣គ្រឿងផងដែរ។ ក្រោយពីកម្លាំងជំនាញកងរាជអាវុធហត្ថក្រុងសួរចម្លើយរួចមកមេខ្យល់បានឆ្លើយសារភាពថា ពួកគេពិតជាបាននាំពលករឆ្លងដែនទៅប្រទេសថៃពិតប្រាកដមែន ហើយកន្លងមកពួកខ្លួនបាននាំពលករឆ្លងដែនទៅប្រទេសថៃជាច្រើនលើកមកហើយ។ មេខ្យល់ទាំង៣នាក់ និងវត្ថុតាង ត្រូវបានកម្លាំងជំនាញមូលដ្ឋានកងរាជអាវុធហត្ថក្រុងប៉ោយប៉ែត កសាងសំណុំរឿងបញ្ជូនមកបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តចាត់ការបន្ត។

លោកវរសេនីយ៍ទោ ព្រហ្ម ថេង ប្រធានមន្ទីរស្រាវជ្រាវ និងបង្ក្រាបបទល្មើស បានឲ្យដឹងថា មេខ្យល់ទាំង៣នាក់និងម៉ូតូ៣គ្រឿងតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ត្រី បោន ប៊ិន មេបញ្ជាការកងរាជអាវុធហត្ថខេត្តបានឲ្យកម្លាំងជំនាញការិយាល័យប្រឆាំងការជួញដូរមនុស្ស បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត បញ្ជូនទៅសាលាដំបូងខេត្តចាត់ការតាមនីតិវិធីហើយនៅរសៀលថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១នេះ ចំណែកពលករ៤នាក់កម្លាំងអាវុធហត្ថបញ្ជូនទៅមណ្ឌលចត្តាឡីស័ក នៅខេត្តបន្ទាយមានជ័យចំនួន១៤ថ្ងៃ ទើបអនុញ្ញាតឲ្យវិលត្រឡប់ទៅផ្ទះវិញបាន។ *ដោយ ៖ ភ័ន់ ណាង*

## អាជ្ញាធរខេត្តបាត់ដំបង ព្រមានមន្ត្រីពាក់ព័ន្ធជាមួយ មេខ្យល់ នាំពលករឆ្លងដែនខុសច្បាប់ ត្រូវបញ្ឈប់សកម្មភាព ជាបន្ទាន់

https://dap-news.com/national/ BySS107 Posted on May 26, 2021

បាត់ដំបង៖ លោក ណុប ដារ៉ា អភិបាលរងខេត្តបាត់ដំបងស្នើដល់មន្ត្រីដែលពាក់ព័ន្ធជាមួយមេខ្យល់នាំពលករឆ្លងដែនខុសច្បាប់ក្នុងភូមិសាស្ត្រខេត្តបាត់ដំបង ត្រូវបញ្ឈប់សកម្មភាពជាបន្ទាន់។

ជាក់ស្តែង កាលពីល្ងាចថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ លោក ណុប ដារ៉ា អភិបាលរងខេត្ត និងជាប្រធានដឹកនាំការស្រាវជ្រាវបង្ក្រាបបទល្មើសឆ្លងដែនខុសច្បាប់គ្រប់ប្រភេទ និងមេខ្យល់ដែលនាំប្រជាពលរដ្ឋ ចេញ-ចូលនៅប្រទេសថៃ ដោយមានការដឹកនាំបញ្ជាផ្ទាល់ពីលោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគបាលខេត្តបាត់

ដំបង កម្លាំងនគរបាលការពារព្រំដែនលេខ៨១៩ និងកម្លាំងកងយោធពលខេមរភូមិន្ទ បានសហការជាមួយកម្លាំងទាហានឈុតខ្មៅថៃកងវរយលេខ៥២៥ ឃាត់ខ្លួនមុខសញ្ញានាំចេញដោយមិនស្របច្បាប់ (មេខ្យល់) ចំនួន១ករណី ដោយធ្វើសកម្មភាព នាំពលករចំនួន ២នាក់ ឆ្លងដែនចូលទៅទឹកដីចំណុចម្តុំ(ស្ពាន៣) ភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ត្រូវសមត្ថកិច្ចឃាត់ខ្លួនបាន មុខសញ្ញាសង្ស័យមេខ្យល់ ចំនួន១នាក់ ឈ្មោះ កែង ជា ភេទប្រុស អាយុ ៣៨ឆ្នាំ ដោយឡែកពលករចំនួន២នាក់ និងមេខ្យល់ម្នាក់ទៀតបានរត់គេចខ្លួនបាត់ បច្ចុប្បន្នជនសង្ស័យខាងលើ បានបញ្ជូនទៅអោយកម្លាំងអធិការដ្ឋាននគរបាលស្រុកកំរៀងអនុវត្តន៍តាមនីតិវិធីបន្ត៕\

## ប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៣៧នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃពុធ ទី២៦ ខែឧសភា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៣៧នាក់ ស្រី ១៧នាក់ ក្នុងនោះកុមារា ២នាក់ កុមារី ០០នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៦នាក់ ស្រី ៣នាក់ កុមារា ១នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៣នាក់ ស្រី ១នាក់ កុមារា ១នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ២៨នាក់ ស្រី ១៣នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ប្រុសចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៣៧នាក់ ស្រី ១៧នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ពលករខ្មែរ ៦ នាក់ និងកុមារ ២ នាក់ រស់នៅម៉ាឡេស៊ី ដោយខុសច្បាប់ត្រូវបានជួយឱ្យត្រឡប់មកស្រុកកំណើតវិញ

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 27 May 2021 | 10:36 ICT

**ភ្នំពេញ៖** កម្ពុជាបានស្វែងរកកិច្ចអន្តរាគមន៍ទៅកាន់រដ្ឋាភិបាលប្រទេសម៉ាឡេស៊ី រួចហើយ ដើម្បីនាំយកពលករ ពលការិនីខ្មែរចំនួន ៦ នាក់ និងកុមារ ២ នាក់ឱ្យបានត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ បន្ទាប់ពីពួកគេបានបន្តរស់នៅក្នុងប្រទេសនេះដោយខុសច្បាប់។ នេះបើតាមអ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា លោក កុយ គួង។ លោក កុយ គួង ប្រាប់ ភ្នំពេញ ប៉ុស្តិ៍ ពីម្សិលមិញថា ដោយមានកិច្ចអន្តរាគមន៍របស់ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី ពលករ-ពលការិនីខ្មែរ ៦ នាក់ និងកុមារ ២ នាក់ធ្វើដំណើរត្រឡប់មកមាតុប្រទេសវិញតាមជើងយន្តហោះ

លេខ SQ158 នៅថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០២១ វេលាម៉ោង ០៥:៣៥ នាទីល្ងាច។ លោកបញ្ជាក់ថា៖ «ស្ថានទូតបានចេញលិខិតធ្វើដំណើរបណ្តោះអាសន្ន ចំពោះអ្នកដែលគ្មានលិខិតឆ្លងដែន និង ជូនទៅធ្វើតេស្តកូវីដ ១៩ ព្រមទាំងជូនដំណើរពួកគាត់ទៅអាកាសយានដ្ឋានអន្តរជាតិ KLIA ផងដែរ។ ខ្ញុំគ្រាន់តែដឹងត្រឹមថា ពួកគាត់ជាពលករខុសច្បាប់ ហើយចង់ត្រឡប់មកកម្ពុជាវិញ ទើបសុំឱ្យស្ថានទូតជួយអន្តរាគមន៍»។

កាលពីថ្ងៃទី ២១ ខែឧសភា ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ីក៏បានអន្តរាគមន៍ ដើម្បីសម្របសម្រួលឱ្យពលករខ្មែរ ចំនួន ៧ នាក់ដែលបានមករស់នៅ និងធ្វើការខុសច្បាប់នៅប្រទេសម៉ាឡេស៊ីបានត្រឡប់មកកម្ពុជាវិញ ផងដែរ។ នេះបើតាមទំព័រហ្វេសប៊ុកផ្លូវការរបស់ស្ថានទូត។ ជាមួយគ្នានេះ ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ីក៏បានអំពាវនាវឱ្យប្រជាពលរដ្ឋខ្មែរ គួរបញ្ឈប់ជាបន្ទាន់ក្នុងការធ្វើចំណាកស្រុកដោយខុសច្បាប់ទៅប្រទេសម៉ាឡេស៊ីនេះ ដោយបង្ហាញក្តីបារម្ភថា អាចប្រឈមនឹងគ្រោះថ្នាក់ និងការចាញ់បោកពីសំណាក់ជនខិលខូច។ ស្ថានទូតបានបញ្ជាក់ថា៖ «សូមបងប្អូនអនុវត្តឱ្យបានត្រឹមត្រូវនូវវិធានការសុខាភិបាល ដើម្បីសុខភាព និងសុវត្ថិភាពសង្គមជាតិយើង»។

លោក ឌី ថេហូយ៉ា មន្ត្រីកម្មវិធីផ្នែកសិទ្ធិពលករចំណាកស្រុកនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារកម្ពុជា (សង់ត្រាល់) លើកឡើងថា ចាប់ពីឆ្នាំ ២០១២ មក ប្រទេសម៉ាឡេស៊ីក៏ចាប់ផ្តើមមានពលករខុសច្បាប់កម្ពុជាច្រើន ព្រោះប្រទេសនេះបានបញ្ចប់អនុស្សរណៈយោគយល់ (MoU) ជាមួយកម្ពុជាក្នុងការនាំពលករខ្មែរទៅប្រទេសនេះ។ ជាថ្មីម្តងទៀតនៅឆ្នាំ ២០១៦ ប្រទេសទាំង ២ ក៏បានចាប់ផ្តើម MoU ជាមួយគ្នាវិញ។ ប៉ុន្តែលោកថា ពលករខ្មែរមួយចំនួនក៏នៅបន្តរស់នៅដោយខុសច្បាប់ តាមរយៈការឆ្លងដែនដោយខុសច្បាប់ បើទោះជាពលករមួយចំនួនទៀតទទួលបានសិទ្ធិស្របច្បាប់វិញក៏ដោយ។ ក្រៅពីនេះលោកសង្កេតឃើញថា ក្នុងរយៈពេលនៃការផ្ទុះជំងឺកូវីដ ១៩ ក៏មានពលរដ្ឋខ្មែរជាច្រើនដែលរស់នៅក្នុងប្រទេសនេះ ទទួលបានសិទ្ធិស្របច្បាប់ ស្របពេលរដ្ឋាភិបាលនៃប្រទេសនេះបានផ្តល់ភាពអនុគ្រោះ។ ប៉ុន្តែក៏មានពលរដ្ឋខ្មែរជាច្រើនបន្តរស់នៅខុសច្បាប់ ដោយសារតែពួកគេមិនបានទទួលព័ត៌មានគ្រប់ជ្រុងជ្រោយ។

លោក ឌី ថេហូយ៉ា រំពឹងថា រដ្ឋាភិបាលកម្ពុជានឹងផ្តល់កិច្ចគាំពារបន្ថែមទៀត ទៅដល់ប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅដោយខុសច្បាប់ និងស្របច្បាប់ក្នុងប្រទេសម៉ាឡេស៊ី ដើម្បីធ្វើយ៉ាងណាឱ្យពួកគេអាចទទួលបានសិទ្ធិការពារ ដោយរួចពីការដាក់ទោសទណ្ឌនៃច្បាប់ប្រទេសម៉ាឡេស៊ី។ លោកបញ្ជាក់ថា៖ «ពាក់ព័ន្ធនឹងអ្នកដែលអត់មានការងារធ្វើក្នុងអំឡុងពេលកូវីដនេះ ចំពោះស្បៀងអាហារ រដ្ឋាភិបាលក៏គួរតែរៀបចំផ្តល់ជូនដល់ពួកគាត់ផងដែរ។ អ្នកដែលមានបំណងត្រឡប់មកខ្មែរវិញ រដ្ឋាភិបាលគួរតែធានា និងរៀបចំនីតិវិធីបែបណា ដើម្បីឱ្យពួកគាត់អាចត្រឡប់មកមាតុប្រទេសវិញ ដោយមិនទទួលបានការដាក់ទោសទណ្ឌរបស់ប្រទេសម៉ាឡេស៊ី»។

បើតាមលោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជាក្នុងរយៈពេល ៣ ខែដំបូងគឺ ខែមករា កុម្ភៈ និង ខែមីនា ឆ្នាំ ២០២១ នេះ ស្ថានទូតតំណាងកម្ពុជានៅបរទេសបានជួយអន្តរាគមន៍សង្គ្រោះពលរដ្ឋខ្មែររងគ្រោះក្នុងប្រទេសចំនួន ៧ ឱ្យត្រឡប់មកមាតុប្រទេសវិញបានចំនួន ១ ២៥៧ នាក់៕

## មេបញ្ជាការកងពលតូចថ្មើរជើងលេខ៥១ ដាក់ផែនការម៉ឺងម៉ាត់ ដើម្បីទប់ស្កាត់ការលួចឆ្លងព្រំដែនកម្ពុជា-ថៃ និងបិទខ្ទប់តំបន់ក្រហម

http://nokorwatnews.com/ 27/05/2021

ខេត្តបន្ទាយមានជ័យ៖ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១ ឧត្តមសេនីយ៍ត្រី សឹង្ហ ទុំ មេបញ្ជាការ កងពលតូចថ្មើរជើងលេខ៥១បន្តដាក់ផែនការយ៉ាងម៉ឺងម៉ាត់ដល់ កងកម្លាំងជួរមុខ របស់កងពលតូចថ្មើរជើងលេខ៥១ បន្តអនុ

វត្តរីតត្បិតតាមបណ្តាចំណុចឈរជើង និងតំបន់ក្រហម ដោយសហការជាមួយកងកម្លាំងចម្រុះ ឈរជើងនៅតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ។

គួរកត់សំគាល់ថា កងកម្លាំងជួរមុខកងពល បានចេញបេសកកម្មប្រតិបត្តិការទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ-១៩ តាមបន្ទាត់ព្រំដែន មានរយៈពេល១៥៣ថ្ងៃមកហើយ គិតត្រឹមថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១ នេះ ដោយឈរជើងជាច្រើនចំណុច ប្រតិបត្តិការល្បាត ត្រួតពិនិត្យ២៤ម៉ោងលើ២៤ម៉ោង និងឃាត់ខ្លួនពលករលួចឆ្លងចេញ-ចូលសរុប ១២០៤នាក់ ស្រាវជ្រាវ និងឃាត់ខ្លួនមេខ្យល់សរុបបានចំនួន ១៥នាក់ បញ្ជូនឲ្យសមត្ថកិច្ចជំនាញចាត់ការតាមផ្លូវច្បាប់។ ក្រៅពីភារកិច្ចឈរជើងនៅតាមបន្ទាត់ព្រំដែន កម្លាំងមួយផ្នែកទៀតក៏បានអនុវត្តភារកិច្ច ចូលរួមជាមួយកម្លាំងចម្រុះធ្វើការបិទខ្ទប់ តំបន់មួយចំនួនក្នុងក្រុងប៉ោយប៉ែត ទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ-១៩ ទៅតំបន់ផ្សេងទៀត។

ឧត្តមសេនីយ៍ត្រី សឹង្ហ ទុំ បានគូសបញ្ជាក់ថា ស្ថិតនៅក្នុងកាលៈទេសៈដ៏លំបាកនេះ អនុវត្តតាមបទបញ្ជាប្រមុខរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងថ្នាក់ដឹកនាំកងទ័ពគ្រប់លំដាប់ថ្នាក់ នាយ-ពលទាហាន អង្គភាពកងពលតូចថ្មើរជើងលេខ៥១ បានគោរព និងអនុវត្ត រាល់បទបញ្ជា សេចក្តីណែនាំ ដែលបានដាក់ប្រកបដោយភាពទទួលខុសត្រូវខ្ពស់ ជូនជាតិមាតុភូមិ និងប្រជាជន៕

## ឃាត់ខ្លួនមេខ្យល់ម្នាក់ក្នុងចំណោម២នាក់ នាំពលករឆ្លងដែនទៅថៃខុសច្បាប់

http://nokorwatnews.com/ 28/05/2021

ខេត្តបាត់ដំបង៖ កម្លាំងសមត្ថកិច្ចចម្រុះតាមព្រំដែន បានឃាត់ខ្លួនមេខ្យល់ម្នាក់កាលពីរសៀលថ្ងៃទី២៦ខែឧសភានេះក្រោយធ្វើសកម្មភាព នាំពលករចំនួន២នាក់ ឆ្លងដែនចូលទៅទឹកដីថៃខុសច្បាប់ត្រង់ ចំណុចម្តុំ (ស្ថាន ៣) ភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង។

សមត្ថកិច្ចព្រំដែនបានឲ្យដឹងថា កម្លាំងនគរបាលការពារព្រំដែនលេខ៨១៩ និងកម្លាំងកងយោធពលខេមរភូមិន្ទ សហការជាមួយកម្លាំងទាហានឈុតខ្មៅថៃ កងរយលេខ៥២៥ ដោយធ្វើឡើង បន្ទាប់ពីមានការបញ្ជាផ្ទាល់ពីឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ។ ក្នុងករណីនេះមុខសញ្ញាសង្ស័យជាមេខ្យល់ចំនួន១នាក់ ដែលឃាត់ខ្លួនបាននេះមានឈ្មោះ កែង ជា ភេទប្រុស អាយុ៣៨ឆ្នាំ។ ដោយឡែកពលករចំនួន២នាក់ និងមេខ្យល់ម្នាក់ទៀត បានរត់គេចខ្លួនបាត់។

បច្ចុប្បន្នជន សង្ស័យខាងលើ ត្រូវបានបញ្ជូនទៅឱ្យកម្លាំងអធិការដ្ឋាននគរបាលស្រុកកំរៀង អនុវត្តតាមនីតិវិធីច្បាប់បន្ត។ពាក់ព័ន្ធនឹងករណី នេះ លោក ណុប ដារ៉ា អភិបាលរងខេត្តបាត់ដំបង និងជាប្រធានដឹកនាំការស្រាវជ្រាវបង្ក្រាបបទល្មើសឆ្លងដែនខុសច្បាប់គ្រប់ប្រភេទ និងមេខ្យល់ដែលនាំប្រជាពលរដ្ឋចេញ-ចូលនៅប្រទេសថៃ បានស្នើឱ្យមន្ត្រីដែលពាក់ព័ន្ធជាមួយមេខ្យល់នាំពលករឆ្លងដែនខុសច្បាប់ ក្នុងភូមិសាស្ត្រខេត្តបាត់ដំបង ត្រូវបញ្ឈប់សកម្មភាពនេះជាបន្ទាន់ ព្រោះទង្វើនេះជាអំពើល្មើសច្បាប់៕

## ប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ២៧នាក់

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃព្រហស្បតិ៍ ទី២៧ ខែឧសភា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ២៧នាក់ ស្រី ១៤នាក់ ក្នុងនោះ កុមារា ២នាក់ កុមារី ០០នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ១នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ២នាក់ ស្រី ១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ១៦នាក់ ស្រី ៨នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ៨នាក់ ស្រីចំនួន ៥នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ប្រុសចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ២៧នាក់ ស្រី ១៤នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ខេត្តបាត់ដំបងរកឃើញពលករ ០៧នាក់ និងពលរដ្ឋធ្វើដំណើរពីភ្នំពេញ ០៣នាក់ ឆ្លងមេរោគកូវីដ-១៩

https://news.btv.com.kh/ 05/27/2021 10:05 PM

បាត់ដំបង៖ រដ្ឋបាលខេត្តបាត់ដំបង បានប្រកាសពីការរកឃើញមនុស្ស ១០នាក់ទៀតបានឆ្លងមេរោគកូវីដ-១៩ ដែលភាគច្រើនជាពលករខ្មែរវិលត្រឡប់មកពីប្រទេសថៃ។ ក្នុងសេចក្តីប្រកាសព័ត៌មាននៅថ្ងៃនេះ រដ្ឋបាលខេត្តបាត់ដំបងបានបញ្ជាក់ថា ករណីឆ្លងថ្មីចំនួន ៣នាក់ ត្រូវបានរកឃើញលើពលរដ្ឋ ៣នាក់ ដែលបានធ្វើដំណើរវិលត្រឡប់ទៅពីរាជធានីភ្នំពេញ ហើយមានពាក់ព័ន្ធនឹងព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ។ ចំណែកឯករណីឆ្លងថ្មី ៧នាក់ទៀត រដ្ឋបាលខេត្តនេះបញ្ជាក់ថា ត្រូវបានរកឃើញលើពលករខ្មែរ ដែលទើបវិលត្រឡប់មកពីប្រទេសថៃ។ រដ្ឋបាលខេត្តបាត់ដំបងក៏បានប្រកាសឱ្យដឹងផងដែរថា អ្នកជំងឺ ២នាក់ទៀត ត្រូវបានព្យាបាលជាសះស្បើយ។ គិតត្រឹមថ្ងៃនេះ ខេត្តបាត់ដំបងរកឃើញមនុស្សសរុប ១៨៨នាក់ហើយបានឆ្លងមេរោគកូវីដ-១៩ ក្នុងនោះអ្នកជំងឺ ២នាក់បានស្លាប់ ហើយអ្នកជំងឺ ៧០នាក់ត្រូវបានព្យាបាលជាសះស្បើយ ខណៈអ្នកជំងឺ ១១៤នាក់ទៀត កំពុងស្ថិតក្រោមការព្យាបាលបន្ត៕

# ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២១

## តុលាការឃុំខ្លួនមេខ្យល់ ៣ នាក់ ដែលនាំពលករឆ្លងដែនទៅថៃ

https://www.postkhmer.com/ គីម សារុំ | Publication date 28 May 2021 | 09:57 ICT

**បន្ទាយមានជ័យ:** តុលាការខេត្តបន្ទាយមានជ័យនៅថ្ងៃទី ២៧ ឧសភា បានសម្រេចឃុំខ្លួនមេខ្យល់ប្រុសស្រី ៣ នាក់ ក្នុងពន្ធនាគារខេត្តពាក់ព័ន្ធករណីនាំពលករឆ្លងដែនទៅថៃខុសច្បាប់ បន្ទាប់ពីចាប់ខ្លួនបានកាលពីយប់ថ្ងៃទី ២២ និងថ្ងៃទី ២៥ ឧសភា នៅក្នុងភូមិព្រៃគប់ សង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែត។

លោកវរសេនីយ៍ទោ ព្រហ្ម ថេង ប្រធានមន្ទីរស្រាវជ្រាវ និងបង្ក្រាបបទល្មើសនៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ ឱ្យភ្នំពេញប៉ុស្ដិ៍ដឹងនៅថ្ងៃទី ២៧ ឧសភាថា ជនសង្ស័យទាំង ៣ នាក់ទី១- ឈ្មោះ ជួន ចំណាប់ ភេទប្រុស អាយុ ២៨ ឆ្នាំ រស់នៅភូមិទំនប់ក៥ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ទី២- ចាន់ ស្រី ភេទស្រី អាយុ ៣៤ ឆ្នាំ រស់នៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែត និង រី ចិត្រា ភេទប្រុសអាយុ ៣២ ឆ្នាំនៅសង្កាត់-ក្រុងប៉ោយប៉ែត។ ពួកគេត្រូវបានចៅក្រមចេញដីកាឃុំខ្លួនក្នុងពន្ធនាគារហើយនៅវេលាថ្ងៃត្រង់ថ្ងៃទី ២៧ ឧសភា។ លោកថា៖ «តំណាងអយ្យការអមសាលាដំបូងចោទពីបទការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន តាមបញ្ញត្តិមាត្រា ១១ ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ»។ យោងមាត្រា ១១ ច្បាប់ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនេះ ប្រសិនបើតុលាការរកឃើញថា ក្រុមជនត្រូវចោទពិតជាបានធ្វើសកម្មភាពនាំមនុស្សឆ្លងដែនមែននោះនឹងត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី៧ទៅ១៥ ឆ្នាំ។

លោក ព្រហ្ម ថេងឱ្យដឹងបន្តថាការងារចាប់មេខ្យល់ និងជួយសង្គ្រោះពលករពីអំពើនាំឆ្លងដែនខុសច្បាប់នេះគឺកម្លាំងសមត្ថកិច្ចមានការលំបាកដែរព្រោះថាក្រុមមេខ្យល់ទាំងនោះភាគច្រើនតែងលួចនាំពលករឆ្លងដែននៅពេលយប់។ ហេតុដូច្នេះសមត្ថកិច្ចត្រូវដើរល្បាតជាប្រចាំទាំងយប់ទាំងថ្ងៃ ប្ដូរវេនគ្នាហើយសមត្ថកិច្ចក៏តែងតែចាប់បានមេខ្យល់ និងជួយសង្គ្រោះពលករជាញឹកញាប់ដែរ។ លោកថ្លែងថា៖ «ការងារចាប់មេខ្យល់នេះយើងមានការលំបាកព្រោះយើងមិនមែនចាប់ពួកគេហើយបញ្ជូនទៅតុលាការតែម្ដងទេ គឺត្រូវឱ្យគ្រូពេទ្យយកសំណាកពួកគេពិនិត្យរកមេរោគកូវីដសិន។ បើពិនិត្យទៅឃើញមានវិជ្ជមានជំងឺកូវីដ ១៩ គឺត្រូវយកជនសង្ស័យ ទៅព្យាបាលសិន តែបើពិនិត្យទៅឃើញថា គ្មានវិជ្ជមានកូវីដទេទើបយើងកសាងសំណុំរឿងបញ្ជូនទៅតុលាការ»។

លោករំឭកប្រាប់ថា កាលពីយប់ថ្ងៃទី ២២ ឧសភា កម្លាំងសមត្ថកិច្ចកងរាជអាវុធហត្ថក្រុងប៉ោយប៉ែត បានដាក់កម្លាំងល្បាតតាមគោលដៅនៅតំបន់ដែលមេខ្យល់ធ្លាប់នាំពលករឆ្លងកាត់។ ខណៈកម្លាំងសមត្ថកិច្ចកំពុងដើរល្បាតនៅចំណុចភូមិព្រៃគប់ សង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែតក៏ឃើញមនុស្សប្រុសស្រីចំនួន ៧ នាក់ ដែលម្នាក់ៗមានសាក់កាដូរៀងៗខ្លួនផង។ ដោយមានការសង្ស័យសមត្ថកិច្ចបានហៅពួកគេសាកសួរតែភ្លាមៗនោះ មេខ្យល់ម្នាក់បានរត់គេចខ្លួន ខណៈដែលមេខ្យល់ ២ នាក់ ត្រូវចាប់ខ្លួន និងជួយសង្គ្រោះបានពលករចំនួន ៤ នាក់ និងស្រីម្នាក់។ រហូតដល់ថ្ងៃទី ២៥ ឧសភា អាវុធហត្ថរបស់លោកបានឃាត់ខ្លួនជនសង្ស័យបានម្នាក់ទៀត៕

## នគរបាលការពារព្រំដែនគោក បង្ក្រាបទប់ស្កាត់ ពលរដ្ឋខ្មែរបម្រុងឆ្លងដែនចូលទឹកដីថៃ ខុសច្បាប់ ចំនួន១៥នាក់

https://cen-news.com/archives/ Posted ByPen Srey Neat May 28, 2021

ខេត្តបាត់ដំបង ៖ នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១ លោកវរសេនីយ៍ ឯក ស៊ិន ប៊ុនរស្មី ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៩ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ីមេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៩ បានដឹកនាំកម្លាំងប៉ុស្ដិ៍នគរបាលការពារព្រំដែន

គោកបឹងអាជាង សហការជាមួយកម្លាំងកងយោធពលខេមរភូមិន្ទ ឈរជើងជួរមុខក្នុងភូមិសាស្ត្រស្រុកកំរៀង ចេញល្បាត និងធ្វើការទប់ស្កាត់ពលករបម្រុងលួចឆ្លងដែនចូលទឹកដីថៃដោយមិនស្របច្បាប់ ចំនួន ១ករណី នៅចំណុចភូមិរការបុស ឃុំកំរៀង ស្រុកកំរៀង។ ការបង្រ្កាបទប់ស្កាត់ ពលរដ្ឋខ្មែរបម្រុងឆ្លងដែននេះ យោងតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្ដីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករ ចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ។ ពលករដែលកម្លាំងសមត្ថកិច្ចឃាត់ខ្លួន មានចំនួន ១៥នាក់ (ស្រី ៦នាក់) បានបញ្ជូនទៅឲ្យកម្លាំងអធិការដ្ឋាននគរបាលស្រុកកំរៀងសាកសួរ និងអនុវត្តតាមផ្លូវច្បាប់បន្ត ៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## អ្នកឆ្លងជំងឺកូវីដ-១៩នៅខេត្តបាត់ដំបងកើនឡើងដល់ជាង២០០នាក់ភាគច្រើនជាពលករមកពីថៃ

https://www.kampucheathmey.com/ ថ្ងៃសៅរ៍ ២៩ ឧសភា ២០២១ ដោយ Sorn Phanith

គិតត្រឹមថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២១នេះ ខេត្តបាត់ដំបងមានអ្នកឆ្លងជំងឺកូវីដ-១៩ ចំនួន២១០នាក់ ហើយនិងស្លាប់បាត់បង់ជីវិតចំនួន២នាក់។ យោងសេចក្ដីជូនដំណឹងរបស់រដ្ឋបាលខេត្តបាត់ដំបង ចុះថ្ងៃទី២៩ ខែឧសភានេះ បានឲ្យដឹងថា ជាក់ស្ដែងនៅថ្ងៃទី២៨ ខែឧសភាឆ្នាំ២០២១ រដ្ឋបាលខេត្តបានរកឃើញអ្នកឆ្លងជំងឺកូវីដ-១៩ថ្មីចំនួន១១នាក់បន្ថែមទៀត ក្នុងនោះមាន៤នាក់ ជាអ្នកឆ្លងក្នុងព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ និង៧នាក់ទៀតជាពលករវិលត្រឡប់មកពីប្រទេសថៃនិងមានអ្នកជាសះស្បើយចំនួន៦នាក់។ តាមរដ្ឋបាលខេត្តការរកឃើញថ្មីចំនួន១១នាក់បន្ថែមទៀតនេះ បានធ្វើឱ្យតួលេខនៃអ្នកឆ្លងជំងឺកូវីដ-១៩សរុប ចំនួន២១០នាក់ អ្នកជាសះស្បើយចំនួន៧៨នាក់ អ្នកកំពុងសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យចំនួន១២៨នាក់ បញ្ជូនទៅព្យាបាលនៅខេត្តបន្ទាយមានជ័យចំនួន២នាក់និងស្លាប់ចំនួន២នាក់។ មួយរយៈពេលចុងក្រោយនេះការឆ្លងទៅលើពលករខ្មែរ ដែលធ្វើដំណើរវិលត្រឡប់មកពីប្រទេសថៃហាក់មានចំនួនកើនឡើងដែលធ្វើឲ្យក្រសួងសុខាភិបាលបានណែនាំដល់អភិបាលរាជធានីខេត្តទាំងអស់ត្រូវពង្រឹងការធ្វើចត្តាឡីស័កនិងធ្វើតេស្តដល់ពលរដ្ឋដែលទៅពីបណ្ដាខេត្តដែលសង្ស័យនិងពលករមកពីក្រៅប្រទេសពិសេសពលករមកពីប្រទេសថៃ។

លោក សាស្ត្រា ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល បានមានប្រសាសន៍ឱ្យដឹងថា ការពង្រឹងវិធានការធ្វើចត្តាឡីស័ក និងធ្វើតេស្តកូវីដ ១៩ បន្ទាប់ពីមានការកើនឡើងករណីវិជ្ជមានជំងឺកូវីដ ១៩ជារៀងរាល់ថ្ងៃ នៅបណ្ដាប្រទេសជិតខាង ហើយជាពិសេសពលករចំណាកស្រុក ដែលត្រឡប់ចូលមកវិញក៏មានការរកឃើញករណីវិជ្ជមានច្រើនផងដែរ។ លោករដ្ឋមន្ត្រី ក៏បានណែនាំឱ្យអភិបាលរាជធានី-ខេត្តត្រូវចាត់តាំងកម្លាំងគ្រប់គ្រង ឃ្លាំមើល និងធ្វើការណែនាំ ការអនុវត្តឱ្យបានខ្ជាប់ខ្ជួន នូវការធ្វើចត្តាឡីស័ករបស់ប្រជាពលរដ្ឋ នៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងគោលបំណងពង្រឹងការធ្វើចត្តាឡីស័ក ឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព។ ជាងនេះទៀតត្រូវ ពង្រីកការធ្វើតេស្តរកកូវីដ-១៩ ទៅលើអ្នកសង្ស័យ និងពលករមកពីខេត្តមានហានិភ័យខ្ពស់នៃប្រទេសជិតខាង ជាពិសេសប្រទេសថៃ៕ អត្ថបទ៖ សំអឿន

## ឧត្តរមានជ័យ រកឃើញជំងឺកូវីដ-១៩ លើពលករខ្មែរ ០៦នាក់បន្ថែមទៀត ឆ្លងដែនពីប្រទេសថៃ ថ្ងៃសៅរ៍ ២៩ ឧសភា ២០២១

https://www.kampucheathmey.com/ ដោយ Sorn Phanith ដោយៈចាន់ ជី

នៅល្ងាចថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២១នេះ ខេត្តឧត្តរមានជ័យបានប្រកាសរកឃើញអ្នកឆ្លងកូវីដ១៩ចំនួន ០៦នាក់បន្ថែមទៀត ដែលជាពលករខ្មែរឆ្លងដែនពីប្រទេសថៃ មកប្រទេសកម្ពុជា តាមច្រកអន្តរជាតិអូរស្មាច់។ សូមបញ្ជាក់ថា៖ មកទល់ពេលនេះ ខេត្តឧត្តរមានជ័យមានអ្នកជំងឺកូវីត-១៩ចំនួន ៤៧នាក់ហើយ រួចបានព្យាបាលជាសះស្បើយចំនួន១០នាក់ផងដែរ និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តឧត្តរមានជ័យចំនួន៣៧នាក់៕

## កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការទទួលពលករខ្មែរត្រឡប់មកពីប្រទេសថៃ ចំនួន៥នាក់

http://cambodiapolice.com/policekh/ 12:32 pm 29 ឧសភា 2021

ខេត្តបាត់ដំបង ៖ តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករ ចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ។ ជាក់ស្ដែង នៅថ្ងៃសៅរ៍ ៣ រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២១ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានដឹកនាំកម្លាំងសហការជាមួយកម្លាំងកងខេមរភូមិន្ទ ឈរជើងជួរមុខក្នុងភូមិសាស្ត្រស្រុកសំពៅលូន ទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ពីយោធាថៃកងអនុសេនាធំ១៣០៥ ត្រង់ចំណុចនៃភូមិសាស្ត្រភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូនិងចំណុចស្ពានយោល ឃុំជ្រៃសីម៉ា ស្រុកសំពៅលូន សរុបចំនួន៥នាក់, ស្រី២នាក់ ក្នុងនោះក្មេងប្រុស ១នាក់ និងក្មេងស្រី ១នាក់ ។ បន្ទាប់ពីធ្វើការសាកសួរ និងកត់ត្រាឈ្មោះរួច ក៏ធ្វើការអប់រំណែនាំ ហើយកម្លាំងយើងបានប្រគល់គាត់ឲ្យទៅក្រុមគ្រូពេទ្យដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ តាមការណែនាំរបស់ក្រសួងសុខាភិបាល ។ ជាមួយគ្នានេះ កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានសហការជាមួយកម្លាំងកងខេមរភូមិន្ទ ឈរជើងជួរមុខ ក្នុងភូមិសាស្ត្រស្រុកសំពៅលូនធ្វើការចុះល្បាតតាមខ្សែបន្ទាត់ព្រំដែនក្នុងស្រុកសំពៅលូនផងដែរ ៕

## កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការទទួលពលករខ្មែរ មកពីថៃម្នាក់ បញ្ជូនទៅមណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២

http://cambodiapolice.com/policekh/ 3:00 pm 28 ឧសភា 2021

ខេត្តបាត់ដំបង ៖ តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករ ចេញ-ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ។ ជាក់ស្ដែង នៅព្រឹកថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១ លោកវរសេនីយ៍ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពាព្រំដែនគោកលេខ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ ជាមេបញ្ជា បានចាត់តាំងកម្លាំងប៉ុស្ដិ៍នគរបាលព្រំដែនគីឡូ១៣ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ដឹកនាំដោយលោកអនុសេនីយ៍ទោ ម៉ឹង ម៉េត នាយប៉ុស្ដិ៍ស្ដីទី) សហការជាមួយកម្លាំងលយោធាផ្នែកសឹករងសំពៅលូន ដឹកនាំដោយលោកវរសេនីយ៍ត្រី វ៉ាន់-

សុផល មេបញ្ជាការរងផ្នែកសឹករង និងកម្លាំងយោធារសេនាតូច៥៣៣ ដឹកនាំដោយលោកអនុសេនីយ៍ឯក ឯក អាំផន មេបញ្ជាការ-គ ទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញពីយោធាថៃកងអនុសេនាធំ ១៣០៥ ត្រង់ចំណុចនៃភូមិសាស្ត្រភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូនចំនួន ១នាក់។ បន្ទាប់ពីធ្វើការសាកសួរ និងកត់ត្រាឈ្មោះរួច ក៏ធ្វើការអប់រំណែនាំ ហើយកម្លាំង បានប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ តាមការណែនាំរបស់ក្រសួងសុខាភិបាល ៕

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៥៣នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃសៅរ៍ ទី២៩ ខែឧសភា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៥៣នាក់ ស្រី ២៦នាក់ ក្នុងនោះកុមារ ០០នាក់ កុមារី ១នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ៥នាក់ ស្រី ១នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៧នាក់ ស្រី ៣នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ១០នាក់ ស្រី ៧នាក់ កុមារ ០០នាក់ កុមារី ១នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ១៩នាក់ ស្រី ១០នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ១២នាក់ ស្រីចំនួន ៥នាក់ កុមារចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ប្រុសចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៥៣នាក់ ស្រី ២៦នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៤៥នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃសុក្រ ទី២៨ ខែឧសភា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៤៥នាក់ ស្រី ១៧នាក់ ក្នុងនោះកុមារ ២នាក់ កុមារី ២នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ១នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ២០នាក់ ស្រី ៨នាក់ កុមារា ២នាក់ កុមារី ២នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ២៤នាក់ ស្រី ៩នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារា ចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ប្រុសចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៤៥នាក់ ស្រី ១៧នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## បញ្ជូនពលករខ្មែរត្រឡប់មកពីស្រុកថៃជាង១០នាក់ទៅធ្វើចត្តាឡីស័ក

https://cambodiaflashnews.com/ by Mr Ratanak May 28, 2021 ដោយ៖វិចិត្រ

បាត់ដំបង៖ ពលករខ្មែរជាង១០នាក់ មានទាំងក្មេងតូចផង ដែលបានវិលត្រឡប់មកពីស្រុកថៃ ទៅស្រុកកំណើតវិញកាលពីរសៀលថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១ ត្រូវសមត្ថកិច្ចឈរជើងនៅតាមបណ្ដោយព្រំដែនបានយកឧបករណ៍សម្រាប់ឆ្លងអូររង់ចាំទទួល។ មុនពេលឆ្លងមានភ្លៀងធ្លាក់ខ្លាំងធ្វើឱ្យទឹកអូរមានការកើនឡើងពិបាកឆ្លងមកខាងកម្ពុជា។ តែអាជ្ញាធរ និងសមត្ថកិច្ចឈរជើងនៅតាមបណ្ដោយព្រំដែន បានយកសម្ភារធ្វើជាក្បូនដែលរៀបចំទុកចាំជាស្រេចហើយទៅចម្លងពួកគាត់ រួចដឹកទៅមណ្ឌលសុខភាពធ្វើចត្តាឡីស័កចំនួន១៤ថ្ងៃមុនឱ្យត្រឡប់ទៅលំនៅវិញ៕

## អាជ្ញាធរខេត្តបាត់ដំបង ឃាត់ខ្លួនមេខ្យល់ម្នាក់ និងតៃកុងរថយន្ត ២នាក់ ដែលនាំពលករ ២៦នាក់ ឆ្លងដែនខុសច្បាប់

http://freshnewsasia.com/ 2021-05-30 02:10pm

**(បាត់ដំបង)៖** គណៈបញ្ជាការកងឯកភាពស្រុកកំរៀង ដែលមានកម្លាំងកងកាពារព្រំដែនលេខ៥០៤ កងរាជអាវុធហត្ថ កម្លាំងនគបាល បានឃាត់ខ្លួនមេខ្យល់ម្នាក់ និងតៃកុងរថយន្ត២នាក់ ដែលបានដឹកនាំពលករឆ្លងដែនដោយខុសច្បាប់ ទៅប្រទេសថៃ ក្នុងភូមិសាស្ត្រស្រុកកំរៀង ខេត្តបាត់ដំបង។ ប្រតិបត្តិការបានធ្វើឡើង នាថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២១ ដោយមានការចង្អុលបង្ហាញពីលោក ណុប ដារ៉ា អភិបាលរងខេត្តបាត់ដំបង និងជាប្រធានគណៈកម្មការស្រាវជ្រាវបង្ក្រាបបទល្មើសឆ្លងដែនគ្រប់ប្រភេទ ជាពិសេសបទល្មើសនាំប្រជាពលរដ្ឋចេញ-ចូលក្នុងទឹកដីថៃដោយខុសច្បាប់។

**ប្រតិបត្តការខាងលើមាន ២ករណីរួមមាន៖**

*ករណីទី១ កម្លាំងធ្វើការឃាត់ខ្លួនមេខ្យល់ឈ្មោះ វង្ស គឿត ភេទប្រុស អាយុ ២៩ឆ្នាំ រស់នៅក្នុង ភូមិអូរជ្រៃ ស្រុកកំរៀង និងឃាត់រថយន្តបាន១គ្រឿង ម៉ាក ហាយឡិនឌ័រពណ៌ខៀវ ស្លាកលេខភ្នំពេញ 2P:7179 បើកបរដោយឈ្មោះ គង់ ថង ភេទប្រុស អាយុ៤០ឆ្នាំ រស់នៅក្នុងភូមិស្ពោ ឃុំស្ពោ ស្រុករតនមណ្ឌល ដែលបានដឹកនាំពលករចំនួន ១១នាក់ ក្នុងនោះក្មេង៤នាក់ នាំយកចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែននៅប្រទេសថៃ ហើយត្រូវបានបង្ក្រាបក្នុងភូមិសាស្ត្រក្រុមទី៦ ភូមិអូរជ្រៃ ឃុំកំរៀង ស្រុកកំរៀង ខេត្តបាត់ដំបង ។

*ករណីទី២ កាលពីវេលាម៉ោង ១៧៖៣០នាទីនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១ ជនសង្ស័យឈ្មោះកាន់ ឌីណា បានយករថយន្តម៉ាកសាំយ៉ុងពណ៌ស ស្លាកលេខព្រះសីហនុ 2A: 6649 ដឹកពលករពីស្រុកក្រឡាញ់ចំនួន ១៥នាក់ ក្នុងនោះស្រី ៦នាក់ មកស្រុកកំរៀងដោយធ្វើដំណើរឆ្លងកាត់តាមទីរួមខេត្តបាត់ដំបង ឆ្ពោះទៅប៉ៃលិនចេញពីខេត្តប៉ៃលិនចូលមកដល់ភូមិសាស្ត្រខេត្តបាត់ដំបងវិញ។ នៅវេលាម៉ោង១៖០០ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១ ជនសង្ស័យ ឈ្មោះ កាន ឌីណា បានឲ្យពលករទាំង ១៥នាក់នោះ ចុះត្រង់ចំណុចក្បែរព្រំដែនចម្ងាយប្រហែល ១.០០០ម៉ែត្រ ពីបង្គោលសីម៉ាលេខ៦២ ស្ថិតនៅក្នុងភូមិរការបោះ ឃុំកំរៀង ស្រុកកំរៀង ហើយជនសង្ស័យបានបើករថយន្តម៉ាកសាំយ៉ុងពណ៌សស្លាកលេខ 2A:6649 រត់គេចខ្លួន។

លុះម៉ោង ៧៖៣៦នាទី ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១ កងការពារព្រំដែនលេខ៥០៤ បានឃាត់ខ្លួនពលករទាំង ១៥នាក់នោះ ដោយសារពួកគាត់ (ពលករ) បំរុងលួចឆ្លងព្រំដែនចូលទៅក្នុងប្រទេសថៃ ដោយខុសច្បាប់ បន្ទាប់មកកម្លាំងកងល្បាត៥០៤ បានបញ្ជូនមកអធិការនគរបាលស្រុកកំរៀង ដើម្បីធ្វើការសាកសួរ។ នៅវេលាម៉ោង ២៖៣០នាទី ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២១ នៅចំណុចបេនឡានថ្មី ស្ថិតនៅក្នុងភូមិដូង ឃុំបឹងរាំងស្រុកកំរៀង ខេត្តបាត់ដំបង កម្លាំងកងរាជអាវុធហត្ថស្រុកកំរៀង បានធ្វើការឃាត់ខ្លួនជនសង្ស័យឈ្មោះ កាន ឌីណា ភេទប្រុស អាយុ២៥ ឆ្នាំមុខរបររត់តាក់ស៊ី រស់នៅក្នុងភូមិភ្នំមួយរយ ឃុំត្រាង ស្រុកកំរៀង ខេត្តបាត់ដំបង វត្ថុតាងដកហូតរួមមានរថយន្តម៉ាកសាំយ៉ុងពណ៌សផ្លាកលេខព្រះសីហនុ 2A:6649 ចំនួន ១គ្រឿងដោះកៅអីចេញសម្រាប់ដឹក ។

បច្ចុប្បន្នជនសង្ស័យមានមេខ្យល់ និងតៃកុងឡាន កំពុងតែកសាងសំណុំដើម្បីចាត់ការតាមនីតិវិធី ឯពលករចំនួន២៦នាក់ បានបញ្ជូនទៅស្រុកកំណើតវិញ៕

## ស្ថានទូតកម្ពុជាប្រចាំ ម៉ាឡេស៊ី ជួយពលករខ្មែរ១១នាក់ មានកុមារម្នាក់ឱ្យត្រឡប់មកវិញ

https://www.kampucheathmey.com/ ថ្ងៃអាទិត្យ ៣០ ឧសភា ២០២១ ដោយ deth leng

លោក កុយ គួង រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា បានឲ្យដឹងនៅព្រឹកថ្ងៃទី៣០ ខែឧសភានេះថា ដោយមានកិច្ចជួយអន្តរាគមន៍របស់ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី ពលករ ពលការិនីខ្មែរ១១នាក់ និងកុមារ ០១ នាក់ នឹងធ្វើដំណើរមកមាតុភូមិវិញ តាមជើងយន្តហោះលេខ SQ158 ហើយនឹងមកដល់នៅវេលាម៉ោង៥ និង៣៥ នាទីល្ងាចថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២១នេះ។ បើតាមលោក កុយ គួង ក្រុមពលករខ្មែរទាំងនោះ ត្រូវបានស្ថានទូតចេញលិខិតធ្វើដំណើរបណ្ដោះអាសន្ន ចំពោះអ្នកដែលគ្មានលិខិត ឆ្លងដែន និងរៀបចំឯកសារទៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ម៉ាឡេស៊ី ជូនទៅធ្វើតេស្តកូវីដ១៩ ព្រមទាំងបានចាត់មន្ត្រីជូនពួកគាត់ខាងលើ ទៅអាកាសយានដ្ឋានអន្តរជាតិ KLIA ផងដែរ៕ អត្ថបទ៖កោះកែវ

## ទាហានថៃ ចាប់ពលករខ្មែរ១៩នាក់និងមេខ្យល់ជនជាតិថៃ២នាក់ក្បែរព្រំដែនកម្ពុជា

http://nokorwatnews.com/ 29/05/2021

**ក្រុងប៉ោយប៉ែត៖** ទាហានឈុតខ្មៅថៃ អង្គភាពទី១៣ ចាប់ឃុំខ្លួនពលករខ្មែរ១៩នាក់ នឹងមេខ្យល់ជានជាតិថៃ២នាក់ ដែលលួចឆ្លងដែនខុសច្បាប់ចូលប្រទេសថៃ នៅបរិវេណព្រំដែនភូមិ ថាប់ព្រិក ស្រុកអារញ្ញ ខេត្តស្រះកែវ។ សេចក្តីរាយការពីប្រទេសថៃកាលពីថ្ងៃទី២៩ឧសភា ២០២១ តាមវិធានការរឹតបន្តឹងការលួចឆ្លងដែនចូលប្រទេស ដោយខុសច្បាប់ ដើម្បីការពារការរាតត្បាតរបស់កូវីដ-១៩ ទាហានឈុតខ្មៅ ទី១៣ បញ្ជាឲ្យសមត្ថកិច្ចកងរយទី ១៣០២ ត្រួតពិនិត្យភូមិសាស្រ្តព្រំដែន ចាប់តាំងពីស្រុកខ្លងហាត រហូតទៅដល់ស្រុកអារញ្ញ បានជួបក្រុមបុគ្គលត្រូវសង្ស័យជាពលករខ្មែរលួចឆ្លងដែនចូលមកក្នុងប្រទេសដោយខុសច្បាប់ ទើបធ្វើការត្រួតពិនិត្យ នឹងចាប់ឃុំខ្លួនភ្លាម។

សមត្ថកិច្ចឈុតខ្មៅអង្គភាពទី១៣ ប្រចាំស្រុកខ្លុងហាត កងកម្លាំងបូរផា នឹងកងវរយទាហានឈុតខ្មៅទី ១៣០២ បានឃ្លាំមើលដើម្បីបង្កើនការរឹតបន្តឹង ក្នុងការទប់ស្កាត់ពលករលួចឆ្លងដែនដោយខុសច្បាប់ នឹងបង្ក្រាបទង្វើខុសច្បាប់គ្រប់រូបភាព រហូតអាចស្កាត់ចាប់ឃុំពលករខ្មែរបានចំនួន១៩នាក់ ក្នុងនោះប្រុស១២ នឹងស្រី៧នាក់ ព្រមទាំងមេខ្យល់ជនជាតិថៃចំនួន២នាក់ នឹង រថយន្តចំនួន២គ្រឿងបាននៅបរិវេណថ្នល់លូកពុំងចម្ការអំពៅ ខាងក្រោយភូមិថាន់ចៃ-ភូមិប៉ាខៀវ ឃុំថាប់ព្រិក ស្រុកអារញ្ញ ខេត្តស្រះកែវ ក្រោយសួរនាំពួកគេថា ពលរដ្ឋខ្មែរទាំងអស់ធ្វើដំណើរមកពីខេត្តបាត់ដំបង នឹងខេត្តព្រៃវែង ប្រទេសកម្ពុជា លួចចូលប្រទេសថៃតាមច្រករបៀង ដើម្បីធ្វើដំណើរទៅធ្វើការស៊ីឈ្នួលក្នុងទឹកដីខេត្តឈុនបុរី ខេត្តសមុទ្រប្រាកាន នឹងទីក្រុងបាងកក ក្រោយធ្វើកំណត់ហេតុឃុំខ្លួន ព្រមទាំងអនុវត្តតាមវិធានការរបស់ផ្នែកសុខាភិបាល នឹងនាំពលករខ្មែរទាំងអស់ រួមទាំងមេខ្យល់ បញ្ជូនទៅឲ្យជំនាញ ដើម្បីចាត់ការតាមច្បាប់បន្ត៕

## កម្លាំងអជ្ញាធរការពារព្រំដែនថៃឃាត់ខ្លួនពលរដ្ឋខ្មែរប្រុសស្រីចំនួន02នាក់

https://www.facebook.com/Khmer.Channel.kh/ ទឹកចិត្តពលករឆ្លងដែន *ថ្ងៃទី28 ឧសភា ម៉ោង 8:05 PM*

ថ្ងៃទី28 ខែឧសភា ឆ្នាំ2021 កម្លាំងអជ្ញាធរការពារព្រំដែនថៃឃាត់ខ្លួនពលរដ្ឋខ្មែរប្រុសស្រី ចំនួន02នាក់ ខណៈកំពុងឆ្លងដែនខុសច្បាប់ចូលមកស្វែងរកការងារធ្វើនៅក្នុងប្រទេសថៃ នៅត្រង់ចំណុចក្រោយវត្តខៅលូកឆាង ស្រុកតាប្រាក់យ៉ា ខេត្តស្រះកែវ។